**សាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ច**

**Université Royale de Droit et des Sciences Économiques**

**Royal university of Law and Economics**


**សារណាបញ្ចប់ការសិក្សា**

# ការគ្រប់គ្រងរដ្ឋបាលផ្នែកពុទ្ធចក្រ នៃព្រះរាជាណាចក្រកម្ពុជា

ស្រាវជ្រាវចាប់ពីថ្ងៃទី២៧ ខែមេសា ឆ្នាំ២០២១ ដល់ថ្ងៃទី២៥ ខែមិថុនា ឆ្នាំ២០២១


ស្រាវជ្រាវដោយ

និស្សិតឈ្មោះ **អួង ឡាង**

**តាំងនី ពុទ្ធី**

សាស្ត្រាចារ្យណែនាំ

**បណ្ឌិត អ៊ុន សកក្កដា**


ថ្នាក់បរិញ្ញាបត្រ **រដ្ឋបាលសាធារណៈ**

ជំនាន់ទី ១៤

ឆ្នាំចូលរៀន ២០១៧

ឆ្នាំសរសេរសារណា ២០២១

**សាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ច**

**Université Royale de Droit et des Sciences Économiques**

**Royal university of Law and Economics**

# សារណាបញ្ចប់ការសិក្សា

# ការគ្រប់គ្រងរដ្ឋបាលផ្នែកពុទ្ធចក្រ នៃព្រះរាជាណាចក្រកម្ពុជា

ស្រាវជ្រាវចាប់ពីថ្ងៃទី២៧ ខែមេសា ឆ្នាំ២០២១ ដល់ថ្ងៃទី២៥ ខែមិថុនា ឆ្នាំ២០២១


ស្រាវជ្រាវដោយ

និស្សិតឈ្មោះ **អួង ឡាង**

**តាំងនី ពុទ្ធី**

សាស្ត្រាចារ្យណែនាំ

**បណ្ឌិត អ៊ុន សកក្កដា**


ថ្នាក់បរិញ្ញាបត្រ **រដ្ឋបាលសាធារណៈ**

ជំនាន់ទី ១៤

ឆ្នាំចូលរៀន ២០១៧

ឆ្នាំសរសេរសារណា ២០២១

# សេចក្តីថ្លែងអំណរគុណ

ជាបឋមខ្ញុំព្រះករុណាអាត្មាភាពទាំងពីរព្រះអង្គគឺព្រះតេជគុណ**អួន ឡាច** និងព្រះតេជគុណ**តាំងនី ពុទ្ធិ** ជាសមណនិស្សិតថ្នាក់បរិញ្ញាបត្រ ផ្នែករដ្ឋបាលសាធារណៈជំនាន់ទី១៤ នៃសាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ច ក្នុងឆ្នាំសិក្សា២០២០-២០២១។ ឆ្លៀតក្នុងឱកាសនេះដែរ សូមថ្លែងអំណរអរគុណយ៉ាងជ្រាវជ្រៅចំពោះលោកអ្នកមានគុណទាំង ៤រូប របស់ខ្ញុំទាំងពីរអង្គគឺ៖ លោកឪពុក **ខៀវ អន** អ្នកម្តាយ **ទេព សុខា** និងលោកឪពុក **ឈុត តាំងនី** អ្នកម្តាយ **ពូន ម៉េន** កូនសូមសម្តែងនូវមហាកតញ្ញូតាធម៌ជាអនេកប្បការ ចំពោះលោកទាំងពីរ ដែលបានផ្តល់កំណើត និងខិតខំបីបាច់ថែរក្សាចិញ្ចឹមរូបកូនតាំងពីក្នុងផ្ទៃ រហូតកូនធំពេញរូបពេញរាង ព្រមទាំងបានទទួលការអប់រំទូន្មានប្រៀនប្រដៅ ណែនាំកូនចៅឱ្យខិតខំរៀនសូត្រ តាំងពីបឋមសិក្សា មធ្យមសិក្សា រហូតដល់ឧត្តមសិក្សានេះ។ ព្រះគុណដ៏មហាបវរនេះគឺធ្វើឱ្យកូនចងចាំ និងគ្មានថ្ងៃបំភ្លេចបានឡើយ។ កូនសូមលើកហត្ថប្រណម្យគោរពប្រណិប័តន៍ផ្ញើស្នាដៃនេះ ជូនចំពោះលោកទាំងពីរជាទីគោរពដ៏ខ្ពង់ខ្ពស់។

សូមចម្រើនពរអរគុណ **ញោមឯកឧត្តមបណ្ឌិត សាកលវិទ្យាធិការ សាកលវិទ្យាធិការរង និងគណៈគ្រប់គ្រង ព្រមទាំងសាស្ត្រាចារ្យទាំងអស់ នៃសាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ច** ដែលបានខិតខំប្រឹងប្រែង និងលទ្ធភាពគ្រប់បែបយ៉ាងក្នុងការដឹកនាំក្នុងគោលបំណងបណ្តុះបណ្តាល មូលធនផ្នែកបញ្ញា ធនធានមនុស្សកម្ពុជាឱ្យមានចំណេះដឹង បទពិសោធន៍ និងមានសមត្ថភាពខ្ពស់ ដើម្បីក្លាយជាសសរទ្រូងស្របតាម កាលានុវត្តភាពនៃការអភិវឌ្ឍរបស់ប្រទេសជាតិ។

ជាពិសេសសូមថ្លែងអំណរគុណ ចំពោះលោកសាស្ត្រាចារ្យ **បណ្ឌិត អ៊ុន សកក្កដា** ដែលបានដឹកនាំខ្ញុំព្រះករុណាអាត្មាភាពទាំងពីរអង្គ ក្នុងការតាក់តែងសិក្សាស្រាវជ្រាវរាវរកឯកសារសំខាន់ៗ ក៏ដូចជាចំណុចល្អៗមកសរសេរ រៀបរៀងឱ្យបានក្លាយទៅជាសារណាមួយ ដែលពោពេញទៅដោយខ្លឹមសារ សម្រាប់ទុកឱ្យមិត្តនិស្សិតជំនាន់ក្រោយ ឬសាធារណជនទូទៅយកជាមូលដ្ឋានក្នុងការសិក្សាស្រាវជ្រាវបាន។

ជាចុងក្រោយ ខ្ញុំព្រះករុណាអាត្មាភាពទាំងពីរព្រះអង្គ សូមប្រសិទ្ធិពរជ័យ បវរសួស្តីមហាប្រសើរ ចូរកើតមានចំពោះលោកអ្នកមានគុណទាំងពីរ បងប្អូនសាច់ញាតិ អស់លោក លោកស្រី សាស្ត្រាចារ្យ លោកគ្រូ អ្នកគ្រូ រួមទាំងក្រុមគ្រួសារទាំងអស់ ឱ្យជួបនូវពរទាំងឡាយ ៤ ប្រការ គឺ អាយុ វណ្ណៈ សុខៈ ពលៈ និងសម្រេចជោគជ័យគ្រប់ភារកិច្ចកុំបីឃ្លៀងឃ្លាតឡើយ។

# **អារម្ភកថា**

សារណានេះបានតាក់តែងឡើង ដើម្បីជាជំនួយដល់ការសិក្សាសម្រាប់ថ្នាក់បរិញ្ញាបត្រ រដ្ឋបាលសាធារណៈ គឺជាលទ្ធផលដែលកើតឡើងពីការខិតខំប្រឹងប្រែង បន្ទាប់ពីបានឆ្លងកាត់នូវការសិក្សា និងក្រេបជញ្ជក់នូវចំណេះដឹង អស់រយៈពេល ៤ឆ្នាំ នៅសាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ច។ យើងខ្ញុំក៏បានសម្រេចចិត្ត ជ្រើសរើសប្រធានបទមួយស្តីពី **ការគ្រប់គ្រងរដ្ឋបាលផ្នែកពុទ្ធចក្រនៃព្រះរាជាណាចក្រកម្ពុជា** ដើម្បី បន្សល់ទុកជាឯកសារស្រាវជ្រាវសម្រាប់ជូនដល់ សិស្ស-និស្សិត និងបណ្តាអ្នកសិក្សាស្រាវជ្រាវទាំងឡាយ ដែល មានបំណងចង់ឈ្វេងយល់អំពីការគ្រប់គ្រង និងរចនាសម្ព័ន្ធក្នុងស្ថាប័នពុទ្ធសាសនា។ អាត្មាភាពទាំងពីរបានទទួល ការដឹកនាំ ដោយលោកសាស្ត្រាចារ្យ **បណ្ឌិត អ៊ុន សកក្កដា** និងទទួលបាននូវការសហការ ផ្តល់ជាឯកសារនានា ការណែនាំ និងផ្តល់គំនិតយោបល់ល្អៗ ជាពិសេស ការជ្រោមជ្រែងដល់អាត្មាភាពទាំងពីរព្រះអង្គផងដែរ។

ការសម្រេចជ្រើសរើសប្រធានបទខាងលើមកសិក្សាស្រាវជ្រាវ ជាសារណាបញ្ចប់ការសិក្សាថ្នាក់បរិញ្ញាបត្រនេះ ដោយសារតែខ្ញុំព្រះករុណាអាត្មាភាពយល់ឃើញថា វាពិតជាមានសារសំខាន់ខ្លាំងណាស់ ក្នុងការផ្តល់ចំណេះដឹង ផ្នែកព្រះពុទ្ធសាសនា ដើម្បីឱ្យប្រិយមិត្តអ្នកសិក្សាទាំងអស់ បានយល់ដឹងទៅនឹងការគ្រប់គ្រងនៃស្ថាប័នពុទ្ធចក្រ ក្នុងប្រទេសកម្ពុជាយើង។

បន្ថែមទៅលើគោលបំណង នៃការជ្រើសរើសប្រធានបទខាងលើនេះផងដែរ អាត្មាភាពទាំងពីរព្រះអង្គចង់ឱ្យ សាធារណជន ព្រមទាំងសិស្សានុសិស្ស និងនិស្សិតជំនាន់ក្រោយទាំងអស់ ឱ្យបានយល់ជ្រួតជ្រាបអំពីរចនាសម្ព័ន្ធ និងការគ្រប់គ្រងរដ្ឋបាលផ្នែកពុទ្ធចក្រនេះ ឱ្យបានទូលំទូលាយក្នុងប្រទេសរបស់យើង និងបន្តយកស្នាដៃនេះទុកជា ចំណេះដឹងបន្ថែម និងសម្រាប់ធ្វើជាឯកសារពិគ្រោះបានមួយផ្នែកក្នុងការសិក្សាផងដែរ។

អាត្មាភាពទាំងពីរអង្គជឿជាក់ថា ស្នាដៃនេះពិតជាមានចំណុចខ្វះខាត និងមានកំហុសតិច ឬច្រើនត្រង់កន្លែង ណាមួយជាក់ជាពុំខានឡើយ។ ដូច្នេះហើយអាត្មាភាពទាំងពីរអង្គ នឹងរងចាំទទួលនូវរាល់ការរិះគន់ ក្នុងន័យស្ថាបនា ពីសំណាក់លោក លោកស្រី សាស្ត្រាចារ្យ និស្សិត និងមិត្តអ្នកអាន ព្រមទាំងអ្នកស្រាវជ្រាវគ្រប់រូប ដើម្បីឱ្យស្នាដៃ មួយនេះក្លាយទៅជាស្នាដៃដ៏ល្អប្រសើរ។

# មាតិកា

ទំព័រ

**សេចក្តីផ្តើម** ........................................................ ១

## ជំពូក១
## ទស្សនទូទៅ និងប្រវត្តិនៃព្រះពុទ្ធសាសនា

**១.១.ទស្សនទូទៅនៃព្រះពុទ្ធសាសនា** ........................................................ ៥

១.១.១.អំពីការមិនធ្វើនូវអំពើអាក្រក់ទាំងពួង ........................................................ ៥

១.១.២.អំពីការបំពេញនូវសេចក្តីល្អ ........................................................ ៦

១.១.៣.អំពីការសម្អាតចិត្តរបស់ខ្លួនឱ្យបានស្អាត ........................................................ ៨

១.១.៤.ទស្សនកម្មផលក្នុងព្រះពុទ្ធសាសនា ........................................................ ៨

១.១.៥.ខ្លឹមសារសំខាន់នៃពាក្យប្រៀនប្រដៅរបស់ព្រះពុទ្ធ ........................................................ ៩

**១.២.ប្រវត្តិព្រះពុទ្ធសាសនានៅកម្ពុជា** ........................................................ ១១

១.២.១.ទិដ្ឋភាពពុទ្ធសាសនាចូលមកកម្ពុជាដំបូង ........................................................ ១២

១.២.៣.ពុទ្ធសាសនាសម័យអង្គរ ........................................................ ១៣

១.២.២.ពុទ្ធសាសនាសម័យកណ្តាល ........................................................ ១៦

១.២.៣.ពុទ្ធសាសនាសម័យខ្មែរក្រហម (ឆ្នាំ១៩៧៥-១៩៧៩) ........................................................ ១៨

១.២.៤.ពុទ្ធសាសនាសម័យក្រោយឆ្នាំ ១៩៧៩ ........................................................ ១៩

១.២.៥. ការគ្រប់គ្រងរដ្ឋបាលសង្ឃ និងដំណើរការវិវត្តតាំងពីសម័យបុរាណ ........................................................ ២៣

**១.៣.រចនាសម្ព័ន្ធគណៈសង្ឃខ្មែរ** ........................................................ ៣២

១.៣.១.គណៈសង្ឃគ្រប់បណ្តាថ្នាក់ ........................................................ ៣២

១.៣.២.គណៈថេរសភាថ្នាក់ជាតិ ........................................................ ៣៣

១.៣.៣.គណៈថេរសភាសង្ឃថ្នាក់មូលដ្ឋាន ........................................................ ៣៣

១.៣.៤.អង្គការលេខគណៈសង្ឃនាយកពុទ្ធសាសនានៃគណៈមហានិកាយ ........................................................ ៣៤

១.៣.៥.អង្គការលេខគណៈសង្ឃនាយកពុទ្ធសាសនានៃគណៈធម្មយុត្តិកនិកាយ ........................................................ ៣៦

១.៣.៦.អំពីក្រសួងធម្មការ និងសាសនា ........................................................ ៣៦

## ជំពូក២

## ការគ្រប់គ្រងរដ្ឋបាលផ្នែកពុទ្ធចក្រនៃព្រះរាជាណាចក្រកម្ពុជា

**២.១.ការជ្រើសតាំង និងការតែងតាំងមន្ត្រីសង្ឃគ្រប់បណ្តាថ្នាក់** ........................................ ៣៩
២.១.១.ការជ្រើសតាំង និងការតែងតាំងសម្តេចព្រះសង្ឃរាជ និងព្រះសង្ឃនាយក................................ ៣៩
២.១.២.ការជ្រើសតាំង និងការតែងតាំងព្រះសង្ឃនាយករង .............................................................. ៤០
២.១.៣.ការជ្រើសតាំង ការតែងតាំងរាជាគណៈក្នុងតំណែង និងរាជាគណៈកិត្តិយស ................................ ៤០
២.១.៤.ការជ្រើសតាំង និងការតែងតាំងមន្ត្រីសង្ឃឋានានុក្រមថ្នាក់ព្រះគ្រូ.............................................. ៤០
២.១.៥.ការជ្រើសតាំង និងការតែងតាំងគណៈសង្ឃថ្នាក់មូលដ្ឋាន..................................................... ៤១
២.១.៦.អំពីការជ្រើសតាំង និងតែងតាំងអាចារ្យ គណៈកម្មការវត្ត....................................................... ៤៤
**២.២.តួនាទី និងភារកិច្ចមន្ត្រីសង្ឃគ្រប់បណ្តាថ្នាក់នៃគណៈសង្ឃកម្ពុជា**............................... ៤៥
២.២.១.តួនាទី និងភារកិច្ចសម្តេចព្រះមហាសង្ឃរាជ និងព្រះសង្ឃនាយក........................................... ៤៥
២.២.២.តួនាទី និងភារកិច្ចព្រះសង្ឃនាយករង.......................................................................... ៤៦
២.២.៣.តួនាទី និងភារកិច្ចព្រះរាជាគណៈគ្រប់ថ្នាក់ ....................................................................... ៤៧
២.២.៤.តួនាទី និងភារកិច្ចឋានានុក្រមព្រះគ្រូ ............................................................................. ៤៨
២.២.៥.តួនាទី និងភារកិច្ចគណៈសង្ឃថ្នាក់មូលដ្ឋាន ...................................................................... ៤៨
២.២.៦.តួនាទី និងភារកិច្ចអាចារ្យ គណៈកម្មការវត្ត ....................................................................... ៦១
**២.៣.ថេរសភា (តុលាការសង្ឃ) នៃព្រះរាជាណាចក្រកម្ពុជា** .................................................. ៦៣
២.៣.១.ការរៀបចំ និងការប្រព្រឹត្តទៅរបស់គណៈថេរសភានៃព្រះរាជាណាចក្រកម្ពុជា ............................ ៦៣
២.៣.២.ការជ្រើសតាំង និងការតែងតាំងគណៈថេរសភាសង្ឃថ្នាក់ជាតិ ................................................ ៦៣
២.៣.៣.តួនាទី និងភារកិច្ចគណៈថេរសភាសង្ឃថ្នាក់ជាតិ................................................................ ៦៤
២.៣.៤.ការជ្រើសតាំង និងការតែងតាំងគណៈថេរសភាសង្ឃថ្នាក់មូលដ្ឋាន ......................................... ៦៤
២.៣.៥.តួនាទី និងភារកិច្ចថេរសភាសង្ឃថ្នាក់រាជធានី-ខេត្ត ............................................................. ៦៦
២.៣.៦.តួនាទី និងភារកិច្ចថេរសភាសង្ឃថ្នាក់ក្រុង-ស្រុក-ខណ្ឌ .......................................................៦៧

**សេចក្ដីសន្និដ្ឋាន**......................................................................................................... ៦៨
**អនុសាសន៍**...................................................................................................................... ៧០
**ឯកសារយោង**
**ឧបសម្ព័ន្ធ**

# សេចក្តីផ្តើម

# សេចក្តីផ្តើម

## ១.លំនាំបញ្ហានៃការស្រាវជ្រាវ

ព្រះពុទ្ធសាសនាជាឈ្មោះដែលចេញពីពាក្យថា ពោធិ ដែលមានន័យថាត្រាស់ដឹង ហើយព្រះពុទ្ធសាសនាជាទស្សនវិជ្ជានៃការត្រាស់ដឹង។ ទស្សនវិជ្ជានេះ មានប្រភពមកពីបទពិសោធពិតរបស់សិទ្ធត្ថគោតមដែលគេស្គាល់ថាជាព្រះពុទ្ធ ដែលព្រះអង្គត្រាស់ដឹងនៅព្រះជន្ម៣៥ព្រះវស្សា។ ព្រះពុទ្ធសាសនាឥឡូវនេះមានអាយុជាង ២៥០០ឆ្នាំ ហើយមានសាសនិកជាង ៣០០លាននាក់ ទូទាំងពិភពលោក។ ដែលរយៈពេលជាង ២៥០០ឆ្នាំមកហើយនោះ ព្រះពុទ្ធសាសនាបានផ្សាយចេញស្ទើរពាសពេញពិភពលោក ជាពិសេសនៅទ្វីបអាស៊ីហើយបាន និងកំពុងបង្កើតសាសនិកយ៉ាងច្រើននៅ អឺរ៉ុប អូស្ត្រាលី និងអាមេរិកជាដើម។

ព្រះពុទ្ធសាសនា គឺជាសាសនាដែលទូន្មានប្រៀនប្រដៅ ដល់មនុស្សទូទៅឱ្យខិតខំកសាងអំពើល្អ មិនឱ្យបៀតបៀនព្យាបាទគ្នា ចេះស្រឡាញ់គ្នា ជួយគ្នាទៅវិញទៅមក ចេះអត់ឱន សន្តោសប្រោសប្រណីគ្នា មេត្តាដល់គ្នានិងគ្នាទៅវិញទៅមក។ ព្រះពុទ្ធសាសនាជាសាសនាមួយ ត្រូវបានទទួលការគោរពប្រតិបត្តិពីប្រជាពលរដ្ឋកម្ពុជាយ៉ាងច្រើនលើសលប់ ហើយត្រូវបានចាត់ទុកជាសាសនារបស់រដ្ឋដោយរដ្ឋធម្មនុញ្ញរបស់ជាតិ នៃព្រះរាជាណាចក្រកម្ពុជា។

ដោយសារប្រជារាស្ត្រខ្មែរភាគច្រើនគោរពព្រះពុទ្ធសាសនា ទើបរដ្ឋធម្មនុញ្ញលើកតម្កើងព្រះពុទ្ធសាសនាជាសាសនារបស់រដ្ឋ។ ព្រះពុទ្ធសាសនាត្រូវបានប្រជារាស្ត្រខ្មែរគោរពប្រតិបត្តិជារៀងរហូតមក ទើបតែនៅសម័យកម្ពុជាប្រជាធិបតេយ្យ(ខ្មែរក្រហម) បានលុបបំបាត់ចោល ដោយពួកគេចោទថាជាសាសនាប្រតិកិរិយា។ បើទោះបីជាសម័យខ្មែរក្រហមបានលុបបំបាត់ក៏ពិតមែន ប៉ុន្តែព្រះពុទ្ធសាសនាមិនបានរលាយសាបសូន្យទេ គឺបានស្ថិតជាប់ក្នុងក្រអៅបេះដូងកូនខ្មែរជានិច្ច។

ក្រោយមកទៀត វត្តអារាមកាន់តែកើនច្រើនឡើងទៅតាមចំនួនគ្រហស្ថពុទ្ធសាសនិក ដែលកើនឡើងកាន់តែច្រើនក្នុងភូមិ-ឃុំ-ស្រុក-ខេត្តនោះៗ សម្តេចព្រះសង្ឃរាជ បានប្រជុំពិភាក្សាគ្នាជាមួយនឹងមន្ត្រីសង្ឃដែលមានស្រាប់ និងមន្ត្រីក្រសួងធម្មកា ព្រមព្រៀងគ្នាជាឯកច្ឆន្ទធ្វើសំណូមពរថ្វាយព្រះមហាក្សត្រ ដើម្បីសូមព្រះរាជានុញ្ញាតរៀបចំរចនាសម្ព័ន្ធ ផ្នែកខាងពុទ្ធចក្រឱ្យសមស្របនឹងផ្នែកអាណាចក្រដែរ។ ព្រះមហាក្សត្រក៏ទ្រង់បានសព្វព្រះរាជហឫទ័យព្រះរាជានុញ្ញាតតាមសំណូមពរ។ សម្តេចព្រះសង្ឃរាជ និងក្រសួងធម្មការ មួយអន្លើដោយព្រះមហាថេរជាច្រើនទៀតក៏បានប្រជុំរៀបចំរចនាសម្ព័ន្ធផ្នែកពុទ្ធចក្រជា៤ថ្នាក់គឺ៖ ថ្នាក់ទី១ គណៈសង្ឃវត្ត ថ្នាក់ទី២ គណសង្ឃស្រុក ថ្នាក់ទី៣ គណៈសង្ឃខេត្ត និងថ្នាក់ទី៤ គណៈសង្ឃនាយក គឺដើម្បីសម្រួលដល់ការដឹកនាំ និងគ្រប់គ្រងវិស័យពុទ្ធសាសនា

ឱ្យកាន់តែមានប្រសិទ្ធភាព និងរីកចម្រើនជាលំដាប់។ ដំណើរការវិវត្តរីកចម្រើនរបស់ព្រះពុទ្ធសាសនាបានរហូតដល់ឆ្នាំ១៩៧៥ បើទោះបីក្នុងឆ្នាំ១៩៧០ ប្រទេសជាតិកម្ពុជាមានការប្រែប្រួលលើសភាពការណ៍នយោបាយខ្លះក៏ដោយពោលគឺ ស្ថាប័នពុទ្ធសាសនានៅតែរក្សាបានដដែល។ ការវិវត្តរីកចម្រើននៃស្ថាប័នសង្ឃកាន់តែជឿនលឿនទៅមុខសមស្របតាមសម័យកាលសង្គម ក្នុងនោះយើងឃើញមានស្ថាប័នថេរសភា ដែលជាស្ថាប័នដ៏សំខាន់ក្នុងវិស័យពុទ្ធសាសនា។ ស្ថាប័ននេះ មានតួនាទីយ៉ាងសំខាន់ក្នុងការវិនិច្ឆ័យសេចក្តីនៃដំណាក់កាលចុងក្រោយបំផុតដែលមន្ត្រីសង្ឃថ្នាក់ក្រោម គឺថ្នាក់មូលដ្ឋានដោះស្រាយមិនបានសម្រេច។

ការវិវត្តន៍នៃស្ថាប័នសង្ឃកម្ពុជា និងការគ្រប់គ្ររដ្ឋបាល យើងឃើញមានលក្ខណៈគ្រប់គ្រាន់ និងសមស្របតាមសម័យកាលសង្គម ក្នុងនោះមានស្ថាប័នគ្រប់គ្រងដូចជា៖ ស្ថាប័នសង្ឃរាជ គណៈសង្ឃនាយក គណៈសង្ឃខេត្ត គណៈសង្ឃស្រុក គណៈសង្ឃវត្តស្ថាប័នថេរសភា និងព្រះឧបជ្ឈាយ៍ដែលកត្តាទាំងនេះ ធ្វើឱ្យវិស័យពុទ្ធសាសនាមានការរីកចម្រើនគួរឱ្យកត់សម្គាល់។

សរុបសេចក្តីមក ព្រះពុទ្ធសាសនាមិនត្រឹមតែមានការ ទូន្មានពុទ្ធបរិស័ទ និងមនុស្សលោកឱ្យចេះស្ងប់ម្ងាប់ ឱ្យចេះខន្តី ឱ្យចេះរំដោះខ្លួនឱ្យរួចផុតអំពីសេក្តីទុក្ខលំបាកនោះទេ ថែមទាំងបានជួយដល់មនុស្សលោកឱ្យមានការទំនាក់ទំនងគ្នាឱ្យបានល្អ និងជួយធ្វើសេដ្ឋកិច្ចជាតិឱ្យមានការអភិវឌ្ឍទៅមុខមួយកម្រិតទៀត ព្រមទាំងជួយផ្សព្វផ្សាយ និងថែរក្សាប្រពៃណីទំនៀមទំលាប់របស់ខ្មែរយើងមួយកម្រិត តាមរយៈព្រះពុទ្ធសាសនានា។ ដោយព្រះពុទ្ធសាសនាមានការរៀបចំនូវរចនាសម្ព័ន្ធ រដ្ឋបាលមួយ ឱ្យមានដំណើរការល្អក្នុងការដឹកនាំនៅក្នុងប្រទេសផងដែរ។

## ២.ចំណោទបញ្ហានៃការស្រាវជ្រាវ

-ព្រះពុទ្ធសាសនាជាសាសនារបស់រដ្ឋ តើព្រះពុទ្ធសាសនាបានចូលរួមក្នុងការអភិវឌ្ឍសង្គមលើវិស័យអ្វីខ្លះ?

-តើការតាក់តែង និងរៀបចំនូវច្បាប់ទម្លាប់បែបណាដែលធ្វើឱ្យសង្គមមានសុខសន្តិភាព ស្ថេរភាព និងមានការរីកចម្រើន ហើយធ្វើឱ្យប្រជាពលរដ្ឋមានសុខុដមរមនាក្នុងសង្គម?

-ក្នុងស្ថាប័នព្រះពុទ្ធសាសនា តើត្រូវប្រតិបត្តិអនុវត្តពុទ្ធវិន័យ និងរៀបចំការគ្រប់គ្រងសហគមន៍សង្ឃឱ្យបានល្អប្រសើរដោយវិធីណា?

-តើការគ្រប់គ្រងរដ្ឋបាលផ្នែកពុទ្ធចក្រមានលក្ខណៈបែបណាខ្លះ?

-តើស្ថាប័នព្រះពុទ្ធសាសនាមានតួនាទី និងភារកិច្ចយ៉ាងដូចម្ដេចខ្លះ?

## ៣.គោលបំណងនៃការស្រាវជ្រាវ

នៅក្នុងវិធីសាស្ត្រស្រាវជ្រាវនេះ បានផ្តោតទៅលើការគ្រប់គ្រងរដ្ឋបាលផ្នែកពុទ្ធចក្រនៃព្រះរាជាណាចក្រកម្ពុជា គឺសង្កត់ធ្ងន់ទៅលើការគ្រប់គ្រងរដ្ឋបាល ផ្នែកពុទ្ធចក្រឱ្យបានទូលំទូលាយ ហើយដើម្បីជាគុណប្រយោជន៍ដល់ការលើកស្ទួយវិស័យព្រះពុទ្ធសាសនា ឱ្យមានមូលដ្ឋានគ្រឹះទៅលើការគ្រប់គ្រងរដ្ឋបាលផ្នែកពុទ្ធចក្រ ឱ្យសមស្របទៅវិស័យអាណាចក្រ ដើម្បីជួយជំរុញ ពង្រឹងការគ្រប់គ្រង និងការអនុវត្តព្រះពុទ្ធោវាទរបស់ព្រះសម្មាសម្ពុទ្ធបរមគ្រូនៃយើង ឱ្យបានជ្រួតជ្រាបដល់ជនានុជនដែលជាកុលបុត្រខ្មែរគ្រប់ស្រទាប់ជាន់ថ្នាក់ និងដើម្បីរក្សានូវតម្លៃសីលធម៌ ប្រពៃណី ទំនៀមទម្លាប់របស់បុព្វបុរសខ្មែរ ឱ្យស្ថិតថេរជាអង្វែងតទៅ។

## ៤.ទំហំ និងដែនកំណត់នៃការស្រាវជ្រាវ

បើទោះបីជាប្រធានបទ (ការគ្រប់គ្រងរដ្ឋបាលផ្នែកពុទ្ធចក្រនៃព្រះរាជាណាចក្រកម្ពុជា) មើលទៅហាក់បីដូចជាមានវិសាលភាពធំទូលំទូលាយក៏ពិតមែន ប៉ុន្តែការស្រាវជ្រាវនេះ ផ្តោតសំខាន់ខ្លាំងទៅលើការគ្រប់គ្រងរដ្ឋបាលផ្នែកព្រះពុទ្ធសាសនាក្រោយសម័យខ្មែរក្រហមមកទល់ពេលបច្ចុប្បន្នប៉ុណ្ណោះ ក៏ដូចជាការតែងតាំងសម្តេចព្រះរាជាគណៈ ព្រះមន្ត្រីសង្ឃគ្រប់ឋានានុក្រម និងបង្ហាញពីតួនាទី ភារកិច្ចរបស់គណៈសង្ឃគ្រប់ជាន់ថ្នាក់ ក្នុងការគ្រប់គ្រងរដ្ឋបាលផ្នែកពុទ្ធចក្រនេះ។ ម្យ៉ាងទៀតយើងមិនបានសិក្សាស្រាវជ្រាវលំអិតទៅលើផ្នែកផ្សេងៗ ដែលពាក់ព័ន្ធបានគ្រប់ជ្រុងជ្រោយនៅឡើយទេ គឺទុកឱកាសឱ្យអ្នកសិក្សាស្រាវជ្រាវក្រោយៗទៀត ជួយបំពេញចំណុចខ្វះខាតដែលអាចនឹងកើតមានក្នុងសារណានេះជាក់ជាមិនខានឡើយ។ ហើយចំពោះការស្រាវជ្រាវនេះសោត គឺយើងកំណត់យកការគ្រប់គ្រងរដ្ឋបាលផ្នែកពុទ្ធចក្រ តែនៅក្នុងព្រះរាជាណាចក្រកម្ពុជា មកធ្វើការសិក្សាស្រាវជ្រាវសារណានេះឡើងតែប៉ុណ្ណោះ។

## ៥.សារសំខាន់នៃការស្រាវជ្រាវ

បន្ទាប់ពីបានសិក្សាស្រាវជ្រាវរួចមក យើងទទួលបាននូវលទ្ធផលដូចខាងក្រោមៈ

-ទទួលបានចំណេះដឹងផ្សេងៗ អំពីទ្រឹស្តីនៃព្រះពុទ្ធសាសនា។

-ប្រវត្តិព្រះពុទ្ធសាសនា ដែលបានផ្សព្វផ្សាយចូលមកក្នុងព្រះរាជាណាចក្រកម្ពុជា។

-ការតែងតាំង គណៈសង្ឃពុទ្ធសាសនាគ្រប់ឋានានុក្រម ដែលត្រូវបំពេញក្នុងកិច្ចការប្រចាំថ្ងៃ។

-ភារកិច្ចរបស់ថេរសភាសង្ឃ តាំងពីថ្នាក់កណ្តាល រហូតដល់ថ្នាក់មូលដ្ឋាន។

-យល់ដឹងពីដំណើរការ នៃការគ្រប់គ្រងរបស់មន្ត្រីសង្ឃគ្រប់បណ្តាថ្នាក់។

-ការរៀបចំនូវរចនាសម្ព័ន្ធសង្ឃ តាមឋានានុក្រមឱ្យមានលក្ខណៈជាប្រព័ន្ធ។

-យល់ដឹងពីគោលការណ៍សំខាន់ៗ សម្រាប់ការងារគ្រប់គ្រង និងដឹកនាំផ្នែកពុទ្ធចក្រ។

-ដើម្បីដោះស្រាយនូវវិវាទ ឬអធិករណ៍ផ្សេងៗ ដែលកើតឡើងតាមវត្តអារាម។

## ៦.វិធីសាស្ត្រនៃការស្រាវជ្រាវ

ដើម្បីធ្វើការស្រាវជ្រាវទាក់ទងនឹងប្រធានបទ (ការគ្រប់គ្រងរដ្ឋបាលផ្នែកពុទ្ធចក្រនៃព្រះរាជាណាចក្រកម្ពុជា) មួយនេះ ខ្ញុំព្រះករុណាអាត្មាភាពបានធ្វើការ សិក្សាស្រាវជ្រាវលើគ្រប់ឯកសារដែលពាក់ព័ន្ធ ដូចជាច្បាប់ ព្រះរាជក្រឹត្យ អនុក្រឹត្យ ទស្សនាវដ្ដី(កម្ពុជសុរិយា, ពន្លឺពុទ្ធចក្រ) សៀវភៅនានា និងតាមរយៈគេហទំព័រ (Internet) ព្រមទាំងបានសម្ភាសផ្ទាល់ជាមួយសម្ដេច(ព្រះមន្ត្រីសង្ឃ)ផងដែរ។

## ៧.រចនាសម្ព័ន្ធនៃការស្រាវជ្រាវ

សារណានេះធ្វើការបែងចែកជា២ជំពូករួមមាន៖ ជំពូកទី១ ទស្សនទូទៅ និងប្រវត្តិព្រះពុទ្ធសាសនានៅកម្ពុជា ដែលនៅក្នុងជំពូកនេះបែងចែកជា៣ចំណុចគឺ៖ ចំណុចទី១ ស្ដីពី ទស្សនទូទៅនៃព្រះពុទ្ធសាសនា ចំណុចទី២ស្ដីពី ប្រវត្តិព្រះពុទ្ធសាសនានៅកម្ពុជា និងចំណុចទី៣ស្ដីពី រចនាសម្ព័ន្ធគណៈសង្ឃខ្មែរ។ ចំណែក ជំពូកទី២ ការគ្រប់គ្រងរដ្ឋបាលផ្នែកពុទ្ធចក្រនៃព្រះរាជាណាចក្រកម្ពុជា ក្នុងនោះបែងចែកជា៣ចំណុចគឺ៖ ចំណុចទី១ស្ដីពី ការជ្រើសតាំង និងការតែងតាំងមន្ត្រីសង្ឃគ្រប់បណ្ដាថ្នាក់ ចំណុចទី២ស្ដី តួនាទី និងភារកិច្ចមន្ត្រីសង្ឃគ្រប់បណ្ដាថ្នាក់នៃគណៈសង្ឃកម្ពុជា និងចំណុចទី៣ស្ដីពី ថេរសភាសង្ឃនៃព្រះរាជាណាចក្រកម្ពុជា។

# ជំពូក១

# ទស្សនទូទៅ និងប្រវត្តិព្រះពុទ្ធសាសនានៅកម្ពុជា

# ជំពូក១
# ទស្សនទូទៅ និងប្រវត្តិព្រះពុទ្ធសាសនានៅកម្ពុជា

## ១.១.ទស្សនទូទៅនៃព្រះពុទ្ធសាសនា

ព្រះពុទ្ធសាសនា ជាសាសនាមួយសម្បូរពាក្យប្រៀនប្រដៅ ដែលប្រកបដោយខ្លឹមសារ មានសារៈប្រយោជន៍ មានតម្លៃខ្ពង់ខ្ពស់ច្រើនណាស់។ មានពាក្យប្រៀនប្រដៅខ្លះ ត្រូវគ្នានឹងពាក្យប្រៀនប្រដៅរបស់អ្នកប្រាជ្ញទាំងឡាយអំពីបុរាណ ដែលមនុស្សលោកគេបានចេះចាំរៀងៗមក តាំងអំពីមុនពុទ្ធកាលក៏មាន។ មានពាក្យប្រៀនប្រដៅខ្លះខ្ពង់ខ្ពស់បំផុត ហួសពីគំនិតរបស់មនុស្សបុថុជ្ជនទាំងអស់ ដែលក្រៅអំពីព្រះសម្មាសម្ពុទ្ធ ឥតមានអ្នកណាមួយមានគំនិតគិតឃើញ មានសមត្ថភាពយល់យល់ ចាក់ធ្លុះដឹងច្បាស់នូវអាថ៌កំបាំងដ៏ជ្រាលជ្រៅបានឡើយ។ ព្រះពុទ្ធសាសនាជាសាសនាចង្អុលបង្ហាញប្រាប់អំពីហេតុផល និងណែនាំអប់រំឱ្យសត្វលោកដើរក្នុងផ្លូវត្រូវ គឺផ្លូវនៃសេចក្តីសុខចម្រើន ដែលសត្វលោកខ្លួនឯងប្រាថ្នាចង់បាន ព្រះពុទ្ធសាសនា គឺជាផែនទីនៃជីវិតសត្វលោក ឯការប្រព្រឹត្តរបស់សត្វលោក គឺជាការដើរលើផ្លូវមជ្ឈិមាបដិបទា។[1]

ព្រះពុទ្ធសាសនាបានបង្ហាញប្រាប់ផ្លូវនៃការប្រតិបត្តិ មាន ៣ ប្រការគឺ ការមិនធ្វើនូវអំពើអាក្រក់ទាំងពួង១ ការបំពេញនូវសេចក្តីល្អ១ និងការសម្អាតចិត្តរបស់ខ្លួនឱ្យបានស្អាតផូរផង់១ ដែលឱវាទទាំង៣នេះជាសេចក្តីសង្ខេប ឬបង្រួញព្រះពុទ្ធោវាទទាំងបីគម្ពីរមាន ៨៤០០០ ព្រះធម្មខន្ធ នៅសល់តែ៣ប្រការនេះប៉ុណ្ណោះ។ ហើយព្រះធម៌ទាំង៣ប្រការនេះ គឺជាមូលដ្ឋានឱវាទដ៏សំខាន់ក្រៃលែង ដែលព្រះអង្គទ្រង់អប់រំមនុស្ស ដើម្បីជាមាគ៌ាឆ្ពោះទៅកាន់សេចក្តីសុខសុភមង្គលក្នុងជីវិតរស់នៅនាពេលបច្ចុប្បន្ន និងទៅបរលោក។

### ១.១.១.អំពីការមិនធ្វើនូវអំពើអាក្រក់ទាំងពួង

ការមិនធ្វើនូវអំពើអាក្រក់ទាំងពួង សំខានបំផុតគឺការមិនបៀបបៀនអ្នកដទៃ សេចក្តីសុខដែលកើតមកពីការមិនបៀបបៀនអ្នកដទៃ ជាសេចក្តីសុខដ៏ធំទូលាយ និងជាគ្រឹះនៃសេចក្តីសុខថ្នាក់ខ្ពស់តទៅទៀតផង។ ការមិនធ្វើអំពើអាក្រក់ គឺលោកចង់អប់រំមនុស្សទាំងឡាយ ឱ្យឈប់បន្តការប្រព្រឹត្តនូវអំពើបាបទាំងពួង ដែលបង្កផលប៉ះពាល់ និងការឈឺចាប់ដល់មនុស្សសត្វដទៃ និងនាំឱ្យខ្លួនឯងវិនាសអន្តរាយ។ អំពើបាបទាំងនោះ មានដូចជា ការកាប់សម្លាប់ជីវិតមនុស្សសត្វ ការឆក់យកទ្រព្យដោយមានម្ចាស់ហួងហែង ការប្រព្រឹត្តឆ្កាំឆ្កងលើកូនប្រពន្ធអ្នកដទៃ ការភូតកុហកបោកប្រាស់សាធារណជនដើម្បីកេងចំណេញផលប្រយោជន៍ផ្ទាល់ខ្លួន ការជិះជាន់កេងប្រវ័ញ្ច ជញ្ជក់ឈាមជនស្លូត

[1] ភិក្ខុ អ៊ុក អ៊ាន កម្ពុជាសុរិយាលេខ៩(ទស្សនៈពុទ្ធសាសនា) ការផ្សាយពុទ្ធសាសនាបណ្ឌិតឆ្នាំ១៩៧១, ទំព័រ៧៣៨

ត្រង់ក្រោមស្លាកនៃអំពើល្អ។ល។ ដូច្នេះ ដើម្បីទទួលបានសុភមង្គលក្នុងគ្រួសារ និងសេចក្ដីសុខក្នុងសង្គម គេត្រូវយកមាគ៌ាសន្តិភាពមកគោរពប្រតិបត្តិ ហើយដើម្បីទទួលបានសុខសន្តិភាព គឺតម្រូវឱ្យបុគ្គលគ្រប់រូបបញ្ឈប់ប្រព្រឹត្តអំពើបាបទាំងអស់ ដែលធ្លាប់មានក្នុងសន្តានរបស់ខ្លួនកន្លងមក។

ការបៀតបៀនអ្នកដទៃ វាកើតមកអំពីចិត្តដែលប្រាសចាកនូវសតិសម្បជញ្ញៈ ចិត្តមេត្តា ចិត្តមិនមាននូវសេចក្ដីសុខស្ងប់ ព្រោះហេតុតែចិត្តមានសភាពវរវីកជាទុក្ខយ៉ាងនេះហើយ ទើបបានបញ្ចេញនូវសកម្មភាពធ្វើឱ្យអ្នកដទៃមានសេចក្ដីទុក្ខផង ធ្វើឱ្យសង្គមជាតិវរវីកមិនមានសេចក្ដីស្ងប់ផង។ ដើម្បីការមិនបៀតបៀនអ្នកដទៃ មនុស្សយើងត្រូវតែអប់រំចម្រើននូវធម៌មាន ទី១មេត្តា មនុស្សបណ្ដុះមេត្តាឱ្យច្រើនអត់ហ៊ានសម្លាប់ទេ សូម្បីតែវាយគេមួយដៃទាត់គេមួយជើងក៏អត់ហ៊ានដែរ គឺមានក្ដីស្រឡាញ់។ ទី២ សម្មាអាជីវៈ ចិញ្ចឹមជីវិតត្រឹមត្រូវ។ កាលណាចិញ្ចឹមជីវិតត្រូវត្រឹម គឺអត់ទៅលួចគេ ទៅប្លន់គេ រស់ដោយកម្លាំងញើសឈាមខ្លួនឯង។ ទី៣ សទារសន្តោស មានន័យថា សន្តោសជាមួយភរិយា ឬជាមួយស្វាមីខ្លួនឯង កុំទៅរកអ្នកដទៃ។ ធម៌ទី៤គឺ សច្ចៈ កាលណាមនុស្សប្រកាន់សច្ចៈ មនុស្សនោះទៀងត្រង់មិននិយាយកុហក ហាមាត់កុហកទៅ គឺហាមិនកើត ដោយសារខ្លួនប្រកាន់នៅពាក្យសច្ចៈ។ ទី៥ យើងកាន់នូវធម៌មួយគឺ អប្បមាទ មានន័យថា មិនប្រមាថ កុំគិតថាផឹកមួយកែវអត់អី ផឹកមួយកេសវាមិនអី។ កាលណាយើងកាន់ធម៌ទាំង៥ យើងអាចរក្សាសីល៥បាន។[2] ការដែលមិនធ្វើនូវអំពើអាក្រក់ទាំងពួង ព្រោះមកអំពីមានសេចក្ដីសុខនៅក្នុងចិត្ត សេចក្ដីសុខនេះមានជាតិជាកុសល ជាសេចក្ដីសុខដែលប្រាសចាកគំនុំគុំគួន ប្រាសចាកការច្រណែន ប្រាសចាកគំនិតបៀតបៀន និងប្រាសចាកគ្រឿងសៅហ្មងរបស់ចិត្តផ្សេងៗទៀត។ សូមមនុស្សទាំងឡាយក្រងនូវកុសលធម៌ដើម្បីឱ្យខ្លួនឯងបានទៅជាមនុស្សដ៏ល្អ ដូចជាអ្នកក្រងផ្កា បានរើសយកផ្កាដែលល្អៗ មកក្រងសម្រេចបានទៅជាភួងមាលាដ៏ល្អយ៉ាងនោះឯង។ សូមមនុស្សទាំងឡាយស្វែងរកសេចក្ដីសុខ ពីក្នុងចិត្តរបស់ខ្លួនឱ្យបានច្រើន សូមចេះត្រេកអរនឹងអំពើល្អរបស់ខ្លួន សូមកុំបៀតបៀនសត្វដទៃ និងសូមកុំធ្វើនូវបាបទាំងពួងឡើយ។[3]

### ១.១.២.អំពីការបំពេញនូវសេចក្ដីល្អ

ការមិនធ្វើនូវអំពើអាក្រក់ទាំងពួង ប្រៀបដូចជាការងូតទឹកសម្អាតកាយ ឯការបំពេញនូវសេចក្ដីល្អ ប្រៀបដូចជាការស្លៀកពាក់ និងប្រដាប់តាក់តែងកាយដោយអលង្ការ។ ការបំពេញនូវសេចក្ដីល្អ គឺការបំពេញតាមតួនាទីជាមនុស្ស តួនាទីជាបុត្រធីតា តួនាទីជាភរិយា ឬជាស្វាមី តួនាទីជាមិត្ត តួនាទីជាមាតាបិតា និងតួនាទីជាបព្វជិតជាដើម។

---

[2] ដកស្រង់ចេញពីគេហទំព័រ ការរក្សាសីលនៅក្នុងព្រះពុទ្ធសាសនា - Lotus Broadcasting Services (lotus-radio.com) នៅថ្ងៃទី២៦ មិថុនា ឆ្នាំ២០២១

[3] អគ្គបណ្ឌិត ប៊ុត សាវង្ស ព្រះពុទ្ធសាសនា ព.ស.២៥៤៦, ទំព័រ០១

កិច្ចការក្នុងតួនាទី ដែលត្រូវបំពេញយ៉ាងណានោះ ព្រះសម្មាសម្ពុទ្ធទ្រង់បានត្រាស់សម្តែងប្រាប់សព្វគ្រប់ទាំងអស់។ ដូច្នេះ ដើម្បីបំពេញនូវតួនាទីរបស់ខ្លួន ឈានឆ្ពោះទៅរកសេចក្តីសុខ មនុស្សគ្រប់គ្នាត្រូវសិក្សាព្រះធម៌ ដែលជាពាក្យទូន្មានរបស់ព្រះសម្មាសម្ពុទ្ធ ជាប្រយោជន៍ដើម្បីការយល់ត្រូវ ចំពោះការងារដែលត្រូវធ្វើ និងដើម្បីតម្កល់ខ្លួន ក្នុងតួនាទីដ៏ប្រពៃដែលជាមុខតួនាទីរបស់ខ្លួនពិតៗ។ មនុស្សយើងត្រូវតែព្យាយាម ធ្វើសេចក្តីល្អឱ្យអស់ពីសមត្ថភាព បំពេញតួនាទីឱ្យបានពេញលេញបរិបូណ៌ ដើម្បីពូននូវគុណតម្លៃនៃជីវិត ឱ្យជាមនុស្សល្អ ជាមាតាបិតាល្អ ជាកូនល្អ ជាគ្រូល្អ ជាសិស្សល្អ ជាភរិយាស្វាមីល្អ ជាមិត្តល្អ ជាចៅហ្វាយនាយល្អ ជាអ្នកបំរើល្អ ជាបរិស័ទល្អ ជាប្រជាពលរដ្ឋល្អ និងឱ្យជាមនុស្សមានតម្លៃសម្រាប់សាសនា និងសង្គមជាតិ។ ពុទ្ធសាសនិកដែលល្អ គឺជាអ្នកដែលបានបំពេញតួនាទីយ៉ាងខ្ជាប់ខ្ជួន ចំពោះបព្វជិតត្រូវបំពេញនូវគន្ថធុរៈ និងវិបស្សនាធុរៈ ព្រមដោយការពន្យល់ប្រាប់អំពីព្រះពុទ្ធសាសនា ជាឧបាសក ជាឧបាសិកា ត្រូវខ្វល់ខ្វាយបំពេញកិច្ចការទំនុកបម្រុង ព្រះពុទ្ធសាសនាដោយម៉ឺងម៉ាត់ មកវត្តដើម្បីជួយកិច្ចការរបស់វត្តឱ្យបានពេញដៃ ពេញជើង ធ្វើការដោយចិត្តស្មោះត្រង់ ត្រូវកសាងខ្លួនឱ្យមានតម្លៃ និងទៅជាធនធានដ៏សំខាន់របស់ព្រះពុទ្ធសាសនា។

ម្យ៉ាងទៀត មនុស្សដែលមានតម្លៃ គឺមនុស្សដែលពឹងបាន ដំបូលផ្ទះមានតម្លៃព្រោះធ្វើឱ្យយើងពឹងបាន ដោយបិទបាំងនូវកម្តៅថ្ងៃ និងទឹកភ្លៀងជាដើម។ ទោះបីជាអ្វីទៀតក៏ដោយឱ្យតែជាទីពឹងបាន គឺសុទ្ធតែជារបស់មានតម្លៃទាំងអស់ យ៉ាងណាមិញ មនុស្សយើងដែលកើតមកហើយ អាចជាទីពឹងបានដល់អ្នកដទៃ ឬឱ្យអ្នកដទៃពឹងបាន គឺជាមនុស្សមានតម្លៃយ៉ាងនេះឯង។ ការបំពេញនូវអំពើល្អគ្រប់យ៉ាង គឺដើម្បីធ្វើខ្លួនឱ្យបានជាទីពឹង យ៉ាងហោចណាស់ក៏ត្រូវឱ្យបានជាទីពឹងនៃខ្លួនឯងដែរ។[4]

ការបំពេញដោយការធ្វើសេចក្តីល្អ គឺព្រះពុទ្ធមានព្រះបំណងឱ្យយើងគ្រប់គ្នា ចាប់ផ្តើមធ្វើអំពើល្អទាំងពួង មិនមែនឈប់ធ្វើអំពើអាក្រក់ហើយ ឈប់ធ្វើអ្វីៗទាំងអស់ ហើយសំងំនៅស្ងៀមមិនធ្វើអ្វីនោះទេ។ ហើយការធ្វើអំពើល្អ ដូចជា ការមិនបៀតបៀនឈ្នានីសអ្នកដទៃ ការចេះជួយសង្គ្រោះដល់អ្នកដទៃ ការចេះចែករំលែកនូវសេចក្តីសុខ និងទ្រព្យសម្បត្តិដែលខ្លួនមានដល់អ្នកដទៃ ការចូលរួមជួយដោះស្រាយបញ្ហាផ្សេងៗដល់សាច់ញាតិ ក្រុមគ្រួសារ បងប្អូន ក្នុងសហគមន៍ និងការជួយគិតគូរដល់បញ្ហាសង្គមទាំងមូលផងដែរ។ មួយវិញទៀត ការលះបង់ផលប្រយោជន៍ និងសេចក្តីសុខផ្ទាល់ខ្លួនដើម្បីអ្នកដទៃ គឺជាអំពើដ៏ប្រពៃមួយ ដែលព្រះជិនស្រីនៃយើង ទ្រង់កោតសរសើរ ហើយសូម្បីអ្នកប្រាជ្ញទស្សនវិទូក្នុងលោកក៏ឱ្យតម្លៃដែរ។

---

[4] អគ្គបណ្ឌិត ប៊ុត សាវង្ស ព្រះពុទ្ធសាសនា ព.ស.២៥៤៦, ទំព័រ០៦

### ១.១.៣.អំពីការសម្អាតចិត្តរបស់ខ្លួនឱ្យបានស្អាត

ការមិនធ្វើនូវអំពើបាបទាំងពួង ប្រៀបដូចអ្នកឈឺវៀរចំណីទាស់ ការបំពេញនូវសេចក្តីល្អ ប្រៀបដូចអ្នកឈឺបរិភោគអាហារប៉ប៉នសុខភាព ឯការសម្អាតចិត្តរបស់ខ្លួនឱ្យបានស្អាត ប្រៀបដូចអ្នកឈឺលេបថ្នាំកម្ចាត់បង់នូវរោគឱ្យបានជាសះស្បើយ។ ការសម្អាតចិត្តឱ្យស្អាតផូរផង់ គឺលោកចង់ឱ្យយើងជម្រះចិត្តឱ្យស្អាតបរិសុទ្ធ ដោយកម្ចាត់ចោលនូវកិលេស ជាគ្រឿងសៅហ្មងទាំងឡាយឱ្យអស់ពីខន្ធសន្តានរបស់យើង។ គ្រឹះនៃកិលេសដែលធ្វើឱ្យចិត្តរបស់យើងសៅហ្មង កន្ទក់កន្ទេញនោះ គឺលោភៈ ទោសៈ និងមោហៈ។ លោភៈ គឺសេចក្តីចង់បាននូវអ្វីៗ គ្រប់យ៉ាងគ្មានព្រំដែន។ ទោសៈ គឺការក្រោធខឹងនឹងវត្ថុក្នុងលោក។ មោហៈ គឺភាពវង្វេងក្នុងលោក ដោយយល់ខុសពីការពិតចំពោះធម្មជាតិ។

ការសម្អាតចិត្តរបស់ខ្លួនឱ្យស្អាត អាស្រ័យដោយបញ្ញាយល់ដឹងអំពីការពិតនៃជីវិត បញ្ញាធ្វើកិច្ចកម្ចាត់បង់នូវគ្រឿងសៅហ្មងរបស់ចិត្ត ដូច្នេះ ក្នុងជីវិតរាល់ថ្ងៃត្រូវអប់រំចម្រើនបញ្ញា។ ការពិតនៃជីវិត គឺរមែងមានលាភ រមែងអត់លាភ រមែងមានយស រមែងអត់យស រមែងមានគេសរសើ រមែងមានគេនិន្ទា រមែងមានសុខ រមែនមានទុក្ខជាធម្មតា តែព្រោះមិនដឹងការពិតនៃជីវិត ចិត្តក៏រមែនចម្រើនដោយគ្រឿងសៅហ្មង។ ការសិក្សាអំពីសេចក្តីពិតនៃជីវិត ដោយយោនិសោមនសិការ ជាហេតុនាំឱ្យចម្រើននូវបញ្ញា។ យោនិសោមនសិការ គឺឆ្លាតក្នុងការពិចារណា បានដល់ការពិចារណារកហេតុនៃអ្វីៗ ដែលបានកើតឡើង ព្រោះអ្វីៗដែលបានកើតក្នុងជីវិត សុទ្ធតែត្រឹមត្រូវពិតទៅតាមហេតុ។ ហេតុផលជាច្បាប់ធម្មជាតិ ជាការពិតនៃជីវិត ជាសច្ចធម៌ ជាធម្មដែលសម្រាប់សិក្សា ដូច្នេះហើយយើងត្រូវកែប្រែពីការញាប់ញ័រចំពោះ សេចក្តីពិតនៃជីវិត ត្រឡប់មកជាការសិក្សាអប់រំចម្រើនប្រាជ្ញាស្មារតី ក្នុងសេចក្តីនៃជីវិតវិញ។

ជារួមការមិនធ្វើអំពើអាក្រក់ទាំងពួង បានផ្តល់ឱកាសដល់ការបំពេញសេចក្តីល្អ ឯការបំពេញសេចក្តីល្អមានឧបការៈដល់ការសម្អាតចិត្តរបស់ខ្លួន ជាទីបំផុតនៃព្រហ្មចរិយធម៌ទាំងបីមុខនេះ គឺចិត្តស្អាតផូរផង់ហ្នឹងឯងចិត្តស្អាតផូរផង់មានប្រយោជន៍ដល់ការឈ្នះអស់នូវទុក្ខទាំងពួង។[5]

### ១.១.៤.ទស្សនកម្មផលក្នុងព្រះពុទ្ធសាសនា

ទស្សនកម្មផលរបស់ព្រះពុទ្ធបរមគ្រូនៃយើង មានទំនាក់ទំនងទៅនឹងការវិលកើត-ស្លាប់នៃសត្វលោក។ នៅក្នុងព្រាហ្មណ៍លទ្ធិ ភាវៈកើតឡើងដោយមានអាទិទេពជាអ្នកបង្កើត។ ចំណែកក្នុងពុទ្ធលទ្ធិ ភាវៈកើតឡើងដោយខ្លួនឯងតាមច្បាប់ធម្មជាតិ។ មនុស្ស ឬសត្វធាតុដែលកើត ឬស្លាប់គឺដោយសារខន្ធទាំង ៥ (រូបក្ខន្ធ វេទនាក្ខន្ធ សញ្ញាក្ខន្ធ សង្ខារក្ខន្ធ វិញ្ញាណក្ខន្ធ) បានជួបប៉ះទង្គិចផ្គុំផ្សំគ្នាហើយកើតឡើង។ ភាវៈដែលមានកំណើត ហើយបែបនេះរមែងមានការប្រែប្រួល ធំធាត់ ហើយទ្រុឌទ្រោមរួចរលត់ខន្ធទាំង ៥ ទៅវិញ (ស្លាប់) រួចហើយទើបមានការប៉ះទង្គិចផ្គុំផ្សំគ្នា

[5] អគ្គបណ្ឌិត ប៊ុត សាវង្ស ព្រះពុទ្ធសាសនា ព.ស.២៥៤៦ ទំព័រ១០-១៤

ឡើងវិញជាថ្មីទៀត (ជីវិតថ្មី ) យ៉ាងនេះរៀងដរាបទៅ។

ក្នុងទស្សនៈនេះគេចាត់ទុកការស្លាប់ជាខណៈមួយ ដែលខន្ធទាំងប្រាំត្រូវរលាយ ហើយចាត់ទុកការកើតជាខណៈមួយដែលខន្ធទាំង ៥ ផ្គុំផ្សំជាថ្មីឡើងវិញ។ ខន្ធទាំង ៥ នៃមនុស្សសត្វត្រូវរលាយរលត់ ទៅវិញនៅពេលស្លាប់ក៏ពិតមែនហើយ ប៉ុន្តែនៅសល់ថាមពល ឬចំហាយនៃខន្ធ ដែលបានប៉ះទង្គិចនូវធាតុឯទៀតៗ បណ្តាលឱ្យកើតមានជារូបមួយឡើងទៀត។ ថាមពល ឬចំហាយនៃជីវិតចាស់នេះមានឈ្មោះថា "កម្មផល" នេះឯង។ ដូចនេះជីវិតចាស់មានទំនាក់ទំនងជាមួយជីវិតថ្មី។ ជីវិតចាស់ និងជីវិតថ្មីដូចគ្នាផងប្លែកគ្នាផង។ ដូចគ្នាត្រង់ជីវិតថ្មីទទួលចំហាយកម្មផលពីជីវិតចាស់ ប៉ុន្តែពុំដូច ឬប្លែកគ្នាត្រង់ជីវិតថ្មីមានការកសាងការអប់រំថ្មីៗទៀត។

ទស្សនៈពុទ្ធនិយមបានពន្យល់ឃើញថា សត្វលោកទាំងឡាយរមែងវិលកើតវិលស្លាប់ មិនចេះអស់មិនចេះហើយក្នុងសំហវៈ។ កាលបើកើតឡើងហើយ រមែងមានចាស់ ឈឺ ស្លាប់ ហើយនៅពេលចាស់រមែងជួបប្រទះ នឹងទុក្ខសោករោគាព្យាធិ និងសេចក្តីលំបាកវេទនាផ្សេងៗ មិនអាចជៀសផុត។ ឯការដែលនាំឱ្យផុតចាកជរា-ឈឺ-ស្លាប់ និងទុក្ខសោកផ្សេងៗបាន គឺមិនចាប់កំណើតតទៅទៀត ព្រះពុទ្ធសាសនាឱ្យឈ្មោះថា "និព្វាន" ។[6]

### ១.១.៥.ខ្លឹមសារសំខាន់នៃពាក្យប្រៀនប្រដៅរបស់ព្រះពុទ្ធ

ពាក្យប្រៀនប្រដៅរបស់ព្រះពុទ្ធជាម្ចាស់ទាំងអស់ មានអរិយសច្ចៈ៤ ជាស្នូលដូចគ្នានឹងខ្នងកង់ និងកាំកង់មានដុំកង់ជាស្នូល។ គេហៅថាបួន ពីព្រោះមានបួនក្នុងចំណោមស្នូលទាំងនោះ។ គេហៅថា អរិយៈ ពីព្រោះគេចង់លើកកំពស់បុគ្គលណាយល់នូវធម៌ទាំងបួននោះហើយគេហៅថាសច្ចៈ ពីព្រោះជាសេចក្តីពិត និងឱបក្រសោបជាមួយសេចក្តីពិតជានិច្ច។[7] គឺជាសច្ចៈភាពទាំងបួន ដែលត្រូវបានជួបពិសោធន៍ថាត្រឹមត្រូវ ដោយបុគ្គលណាដែលបានមើលឃើញនូវសភាវៈពិត។

**អរិយសច្ចៈទី១** គឺជីវិតដែលប្រទះតែសេចក្តីទុក្ខ។ ដើម្បីមានជីវិតអ្នកច្បាស់ជាមានទុក្ខ។ វាមិនអាចប្រព្រឹត្តទៅបានដែលថាជីវិតរស់នៅ មិនដែលប្រឈមមុខនឹងសេចក្តីទុក្ខនោះ។ យើងត្រូវតែឆ្លងកាត់ សេចក្តីទុក្ខខាងផ្លូវកាយដូចជាឈឺរបួសការនឿយហត់ ចាស់ជរា និងសេចក្តីស្លាប់នៅទីបញ្ចប់ ហើយយើងត្រូវតែឆ្លងកាត់សេចក្តីទុក្ខខាងផ្លូវចិត្តដូចជាភាពឯកោ ការព្រួយកង្វល់ ការភិតភ័យ ការតូញត្អែរ ការអស់សង្ឃឹម និងសេចក្តីខឹងជាដើម។

---

[6] ដកស្រង់ចេញពីគេហទំព័រ ទស្សនៈពុទ្ធសាសនា | ឃ្លាំងគំនិត (wordpress.com) នៅថ្ងៃទី២៨ មិថុនា ឆ្នាំ២០២១

[7] S.Dhammika សំណួរល្អ ចំឡើយល្អ(Good Question, Good Answer) បកប្រែដោយភិក្ខុ សេង សុភ័ណ ព.ស.២៥៤៧ គ.ស.២០០៤, ទំព័រ២០

**អរិយសច្ចៈទី២** គឺសេចក្តីទុក្ខទាំងអស់មានមូលហេតុមកពីតណ្ហា។ ពេលយើងសម្លឹងមើលសេចក្តីទុក្ខខាងផ្លូវចិត្តយើងឃើញយ៉ាងងាយ នូវតណ្ហាដែលជាហេតុនៃសេចក្តីទុក្ខ។ ពេលយើងត្រូវការវត្ថុខ្លះតែ មិនបានដូចបំណងយើងនឹងព្រួយកង្វល់។ ពេលយើងសង្ឃឹមថា មាននរណាម្នាក់មករកយើង តែគេមិនបានមកយើងហាក់ដូចជាអស់កម្លាំងកំហែង និងអស់សង្ឃឹម។ ពេលយើងចង់ឱ្យអ្នកដទៃដូចយើង តែវាមិនដូចយើងនឹងឈឺចុកចាប់។ ទោះបីពេលយើងចង់បានអ្វីមួយ ហើយយើងអាចបានរបស់នោះ ក៏មិនបាននាំសេចក្តីសុខមកឱ្យយើងគ្រប់ពេលផងដែរ ពីព្រោះមិនយូរប៉ុន្មាន យើងហាក់ដូចជាធុញទ្រាន់ ជាមួយវត្ថុនោះចំណូលចិត្តចំពោះវត្ថុនោះហើយចាប់ផ្តើមប្រាថ្នាចង់បានវត្ថុដទៃផ្សេងៗទៀត។ និយាយឱ្យសាមញ្ញ គឺថាអរិយសច្ចៈទី២ បានន័យថា បានអ្វីក៏ដោយដែលអ្នកត្រូវការក៏មិនធានាដល់សេចក្តីសុខឡើយ។ ទោះបីការតស៊ូជាបន្តបន្ទាប់ ដើម្បីទទួលបាននូវអ្វីដែលអ្នកចង់បាន ព្យាយាមធ្វើឱ្យបាននូវចំណង់របស់អ្នក។ តណ្ហាដកហូត ពីយើងនូវភាពស្ងប់ចិត្ត និងសេចក្តីសុខ។

**អរិយសច្ចៈទី៣** គឺយើងអាចយកជំនះលើសេចក្តីទុក្ខបានហើយ សេចក្តីសុខអាចធ្វើបានសម្រេច។ នេះអាចពិតជាសារៈសំខាន់បំផុត របស់អរិយសច្ចៈទី៤ ពីព្រោះចំពោះអរិយសច្ចៈនេះព្រះពុទ្ធជាម្ចាស់ បញ្ជាក់ប្រាប់យើងថាសេចក្តីសុខពិត និងភាពពេញបរិបូរណ៍អាចសម្រេចយកបាន។ ពេលយើងបោះបង់ចោលចំណង់ឥតប្រយោជន៍ចេញ ហើយរៀនសូត្រក្នុងការរស់នៅពីមួយថ្ងៃទៅមួយថ្ងៃរីករាយចិត្ត ដោយមិនចាំបាច់មានចំណង់គ្មានឈប់ឈរដែលជាបទពិសោធន៍ ពិតរបស់ជីវិតបន្តការងារដោយការអត់ធន់នូវបញ្ហាដែលទាក់ទង ជីវិតដោយគ្មានសេចក្តីភ័យខ្លាចសេចក្តីខឹងនិងក្រេវក្រោធពេលនោះ យើងនឹងបានជាអ្នកមានសេចក្តីសុខ នឹងរំដោះរួចពីទុក្ខទាំងពួង។ ពេលនោះហើយជាពេលតែមួយដែលយើងចាប់ផ្តើមមានជីវិតយ៉ាងពេញបរិបូរណ៍។ ពីព្រោះ យើងមិនធុញថប់អ្វីទៀតឡើយជាមួយនឹងការធ្វើឱ្យស្កប់ស្កល់ នូវចំណង់អត្តភាពផ្ទាល់ខ្លួនរបស់យើង ហើយយើងមានពេលច្រើនជាងមុន ដើម្បីជួយអ្នកដទៃបំពេញតម្រូវការរបស់គេ។ អាណាចក្រនេះគេហៅថាព្រះនិព្វាន។ យើងរំដោះខ្លួនរួចផុត ពីសេចក្តីទុក្ខខាងផ្លូវចិត្តបានយ៉ាងពិតប្រាកដ។ នេះគេហៅថា ព្រះនិព្វាននៅទីបំផុត។

**អរិយសច្ចៈទី៤** គឺផ្លូវនាំទៅរកការឈ្នះនូវទុក្ខទាំងពួង។ ផ្លូវនេះ គេហៅថាអរិយមគ្គប្រកបដោយអង្គ ៨ ហើយមានអង្គប្រកបដូចតទៅនេះ។ គឺការយល់ឃើញត្រូវ ការត្រិះរិះត្រូវ ការពោលពាក្យត្រូវ ការងារត្រូវ ការប្រកបរបរកស៊ីចិញ្ចឹមជីវិតត្រូវ ការព្យាយាមត្រូវ ការភ្ញាក់រឭកត្រូវ សមាធិត្រូវ។[8] ការបដិបត្តិរបស់ពុទ្ធបរិស័ទមានគ្រប់អង្គទាំង ៨ នេះរហូតដល់ពួកគេអាចសម្រេចធម៌តាមលំដាប់បាន។ អ្នកអាចសង្កេតឃើញថា ជាន់ថ្នាក់នៃអរិយមគ្គ ប្រកបដោយ

[8] ដកស្រង់ចេញពីគេហទំព័រ អរិយសច្ចៈ | អ្នកមាន (neakmien.club) នៅថ្ងៃទី២៦ មិថុនា ឆ្នាំ២០២១

អង្គ៨ គ្របដណ្តប់ទៅលើបញ្ហាគ្រប់បែបយ៉ាង របស់ជីវិតដូចជាបញ្ហាសតិបញ្ញា បញ្ហាចរិយាធម៌ បញ្ហាសេដ្ឋកិច្ច បញ្ហាផ្លូវចិត្ត និងមិនតែប៉ុណ្ណោះនៅមានវត្ថុគ្រប់យ៉ាង ដែលមនុស្សត្រូវការដើម្បីធ្វើឱ្យជីវិតបានល្អប្រសើរ និងអភិវឌ្ឍន៍ចិត្តវិញ្ញាណបាន។

## ១.២.ប្រវត្តិព្រះពុទ្ធសាសនានៅកម្ពុជា

ប្រទេសខ្មែរបានទទួលអរិយធម៌ឥណ្ឌាទុកជាមរតកតាំងពីបុរាណកាល សាសនាព្រហ្មណ៍ក្តី ពុទ្ធសាសនាក្តីដែលបានមកប្រតិស្ឋាននៅលើដែនដីខ្មែរ ហើយក៏បានក្លាយទៅជាអរិយធម៌សម្រាប់ប្រទេស ប្រជាជនខ្មែរបានរក្សាអរិយធម៌នោះទុកជាប្រពៃណីដោយប្រពៃ តពូជពង្សរៀងរាបរហូតមកដល់បច្ចុប្បន្នកាល។ ដើមឡើយបុព្វជនខ្មែរក៏ដូចជាបុព្វជននៃមនុស្សទាំងឡាយ លើពិភពលោកសម័យមុនប្រវត្តិសាស្ត្រដែរ តែងតែគោរពលោកធាតុគឺ ទឹក ដី ភ្លើង ខ្យល់ អារក្ស ទេពារក្ស ព្រះធរណី ព្រះពាយ យកឈើព្រៃភ្នំក្រំថ្មជាទីពឹងទីរឭក សម្រប់បង្ក្រាបភ័យតក់ស្លុត ដូចយើងបានឃើញការលៀងអារក្ស ជាទំនៀមយើងក្នុងកាលសព្វថ្ងៃនេះសមនឹងពុទ្ធភាសិតថា៖

"មនុស្សទាំងឡាយច្រើន ដែលត្រូវភ័យគម្រាមហើយ តែងយកភ្នំ ព្រៃ អារាម ឈើ ចេតិយជាទីពឹងទីរឭក"។ សម័យតមក ប្រជាជនខ្មែរជ្រើសយកសាសនាតែមួយ ដែលខ្លួនយល់ឃើញថាជាសរណៈដ៏ឧត្តម អាចបង្ក្រាបភ័យតក់ស្លុតបាន អាចសម្រេចសេចក្តីប្រាថ្នា និងសេចក្តីសង្ឃឹមបាន ព្រមទាំងអាចបញ្ជាក់នូវសេចក្តីទុកចិត្តរបស់ខ្លួនទៅអនាគតបានផង សមដូចពុទ្ធភាសិតថា៖ "អ្នកណាបានដល់នូវព្រះពុទ្ធ ព្រះធម៌ ព្រះសង្ឃទុកជាទីពឹងទីរឭក បានឃើញច្បាស់នូវអរិយសច្ចទាំង៤ ដោយប្រាជ្ញាប្រពៃ គឺទុក្ខសច្ច១ សមុទយសច្ច១ និរោធសច្ច១ មគ្គសច្ចមានអង្គ៨ ជាដំណើរទៅកាន់ក្តីរម្ងាប់ទុក្ខ១ នុះឯងជាសរណៈក្សេម នុះឯងជាសរណៈឧត្តម អ្នកនោះទើបរួចចាកទុក្ខទាំងពួងបានព្រោះអាស្រ័យនូវត្រៃសរណៈដ៏ឧត្តមនេះ"។ ព្រះពុទ្ធសាសនាបានទូន្មានអប់រំប្រជាជនខ្មែរ ហើយបង្រៀនឱ្យចេះប្រើជីវិតតស៊ូយកឈ្នះ នូវជំនឿភូតនិយមនៃបុព្វជន ត្រាតែរសព្រះធម៌ជ្រួតជ្រាបក្នុងសាច់ឈាម និងជីវិតចិត្តថ្លើមរៀងរាល់ថ្ងៃ។ តាំងពីបានចូលមកប្រតិស្ឋាននៅលើដែនដីខ្មែរហើយ ព្រះពុទ្ធសាសនាក៏បានតាំងនៅស៊ប់ ឥតសាបសូន្យទៅក្នុងវេលាណាមួយឡើយ គ្រាន់តែមិនបានចេញឈ្មោះជាផ្លូវការ ឬមិនបានទទួលក្តីប្រោសប្រាណពីរាជសំណាក់ក្នុងកាលខ្លះប៉ុណ្ណោះ ហើយក៏បានផ្សាយឥទ្ធិពលទៅលើលិល្បៈ និងអក្សរសាស្ត្រខ្មែរទៀត។ នៅក្នុងសម័យអាប់ឱនព្រះពុទ្ធសាសនាអាចជ្រកជ្រៀតនៅជាមួយសាសនាព្រាហ្មណ៍បាន ហើយស្ថិតនៅបិតថេរថីរកាលនៅរហូតមក ដូចប្រវត្តិពុទ្ធសាសនានៅប្រទេសខ្មែរបង្ហាញឱ្យឃើញស្រាប់។[9]

[9] ព្រះមហាវីរិយបណ្ឌិតោ ប៉ាង ខាត់ ប្រវត្តិពុទ្ធសាសនានៅកម្ពុជា, ទំព័រ១

ព្រះពុទ្ធសាសនាចាប់កំណើតឡើង នៅលើទឹកដីកម្ពុជាតាំងពីសតវត្សទី៥ នៃគ្រឹស្តសករាជមកម្ល៉េះ ហើយបើតាមប្រភពខ្លះ មានជាអាទិ៍ ប្រវត្តិវិទូ David P. Chandler តាមរយៈសៀវភៅរបស់លោក ដែលបានចេញផ្សាយនៅឆ្នាំ១៩៩១ បានបញ្ជាក់ថា ព្រះពុទ្ធសាសនាបានរីកលូតលាស់នៅប្រទេសនេះ នៅក្នុងគ្រឹស្តសតវត្សទី៦ និងទី៧។[10] និងឯកសារខ្លះទៀតបង្ហាញថាព្រះពុទ្ធសាសនាថេរវាទ ត្រូវបាននាំចូលមកលើទឹកដីកម្ពុជា ក្នុងរាជព្រះបាទអសោក ដែលបានបញ្ជូនសមណទូត២អង្គព្រះនាម សោណត្ថេរ និងឧត្តរត្ថេរ មកកាន់ទឹកដីសុវណ្ណភូមិតាំងពីពុទ្ធសតវត្សទី៣។ ហើយសាសនានេះបានបន្តរីកចម្រើនបន្តិចម្តងៗ ជាមួយនឹងព្រហ្មញ្ញសាសនា ដូចមានសិលាចារឹក មួយនៅលើទឹកដីវៀតណាមសព្វថ្ងៃ គឺសិលាចារឹកវ៉ូកាញ់ ខេត្តញ៉ាត្រាងចុះកាលបរិច្ឆេទនាសតវត្សទី៣ ដែលបាននិយាយពីព្រះមហាក្សត្រ គឺព្រះបាទស្រីមារៈទាក់ទងទៅនឹងពុទ្ធសាសនានេះផងដែរ។ ក្រៅពីការចូលមកកាន់ទឹកដីខ្មែរ តាមរយៈអ្នកផ្សព្វផ្សាយទាំងនោះ ពុទ្ធសាសនាក៏ត្រូវបានមកតាមរយៈពួកអ្នកជំនួញឥណ្ឌាផងដែរ។ ហើយចាប់ពីសតវត្សទី១៣រៀងមក លើកលែងតែនៅសម័យដែលខ្មែរក្រហមគ្រប់គ្រងអំណាច ព្រះពុទ្ធសាសនាបានក្លាយទៅជាសាសនារបស់រដ្ឋ ដែលមានពុទ្ធសាសនិកជាខ្មែរប្រមាណជិត៩៥ភាគរយនៃប្រជាជនសរុប។[11]

### ១.២.១.ទិដ្ឋភាពពុទ្ធសាសនាចូលមកកម្ពុជាដំបូង

- **ពុទ្ធសាសនានៅសម័យហ្វូណាន ឬនគរភ្នំ**

អាណាចក្រហ្វូណាន ពីសតវត្សទី២មុនគ្រឹស្តសករាជ រហូតដល់សតវត្សទី៦នៃគ្រឹស្តសករាជ បានកាន់នូវលទ្ធិហិណ្ឌូ ដោយមានព្រះមហាក្សត្រជាអ្នកដឹកនាំ និងមានជំនឿលើព្រះសិវ និងព្រះវិស្ណុ។ ទោះជាយ៉ាងនេះក្តីព្រះពុទ្ធសាសនា ក៏មានវត្តមានរួចជាស្រេចហើយនៅលើទឹកដីនៃអាណាចក្រនេះ ដែលជាសាសនាទី២បន្ទាប់ពី ព្រាហ្មណ៍សាសនា។ ប្រភពលង្កាទ្វីបជាសក្ខីភាព យើងត្រូវនិយាយថាព្រះពុទ្ធសាសនាបានចូលមកប្រទេសនគរភ្នំ(Founan) តាំងពីពុទ្ធសតវត្សរ៍ទី៣(ព.ស.២៣៤) គឺមុនគ្រិស្តសករាជ ៣០៩ឆ្នាំ ព្រោះនគរភ្នំនេះ ឋិតក្នុងតំបន់សុវណ្ណភូមិខាងបុព្វទិស ឬអាស៊ីភាគអគ្នេយ៍។[12] ព្រះពុទ្ធសាសនាមានភាពរីកចម្រើនរុងរឿង នៅកំឡុងគ្រឹស្តសតវត្សទី៥ និងទី៦ ក្នុងរជ្ជកាលព្រះបាទកៅឌិណ្ឌន្យវរ្ម័ន ព្រោះមានការបញ្ជូនព្រះសង្ឃខ្មែរ និងជាតិឥណ្ឌាទៅកាន់ប្រទេសចិនដើម្បីយកឯកសារ និងពុទ្ធរូបទៅថ្វាយដល់ស្តេចក្រុងចិន ព្រមទាំងបានជួយបកប្រែគម្ពីរ ពីសំស្រ្កឹតទៅភាសាចិនទៀតផង។

---

[10] មជ្ឈមណ្ឌលសម្រាប់ការសិក្សាស្រាវជ្រាវជាន់ខ្ពស់ ពិធីបំបួសនាគនៅប្រទេសកម្ពុជា អតីតកាល និងបច្ចុប្បន្ន ឆ្នាំ២០០៥, ទំព័រ១៣

[11] ដកស្រង់ចេញពីគេហទំព័រ ប្រវត្តិព្រះពុទ្ធសាសនានៅកម្ពុជា | (wordpress.com) នៅថ្ងៃទី៣០ មិថុនា ឆ្នាំ២០២១

[12] ឥន្ទ ឱមសាម៉េង កម្រងប្រវត្តិសាស្ត្រនៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ២០០៣, ទំព័រ២៩

ព្រះសង្ឃនាមសង្ឃបាលបានគង់នៅ ស្រុកចិន១៦ឆ្នាំ ព្រមទាំងបានទទួលនូវងារជាព្រះរាជគ្រូរបស់ចិនទៀតផង នេះក៏ព្រោះតែចំណេះដឹងផ្នែកសាសនារបស់ព្រះអង្គ។[13]

- **ពុទ្ធសាសនាសម័យចេនឡា**

នៅសម័យហ្វូណន ព្រះពុទ្ធសាសនានៅរុងរឿងគួរសមនៅឡើយ។ លុះដល់ចុងសតវត្សទី៧ តាមសង្ឃដីការបស់ព្រះសង្ឃចិនមួយអង្គព្រះនាមយីស៊ីង ដែលបាននិមន្តត្រឡប់ពីប្រទេសឥណ្ឌា ទៅកាន់ប្រទេសចិនកាត់តាមរាជាណាចក្រចេនឡាឱ្យដឹងថា ពីដើមឡើយ ព្រះធម៌មានភាពរុងរឿងណាស់ ហើយបានផ្សព្វផ្សាយគ្រប់ទិសទី តែឥឡូវនេះស្តេចកំណាចមួយអង្គ បានបំផ្លិចបំផ្លាញចោលទាំងអស់ ហើយព្រះសង្ឃរកតែមួយអង្គនិមន្តមិនបានផង។ តាមរយៈនេះឃើញថា ព្រះពុទ្ធសាសនាត្រូវបានសាបរលាបនូវឥទ្ធិពលរបស់ខ្លួននៅក្នុងសតវត្សនេះ ប៉ុន្តែមិនមែនមានន័យថាបាត់បង់ទាំងស្រុងនោះទេ ផ្ទុយទៅវិញនៅសតវត្សក្រោយមក ពុទ្ធសាសនាមហាយានបានចាប់ផ្តើមផ្សាយឥទ្ធិពលរបស់ខ្លួន និងមានប្រជាពលរដ្ឋបានគោរពខ្លះៗហើយ។ នៅសម័យនេះមានសិលាចារិកតែមួយគត់ដែលនិយាយពីព្រះភិក្ខុពុទ្ធសាសនាចំនួនពីរអង្គ។

### ១.២.៣.ពុទ្ធសាសនាសម័យអង្គរ

បន្ទាប់ពីការទ្រុឌទ្រោមនៃលទ្ធិពុទ្ធសាសនាហីនយាន(ថេរវាទ) នៅសម័យចេនឡា នាកំឡុងសតវត្សទី៧មក ពុទ្ធសាសនាមហាយានបានចាប់ផ្តើមកកើតឡើង រហូតដល់សម័យអង្គរ។ នៅក្នុងសតវត្សទី៩ រជ្ជកាលព្រះបាទជ័យវរ្ម័នទី២ មានការប្រារព្ធធ្វើពិធីទេវរាជនៅលើភ្នំគូលែន ដែលអាចបង្ហាញថាព្រះរាជាអង្គនេះមានជំនឿយ៉ាងមុតមាំចំពោះព្រហ្មញ្ញសាសនា ដែលមានឥទ្ធិពលខ្លាំងក្លានៅសម័យនោះ និងមានការគោរពរាប់អានខ្លាំងពីប្រជារាស្ត្រខ្មែរ។ តែទោះជាយ៉ាងណាក្តី ក៏ពុទ្ធសាសនាមហាយាន បានបន្តវត្តមានរបស់ខ្លួនដដែលនៅលើទឹកដីខ្មែរលាយឡំជាមួយនឹងលទ្ធិព្រាហ្មផងដែរ។ តាមរយៈឯកសារខ្លះបានបង្ហាញថាពុទ្ធសាសនាបានរីកចម្រើន និងមានការទទួលស្គាល់បន្តិចម្តងៗ ពីប្រជារាស្ត្រ និងព្រះមហាក្សត្រខ្មែរបន្តបន្ទាប់មក។ នៅសតវត្សទី៩ ក្នុងរាជព្រះបាទយសោវរ្ម័នទី១ មានការសាងសង់បារាយណ៍ខាងកើតឈ្មោះ យសោធរតដាក ដោយនៅភាគខាងកើត គឺលើច្រាំងនៃបារាយណ៍នេះមានការសាងសង់បន្ថែមនូវអាស្រមសម្រាប់គណៈសាសនានៅសម័យនោះដូចជា៖

-ព្រាហ្មណាស្រម សម្រាប់អ្នកកាន់និកាយព្រះឥសូរ

-វៃស្នាវាស្រម សម្រាប់អ្នកកាន់និកាយព្រះវិស្ណុ

-សៅគតាស្រម សម្រាប់អ្នកកាន់សាសនាព្រះពុទ្ធ

[13] ដកស្រង់ចេញពីគេហទំព័រ ប្រវត្តិព្រះពុទ្ធសាសនានៅកម្ពុជា | (wordpress.com) នៅថ្ងៃទី៣០ មិថុនា ឆ្នាំ២០២១

តាមរយៈនេះឃើញថានៅសម័យនោះពុំមានការហាមឃាត់ មិនឱ្យគោរពព្រះពុទ្ធសាសនានោះទេ បើទោះបីព្រាហ្មណ៍សាសនា មានការរីកចម្រើនខ្លាំងក៏ដោយ។ ហើយព្រះមហាក្សត្រ ក៏មានការបើកចំហ ចំពោះប្រជាពលរដ្ឋឱ្យមានសិទ្ធិក្នុងការគោរពសាសនានោះដែរ។ តាមប្រវត្តិសាស្ត្ររបស់ខ្មែរយើង បានបង្ហាញទៀតថា នាសម័យអង្គរព្រះពុទ្ធសាសនាមហាយានបានចាប់ផ្ដើមរុងរឿងនៅក្នុងរាជ្យរបស់ក្សត្រមួយចំនួន។

**-រាជព្រះបាទសូរ្យវរ្ម័នទី១**

ព្រះបាទសូរ្យវរ្ម័នទី១ ជាបឋមក្សត្រខ្មែរទី១ នៃសម័យអង្គរ ដែលបានលើកតម្កើងព្រះពុទ្ធសាសនា ឱ្យថ្កុំថ្កើងរុងរឿង។ ទ្រង់គ្រងរាជសម្បត្តិនៅកំឡុងឆ្នាំ១០០២-១០៥០ ជាពុទ្ធសាសនិកដ៏ឆ្នើម ដែលបានគាំទ្រ និងលើកទឹកចិត្តដល់ប្រជាពលរដ្ឋ ដែលរាប់អានចំពោះព្រះពុទ្ធសាសនា លើសពីនេះទៀតពុទ្ធសាសនាថេរវាទត្រូវបានព្រះអង្គធ្វើការផ្សព្វផ្សាយ ឱ្យកាន់តែរុងរឿង ហើយបានតម្កើងសាសនានេះជាសាសនារបស់រដ្ឋ។ ទោះជាព្រះអង្គជាពុទ្ធសាសនិកក៏ដោយចុះ ព្រះអង្គក៏តែងមេត្តាដល់សាសនាព្រាហ្មណ៍ផងដែរ ដោយនៅសម័យនោះអ្នកកាន់ព្រះពុទ្ធសាសនា និងអ្នកកាន់សាសនាព្រាហ្មណ៍បានរស់នៅជាមួយគ្នាដោយសុខសាន្ត។ តាមសិលាចារិកបានបង្ហាញអំពីទឹកចិត្តរបស់ព្រះអង្គ គោរពស្រឡាញ់ចំពោះពុទ្ធសាសនាទាំងពីរនិកាយ គឺហិនយាន និងមហាយាន ដោយព្រះអង្គបានប្ដូរតួនាទីរបស់គ្រួសារព្រាហ្មណ៍សិវកៃវល្យ ដែលមាននាទីរៀបចំពិធីសម្រាប់ព្រះមហាក្សត្រតាមបវេណីព្រាហ្មណ៍នោះ ឱ្យទៅជាបុព្វជិតកំពូលរបស់ព្រះអង្គវិញ។ ភស្តុតាងមួយទៀតដែលបង្ហាញឱ្យកាន់តែច្បាស់ថាព្រះអង្គជាពុទ្ធសាសនិកនោះ គឺព្រះអង្គមានមរណៈនាមថា និវ៌ាណបទ។

**-រាជ្យព្រះបាទជ័យវរ្ម័នទី៧**

ព្រះមហាវីរក្សត្រដ៏ឆ្នើមបំផុតរបស់ខ្មែរនៅនាសម័យអង្គរ គឺព្រះបាទជ័យវរ្ម័នទី៧ ដែលព្រះអង្គជាស្ថាបនិកទី៣នៃទីក្រុងអង្គរ សំណង់ប្រាសាទជាច្រើនត្រូវបានសាងសង់នៅក្នុងរាជក្សត្រអង្គនេះ ដែលសំណង់ប្រាសាទទាំងនោះជាប្រភេទសំណង់បែបពុទ្ធសាសនា និងខ្លះទៀតបង្ហាញពីការបញ្ចូលគ្នាទាំងពុទ្ធលក្ខណៈ និងព្រាហ្មណ៍លក្ខណៈ។ ទ្រង់គ្រងរាជ្យសម្បត្តិក្នុងឆ្នាំ១១៨១-១២១៥ ដែលអ្នកប្រវត្តិវិទូបានចាត់ទុកថាជាសម័យកាលមួយដែលកម្ពុជារុងរឿងជាទីបំផុត ក្នុងប្រវត្តិសាស្ត្រខ្មែរ។ ក្រៅពីការរីកចម្រើនរុងរឿងក្នុងផ្នែកសង្គម នយោបាយ ហើយវិស័យសាសនាក៏រីកចម្រើនព្រមជាមួយនោះផងដែរ។ ព្រះអង្គបានលើកស្ទួយព្រះពុទ្ធសាសនាមហាយាន ឱ្យបានថ្កុំថ្កើង តែទោះជាយ៉ាងនេះក្ដី ព្រះអង្គក៏មិនដែលបំភ្លេចចោលព្រហ្មញ្ញសាសនានោះដែរ។ ព្រះអង្គបានបង្រួមសាសនាទាំងពីរចូលគ្នាតែមួយ ក្នុងបំណងដើម្បីលើកស្ទួយដល់ពុទ្ធសាសនាមហាយាន ដែលព្រះអង្គបានគោរពជាសាសនារបស់រដ្ឋ និងដើម្បីកុំឱ្យប្រជាពលរដ្ឋខ្មែរ ដែលនៅជាប់ជិតដាមជាមួយ ព្រហ្មញ្ញសាសនាមានការអាក់អន់ចិត្តផងដែរ។

ភាពវៃឆ្លាតនេះ បានធ្វើឱ្យមានការឯកភាពគ្នាក្នុងការរស់នៅរបស់ប្រជាពលរដ្ឋ ក្រោមការដឹកនាំរបស់ទ្រង់ និងធ្វើឱ្យមានស្ថេរភាពនយោបាយក្នុងស្រុកផងដែរ។ លទ្ធិទេវរាជត្រូវបានប្រែក្លាយទៅជាពុទ្ធិរាជវិញ មានភស្តុតាងដែលបង្ហាញថា ព្រះពុទ្ធសាសនាបែបមហាយាន មានការរីកចម្រើនខ្លាំងនៅក្នុងសម័យនេះ ដូចជាសំណង់ប្រាសាទបែបពុទ្ធសាសនាជាច្រើនពាសពេញផ្ទៃប្រទេសដូចជា ប្រាសាទតាព្រហ្ម ប្រាសាទព្រះខ័នជាដើម ដែលជាស្នាមព្រះហស្ថរបស់ព្រះអង្គ។ នៅសម័យឆ្នាំ១១៨០ ព្រះសង្ឃខ្មែរមួយរូប ជាបុត្ររបស់ព្រះបាទជ័យវរ្ម័នទី៧ ព្រះនាមតាមលិន្ទ បានទៅសិក្សាភាសាបាលី និងចំណេះដឹងផ្នែកព្រះពុទ្ធសាសនានៅកោះសេរីលង្កា ហើយបាននាំចូលចំណេះដឹងទាំងនេះមកវិញនៅកំឡុងឆ្នាំ១១៨០។ ព្រះអង្គទទួលមរណៈនាមថា មហាបរមសៅគត។ ដែលជាភស្តុតាងបញ្ជាក់កាន់តែច្បាស់ថាពុទ្ធសាសនាថេរវាទបានរីកចម្រើនរុងរឿងខ្លាំងនៅសម័យនោះ។ បេសកកម្មរបស់ពួកចិននៅសម័យនោះមកកាន់ក្រុងអង្គរ ដែលដឹកនាំដោយ Chou Ta-Laun នៅឆ្នាំ១២៩៦-១២៩៧ បានកត់សម្គាល់ឃើញមានព្រះសង្ឃពុទ្ធសាសនាថេរវាទនៅលើទឹកដីនេះ។[14]

❖ **ពុទ្ធសាសនានៅសម័យចុងអង្គរ**

គេបានដឹងមកហើយដែរថា ព្រះពុទ្ធសាសនាថេរវាទនេះ រីកចម្រើនតាំងពីរាជព្រះបាទជ័យវរ្ម័នទី៧មកម្ល៉េះ ដោយទ្រង់បានបញ្ជូនបុត្ររបស់ទ្រង់ ព្រះនាមតាមលិន្ទទៅបួសជាព្រះសង្ឃ និងសិក្សាចំណេះដឹងពីពុទ្ធសាសនាជាភាសាបាលីនៅកោះស្រីលង្ការ។ ព្រះអង្គម្ចាស់តាមលិន្ទ បានត្រឡប់មកកម្ពុជាវិញ ហើយបានផ្សព្វផ្សាយ អប់រំប្រជាពលរដ្ឋខ្មែរតាមជំនឿ និងបែបបទព្រះពុទ្ធសាសនាដែលទ្រង់បានរៀនសូត្រ។ ទ្រង់បានក្លាយទៅជាព្រះសង្ឃជាន់ខ្ពស់នៅសម័យនោះ ដោយការចេះដឹងរបស់ព្រះអង្គ។ សេចក្តីនេះហើយ ដែលនាំឱ្យអ្នកប្រាជ្ញពង្សាវតាយល់ច្រឡំថា ភិក្ខុតាមលិន្ទ នាំពុទ្ធសាសនាថេរវាទ ពីលង្កាវង្សចូលមកផ្សាយក្នុងប្រទេសកម្ពុជាមុនដំបូងបង្អស់ ក្នុងពង្សាវតាខ្មែរ។ តាមពិតពុទ្ធសាសនាថរវាទ បានចូលមកប្រទេសកម្ពុជាតាំងពីសម័យនគរភ្នំម្ល៉េះ។[15]

នៅក្នុងរាជព្រះបាទជ័យវរ្ម័នទី៨(១២៤៣-១២៩៥) ព្រះពុទ្ធសាសនាត្រូវបានបំផ្លិចបំផ្លាញ មានរូបចម្លាក់បែបពុទ្ធសាសនាត្រូវបានកោសលុប និងបំផ្លាញចោល ឬប្តូរទៅជារូបបែបព្រាហ្មណ៍វិញ។ គេឃើញមានការវាយកម្ទេចព្រះពុទ្ធរូបចោល។ សម័យនេះពួកព្រាហ្មណ៍ទាំងអស់ត្រូវបានសន្តោសឡើងវិញ និងផ្តល់សិទ្ធក្នុងការពង្រឹងសាសនានេះឡើងវិញផងដែរ។ តែទោះបីជាយ៉ាងណាក៏ដោយ ព្រះពុទ្ធសាសនាត្រូវបានប្រជាពលរដ្ឋខ្មែរនិយមកាន់តែច្រើនណាស់ទៅហើយ។ បើទោះបីជាមានប្រជាពលរដ្ឋខ្មែរ កាន់ព្រះពុទ្ធសាសនានេះ ច្រើនណាស់ទៅហើយយ៉ាងណាក្តី

[14] ដកស្រង់ចេញពីគេហទំព័រ ប្រវត្តិព្រះពុទ្ធសាសនានៅកម្ពុជា | (wordpress.com) នៅថ្ងៃទី២ កក្កដា ឆ្នាំ២០២១

[15] ឥន្ទ ឱមសាម៉េង កម្រងប្រវត្តិសាស្ត្រនៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ២០០៣, ទំព័រ១១៤

ក៏បដិវត្តសាសនាពីព្រាហ្មណ៍ ទៅព្រះពុទ្ធនោះមិនអាចធ្វើទៅរួចនោះដែរ។ ដូចនេះពុទ្ធសាសនា បានពួនសម្ងំនៅក្នុងស្រទាប់ប្រជាពលរដ្ឋខ្មែរ រហូតដល់រជ្ជកាលព្រះបាទត្រសក់ផ្អែម ទើបមានការលើកស្ទួយពុទ្ធសាសនាឱ្យរីកចម្រើនឡើងវិញ រហូតមកដល់សព្វថ្ងៃនេះ។[16]

### ១.២.២.ពុទ្ធសាសនាសម័យកណ្ដាល

ក្រោយសតវត្សទី១៣មក ព្រះពុទ្ធសាសនា ត្រូវបានលើកតម្កើងជាសាសនារបស់រដ្ឋ។ ព្រះមហាក្សត្រខ្មែរ និងប្រជាពលរដ្ឋគ្រប់មជ្ឈដ្ឋាន និយមព្រះពុទ្ធសាសនានេះខ្លាំងណាស់ និងមានជំនឿយ៉ាងមុតមាំ ដែលគេចាត់ទុកជាទីពឹងនឹករឭក បើទោះបីជាប្រជាពលរដ្ឋខ្មែរ មិនទាន់បោះបង់ចោលជំនឿលើព្រលឹង អារក្ខ អ្នកតាក៏ដោយ។ ប៉ុន្តែចំពោះព្រាហ្មណ៍សាសនា ពុំមានប្រជាពលរដ្ឋខ្មែរគោរពរាប់អានទៀតនោះឡើយ។ ទោះបីជាយ៉ាងនេះក្ដីក៏ទំនៀមទម្លាប់បែបព្រាហ្មណ៍ នៅតែជិតដាមក្នុងប្រពៃណី របស់ជនជាតិខ្មែររហូតដល់សព្វថ្ងៃ។ ឯក្នុងព្រះបរមរាជវាំងវិញគេនៅឃើញមានពួកព្រាហ្មណ៍បាគូនៅមានសេសសល់ ក្នុងភារកិច្ចជាអ្នករៀបចំពិធីផ្សេងៗ និងថែរក្សាទ្រព្យសម្បត្តិសម្រាប់រាជ្យ។ រហូតក្នុងកំឡុងសតវត្សទី ១៧ ១៨ ១៩ ប្រទេសសៀមបានមានឥទ្ធិពលយ៉ាងខ្លាំង មកលើនយោបាយក្នុងស្រុកខ្មែរ ដែលជាហេតុធ្វើឱ្យឥទ្ធិពលនៃប្រពៃណីសាសនា ក៏លាយឡំជាមួយគ្នានោះផងដែរ។ គួររំលឹកផងដែរថា ក្នុងកំឡុងនោះចំពោះការស្ដារឡើងវិញ នៃវិស័យព្រះពុទ្ធសាសនាក្នុងគ្រានោះ បណ្ដាលឱ្យមានការប្រសូត្រចេញនូវនិកាយថ្មីមួយ គឺគណៈធម្មយុត្តិកនិកាយទន្ទឹមនឹងនិកាយបែបប្រពៃណី គឺគណៈមហានិកាយ។ រីឯប្រវត្តិនៃការបដិសន្ធិនេះ ពាក់ព័ន្ធនឹងព្រឹត្តិការណ៍ដូចខាងក្រោមនេះ៖

ក្នុងគ.ស.១៨៤៩ ព្រះបាទអង្គឌួងកាលដែលបានគ្រងរាជ្យ នៅក្រុងឧត្តុងមានជ័យហើយ ទ្រង់បានសុំព្រះចៅក្រុងសៀមអនុញ្ញាតឱ្យព្រះភិក្ខុ និល ទៀង និមន្តត្រឡប់មកស្រុកខ្មែរវិញ ដើម្បីរៀបចំព្រះពុទ្ធសាសនាឡើងវិញ និងបានឡើងសមណៈសក្ដិជាបន្តបន្ទាប់គឺ នៅព្រះជន្ម៣០វស្សាបានឡើងឋានៈជាមហាវិមលធម្ម ដល់ព្រះជន្ម៣១វស្សាទទួលឋានៈជាមហាព្រហ្មមុនី លុះមកដល់ឆ្នាំ១៨៥៧ ទើបបានទទួលការតែងតាំងជាសម្ដេចព្រះសង្ឃរាជ គ្រប់គ្រងលើព្រះសង្ឃ និងវត្តអារាមនានានៅទូទាំងព្រះរាជនគរ។

ទន្ទឹងនឹងនោះក្នុងគ.ស.១៨៥៤ ព្រះបាទអង្គឌួងក៏ទ្រង់បានសុំព្រះចៅក្រុងសៀម អនុញ្ញាតឱ្យព្រះភិក្ខុមហាប៉ាន វិលត្រឡប់មកប្រទេសកម្ពុជាវិញផងដែរ ដើម្បីជួយរៀបចំព្រះពុទ្ធសាសនា នៅប្រទេសកម្ពុជាឡើងវិញ។ នៅក្នុងតួនាទី ព្រះភិក្ខុមហាប៉ាន បានឡើងឋានៈជាលំដាប់លំដោយ ពីព្រះអរិយវង្ស ទៅព្រះមហាវិមលធម្ម ហើយជាពិសេស

[16] ដកស្រង់ចេញពីគេហទំព័រ ប្រវត្តិព្រះពុទ្ធសាសនានៅកម្ពុជា | (wordpress.com) នៅថ្ងៃទី២ កក្កដា ឆ្នាំ២០២១

នៅក្នុងគ.ស.១៨៥៧ ព្រះបាទអង្គឌួងទ្រង់បានតែងតាំងលោក ជាសម្តេចព្រះសង្ឃនាយកគណៈធម្មយុត្តិកនិកាយ ដោយមាននាមថា សម្តេចព្រះសុគន្ធាធិបតី ប៉ាន ដំបូងគេបង្អស់នៅក្នុងប្រទេសកម្ពុជា ហើយប្រពៃណីនេះបានបន្ត ជាប់គ្រប់រាជការព្រះមហាក្សត្រខ្មែររហូតមក។[17]

គួបញ្ជាក់ផងដែរថា ក្នុងសម័យនោះចំនួនវត្តអារាមបានកើនឡើងជាលំដាប់។ ព្រះមហាថេរ ដែលមានតួនាទីមើលការខុសត្រូវលើការរៀបចំខាងសាសនា និងលើវត្តអារាមនៅក្នុងខេត្តនីមួយៗ លែងមានលទ្ធភាពបន្តការគ្រប់គ្រងនោះតទៅទៀតហើយ។ ដោយហេតុនោះ សម្តេចសង្ឃរាជ ដោយមានការព្រមព្រៀងជាមួយរាជាគណៈ ឋានានុក្រម និងសហការីទាំងអស់ ទ្រង់បានស្នើទៅព្រះរាជាសូមឱ្យមានការកែប្រែ ដែលមានបែងចែកដូចតទៅៈ

ព្រះមហាថេរមួយអង្គៗ ពីមុនឥឡូវត្រូវតែងតាំងជាមេគណទទួលខុសត្រូវ លើគណៈសង្ឃក្នុងខេត្តនីមួយៗ។ ចំណែកឯព្រះរាជាគណៈទាំង៤សម្រាប់ និងសម្តេចព្រះសង្ឃរាជជាអ្នកត្រួតពិនិត្យ និងសម្រេចកិច្ចការសាសនាទាំងពួងក្នុងព្រះរាជាណាចក្រកម្ពុជាទាំងមូល។ រាជាគណៈ ឬមន្ត្រីសង្ឃទាំង៤សម្រាប់ ត្រូវបែងចែកជាឯក ទោ ត្រី ចត្វា ដូចមន្ត្រីជាន់ខ្ពស់ខាងអាណាចក្រដែរ។

-សម្រាប់ឯកជារាជាគណៈរបស់ក្សត្រិយ៍ទ្រង់រាជ្យ

-សម្រាប់ទោជារាជាគណៈរបស់ក្សត្រិយ៍ឧភយោរាជ

-សម្រាប់ត្រីជារាជាគណៈរបស់សម្តេចព្រះមហាឧបរាជ

-សម្រាប់ចត្វាជារាជាគណៈរបស់សម្តេចព្រះវររាជជននី។[18]

ព្រះពុទ្ធសាសនាក៏ដើរតួយ៉ាងសំខាន់ផងដែរ ក្នុងវិស័យអក្សរសាស្ត្រ និងការតាក់តែងនិពន្ធ។ ហេតុនេះហើយទើបឃើញកើតមានជាអត្ថបទគម្ពីរ បិដក ជាតកច្រើនកើតឡើងហូរហែ។ មិនតែប៉ុណ្ណោះអត្ថបទបែបព្រះពុទ្ធសាសនាពោលគឺទស្សនៈពុទ្ធនិយម ត្រូវបានអ្នកនិពន្ធខ្មែរយកមកធ្វើជាវិធីសាស្ត្រ ក្នុងការតាក់តែងអត្ថបទរបស់ខ្លួនផងដែរ។ ព្រឹត្តិការណ៍ទាំងនេះ បានកើតឡើងនៅក្រោយពេលដែលទីក្រុងអង្គរ ត្រូវបានព្រះរាជាខ្មែរបោះបង់ចោល ហើយប្រទេសធ្លាក់ចូលទៅក្នុងកលិយុគចម្បាំងកើតមានញឹកញាប់។

ការលើកយកទស្សនៈបុណ្យបាប របស់ពុទ្ធសាសនាមកតាក់តែងជាស្នាដៃអក្សរសិល្ប៍នេះ ត្រូវបានអ្នកសិក្សាខ្លះវិភាគថាជាការលើកទឹកចិត្តដល់ប្រជាពលរដ្ឋខ្មែរ ជាការលួងលោម កុំឱ្យពួកគាត់ធ្លាក់ទឹកចិត្ត បាក់ទឹកចិត្ត ដោយចាត់ទុកហេតុការណ៍ ឬទុក្ខលំបាកវេទនា ដែលជួបប្រទះនេះជាកម្មពៀររបស់ខ្លួន ដែលបានសាងមកពីអតីតជាតិ។

[17] មជ្ឈមណ្ឌលសម្រាប់ការសិក្សាស្រាវជ្រាវជាន់ខ្ពស់ ពិធីបំបួសនាគនៅប្រទេសកម្ពុជា អតីតកាល និងបច្ចុប្បន្ន ឆ្នាំ២០០៥, ទំព័រ១៦-១៨

[18] ត្រឹង ងា ប្រវត្តិសាស្ត្រខ្មែរភាគ២ ឆ្នាំ១៩៧៣, ទំព័រ១៩២

ព្រះសង្ឃក្នុងពុទ្ធសាសនា បានដើរតួនាទីយ៉ាងសំខាន់ក្នុងការថែរក្សា អក្សរសិល្ប៍ អក្សរសាស្ត្រជាតិ និងប្រពៃណីទំនៀមទម្លាប់របស់ខ្មែរឱ្យនៅគង់វង្ស។ ចំពោះវិស័យសង្គមកិច្ចវិញ ព្រះសង្ឃជាគ្រូពេទ្យ ជាអ្នកកាត់ក្តី ជាអ្នកមើលការខុសត្រូវដល់ប្រជាពលរដ្ឋខ្មែរផងដែរ។ ទីធ្លាវត្តអារាម បានក្លាយទៅជាទីសម្រាប់ជនទុរគតសម្រាក និងព្យាបាលជំងឺ ការសន្តោសរបស់ព្រះសង្ឃក្នុងពុទ្ធសាសនា ការចូលរួមចំណែកច្រើនក្នុងវិស័យសង្គមជាតិនោះ បានធ្វើឱ្យវិស័យព្រះពុទ្ធសាសនាកាន់តែទទួលបានការរាប់អានពីប្រជាពលរដ្ឋខ្មែរ។[19]

តែនៅក្នុងសម័យអាណានិគមបារាំង ក៏មិនខុសពីសម័យកណ្តាលប៉ុន្មានដែរ ព្រះពុទ្ធសាសនាបានដើរតួនាទីយ៉ាងសំខាន់នៅក្នុងសង្គមខ្មែរ ទាំងវិស័យសង្គមកិច្ច សុខាភិបាល អប់រំ យុត្តិធម៌ និងជាឃ្លាំងអភិរក្សអក្សរសាស្ត្រជាតិខ្មែរ ព្រមទាំងវប្បធម៌ប្រពៃណីរបស់ខ្មែរយើងផងដែរ។ ក្រោមការជិះជាន់របស់បារាំងមកលើប្រជាពលរដ្ឋខ្មែរ និងពុទ្ធសាសនា បានធ្វើឱ្យព្រះសង្ឃខ្មែរងើបឡើងតស៊ូបះបោរប្រឆាំងជាមួយបារាំង ប៉ុន្តែត្រូវបរាជ័យយ៉ាងធ្ងន់ធ្ងរហួតដល់មានការចាប់ខ្លួនធ្វើទោសទណ្ឌទៀតផង។ តែទោះបីជាយ៉ាងណាក៏ដោយ ក៏ពុទ្ធសាសនានៅតែពង្រឹងខ្លួនជានិច្ចពុំមានការចុះញ៉មជាមួយពួកបារាំងនោះឡើយ ដែលនៅឆ្នាំ១៩១៤ គេឃើញមានការសាងសង់សាលាភាសាបាលីជាន់ខ្ពស់មួយនៅភ្នំពេញ និងក្រោយមកកែប្រែទៅជាមហាវិទ្យាល័យ។ ការសិក្សាអប់រំចំពោះព្រះសង្ឃ មិនត្រឹមតែចំណេះដឹងខាងភាសាបាលីប៉ុណ្ណោះទេ ក៏ប៉ុន្តែ មូលដ្ឋានគ្រឹះនៃចំណេះដឹងទូទៅតាមបែបទំនើប ក៏ត្រូវយកមកសិក្សារៀនសូត្រនៅឯសាលារៀនផងដែរ។ សាលាបាលីជាន់ទាប ត្រូវបានបង្កើតឡើងនៅក្នុងឆ្នាំ ១៩៣៣ ដើម្បីផ្តល់លទ្ធភាពឱ្យព្រះសង្ឃ ដែលទើបបួសថ្មីអាចសិក្សាពីភាសាបាលីនេះពីកម្រិតដំបូងបាន។[20]

**១.២.៣.ពុទ្ធសាសនាសម័យខ្មែរក្រហម ( ឆ្នាំ១៩៧៥-១៩៧៩ )**

ក្រោយការរីលូតលាស់មួយរយៈកន្លងមក ព្រះពុទ្ធសាសនាក៏ជួបប្រទះនឹងវិបត្តិ ចាប់តាំងពីប្រទេសកម្ពុជាធ្លាក់ចូលទៅក្នុងភ្លើងសង្គ្រាមនៅឆ្នាំ១៩៧០ ហើយបន្តមកដល់ឆ្នាំ១៩៧៥។ ប៉ុន្តែ រឹតតែធ្ងន់ធ្ងរទៅទៀត នៅពេលដែលប្រទេសស្ថិតនៅក្នុងរបបខ្មែរក្រហម គឺជាសម័យអន្តរកប្ប ចន្លោះឆ្នាំ ១៩៧៥-១៩៧៩ ប៉ុល ពត បានរំលាយខ្ទើនព្រះពុទ្ធសាសនា ទាំងវត្តអារាម ទាំងព្រះសង្ឃ ទាំងឧបាសក ឧបាសិកា ទាយកទាយិកាចោលទាំងអស់។ មិនត្រឹមតែប៉ុណ្ណោះទេ ថែមទាំងបានបំផ្លាញគម្ពីរដីកាព្រះពុទ្ធសាសនាមួយចំនួនធំទៀត។[21] ក្នុងនោះជំនឿសាសនាត្រូវបានបំបិទចោលទាំងស្រុង រចនាសម្ព័ន្ធគណៈសង្ឃពុទ្ធសាសនា ត្រូវបានបំផ្លិចបំផ្លាញឱ្យដល់ឬសគល់ ហាមឃាត់មិនឱ្យ

[19] ដកស្រង់ចេញពីគេហទំព័រ http://pisrumsok.blogspot.com/2012/09/blog-post_21.html នៅថ្ងៃទី២ កក្កដា ឆ្នាំ២០២១

[20] ដកស្រង់ចេញពីគេហទំព័រ ប្រវត្តិព្រះពុទ្ធសាសនានៅកម្ពុជា। (wordpress.com) នៅថ្ងៃទី២ កក្កដា ឆ្នាំ២០២១

[21] ដកស្រង់ចេញពីគេហទំព័រ http://pisrumsok.blogspot.com/2012/09/blog-post_21.html នៅថ្ងៃទី២ កក្កដា ឆ្នាំ២០២១

ប្រជាពលរដ្ឋ ប្រើប្រាស់សិទ្ធិសេរីភាពក្នុងការធ្វើអ្វីៗតាមច្បាប់ទេ ដោយក្នុងនោះប្រជាពលរដ្ឋបានលាក់ជំនឿកប់យ៉ាងជ្រៅក្នុងក្រអៅបេះដូង។

កំឡុងពេលដែលខ្មែរក្រហមបានដណ្តើម កាន់កាប់ទីក្រុងភ្នំពេញជាស្ថាពរ វិស័យសាសនាបានធ្លាក់ចុះដល់កម្រិតសូន្យ។ ជាគោលការណ៍ ការប្រតិបត្តិសាសនាត្រូវបានហាមឃាត់ ទោះជាព្រះពុទ្ធសាសនាក្តី ឥស្លាម ឬគ្រឹស្តសាសនាក្តី ឬក៏ការប្រតិបត្តិជំនឿបែបណាក៏ដោយ។ ដោយឡែក វត្តអារាមត្រូវបានបំផ្លិចបំផ្លាញយ៉ាងធ្ងន់ធ្ងរ វត្តត្រូវបានរុះរើ យកដែកទៅធ្វើសំណង់ដូចជាទំនប់ទឹកជាដើម វត្តខ្លះត្រូវបានកែប្រែពីទីសក្ការបូជា ទៅជាឃ្លាំងអំបិល ឃ្លាំងស្រូវអង្ករ ឃ្លាំងគ្រាប់រំសេវ ឬកន្លែងចិញ្ចឹមសត្វ មន្ទីរពេទ្យ ឬក៏ធ្វើជាមន្ទីរឃុំឃាំង។ ឯព្រះសង្ឃវិញក៏ត្រូវរងនូវការធ្វើទុក្ខបុកម្នេញផងដែរ ពីព្រោះព្រះសង្ឃត្រូវផ្សឹក ឬក៏ត្រូវធ្វើគតអស់ជាច្រើនអង្គ។ ដូច្នោះជារួម អ្វីៗទាំងអស់ ដែលពាក់ព័ន្ធនឹងព្រះពុទ្ធសាសនា ត្រូវរលត់រលាយទាំងស្រុងក្នុងគ្រានោះដែរ។[22]

### ១.២.៤.ពុទ្ធសាសនាសម័យក្រោយឆ្នាំ ១៩៧៩

នៅថ្ងៃសៅរ៍ ៣កើត ខែមិគសិរ ឆ្នាំមមែ ព.ស.២៥២២ ត្រូវនឹងថ្ងៃទី២ ខែធ្នូ គ.ស.១៩៧៨ ប្រជាជនបានបង្កើតរណសិរ្សមួយ ឈ្មោះរណសិរ្សសង្គ្រោះជាតិកម្ពុជា ដែលមានគោលការណ៍១១.ខ។ នៅថ្ងៃអាទិត្យ ១០ កើត ខែបុស្ស ឆ្នាំមមែ ព.ស.២៥២២ ត្រូវនឹងថ្ងៃទី៧ ខែមករា ឆ្នាំ១៩៧៩ រំដោះប្រជាជនឱ្យរួចផុតពី របបបនប្រល័យពូជសាសន៍ ប៉ុល ពត បានដូចបំណង។ នៅពេលនោះឯងហើយប្រជាជនកម្ពុជា អាចមានជំនឿលើព្រះពុទ្ធសាសនាឡើងវិញបានជាបណ្តើរៗ។ ដោយគ្រាន់តែបានដឹងថា រដ្ឋអំណាចបន្ធូរឱ្យប្រជាជនមានជំនឿ លើព្រះពុទ្ធសាសនាបានភ្លាមប្រជាជនដែលធ្លាប់ជាពុទ្ធបរិស័ទពីជំនាន់មុន ងើបច្រូងច្រាងនាំគ្នាធ្វើបុណ្យ។ តែនៅពេលនោះមិនទាន់មានព្រះសង្ឃនៅឡើយ នាំគ្នាអញ្ជើញលោកតាៗ ដែលចេះព្រះពុទ្ធសាសនា ឱ្យធ្វើជាព្រះសង្ឃ ហើយនាំគ្នាវេរបច្ច័យ៤ ឧទ្ទិសកុសលជូនវិញ្ញាណក្ខន្ធបុព្វបរស ដូចជាព្រះពុទ្ធគង់ធរមានដូចនោះដែរ។

នៅពេលនោះឯង ព្រះសង្ឃអង្គខ្លះដែលព្រះអង្គស្លៀកស្បង់គ្រងចីវរ អស់រយៈពេលជាង៣ឆ្នាំកន្លងមកហើយនេះ ព្រះអង្គប្រកាសខ្លួនថានៅសម័យ ប៉ុល ពត ព្រះអង្គមិនដែលឃ្លាតចាកពីភេទបព្វជិតឡើយ ព្រះអង្គស្លៀកស្បង់គ្រងចីវរជាធម្មតាវិញ។ ក៏មានការយល់ថា ការស្លៀកខោពាក់អាវដោយការបង្ខំពីសត្រូវ សីលធ្លុសរបស់ព្រះអង្គមិនដាច់ឡើយ ពីព្រោះព្រះអង្គបានរក្សាសីលធ្លុសរបស់ព្រះអង្គបានដូចធម្មតា។ ការយល់ឃើញដូចនេះ លោកយកស្បង់ចីវរមកស្លៀកដណ្តាប់ ហើយប្រកាសខ្លួនថាជាអ្នកបួសពិតប្រាកដ។

[22] មជ្ឈមណ្ឌលសម្រាប់ការសិក្សាស្រាវជ្រាវជាន់ខ្ពស់ ពិធីបំបួសនាគនៅប្រទេសកម្ពុជា អតីតកាល និងបច្ចុប្បន្ន ឆ្នាំ២០០៥, ទំព័រ២១

ដោយមានការបួសគ្មានសណ្តាប់ធ្នាប់បែបនេះ ទើបទីស្តីការគណៈកម្មាធិការ មជ្ឈិមរណសិរ្សសង្គ្រោះជាតិកម្ពុជាបានចាត់ចែង និមន្តព្រះសង្ឃពីប្រទេសវៀតណាមចំនួន៩អង្គ មកបំបួសលោកអាចារ្យដែលជាអតីតបុព្វជិតហើយដែលមិនមានប្រពន្ធកូន ធ្វើជាពូជព្រះសង្ឃដើម្បីបំបួសកុលបុត្របន្តទៅទៀត។ តាមព្រះសពសម្តេចមង្គលទេព្វាចារ្យ អ៊ុម ស៊ុម បានឱ្យដឹងថា ព្រះសង្ឃ ៩ អង្គដែលរដ្ឋាភិបាលវៀតណាម បានចាត់តាំងឱ្យមកបំបួសនោះលោកអាចារ្យ តុង ធ្វើជាឧបជ្ឈាយ៍ និមន្តមកដល់ក្រុងភ្នំពេញព្រះអង្គសុគត។ សូមបញ្ជាក់ថា ព្រះអង្គព្រះនាម តុងនេះពីមុនពេលសម័យ ប៉ុល ពត ឆ្នាំ១៩៧៥ ព្រះអង្គគង់នៅវត្តមហាមន្ត្រី ក្រុងភ្នំពេញ។ ឯព្រះសង្ឃមួយអង្គទៀត ព្រះនាម ថាច់ មិញ ជាព្រះសង្ឃមហាយាន ព្រះអង្គជាអ្នកសង្កេតការណ៍ ព្រះអង្គមិនបានចូលរួមជាការកសង្ឃទេ។

ដូច្នេះ ព្រះសង្ឃជាការកសង្ឃរៀបចំការបំបួសនោះមានចំនួន៧អង្គ៖

១.ព្រះភិក្ខុ យីវ ងីម ជាព្រះឧបជ្ឈាយ៍

២.ព្រះភិក្ខុ ថាច់ ធៀងតុង ជាគ្រូសូត្រស្តាំ

៣.ព្រះភិក្ខុ ធីវ វីត ជាគ្រូសូត្រឆ្វេង

ឯព្រះភិក្ខុ៤រូបទៀត សម្តេចមិនបានស្គាល់។ ការរៀបចំបំបួសចំពោះអតីតបុព្វជិត ៧ រូប នៅថ្ងៃពុត ១៣រោចខែភទ្របទ ឆ្នាំមមែ ព.ស.២៥២៣ ត្រូវនឹងថ្ងៃទី ១៩ ខែកញ្ញា គ.ស.១៩៧៩។ បានអនុញ្ញាត និងនិមន្តព្រះសង្ឃពីកម្ពុជាក្រោមដើម្បីបំបួស កុលបុត្រខ្មែរជាដំបូងចំនួន៧អង្គមានដូចខាងក្រោម៖

| | |
|---|---|
| ១.ភិក្ខុ កើត វ៉ាយ | មកពី ខេត្តកំពង់ធំ |
| ២.ភិក្ខុ ប្រាក់ ឌិត | មកពី ខេត្តតាកែវ |
| ៣.ភិក្ខុ ឌិន សារុន | មកពី ខេត្តកណ្តាល |
| ៤.ភិក្ខុ អ៊ិត ស៊ុម | មកពី ខេត្តតាកែវ |
| ៥.ភិក្ខុ នន្ទ ង៉ែត | មកពី ខេត្តតាកែវ |
| ៦.ភិក្ខុ កែន វង្ស | មកពី ខេត្តព្រៃវែង |
| ៧.ភិក្ខុ ទេព វង្ស | មកពី ខេត្តសៀមរាប |

ចាប់ពីពេលបានបំបួសព្រះសង្ឃនេះរួចមក ព្រះឧបជ្ឈាយ៍ព្រះនាម បិតស្រីលោ ដែលបានបំបួសភិក្ខុទាំង៧អង្គនេះ បានសម្រេចប្រគល់ភារកិច្ចឱ្យភិក្ខុ កើត វ៉ាយ ធ្វើជាព្រះឧបជ្ឈាយ៍បំបួសភិក្ខុ សាមណេរបន្តទៅទៀត។ ដោយមានមូលហេតុនេះហើយទើបភិក្ខុ កើត វ៉ាយ និមន្តមកបំបួសបានត្រឹមតែមួយលើកប៉ុណ្ណោះ ព្រះអង្គបានប្រគល់នាទីព្រះឧបជ្ឈាយ៍ទៅឱ្យភិក្ខុ ទេព វង្ស បំបួសភិក្ខុ សាមណេរបន្តពីព្រះអង្គទៅទៀត។ បន្ទាប់ពីការបំបួសបានព្រះសង្ឃ៧

អង្គរួចមក គណៈកម្មាធិការមជ្ឈិមរណសិរ្ស និងក្រុមប្រឹក្សាប្រជាជនបដិវត្តន៍កម្ពុជា មានចំណាប់អារម្មណ៍លើះ

-ព្រះពុទ្ធសាសនាបានកើតហើយ តែការរៀបចំព្រះពុទ្ធសាសនា នៅមិនទាន់មានរបៀបរៀបរយល្អនៅឡើយ។ ដូចនេះគួរតែរៀបចំព្រះសង្ឃឱ្យមានឯកភាព គឺគ្មានគណៈនិកាយឡើយ។

-គួររៀបចំពុទ្ធសាសនាឱ្យមានព្រះសង្ឃមជ្ឈិម និងក្រសួងធម្មការដើម្បីសម្រាប់ជួយ សម្រួលកិច្ចការខាងព្រះពុទ្ធសាសនា។

-អ្នកមានសទ្ធាចូលបួសក្នុងព្រះពុទ្ធសាសនាកាន់តែមានច្រើនឡើង។ ឯព្រះសង្ឃមជ្ឈិមអាចចេញទៅបំបួសតាមខេត្តនានា មិនទាន់ពេលតាមសំណោមពរ របស់ពុទ្ធបរិស័ទបានឡើយ។

ដូចនេះ គណៈកម្មការមជ្ឈិមរណសិរ្ស និងក្រុមប្រឹក្សាប្រជាជនបដិវត្តន៍កម្ពុជា បានឯកភាពជាមួយព្រះសង្ឃមជ្ឈិមរណសិរ្សបង្កើតឱ្យមានព្រះឧបជ្ឈាយ៍ និងការកសង្ឃនៅគ្រប់ខេត្ត ក្នុងប្រទេសកម្ពុជាទាំងមូល។

ឯការបំបួសនោះទៀតសោត ត្រូវគោរពតាមសារាចរស្តីពីរបៀបបំបួសកុលបុត្រ ក្នុងព្រះពុទ្ធសាសនាលេខៈ ២៤-៨១ស.រ ចុះថ្ងៃទី៥ ខែមិថុនា គ.ស.១៩៨១/ ព.ស.២៥២៤។ សារាចរបានរៀបរាប់ថា ព្រះពុទ្ធសាសនាបានដុះជាប់ជានិស្ស័យចិត្តគំនិតរបស់ប្រជាជនកម្ពុជា ជាច្រើនពាន់ឆ្នាំមកហើយ ថែមទាំងបានផ្សាភ្ជាប់នឹងទំនៀមទម្លាប់ខ្មែរទៀតផង ព្រោះហេតុនោះទើបប្រជាជនកម្ពុជា៩៩ភាគរយគោរពរាប់អាន។[23]បន្ទាប់ពីការចេញសារាចរ និងសេចក្តីសម្រេចផ្សេងៗ មានជាបន្តបន្ទាប់ស្តីពីការបំបួស ការបួស និងការរៀបចំវត្តអារាម ឃើញថាការបំបួសក្តី ការបួសក្តី ការរៀបចំវត្តអារាមក្តី ចេះតែមានការប្រព្រឹត្តទៅ តាមលំដាប់លំដោយរហូតដល់មានវត្តអារាម និងព្រះសង្ឃច្រើនពាសពេញប្រទេសខ្មែរ។ តែរចនាសម្ព័ន្ធគ្រប់គ្រងព្រះសង្ឃ និងវត្តអារាមមិនទាន់មាននៅឡើយ។ ដូចនេះ ក្រុមប្រឹក្សាជាតិរណសិរ្ស សាមគ្គី កសាង ការពារមាតុភូមិកម្ពុជា បានចេញសេចក្តីណែនាំលេខ០៧/៩០ គជរស ស្តីពីការរៀបចំរចនាសម្ព័ន្ធពុទ្ធសាសនា តាំងពីមជ្ឈិមរហូតដល់មូលដ្ឋាន។

ជាខាងក្រោយមកទៀត គណៈសង្ឃនាយកបានរៀបចំឱ្យមានមេគណសម្រាប់ខេត្ត-ក្រុង និងសហការី៥អង្គទៀតជាជំនួយការ នៅតាមស្រុក-ខណ្ឌ មានអនុគណ១អង្គ និងសហការី៤អង្គទៀតជាជំនួយការ នៅតាមវត្តឱ្យមានព្រះចៅអធិការ១អង្គ និងគ្រូសូត្រស្តាំ ឆ្វេងជាជំនួយការ ដោយអនុវត្តតាមសេចក្តីសម្រេចលេខ ៥៥/៩១ កជរស ចុះថ្ងៃទី៨ ខែវិច្ឆិកា ឆ្នាំ១៩៩០។ មន្ត្រីសង្ឃថ្នាក់មេគណ អនុគណ ថ្នាក់ចៅអធិការនេះ ហៅថាមន្ត្រីសង្ឃថ្នាក់មូលដ្ឋាន។ ពុទ្ធសាសនា ដែលបានរស់ឡើងវិញនៅឆ្នាំ១៩៧៩នោះ ក៏ត្រូវបានឱ្យរៀបចំរចនាសម្ព័ន្ធសម្រាប់ដឹកនាំ និងគ្រប់គ្រង

[23] ដកស្រង់ចេញពីគេហទំព័រ http://pisrumsok.blogspot.com/2012/09/blog-post_21.html នៅថ្ងៃទី៥ កក្កដា ឆ្នាំ២០២១

មួយឱ្យបានល្អប្រសើរ និងគួរឱ្យកត់សម្គាល់។ បើយើងពិនិត្យមើលទៅឃើញថាពីឆ្នាំ១៩៧៩ មកដល់ដើមឆ្នាំ១៩៩០ រចនាសម្ព័ន្ធគ្រប់គ្រងគណៈសង្ឃខ្មែរមានឋានានុក្រម ប្រធានសង្ឃថ្នាក់មជ្ឈិម ប្រធានសង្ឃខេត្ត-ក្រុង ប្រធានសង្ឃស្រុក-ខណ្ឌ ប្រធានសង្ឃវត្ត ការកសង្ឃ និងព្រះឧបជ្ឈាយ៍សង្ឃ។ លុះដល់ចុងឆ្នាំ១៩៩០ តមកទើបមានគណៈនាយក ថេរសភា មេគណខេត្ត-ក្រុង អនុគណស្រុក-ខណ្ឌ និងចៅអធិការព្រមទាំងមានសេចក្តីសម្រេចឱ្យបង្កើតពុទ្ធិកសិក្សាសម្រាប់បណ្តុះបណ្តាលព្រះសង្ឃផងទៀត។ ឆ្នាំ១៩៩១មានការតែងតាំងសម្តេចព្រះសង្ឃរាជ ឆ្នាំ១៩៩៥ ទើបបង្កើតឱ្យមានទីរាជាគណៈគ្រប់ទាំង៤ថ្នាក់ នឹងឋានានុក្រមសង្ឃជាបន្តបន្ទាប់។ ការវិវត្តនៃស្ថាប័នរបស់ព្រះសង្ឃ និងរចនាសម្ព័ន្ធគ្រប់គ្រង តាំងពីអតីតកាលមកដល់សម័យបច្ចុប្បន្ននេះ គឺការវិវត្តបានយ៉ាងលឿន និងធ្វើឱ្យមានការរីកចម្រើនជាលំដាប់។

បច្ចុប្បន្ននេះ ព្រះពុទ្ធសាសនាបានដើរតួនាទីយ៉ាងសំខាន់ ក្នុងការដឹកនាំប្រទេស ពុទ្ធសាសនាបានក្លាយជាអ្នកអប់រំដល់ពលរដ្ឋទូទៅ ពុទ្ធសាសនាក៏បានជួយសង្គមខ្មែរក្នុងវិស័យផ្សេងៗ ផងដែរ។ ព្រះសង្ឃមានរាប់ពាន់អង្គនៅទូទាំងប្រទេស ដែលទន្ទឹមនឹងនោះ វត្តអារាមក៏ត្រូវបានកសាងឡើង ជាបន្តបន្ទាប់ពាសពេញប្រទេសផងដែរ។

នៅឆ្នាំ១៩៩១ ក្រោយពីធ្វើមាតុភូមិនិវត្តន៍ចូលកម្ពុជាវិញ ព្រះបាទនរោត្តម សីហនុ បានរៀបចំឡើងវិញនូវរចនាសម្ព័ន្ធដឹកនាំពុទ្ធសាសនា ដោយមានទាំងគណៈធម្មយុត្តិកនិកាយ។[24] ទន្ទឹមនឹងការចាត់ទុកព្រះពុទ្ធសាសនាជាសាសនារបស់រដ្ឋ ស្របតាមរដ្ឋធម្មនុញ្ញរបស់កម្ពុជានៅឆ្នាំ១៩៩៣ ការប្រកាន់សាសនាជំនឿដទៃទៀត ក៏ត្រូវបានការគាំទ្រពីរាជរដ្ឋាភិបាល ហើយមានការតែងតាំងព្រះមហាសុមេធាធិបតី ទេព វង្ស ព្រះសង្ឃនាយក ជាសម្តេចព្រះសង្ឃរាជគណៈមហានិកាយ ព្រះពោធិវង្ស នន្ទ ង៉ែត ជាសម្តេចព្រះពោធិវង្សនៅឆ្នាំ១៩៩២ និងព្រះមហាថេរមួយចំនួនទៀតជាសម្តេច។ ដោយឡែកសម្តេច បួរ គ្រី ក៏ត្រូវបានតែងតាំងជាព្រះសុគន្ធាធិបតី ជាសម្តេចព្រះសង្ឃរាជគណៈធម្មយុត្តិកនិកាយ។ ចាប់ពីពេលនោះមក ផ្តើមមានគណៈធម្មយុត្តិកនិកាយជាលើកទី២។

ដល់ឆ្នាំ១៩៩៥ ព្រះមហាសុមេធាធិបតី ទេព វង្ស សម្តេចព្រះសង្ឃរាជគណៈមហានិកាយ បានរៀបចំព្រះសង្ឃគណៈមហានិកាយឱ្យមានរាជាគណៈ ថ្នាក់ឯក ថ្នាក់ទោ ថ្នាក់ត្រី ថ្នាក់ចត្វា ហើយស្នើសូមសម្តេចព្រះបាទ នរោត្តម សីហនុ ព្រះមហាក្សត្រនៃព្រះរាជាណាចក្រកម្ពុជា តាមរបៀបពីអតីតកាលដូចក្នុងទសវត្សរ៍ទី៥០-៦០ និងពាក់កណ្តាលទី៧០ ហើយបានស្នើតែងតាំងព្រះមហាថេរ ដែរមានគុណសម្បត្តិចំពោះជាតិ សាសនា ព្រះមហាក្សត្រជាបន្តបន្ទាប់។ ដោយឡែកនៅឆ្នាំ១៩៩៦ សម្តេចព្រះសង្ឃរាជគណៈធម្មយុត្តិកនិកាយ បានស្នើទៅព្រះមហាក្សត្រដើម្បីរៀបចំ

[24] ដកស្រង់ចេញពីគេហទំព័រ [វត្តភិរម្យរាជ ភិរម្យសុខ (pisrumsok.blogspot.com)](pisrumsok.blogspot.com) នៅថ្ងៃទី៧ កក្កដា ឆ្នាំ២០២១

រចនាសម្ព័ន្ធគណៈធម្មយុត្តិកនិកាយឡើងវិញ បន្ទាប់ពីបានទទួលព្រះបរមរាជានុញ្ញាត ក៏ព្រះអង្គបានរៀបចំទីរាជាគណៈដូចសម័យដើមផងដែរ។

### ១.២.៥. ការគ្រប់គ្រងរដ្ឋបាលសង្ឃ និងដំណើរការវិវត្តតាំងពីសម័យបុរាណ

នៅប្រទេសកម្ពុជាកង់ពុទ្ធចក្រ និងកង់អាណាចក្រ គឺកង់ទាំងពីរនេះជាកង់ដ៏សំខាន់ ហើយត្រូវដើរទន្ទឹមគ្នាជានិច្ច មិនអាចមួយណាដើរហួសមួយណាទេ ហេតុនេះហើយទើបបានជាប្រទេសនេះ ធ្វើការអភិវឌ្ឍទាំងវិស័យសេដ្ឋកិច្ច និងវប្បធម៌ បានល្អប្រសើរគួរឱ្យកត់សម្គាល់ ដោយអាស្រ័យកង់ទាំងនេះត្រូវវិលស្មើគ្នាជាដរាប។ ទន្ទឹងនឹងការអភិវឌ្ឍរីកចម្រើននេះ ប្រព័ន្ធគ្រប់គ្រងរដ្ឋបាលត្រូវបានរៀបចំឡើងទាំងផ្នែកអាណាចក្រ និងពុទ្ធចក្រឱ្យសមស្របតាមលក្ខណៈជាប្រព័ន្ធមួយ ក្នុងនោះការគ្រប់គ្រងគណៈសង្ឃនៃព្រះរាជាណាចក្រកម្ពុជា តាំងពីអតីតកាល គឺមានការវិវតន៍តាមកាលៈទេសៈ។

នៅក្នុងរជ្ជកាលព្រេងនាយ ដែលវត្តជាទីលំនៅរបស់ព្រះសង្ឃមានចំនួនតិច ដូច្នោះការគ្រប់គ្រងគណៈសង្ឃនៅតាមខេត្តនីមួយៗ ត្រូវស្ថិតនៅក្រោមបន្ទុករបស់មហាថេរមួយអង្គ មានឋានៈជាព្រះឧបជ្ឈាយ៍។ ព្រះឧបជ្ឈាយ៍ទាំងអស់ ត្រូវស្ថិតនៅក្រោមអំណាចគ្រប់គ្រងរបស់ព្រះសង្ឃនាយក ឬព្រះសង្ឃរាជដែលគង់នៅក្នុងព្រះរាជធានី។ ព្រះអង្គមានព្រះថេរៈ ទីរាជាគណៈថ្នាក់ ឯក ទោ ត្រី ចត្វា ជាសហការី នៅក្នុងការសម្រេចសង្ឃកិច្ចគ្រប់យ៉ាងនៅក្នុងព្រះរាជាណាចក្រ។[25] ក្រោយមកទៀត ក្នុងអំឡុងសតវត្សរ៍ទី១៧ និង១៨ វត្តអារាមកាន់តែកើនច្រើនឡើងទៅតាមចំនួនគ្រហស្ថពុទ្ធសាសនិកដែលកើនឡើងកាន់តែច្រើនក្នុងភូមិ-ឃុំ-ស្រុក-ខេត្តនោះៗ សម្តេចព្រះសង្ឃរាជ បានប្រជុំពិភាក្សាគ្នាជាមួយនឹងមន្ត្រីសង្ឃដែលមានស្រាប់ និងមន្ត្រីក្រសួងធម្មការ ព្រមព្រៀងគ្នាជាឯកច្ឆន្ទធ្វើសំណូមពរថ្វាយព្រះមហាក្សត្រ ដើម្បីសូមព្រះរាជានុញ្ញាត រៀបចំរចនាសម្ព័ន្ធផ្នែកខាងពុទ្ធចក្រឱ្យសមស្របនឹងអាណាចក្រ។

ព្រះមហាក្សត្រក៏ទ្រង់សព្វព្រះរាជហឫទ័យ ព្រះរាជានុញ្ញាតតាមសំណូមពរ។ សម្តេចព្រះសង្ឃរាជ និងក្រសួងធម្មការមួយអន្លើដោយព្រះមហាថេរដទៃទៀត ក៏ប្រជុំរៀបចំរចនាសម្ព័ន្ធផ្នែកពុទ្ធចក្រជា ៤ថ្នាក់គឺៈ ថ្នាក់ទី១ គណៈសង្ឃវត្ត ថ្នាក់ទី២ គណសង្ឃស្រុក ថ្នាក់ទី៣ គណៈសង្ឃខេត្ត ថ្នាក់ទី៤ គណៈសង្ឃនាយក ដើម្បីសម្រួលដល់ការដឹកនាំ និងគ្រប់គ្រងវិស័យពុទ្ធសាសនាឱ្យកាន់តែមានប្រសិទ្ធភាព និងរីកចម្រើនជាលំដាប់។ ការវិវត្តន៍រីកចម្រើននៃស្ថាប័នសង្ឃកាន់តែជឿនលឿនទៅមុខ សមស្របតាមសម័យកាលសង្គម ក្នុងនោះយើងក៏ឃើញមានស្ថាប័នថេរសភា ដែលជាស្ថាប័នដ៏សំខាន់ក្នុងវិស័យពុទ្ធសាសនា។ ស្ថាប័ននេះមានតួនាទីយ៉ាងសំខាន់ក្នុងការវិនិច្ឆ័យសេចក្តីនៃដំណាក់កាល

[25] មជ្ឈមណ្ឌលសម្រាប់ការសិក្សាស្រាវជ្រាវជាន់ខ្ពស់ ពិធីបំបួសនាគនៅប្រទេសកម្ពុជា អតីតកាល និងបច្ចុប្បន្ន ឆ្នាំ២០០៥, ទំព័រ២៦

ចុងក្រោយបំផុត ដែលមន្ត្រីសង្ឃថ្នាក់ក្រោម គឺថ្នាក់មូលដ្ឋានដោះស្រាយមិនបានសម្រេច។ ស្ថាប័នថេរសភានេះកើតឡើងក្នុងសម័យ នៃការដឹកនាំរបស់សម្តេចព្រះសង្ឃរាជថ្នាក់ទី១ ជួន ណាត។

ការគ្រប់គ្រងគណៈសង្ឃក៏ត្រូវផ្លាស់ប្តូរ ដោយសម្របទៅតាមដំណើរការគ្រប់គ្រងប្រទេសខាងអាណាចក្រដែលចាត់របៀបរបបគ្រប់គ្រងតាមខេត្ត ស្រុក តំបន់ ឱ្យមានជាចៅហ្វាយខេត្ត ចៅហ្វាយស្រុក និងមេតំបន់។ ដូច្នោះនៅក្នុងខេត្តនីមួយៗ ត្រូវមានមេគណមួយអង្គ ក្នុងស្រុកនីមួយៗត្រូវមានអនុគណមួយអង្គ ហើយតំបន់ខ្លះក៏មានអនុគណមួយអង្គដែរ។ គណៈសង្ឃសម្រាប់ សាលាគណមាន៥អង្គ គឺមេគណមួយអង្គ បាឡាត់គណមួយអង្គ វិន័យធរគណមួយអង្គ សមុហ៍គណមួយអង្គ និងលេខាធិការអនុគណមួយអង្គ។ ចំណែកសាលាអនុគណវិញមាន៤អង្គ គឺអនុគណមួយអង្គ វិន័យធរអនុគណមួយអង្គ សមុហ៍អនុគណមួយអង្គ និងអនុលេខាធិការអនុគណមួយអង្គ។

ការតែងតាំងសមណសក្តិទីមេគណ មុនដំបូងគឺត្រូវព្រះសង្ឃនាយក ឬព្រះសង្ឃរាជតែងតាំងជាឋានានុក្រមទីព្រះគ្រូដោយរដ្ឋមន្ត្រីក្រសួងធម្មការ បានចុះហត្ថលេខាបោះត្រាពីខាងឆ្វេងលើសន្លឹកសញ្ញាប័ត្រផង។ លុះក្រោយបន្តិចមក ព្រះមហាក្សត្រទ្រង់ព្រះមេត្តាប្រោសប្រទានព្រះរាជក្រឹត្យ តាំងឱ្យឡើងជាព្រះរាជាគណៈទីមេគុណដដែលតាមសេចក្តីក្រាបបង្គំទូលសូម នៃរដ្ឋមន្ត្រីក្រសួងធម្មការ។ អនុគណមានសមណសក្តិ ជាឋានានុក្រមទីព្រះគ្រូ។ ចំណែកឯសមណសក្តិ ទីបាឡាត់ វិន័យធរ សមុហ៍ លេខាធិការ និងអនុលេខាធិការក៏សុទ្ធតែមាន សមណសក្តិទីឋានានុក្រមដែរ។ មន្ត្រីសង្ឃថ្នាក់លើ និងចៅអធិការ គ្រូសូត្រស្តាំ ឆ្វេងគ្រប់វត្តទាំងអស់ ក្នុងព្រះរាជាណាចក្រកម្ពុជា លើកលែងតែសមណស័ក្តិទីរាជាគណៈចេញ សុទ្ធតែត្រូវបានព្រះសង្ឃនាយក ឬព្រះសង្ឃរាជតែងតាំង ហើយរដ្ឋមន្ត្រីក្រសួងធម្មការចុះហត្ថលេខាបោះត្រា ខាងឆ្វេងពីលើសន្លឹកសញ្ញាប័ត្រផង។[26]

រាជាគណៈ(រាជា+គណៈ ពួកឬក្រុមរបស់ស្តេច) លោកទ្រទូង ពាក្យហៅសមណសក្តិ ទ្រទូង សម្រាប់បព្វជិតក្នុងកម្ពុជរដ្ឋ។ បើប្រៀបធៀបនឹងឋានន្តរសក្តិរបស់មន្ត្រីផ្នែកខាងអាណាចក្រ ត្រូវគ្នានឹងបណ្តាសក្តិទី ឧកញ៉ាជួនកាលឡើងដល់ទីសម្តេចក៏មាន ប៉ុន្តែរាជាគណៈនាកាលសម័យនោះមានភារកិច្ច តួនាទីច្បាស់លាស់ និងមានអំណាចគ្រប់គ្រងតាមបណ្តា ខេត្ត ក្រុង ដែលសម្តេចព្រះសង្ឃរាជ ឬព្រះសង្ឃនាយកប្រគល់ឱ្យ។ រាជាគណៈមាន៤សម្រាប់គឺ សម្រាប់ ឯក ទោ ត្រី ចត្វា។ សម្រាប់ឯក ជារាជាគណៈរបស់ក្សត្រទ្រង់រាជ សម្រាប់ទោ ជារបស់ក្សត្រឧបយោរាជ សម្រាប់ត្រី របស់សម្តេចមហាឧបរាជ សម្រាប់ចត្វា របស់សម្តេចព្រះមហាវររាជនី។ ពាក្យថាទ្រទូង មានន័យថា ជាសមណសក្តិទីរាជាគណៈ ដែលព្រះមហាក្សត្រទ្រង់ប្រោសព្រះរាជាទាន ទាំងតាមលំដាប់ថ្នាក់មាន៤ជាន់

[26] មជ្ឈមណ្ឌលសម្រាប់ការសិក្សាស្រាវជ្រាវជាន់ខ្ពស់ ពិធីបំបួសនាគនៅប្រទេសកម្ពុជា អតីតកាល និងបច្ចុប្បន្ន ឆ្នាំ២០០៥ ទំព័រ២៧

គឺសម្រាប់ ឯក ទោ ត្រី ចត្វា ហើយបើរាប់ពីក្រោមុនថា ចត្វា ត្រី ទោ ឯក ក៏បាន។ កាលពីក្នុងបូរាណកាលសម័យយូមកហើយ ទ្រទូង សម្រាន់ឯក ហៅថាទ្រទូងរត្ន័ តែសម័យសព្វថ្ងៃហៅថា រាជាគណៈដូចគ្នាទាំងបួនសម្រាប់។[27]

ចំពោះសមណសក្តិ សក្តិសម្រាប់សមណៈ គឺឋានន្តរសក្តិសម្រាប់បព្វជិត។ តាមបវេណីក្នុងកម្ពុជរដ្ឋ មានសមណស័ក្តិទីស្តេចសង្ឃ ទីសង្ឃនាយក ទីរាជាគណៈ ទីឋានានុក្រម ទីមហា; ចែកជា ៤ សម្រាប់គឺ ឯក ទោ ត្រី ចត្វា។ សមណស័ក្តិទីរាជាគណៈ (ក្នុងតំណែង) មាន៣២ ក្នុងនោះមាន៖ **សម្រាប់ឯកមាន ១១គឺ៖**

១-ព្រះសុគន្ធ (ទីអគ្គមហាសេនា), ប៉ុន្តែចួនកាលព្រះករុណាជាម្ចាស់ជីវិត ទ្រង់តាំងជាស្តេចសង្ឃទីសម្តេចព្រះសង្ឃរាជ ឬទីដូចជាឧបរាជរងបន្ទាប់ពី សម្តេចព្រះមហាសង្ឃរាជមកហៅថា សម្តេចព្រះសុគន្ធាធិបតី។

២-ព្រះមង្គលទេពាចារ្យ (ទីយោមរាជ)

៣-ព្រះពោធិវង្ស (ទីវាំងវរវៀងជ័យ)

៤-ព្រះធម្មលិខិត (ទីក្រឡាហោម)

៥-ព្រះវនរ័ត (ទីចក្រី)

-ទីឱភាសមន្ត្រី (រឿនហ្លួង) មាន ២ គឺ ៖

៦-ព្រះមហាព្រហ្មមុនី (ទីមហាមន្ត្រី)

៧-ព្រះមហាវិមលធម្ម (ទីមហាទេព)

-ទីឃ្លាំងធម៌មាន ៤ គឺ

៨-ព្រះពុទ្ធឃោសាចារ្យ

៩-ព្រះធម្មឃោសាចារ្យ

១០-ព្រះឃោសធម្ម

១១-ព្រះធម្មឧត្តម។

-រាជគណៈសម្រាប់ឯក ឬថ្នាក់ឯកទាំងនេះ ត្រូវប្រើផ្លិតសមណស័ក្តិព័ណ៌ក្រហម ។

**រាជាគណៈសម្រាប់ទោមាន ៧ គឺ៖**

១-ព្រះសិរីសម្មតិវង្ស (ទីសម្តេចចៅពញា)

២-ព្រះពុទ្ធវង្ស (ទីវង្សាអគ្គរាជ)

[27] សម្តេចសង្ឃរាជ ជួន ណាត វចនានុក្រមខ្មែរ ពុទ្ធសាសនាបណ្ឌិត្យ ភ្នំពេញ ព.ស.២៥១១ គ.ស.១៩៦៧, ទំព័រ៤៦២

៣-ព្រះសាក្យវង្ស (ទីស្រីធម្មាធិរាជ)

៤-ព្រះធម្មកវីវង្ស (ទីវិបុលរាជ)

៥-ព្រះអរិយវង្ស (ទីរាជតេជៈ)

-ទីឱភាសមន្ត្រីមាន ២ គឺ

៦-ព្រះអរិយកស្សប (ទីអធិរាជវង្សា);

៧-ព្រះឧបាលិវង្ស (ទីអធិករវង្សា)

ទាំង ៧ រូបនេះ ត្រូវប្រើផ្លិតសមណស័ក្តិពណ៌បៃតង ។

**រាជាគណៈសម្រាប់ត្រីមាន ៧ គឺៈ**

១-ព្រះញាណរង្សី (ទីជេដ្ឋាមន្ត្រី)

២-ព្រះញាណវីរិយៈ (ទី... ឯករាជ)

៣-ព្រះធម្មប្បញ្ញាញាណ (ទី...បទេសរាជ)

៤-ព្រះសិរីវិសុទ្ធិញ្ញាណ (ទីស្រីទិព្វវង់)

៥-ព្រះញាណកោសល (ទីនរិន្ទនាយក)

-ទីឱភាសមន្ត្រីមាន២ គឺ

៦-ព្រះទេពមុនី (ទីវិសេសមន្ត្រី)

៧-ព្រះទេពសត្ថា (ទីមន្ត្រីនាយក); ទាំង ៧ រូបនេះ ត្រូវប្រើផ្លិតសមណស័ក្តិព័ណ៌ស្វាយ។

**រាជាគណៈសម្រាប់ចត្វាមាន ៧គឺៈ**

១-ព្រះធម្មវិបស្សនា (ទីអធិបតីសេនា)

២-ព្រះធម្មវីរិយៈ (ទីវង្សានុរក្ស)

៣-ព្រះធម្មវិសុទ្ធិ (ទីវង្សាភិមន្ត)

៤-ព្រះសមាធិធម្ម (ទីបវររាជ)

៥-ព្រះធម្មនិរោធរង្សី (ទីវង្សាធិបេស)

-ទីឱភាសមន្ត្រីមាន ២ គឺ

៦-ព្រះញាណសំវរ (ទីមហាធិរាជ

៧-ព្រះវិន័យសំវរ (ទីទេពនាយក) ទាំង ៧ រូបនេះត្រូវប្រើផ្លិតសមណស័ក្តិពណ៌ខៀវ។

នៅក្នុងការគ្រប់គ្រងគណៈសង្ឃ ក្នុងសម័យនោះមានឋានានុក្រមពីសម្តេចព្រះសង្ឃរាជ ឬព្រះសង្ឃនាយក ជាអ្នកដឹកនាំគ្រប់គ្រងពុទ្ធសាសនា បន្ទាប់ពីឋានានុក្រមនេះ យើងឃើញមានព្រះរាជាគណៈហៅថា (ទ្រទូង) ដែលព្រះសង្ឃរាជ ឬព្រះសង្ឃនាយកចាត់ឱ្យទៅត្រួតត្រាកាន់កាប់ និងគ្រប់គ្រងសង្ឃតាមបណ្តា ខេត្ត-ក្រុងនានា ដោយបែងចែកចំនួនរាជាគណៈសម្រាប់ដឹកនាំតាមទំហំការងាររបស់ខេត្ត-ក្រុងនោះៗ។ ក្រៅពីរាជាគណៈ យើងឃើញមានព្រះឧបជ្ឈាយ៍មានតួនាទីសំខាន់ក្នុងការជួយរៀបចំ និងដឹកនាំសង្ឃផងដែរ។[28]

សមណសក្តិទាំង៤ថ្នាក់ ដូចខាងលើនេះ ជារបៀបក្នុងសម័យមុន ។ លុះដល់មកគ.ស.១៩៤៣ មានការកែប្រែបន្ថែមបន្ថយខ្លះ ហើយតក្រោយមកដល់ គ.ស.១៩៤៨ បានរៀបចំកែប្រែម្តងទៀត(ព្រះរាជក្រមលេខ១២ នស. ចុះថ្ងៃទី៩-២-៤៣ លេខ ៦៨ នស. ចុះថ្ងៃទី១៨-៩-៤៣ និងលេខ១ រវ. ចុះថ្ងៃទី ២៦-៥-៤៨) មានរបៀបដូចតទៅនេះគឺ សមណសក្តិទីរាជាគណៈក្នុងតំណែងខាងគណៈមហានិកាយ និងធម្មយុត្តិកនិកាយចាប់ពីគ.ស.១៩៤៨ តមកគឺ៖ ដោយហេតុថា នៅប្រទេសកម្ពុជាយើងមាននិកាយពីរ នៅក្នុងព្រះពុទ្ធសាសនា ដូច្នោះហើយទើបបានជាមាន ប្រមុខគ្រប់គ្រងមន្ត្រីសង្ឃតាមនិកាយនីមួយៗដែរ។ ព្រះសង្ឃនាយកខាងគណៈមហានិកាយមានឋានន្តរជាសម្តេចព្រះមហាសុមេធាធិបតី សង្ឃនាយកគណៈមហានិកាយ ហើយព្រះសង្ឃនាយកខាងគណៈធម្មយុត្តិកនិកាយមានឋានន្តរជា សម្តេចព្រះសុធម្មាធិបតី សង្ឃនាយកគណៈធម្មយុត្តិកនិកាយ។ ព្រះសង្ឃនាយកទាំងពីរអង្គនេះ៖ មាននាទីគ្រប់គ្រង ត្រួតត្រាសង្ឃកិច្ចដោយខ្លួនពីគ្នា ប៉ុន្តែកាលបើមានការចេញនូវព្រះសង្ឃប្រកាស ឬព្រះសង្ឃបញ្ញត្តិជាសាធារណៈ មិនចំពោះគណៈនិកាយណាទេ គឺត្រូវរួបរួមជាមួយគ្នា។

| **ថ្នាក់ឯក** | |
|---|---|
| **ផ្នែកមហានិកាយថ្នាក់ឯក មាន៣គឺ** | **ផ្នែកគណៈធម្មយុត្តិកនិកាយថ្នាក់ឯកមាន២គឺ** |
| ១-ព្រះធម្មលិខិត | ១-ព្រះមង្គលទេពាចារ្យ |
| ២-ព្រះពោធិវង្ស | ២-ព្រះពុទ្ធាចារ្យ |
| ៣-ព្រះវនរ័ត | |
| **ថ្នាក់ទោ** | |
| **ផ្នែកមហានិកាយថ្នាក់ទោ មាន៦គឺ** | **ផ្នែកគណៈធម្មយុត្តិកនិកាយថ្នាក់ទោ មាន៣គឺ** |
| ១-ព្រះមហាវិមលធម្ម | ១-ព្រះមហាព្រហ្មមុនី |

[28] អំពីព្រះរាជប្រពៃណីព្រះមហាក្សត្រ និងសម្តេចព្រះសង្ឃរាជ ការផ្សាយរបស់ព្រះបរមរាជវាំង, ឆ្នាំ២០០៣

| | |
|---|---|
| ២-ព្រះពុទ្ធឃោសាចារ្យ | ២-ព្រះធម្មឧត្តម |
| ៣-ព្រះធម្មឃោសាចារ្យ | ៣-ព្រះអរិយកស្សប |
| ៤-ព្រះឃោសធម្ម | |
| ៥-ព្រះសាសនមុនី | |
| ៦-ព្រះមុនីកោសល | |
| **ថ្នាក់ត្រី** | |
| **ផ្នែកមហានិកាយមានត្រី មាន៦គឺ** | **ផ្នែកគណៈធម្មយុត្តិកនិកាយត្រី មាន៤គឺ** |
| ១-ព្រះសិរីសម្មតិវង្ស | ១-ព្រះអរិយវង្ស |
| ២-ព្រះពុទ្ធវង្ស | ២-ព្រះធម្មកវីវង្ស |
| ៣-ព្រះសាក្យវង្ស | ៣-ព្រះញាណវង្សី |
| ៤-ព្រះឧបាលិវង្ស | ៤-ព្រះមហាវីរវង្សាចារ្យ |
| ៥-ព្រះញាណវង្ស | |
| ៦-ព្រះសុមេធវង្ស | |
| **ថ្នាក់ចត្វា** | |
| **ផ្នែកមហានិកាយថ្នាក់ចត្វា មាន២០គឺ** | **ផ្នែកគណៈធម្មយុត្តិកនិកាយថ្នាក់ចត្វា មាន១២គឺ** |
| ១-ព្រះធម្មវិបស្សនា | ១-ព្រះបទុមវង្សា |
| ២-ព្រះសមាធិធម្ម | ២-ព្រះធម្មមុនី |
| ៣-ព្រះញាណកោសល | ៣-ព្រះវជិរមេធា |
| ៤-ព្រះសិរីសង្គាមមុនី | ៤-ព្រះអរិយមុនី |
| ៥-ព្រះសិរីវីសុទ្ធិ | ៥-ព្រះទេពមោលី |
| ៦-ព្រះធម្មវង្សា | ៦-ព្រះធម្មត្ថេរ |
| ៧-ព្រះញាណសំវរ | ៧-ព្រះអមរាភិរក្ខិត |
| ៨-ព្រះវិន័យសំវរ | ៨-ព្រះមហារាជធម្ម |
| ៩-ព្រះឥន្ទមុនី | ៩-ព្រះរតនមុនី |

| | |
|---|---|
| ១០-ព្រះទេពមុនី<br>១១-ព្រះវិន័យមុនី | ១០-ព្រះធម្មត្រ័យលោកាចារ្យ<br>១១-ព្រះធម្មវរោត្តម |
| ១២-ព្រះទេពសត្ថា | ១២-ព្រះញាណវិរិយៈ |
| ១៣-ព្រះសីលសំវរ | |
| ១៤-ព្រះគម្ពីរត្ថេរ | |
| ១៥-ព្រះអរិយមគ្គញ្ញាណ | |
| ១៦-ព្រះវិភទ្ធញ្ញាណ | |
| ១៧-ព្រះបវរសត្ថា | |
| ១៨-ព្រះញាណវិសុទ្ធិវង្ស | |
| ១៩-ព្រះធម្មវិសុទ្ធិវង្ស | |
| ២០-ព្រះបិដកធម្ម | |

រួមសមណសក្តិព្រះរាជាគណៈក្នុងតំណែងទាំង ៤ ថ្នាក់នោះ គឺខាងគណៈមហានិកាយ៣៥, ចំណែកខាងគណៈធម្មយុត្តិកនិកាយ មាន ២១ ត្រូវជា ៥៦ ។ ព្រះសង្ឃនាយក ឬសម្តេចព្រះសង្ឃរាជ ទាំងពីរព្រះអង្គនិងព្រះរាជាគណៈក្នុងតំណែងទាំង៥៦អង្គនេះ សុទ្ធតែព្រះមហាក្សត្រិយ៍ ទ្រង់ប្រោសព្រះរាជទានតែងតាំងដោយព្រះរាជក្រឹត្យ។

**អនុសំវច្ឆរមហាសន្និបាតសង្ឃប្រចាំឆ្នាំ**

ដើម្បីប្រតិបត្តិការ ជាជំនួសការឡើងគណក្នុងសម័យព្រេងនាយនោះ ក្នុងសម័យបច្ចុប្បន្ននេះ មានការប្រជុំមន្ត្រីសង្ឃក្នុងព្រះរាជធានី និងខេត្តក្រៅ ក្នុង១ឆ្នាំមានម្តង។[29]

ដើម្បីជាការជំរុញការងារអភិវឌ្ឍ ក្នុងវិស័យព្រះពុទ្ធសាសនានៅកម្ពុជា ឱ្យបានរីកចំរើនប្រកបដោយនិរន្តរភាព។ គណៈសង្ឃពុទ្ធសាសនា បានបង្កើតឱ្យមាន អនុសំវច្ឆរៈមហាសន្និបាតមន្ត្រីសង្ឃទូទាំងប្រទេសប្រចាំឆ្នាំ ដើម្បីពិនិត្យទៅលើសកម្មភាព និងលទ្ធផលរបស់មន្ត្រីសង្ឃគ្រប់ឋានានុក្រមដែលបានអនុវត្តក្នុងឆ្នាំកន្លងមក និងលើកទិសដៅអនុវត្តទៅក្នុងឆ្នាំខាងមុខទៀត។ ជាងនេះទៀត គឺដើម្បីពិភាក្សាផ្លាស់ប្តូរយោបល់ រវាងមន្ត្រីសង្ឃថ្នាក់កណ្តាល និងមូលដ្ឋាន ព្រមទាំងមន្ត្រីធម្មការ និងសាសនា ដើម្បីរកឱ្យឃើញនូវចំណុចខ្លាំង ចំណុចខ្សោយ ចំណុចរីកចម្រើន និង

[29] ជួន ណាត របៀបការគ្រប់គ្រងគណៈសង្ឃ (ទស្សនាវដ្តី ពន្លឺពុទ្ធចក្រលេខ១) ឆ្នាំ១៩៦១, ទំព័រ៣៨

ចំណុចអន់ថយ ហើយសុំយោបល់ និងផ្តល់អនុសាសន៍ក្នុងមហាសន្និបាតដើម្បីស្ថាបនា សំដៅដើម្បីទទួលបាននូវលទ្ធផលផ្លែផ្កា សម្រាប់ការអភិវឌ្ឍន៍វិស័យពុទ្ធសាសនា។ មហាសន្និបាតនេះ ជាទូទៅត្រូវបានធ្វើឡើងនៅរាជធានីភ្នំពេញ ក្រោមព្រះរាជាធិបតីភាពដ៏ខ្ពង់ខ្ពស់របស់ព្រះមហាក្សត្រ ឬថ្នាក់ដឹកនាំនៃស្ថាប័នកំពូលផ្សេងៗ ដោយមានការចូលរួមពីមន្ត្រីសង្ឃ ថ្នាក់កណ្តាល និងថ្នាក់មូលដ្ឋាន មានរយៈពេល៣ថ្ងៃ។ ចំពោះមន្ត្រីសង្ឃមូលដ្ឋានថ្នាក់មេគណបន្ទាប់ពីបានទទួលនូវសង្ឃប្រកាសអនុសំវច្ឆរៈមហាសន្និបាតមន្ត្រីសង្ឃ ទូទាំងប្រទេសរួចហើយ ត្រូវធ្វើការកោះប្រជុំអនុគណគ្រប់ស្រុក-ខណ្ឌក្នុងខេត្តរបស់ខ្លួនមកផ្សព្វផ្សាយសង្ឃប្រកាស ដោយប្រារព្ធធ្វើអនុសំវច្ឆរៈខេត្តប្រចាំឆ្នាំ។ អនុគណស្រុក-ខ័ណ្ឌ បន្ទាប់ពីបានចូលរួមអនុវច្ឆរខេត្តប្រចាំឆ្នាំរួចហើយ ត្រូវបើកកិច្ចប្រជុំមួយប្រចាំឆ្នាំក្នុងស្រុក-ខ័ណ្ឌរបស់ខ្លួន ដោយមានការនិមន្ត និងអញ្ជើញព្រះគ្រូចៅអធិការ មន្ត្រីសង្ឃវត្តគ្រប់អង្គ និងអាចារ្យគណៈកម្មការគ្រប់វត្តក្នុងស្រុក-ខណ្ឌមកដើម្បីផ្សព្វផ្សាយសង្ឃប្រកាស អនុសំវច្ឆរមហាសន្និបាតមន្ត្រីសង្ឃទូទាំងប្រទេស ដើម្បីអនុវត្តន៍តាមខ្លឹមសារឱ្យមានប្រសិទ្ធភាពខ្ពស់។

**អនុសំវច្ឆរមហាសន្និបាតមន្ត្រីសង្ឃទូទាំងប្រទេសលើកទី២៨**

រាជធានីភ្នំពេញ៖ អនុសំវច្ឆរមហាសន្និបាតមន្ត្រីសង្ឃទូទាំងប្រទេសលើកទី២៨ ដែលមានរយៈពេលពីរថ្ងៃ គឺថ្ងៃទី១៦-១៧ ខែធ្នូ ឆ្នាំ២០១៩ នៅសាលសន្និសីទចតុម្មុខ រាជធានីភ្នំពេញ ត្រូវបានបិទបញ្ចប់ ក្រោមអធិបតីភាពដ៏ឧត្តុងឧត្តមរបស់សម្តេចព្រះមហាសុមេធាធិបតី កិត្តិឧទ្ទេសបណ្ឌិត នន្ទ ង៉ែត ជាសម្តេចព្រះសង្ឃនាយកនៃគណៈមហានិកាយនៃព្រះរាជាណាចក្រកម្ពុជា សម្តេចព្រះមង្គលទេព្វាចារ្យ វង្ស អានេតា សម្តេចព្រះសង្ឃនាយករងគណៈធម្មយុត្តិកនិកាយ នៃព្រះរាជាណាចក្រកម្ពុជា ឯកឧត្តម កិត្តិនីតិកោសលបណ្ឌិត ប៊ិន ឈិន ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី តំណាងប្រមុខរាជរដ្ឋាភិបាលកម្ពុជា ឯកឧត្តម ហ៊ឹម ឆែម រដ្ឋមន្ត្រីក្រសួងធម្មការ និងសាសនា និងការនិមន្ត/អញ្ជើញចូលរួមរបស់មន្ត្រីសង្ឃជាន់ខ្ពស់ មន្ត្រីនៃក្រសួងធម្មការនិងសាសនា និងមន្ត្រីពាក់ព័ន្ធ មកពីគ្រប់រាជធានីខេត្តទូទាំងប្រទេសកម្ពុជា ប្រមាណ ១000អង្គ/នាក់។

អង្គអនុសំវច្ឆរមហាសន្និបាតមន្ត្រីសង្ឃ ឬអាចហៅបានថាជាជំនួបកំពូលមន្ត្រីសង្ឃព្រះពុទ្ធសាសនា ទូទាំងប្រទេសប្រចាំឆ្នាំលើកទី២៨ រយៈពេលពីរថ្ងៃនេះ បានពិភាក្សាផ្លាស់ប្តូរយោបល់ អំពីការអនុវត្តសង្ឃប្រកាសលើកទី២៧កន្លងទៅ និងលើកទិសដៅប្រចាំឆ្នាំ សម្រាប់ការអនុវត្តបន្តក្នុងឆ្នាំខាងមុខ។ សង្ឃប្រកាសដែលមានពីរទំព័រដែលជាសេចក្តីសម្រេចជាឯកច្ឆ័ន្ទ របស់មន្ត្រីសង្ឃទូទាំងប្រទេស បានប្រកាសបន្តគាំទ្រគោលនយោបាយអភិវឌ្ឍន៍ជាតិ របស់រាជរដ្ឋាភិបាលកម្ពុជា។ **គណៈសង្ឃមហានិកាយ បានចេញសង្ឃប្រកាសខ្លឹមសារ៥ ចំណុចមានជាអាទិ៍៖**

(១) ការបង្កើនការរឹតបន្តឹង ការគោរពប្រតិបត្តិធម៌វិន័យ របស់ព្រះសង្ឃគ្រប់ព្រះអង្គ

(២) ការយកចិត្តទុកដាក់និងពង្រឹងវិស័យវិបស្សនាធុរៈ ឱ្យមានចលនា និងសកម្មភាពខ្លាំងក្លា

(៣) ការបន្តកំណែទម្រង់វិស័យ ពុទ្ធិកសិក្សាបន្ថែមទៀតគ្រប់កម្រិត និងការប្រកាសបើកថ្នាក់បណ្ឌិតចាប់ពីឆ្នាំ ២០២០តទៅ

(៤) ការចុះអប់រំសីលធម៌ព្រះពុទ្ធសាសនា ដល់សិស្សានុសិស្សតាមសាលារៀន និងការបំបួសកុលបុត្រ កុលធីតាខ្មែរវគ្គខ្លី ១-២ សប្តាហ៍

(៥) ការបន្តរួមសាមគ្គីគ្នាដើម្បីរួមចំណែក ក្នុងកិច្ចការមនុស្សធម៌ តាមរយៈអង្គការមនុស្សធម៌ផ្សេងៗមាន កាកបាទក្រហមកម្ពុជាជាដើម ។

ចំពោះសង្ឃប្រកាសរបស់គណៈសង្ឃធម្មយុត្តិកនិកាយវិញ ពុំមានអ្វីសំខាន់គួរឱ្យកត់សម្គាល់ទេ។

**សង្ឃប្រកាសបានចេញនូវសេចក្តីសម្រេច ៣ ចំណុចមានជាអាទិ៍**

(១) អនុវត្តន៍តាមប្រកាសរបស់ក្រសួងធម្មការ និងសាសនា ស្តីពីការរៀបចំជ្រើសរើស និងការប្រព្រឹត្តទៅរបស់ អាចារ្យគណៈកម្មការវត្ត

(២) ការបើកវគ្គអប់រំដល់សង្ឃាធិការគ្រប់ព្រះឋានានុក្រម

(៣) ការអប់រំព្រះសង្ឃភិក្ខុសាមណេរទាំងអស់ ឱ្យស្ថិតនៅក្នុងសីល សមាធិ បញ្ញា ។

មានមតិរិះគន់ខ្លះត្រូវបានលើកឡើង ទាក់ទងនឹងកង្វះយន្តការអនុវត្តន៍ជាក់ស្តែង របស់សង្ឃប្រកាសប្រចាំឆ្នាំ នេះ ជាពិសេសត្រង់ចំណុចទាក់ទងនឹងការពង្រឹងគុណភាពពុទ្ធិកសិក្សាជាតិ។ ក្រោយអានសង្ឃប្រកាសហើយ សមណនិស្សិតថ្នាក់បណ្ឌិតមួយព្រះអង្គ សូមមិនបញ្ចេញព្រះនាមមានថេរដីកាចំណាប់អារម្មណ៍ មកកាន់សារ ព័ត៌មានលោកវិទូថា «រឿងសំខាន់សម្រាប់អនុវត្តគឺយន្តការ និងផែនការយុទ្ធសាស្ត្ររយៈពេលវែងខ្លី និងសួរថាតើ នរណាជាអ្នកធ្វើ និងអ្នកតាមដាន...» ។ ដូច្នេះសង្ឃប្រកាសហាក់ដូចជាមានន័យ ស្មើនឹងសេចក្តីអំពាវនាវច្រើនជាង រីឯការអនុវត្តត្រូវធ្វើតាមសទ្ធា ។

ព្រះអង្គដដែលបានបន្ថែមថា «វាជាកាតព្វកិច្ចបែបប្រពៃណីរបស់សង្ឃប្រកាសត្រូវតែចេញ ទោះអនុវត្តមាន ប្រសិទ្ធភាព ឬអត់អាស្រ័យលើលទ្ធផលចុងឆ្នាំ និងស្ថានភាពនយោបាយរបស់ស្រុកទេសផង»។ តែទោះយ៉ាងណា ការបើកឱ្យមានកម្រិតសិក្សាថ្នាក់បណ្ឌិត គឺជាប្រវត្តិសាស្ត្រនៃការអភិវឌ្ឍរបស់ពុទ្ធិកសិក្សាជាតិ ដែលជាចំណុច សំខាន់នៃសង្ឃប្រកាសឆ្នាំនេះ ។ ដូច្នេះ ព្រះអង្គសូមអបអរសាទរសង្ឃប្រកាសនេះ។[30]

---

[30] ដកស្រង់ចេញពីគេហទំព័រ អនុសំវច្ឆរមហាសន្និបាតមន្ត្រីសង្ឃទូទាំងប្រទេសលើកទី២៨៖ ខ្លឹមសារនៃសង្ឃប្រកាស - Lokavidu News (lokavidunewsonline.blogspot.com) នៅថ្ងៃទី១៥ កក្កដា ឆ្នាំ២០២១

## ១.៣.រចនាសម្ព័ន្ធគណៈសង្ឃខ្មែរ

### ១.៣.១.គណៈសង្ឃគ្រប់បណ្ដាថ្នាក់

- **គណៈសង្ឃនាយក**

ព្រះមហាសង្ឃរាជ ឬព្រះសង្ឃនាយក (មានសហការីផ្ទាល់អមចំនួន ៨រូប គឺព្រះគ្រូសង្ឃសត្ថា ព្រះគ្រូសង្ឃសុមេធ ព្រះបាឡាត់សង្ឃវង្ស ព្រះបាឡាត់សង្ឃវ័ក្ខ ព្រះវិន័យធរ ព្រះសមុហ៍សុមេធាចារ្យ ព្រះសមុបណ្ណាវ័ក្ខ)

-ព្រះសង្ឃនាយករងទី១

-ព្រះសង្ឃនាយករងទី២

-ព្រះសង្ឃនាយករងទី៣

- **ព្រះរាជាគណៈមាន៤ថ្នាក់**

-ថ្នាក់ឯក ផ្នែកគណៈមហានិកាយមាន៣ ផ្នែកធម្មយុត្តិកនិកាយមាន២

-ថ្នាក់ទោ ផ្នែកគណៈមហានិកាយមាន៦ ផ្នែកធម្មយុត្តិកនិកាយមាន៣

-ថ្នាក់ត្រី ផ្នែកគណៈមហានិកាយមាន៦ ផ្នែកធម្មយុត្តិកនិកាយមាន៤

-ថ្នាក់ចត្វា ផ្នែកគណៈមហានិកាយមាន២០ ផ្នែកធម្មយុត្តិកនិកាយមាន១២

-ឋានានុក្រមថ្នាក់ព្រះគ្រូ (មានឈ្មោះជាងារ ឧទាហរណ៍ព្រះគ្រូធម្មចរិយាចារ្យ)

-ព្រះឧបជ្ឈាយ៍ (ត្រូវបានតែងតាំង និងរៀបចំឱ្យទៅតាមបណ្ដាខេត្ត-ក្រុង-ស្រុក-ខណ្ឌនីមួយៗ)។

- **គណៈសង្ឃខេត្ត-រាជធានីមាន ៦ រូប**

-ព្រះមេគណខេត្ត ១ រូប

-ព្រះបាឡាត់គណខេត្ត ១ រូប

-ព្រះវិន័យធរគណខេត្ត ១ រូប

-ព្រះធម្មធរគណខេត្ត ១ រូប

-ព្រះសមុហ៍គណខេត្ត ១ រូប

-លេខាធិការគណខេត្ត ១ រូប

- **គណៈសង្ឃក្រុង-ស្រុក-ខណ្ឌមាន ៥ រូប**

-ព្រះគ្រូអនុគណ ១ រូប

-ព្រះវិន័យធរអនុគណ ១ រូប

-ព្រះធម្មធរអនុគណ ១ រូប

-ព្រះសមុហ៍អនុគណ ១ រូប

-លេខាធិការអនុគណ ១ រូប

❖ **គណៈសង្ឃវត្តមាន ៥ រូប**

-ព្រះចៅអធិការ ១ រូប

-ព្រះគ្រូសូត្រស្តាំ ១ រូប

-ព្រះគ្រូសូត្រឆ្វេង ១ រូប

-ព្រះវិន័យធរវត្ត ១ រូប

-ព្រះលេខាវត្ត ១ រូប

**១.៣.២.គណៈថេរសភាថ្នាក់ជាតិ**

មានសមាសភាពចំនួន ១២ រូបក្នុងនោះរួមមានៈ

-អធិបតី ១ រូប

-សមាជិក ៩ រូប

-លេខាធិការ ១ រូប

-អនុលេខា ១ រូប

**១.៣.៣.គណៈថេរសភាសង្ឃថ្នាក់មូលដ្ឋាន**

❖ **ថេរសភាថ្នាក់រាជធានី-ខេត្ត**

-ព្រះមេគណរាជធានី-ខេត្ត ជាប្រធាន

-ព្រះបាឡាត់គណរាជធានី-ខេត្ត ជាអនុប្រធានទី១

-ព្រះវិន័យធររាជធានី-ខេត្ត ជាអនុប្រធានទី២

-ព្រះធម្មធរគណរាជធានី-ខេត្ត ជាសមាជិក

-ព្រះសមុហ៍គណរាជធានី-ខេត្ត ជាសមាជិក

-ព្រះលេខាធិការគណរាជធានី-ខេត្ត ជាសមាជិក

❖ **ថេរសភាថ្នាក់ក្រុង-ស្រុក-ខណ្ឌ**

-ព្រះអនុគណក្រុង-ស្រុក-ខណ្ឌ ជាប្រធាន

-ព្រះវិន័យធរអនុគណក្រុង-ស្រុក-ខណ្ឌ ជាអនុប្រធានទី១

-ព្រះធម្មធរអនុគណក្រុង-ស្រុក-ខណ្ឌ ជាអនុប្រធានទី២

-ព្រះសមុហ៍អនុគណក្រុង-ស្រុក-ខណ្ឌ ជាសមាជិក

-ព្រះព្រះលេខាធិការអនុគណក្រុង-ស្រុក-ខណ្ឌ ជាសមាជិក។

### ១.៣.៤.អង្គការលេខគណៈសង្ឃនាយកពុទ្ធសាសនានៃគណៈមហានិកាយ




- **អង្គការលេខគណៈសង្ឃរាជធានី ខេត្ត**



❖ **អង្គការលេខគណៈសង្ឃក្រុង ស្រុក ខណ្ឌ**




❖ **អង្គការលេខគណៈសង្ឃវត្ត**



### ១.៣.៥.អង្គការលេខគណៈសង្ឃនាយកពុទ្ធសាសនានៃគណៈធម្មយុត្តិកនិកាយ




### ១.៣.៦.អំពីក្រសួងធម្មការ និងសាសនា

ក្រសួងធម្មការ និងសាសនា មានបេសកកម្មដឹកនាំ និងគ្រប់គ្រងវិស័យធម្មការ និងសាសនា ពុទ្ធិកសិក្សា ការអប់រំ ការសិក្សា ស្រាវជ្រាវ វប្បធម៌ អក្សរសាស្ត្រ ប្រពៃណីទំនៀមទម្លាប់ និងការបោះពុម្ពផ្សាយនានាដែលទាក់ទងនឹងសាសនា។[31]

**មុខងារ និងភារកិច្ចក្រសួងធម្មការ និងសាសនាមានដូចតទៅៈ**

- កំណត់វិធានការដឹកនាំ និងគ្រប់គ្រងសាសនាទាំងអស់ ដែលមានទីតាំង និងធ្វើសកម្មភាព នៅលើទឹកដីនៃព្រះរាជាណាចក្រកម្ពុជា ជាពិសេសយកចិត្តទុកដាក់លើព្រះពុទ្ធសាសនាដែលជាសាសនារបស់រដ្ឋ។

- ណែនាំ និងត្រួតពិនិត្យអង្គការសាសនាក្រោមឱវាទ វត្តអារាម និកាយសាសនា មណ្ឌលសិក្សាស្រាវជ្រាវសាសនានានា និងរាល់អង្គការ សមាគមដែលមានចរិតសាសនា ប្រតិបត្តិ និងធ្វើសកម្មភាពសាសនាស្របតាមច្បាប់របស់រដ្ឋ។

[31] អនុក្រឹត្យ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួងធម្មការ និងសាសនា លេខៈ១៥៤. អនក្រ.បក ១១ កក្កដា ២០១១, មាត្រា៤

- សម្របសម្រួលបរិស័ទគ្រប់សាសនា ឱ្យមានសុខដុមនីយកម្ម និងលើកទឹកចិត្តដល់បរិស័ទ ឱ្យប្រតិបត្តិគោរពតាមក្រឹត្យវិន័យ និងពិធីសាសនារៀងៗខ្លួន មានសាមគ្គីភាពក្នុងរង្វង់សាសនារបស់ខ្លួន និងជាមួយអ្នកកាន់សាសនាផ្សេងៗ ។

- សម្របសម្រួលការងារពុទ្ធិកសិក្សា សំដៅបណ្តុះបណ្តាលធនធានមនុស្សក្នុងជួរព្រះសង្ឃ ធ្វើទំនាក់ទំនងនិងសហការយ៉ាងជិតស្និទ្ធ ជាមួយនឹងសម្តេចព្រះសង្ឃរាជទាំងពីរគណៈ គណៈសង្ឃនាយក រាជាគណៈ និងមេដឹកនាំពាហិរសាសនាក្នុងវិស័យកិច្ចការសាសនា។

- រៀបចំគោលនយោបាយសម្រាប់ការគ្រប់គ្រង និងរៀបចំរចនាសម្ព័ន្ធសាសនាគ្រប់និកាយ ទាំងអស់នៅក្នុងព្រះរាជាណាចក្រកម្ពុជា។

- ពិនិត្យ សិក្សាស្រាវជ្រាវ បកប្រែ ចងក្រង ថែរក្សា បោះពុម្ព និងផ្សព្វផ្សាយឱ្យបានទូលំទូលាយ នូវសៀវភៅក្បួនច្បាប់ គម្ពីរដីកាស្តីពីធម៌អាថ៌ អក្សរសាស្ត្រ វប្បធម៌ សិល្បៈ ទំនៀមទម្លាប់ ពុទ្ធសាសនា និងសាសនាផ្សេងៗទៀត។

- ផ្តល់អនុសាសន៍ និងមានវិធានការសមស្រប ចំពោះការសំដែងសិល្បៈ ដែលអាចធ្វើឱ្យប៉ះពាល់ទៅដល់វិស័យសាសនា។

- ពិនិត្យតាមដានការផ្សព្វផ្សាយធម៌អាថ៌ និងឯកសារគ្រប់ប្រភេទមានជាអាទិ៍ ៖ រូបភាព សំឡេង និងសំណេរ ដែលទាក់ទងវិស័យសាសនាដោយសហការជាមួយក្រសួងស្ថាប័នពាក់ព័ន្ធ។

- ពិនិត្យអនុញ្ញាតឱ្យបង្កើត ឬបិទសកម្មភាពព្រះពុទ្ធសាសនា តាមការស្នើសុំរបស់គណៈសង្ឃនាយក ។

- ពិនិត្យអនុញ្ញាតឱ្យបង្កើត ឬបិទសកម្មភាព ឬស្នាក់ការពាហិរសាសនា ។

- ពិនិត្យ និងផ្តល់យោបល់ក្នុងការអនុញ្ញាតឱ្យបង្កើត ឬបិទគ្រឹះស្ថានសាសនសិក្សា។

- ជំរុញ និងលើកទឹកចិត្តឱ្យមានការសន្ទនាព្រះធម៌ និងនាទីព្រះពុទ្ធសាសនាផ្សាភ្ជាប់សង្គម។

- ទទួលស្គាល់ការតែងតាំងមន្ត្រីសង្ឃគ្រប់ឋានានុក្រម ដែលគណៈសង្ឃនាយកបានរៀបចំ។

- ធ្វើសហប្រតិបត្តិការអន្តរជាតិលើវិស័យធម្មការ និងសាសនា។

-សម្របសម្រួល និងជំរុញឱ្យមានការបណ្តុះបណ្តាល និងធ្វើវិក្រឹតការគ្រូបង្រៀន សាស្ត្រាចារ្យពុទ្ធិកសិក្សាអាចារ្យ និងគណៈកម្មការវត្ត។

- ចូលរួមក្នុងការធ្វើអធិការកិច្ចលើវិស័យសាសនា វិស័យសាសនសិក្សាធិការ និងដោះស្រាយអធិករណ៍។

- ពិនិត្យ និងណែនាំការសាងសង់ ការរុះរើ ឬការផ្លាស់ប្តូរទីកន្លែង សំណង់សាសនានានា ដោយសហការជាមួយស្ថាប័នពាក់ព័ន្ធ។

- ជំរុញការបង្កើតបណ្ណាល័យនៅតាមវត្តអារាមនានា សម្រាប់ជាប្រយោជន៍ដល់សាធារណជន រួមទាំងបព្វជិតទាំងគ្រហស្ថក្នុងព្រះរាជាណាចក្រកម្ពុជា។

- លើកទឹកចិត្តឱ្យសាសនាទាំងអស់ ចូលរួមអភិវឌ្ឍសេដ្ឋកិច្ច និងសង្គមជំរុញវត្តអារាម និងវិហារសាសនានានា ឱ្យក្លាយជាមជ្ឈមណ្ឌលអប់រំខាងផ្នែកស្មារតី សីលធម៌ វប្បធម៌ និងសង្គមកិច្ច។

- រក្សាឱ្យបាននូវសុខដុមនីយកម្ម និងសេរីភាពខាងជំនឿសាសនាទាំងអស់។

- សិក្សាស្រាវជ្រាវ និងធ្វើស្ថិតិលើជំនឿ និងចំនួនជនជាតិដើមភាគតិចដើម្បីអភិវឌ្ឍន៍ និងអភិរក្ស។

- ទទួលអនុវត្តនូវភារកិច្ចផ្សេងទៀតដែលរាជរដ្ឋាភិបាលប្រគល់ជូន។[32]

[32] អនុក្រឹត្យ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួងធម្មការ និងសាសនា លេខៈ១៥៤. អនក្រ.បក ១១ កក្កដា ២០១១, មាត្រា៥

# ជំពូកទី២
# ការគ្រប់គ្រងរដ្ឋបាលផ្នែកពុទ្ធចក្រ
# នៃព្រះរាជាណាចក្រកម្ពុជា

# ជំពូកទី២
# ការគ្រប់គ្រងរដ្ឋបាលផ្នែកពុទ្ធចក្រនៃព្រះរាជាណាចក្រកម្ពុជា

## ២.១.ការជ្រើសតាំង និងការតែងតាំងមន្ត្រីសង្ឃគ្រប់បណ្ដាថ្នាក់

នីតិវិធីនៃការតែងតាំង ព្រះមន្ត្រីសង្ឃគ្រប់ឋានានុក្រម មានលក្ខណៈផ្សេងៗគ្នាទៅតាមតួនាទី និងភារកិច្ចរបស់ព្រះមហាថេរនីមួយៗ។ ដើម្បីឱ្យប្រព័ន្ធការងារក្នុងស្ថាប័ន ព្រះពុទ្ធសាសនាមានប្រសិទ្ធិភាពរីកចម្រើន និងមានស្មារតីទទួលខុសត្រូវខ្ពស់ យើងត្រូវមានការជ្រើសរើស ចំពោះព្រះមហាថេរអង្គណា ដែលលោកមានវស្សាចាស់ មានគុណធម៌ខ្ពង់ខ្ពស់ ដល់នូវការគោរពប្រតិបត្តិ ព្រមទាំងមានចំណេះដឹងជ្រៅជ្រះទាំងផ្នែកផ្លូវលោក និងផ្លូវធម៌ឱ្យបានកាន់តែទូលំទូលាយ ដើម្បីដឹកនាំបង្ហាត់បង្រៀនទៅដល់ព្រះសង្ឃ គ្រហស្ថគ្រប់រូបដែលជ្រះថ្លាក្នុងព្រះពុទ្ធសាសនា ក៏ដូចជាផ្សព្វផ្សាយព្រះពុទ្ធសាសនា ឱ្យបានរីកចម្រើនគ្រប់ទីកន្លែង និងនៅតាមបណ្ដាប្រទេសផ្សេងៗ ទៀតនៅលើសាកលលោក។

### ២.១.១.ការជ្រើសតាំង និងការតែងតាំងសម្ដេចព្រះសង្ឃរាជ និងព្រះសង្ឃនាយក

បេក្ខសមណសង្ឃជាសម្ដេចព្រះមហាសង្ឃរាជ ឬព្រះសង្ឃរាជ ឬព្រះសង្ឃនាយក ត្រូវបានជ្រើសរើសក្នុងបណ្ដាព្រះមហាថេរដែលមានសមត្ថភាព គឺមានទាំងចរិយាសម្បត្តិ និងវិជ្ជាសម្បត្តិ ហើយជាព្រះសង្ឃនាយករងក្នុងតំណែងព្រះរាជាគណៈថ្នាក់ឯក។ នីតិវិធីនៃការជ្រើសរើស ត្រូវមានគណៈកម្មការពិសេសមួយ ដោយមានការចូលរួមពីគ្រប់ស្ថាប័នធំៗរបស់រដ្ឋ ដូចជាស្ថាប័នព្រះមហាក្សត្រ ស្ថាប័នព្រឹទ្ធសភា ស្ថាប័នរដ្ឋសភា ស្ថាប័នរាជរដ្ឋាភិបាលជាដើម។ ចំពោះការជ្រើសតាំងសម្ដេចព្រះសង្ឃរាជ ឬព្រះសង្ឃនាយក គឺព្រះសង្ឃនាយករង មន្ត្រីសង្ឃជាន់ខ្ពស់ថ្នាក់សម្ដេច ព្រះមេគណគ្រប់ខេត្ត-ក្រុង។ បន្ទាប់ពីជ្រើសតាំងបានហើយ ព្រះសង្ឃនាយករងគ្រប់រូប និងមន្ត្រីសង្ឃជាន់ខ្ពស់ថ្នាក់សម្ដេចរួមជាមួយរដ្ឋមន្ត្រីក្រសួងធម្មការ និងសាសនា ត្រូវធ្វើលិខិតស្នើទៅសម្ដេចនាយករដ្ឋមន្ត្រី ហើយសម្ដេចនាយករដ្ឋមន្ត្រីបានពិចារណា លើបេក្ខសមណរួចហើយបើយល់ព្រមឯកភាព ក៏ស្នើបន្តទៅព្រះមហាក្សត្រដើម្បីតែងតាំងដោយព្រះរាជក្រឹត្យ។ បន្ទាប់ពីព្រះមហាក្សត្រទ្រង់ពិចារណាច្បាស់លាស់ហើយ ព្រះអង្គទ្រង់នឹងឡាយព្រះហស្ថតែងតាំងព្រះមហាថេរអង្គនោះ។[33]

---

[33] ភិក្ខុគុណវរោ គង់ លី រដ្ឋបាលវត្តអារាម ព.ស.២៥៦០, ទំព័រ៥០

### ២.១.២.ការជ្រើសតាំង និងការតែងតាំងព្រះសង្ឃនាយករង

បេក្ខសមណសង្ឃ ជាព្រះសង្ឃនាយករង ត្រូវបានជ្រើសរើសក្នុងបណ្តា ព្រះមហាថេរដែលមានសមត្ថភាព គឺមានទាំងចរិយាសម្បត្តិ និងវិជ្ជាសម្បត្តិ ហើយជាមន្ត្រីសង្ឃជាន់ខ្ពស់ថ្នាក់សម្តេច និងព្រះរាជាគណៈក្នុងតំណែង។ នីតិវិធីនៃការជ្រើសរើស គឺសម្តេចព្រះមហាសង្ឃរាជ ឬព្រះសង្ឃនាយករួមជាមួយមន្ត្រីសង្ឃជាន់ខ្ពស់ថ្នាក់សម្តេច ព្រះរាជាគណៈក្នុងតំណែង និងរដ្ឋមន្ត្រីកក្រសួងធម្មការ និងសាសនា ដែលជាតំណាងរាជរដ្ឋាភិបាលប្រជុំគ្នាពីភាក្សាលើបេក្ខសមណថា តើអង្គណាមួយដែលសមគួរនឹងទទួលតំណែង និងគោរម្យងារនេះ បើប្រជុំពិភាក្សាចប់សព្វគ្រប់ហើយ ឯកភាពផ្តល់ឱ្យអង្គណាមួយត្រូវធ្វើកំណត់ហេតុ និងធ្វើសំណើរទៅ សម្តេចនាយករដ្ឋមន្ត្រីដើម្បីពិចារណា និងឯកភាពសម្រេចហើយស្នើទៅព្រះមហាក្សត្រ ដើម្បីសុំតែងតាំងដោយព្រះរាជក្រឹត្យ។[34]

### ២.១.៣.ការជ្រើសតាំង ការតែងតាំងរាជាគណៈក្នុងតំណែង និងរាជាគណៈកិត្តិយស

ចំពោះរាជាគណៈថ្នាក់ឯក គឺស្ថិតនៅក្នុងតំណែងព្រះសង្ឃនាយករងទី១ ទី២ និងទី៣ ហើយ។ ដោយឡែកនៅតែរាជាគណៈថ្នាក់ទោ ត្រី ចត្វា និងកត្តិយស។ បេក្ខសមណសង្ឃជាព្រះរាជាគណៈ ត្រូវបានជ្រើសរើសក្នុងបណ្តា ព្រះមហាថេរដែលមានសមត្ថភាព គឺមានទាំងចរិយាសម្បត្តិ និងវិជ្ជាសម្បត្តិ រួមទាំងវស្សាចាស់ ហើយជាមន្ត្រីសង្ឃជាន់ខ្ពស់ថ្នាក់ ព្រះគ្រូ ថ្នាក់មេគណ និងថ្នាក់អនុគណ។ ចំពោះនីតិវិធីនៃការជ្រើសតាំង គឺមានសមាសភាពរួមមានៈ សម្តេចព្រះមហាសង្ឃរាជ ឬព្រះសង្ឃនាយករងទី១ទី២ទី៣ និងរដ្ឋមន្ត្រីក្រសួងធម្មការ និងសាសនាដែលជាតំណាងរបស់រាជរដ្ឋាភិបាល រួមគ្នាប្រជុំពិភាក្សាជ្រើសរើសយកបេក្ខសមណៈ ដែលសមគួរដល់ការផ្តល់តំណែង។ បន្ទាប់ពីឯកភាពយកអង្គណាមួយហើយ សម្តេចព្រះមហាសង្ឃរាជ ឬព្រះសង្ឃនាយក ធ្វើចុតហ្មាយស្នើទៅព្រះមហាក្សត្រ ដោយមានការឯកភាពចុះហត្ថលេខា លើលិខិតស្នើសុំពីសម្តេចនាយករដ្ឋមន្ត្រី ដើម្បីសុំតែងតាំងជាផ្លូវការដោយព្រះរាជក្រឹត្យ។[35] ចំពោះការជ្រើសតាំងតំណែងព្រះរាជាគណៈនេះ ជួនកាលមានការស្នើសុំពី មន្ត្រីសង្ឃថ្នាក់មូលដ្ឋានក៏សឹងមាន។

### ២.១.៤.ការជ្រើសតាំង និងការតែងតាំងមន្ត្រីសង្ឃឋានានុក្រមថ្នាក់ព្រះគ្រូ

បេក្ខសមណសង្ឃជាព្រះគ្រូ ត្រូវបានជ្រើសរើសក្នុងបណ្តា ព្រះមហាថេរដែលមានសមត្ថភាព គឺមានទាំងចរិយាសម្បត្តិ និងវិជ្ជាសម្បត្តិរួមទាំងវស្សាចាស់ ហើយជាមន្ត្រីសង្ឃយ៉ាងហោចណាស់ ជាថ្នាក់ព្រះចៅអធិការឡើងទៅដែរ។ នីតិវិធីនៃការជ្រើសរើស គឺគណៈសង្ឃនាយកធ្វើសំណើរ ថ្វាយសម្តេចព្រះមហាសង្ឃរាជ ដោយមានការ

[34] សម្តេចព្រះសង្ឃរាជ ជួន ណាត របៀបការគ្រប់គ្រងគណៈសង្ឃ (ទស្សនាវដ្តី ពន្លឺពុទ្ធចក្រលេខ១) ឆ្នាំ១៩៦១, ទំព័រ៣១

[35] មជ្ឈមណ្ឌលសម្រាប់ការសិក្សាស្រាវជ្រាវជាន់ខ្ពស់ ពិធីបំបួសនាគនៅប្រទេសកម្ពុជា អតីតកាល និងបច្ចុប្បន្ន ឆ្នាំ២០០៥, ទំព័រ២៨

ឯកភាពចុះហត្ថលេខាពីរដ្ឋមន្ត្រីក្រសួងធម្មការ និងសាសនាដើម្បីតែងតាំង។ សម្តេចព្រះមហាសង្ឃរាជ បន្ទាប់ពីទ្រង់ទទួលបានសំណើរជាផ្លូវការហើយ ព្រះអង្គទ្រង់ចេញប្រកាសនីយបត្រដើម្បីតែងតាំងតែម្តង ដោយមានការឯកភាពពីសម្តេចនាយករដ្ឋមន្ត្រី។ ការជ្រើសរើស និងស្នើសុំតែងតាំង ជួនកាលតាមការស្នើសុំពីមន្ត្រីសង្ឃ ថ្នាក់មូលដ្ឋានក៏សឹងមាន។

### ២.១.៥.ការជ្រើសតាំង និងការតែងតាំងគណៈសង្ឃថ្នាក់មូលដ្ឋាន

- **ការតែងតាំង និងការជ្រើសតាំងគណៈសង្ឃរាជធានី-ខេត្ត**

ព្រះមហាថេរអង្គណាមួយ ដែលត្រូវបានតែងតាំងជាព្រះមេគណជាផ្លូវការ ពីសម្តេចព្រះមហាសង្ឃរាជ ឬព្រះសង្ឃនាយកហើយ ត្រូវបំពេញតួនាទីរបស់ខ្លួនក្នុងឋានៈជាមេគណ រួមជាមួយគណៈសង្ឃជាសហការី គឺព្រះបាឡាត់គណ ព្រះវិន័យធរគណ ព្រះធម្មធរគណ ព្រះសមុហ៍គណ និងលេខាធិការគណ។ មេគណសម្រាប់រាជធានី-ខេត្ត នីមួយៗ មានអំណាចត្រួតត្រាព្រមទាំងចាត់ការផ្សេងៗ ខាងព្រះពុទ្ធសាសនាមានកម្រិតព្រំដែនតែក្នុងរាជធានី-ខេត្តរបស់ខ្លួនតែប៉ុណ្ណោះ។ ចំពោះកន្លែងធ្វើការរបស់គណៈសង្ឃរាជធានី-ខេត្ត ហៅថា សាលាគណ ដែលមានទីតាំងនៅវត្តព្រះមេគណគង់នៅ។[36]

- **ការជ្រើសតាំង និងការតែងតាំងព្រះមេគណរាជធានី-ខេត្ត**

បេក្ខសមណសង្ឃជាព្រះមេគណ ត្រូវបានជ្រើសរើសក្នុងបណ្តាព្រះមហាថេរអង្គណា ដែលមានសមត្ថភាព គឺមានទាំងចរិយាសម្បត្តិ និងវិជ្ជាសម្បត្តិរួមទាំងវស្សាចាស់ហើយជាមន្ត្រីសង្ឃ យ៉ាងហោចណាស់ជាព្រះគ្រូអនុគណ និងសហការីគណឡើងទៅ។ នីតិវិធីនៃការជ្រើសរើសគឺ មន្ត្រីសង្ឃ រួមជាមួយមន្ទីរធម្មការ និងសាសនាខេត្ត រាជធានី ធ្វើសំណើរថ្វាយគណៈសង្ឃនាយក ដោយមានការឯកភាពពីអភិបាលរាជធានី-ខេត្ត។ បន្ទាប់មកគណៈសង្ឃនាយក ធ្វើសំណើរថ្វាយសម្តេចព្រះមហាសង្ឃរាជដើម្បីតែងតាំងជាផ្លូវការ ដោយមានការឯកភាពពីសម្តេចនាយករដ្ឋមន្ត្រី។

- **ការជ្រើសតាំង និងការតែងតាំងសហការីគណ**

សហការីគណមាន៖ ព្រះបាឡាត់គណ ព្រះវិន័យធរគណ ព្រះធម្មធរគណ ព្រះសមុហ៍គណ និងលេខាធិការគណ។ បេក្ខសមណសង្ឃជាសហការីគណ ត្រូវបានជ្រើសរើសក្នុងបណ្តាព្រះមហាថេរដែលមានសមត្ថភាព គឺមានទាំងចរិយាសម្បត្តិ និងវិជ្ជាសម្បត្តិរួមទាំងវស្សាចាស់ហើយជាមន្ត្រីសង្ឃ យ៉ាងហោចក៏ឋានៈជាព្រះគ្រូអនុគណ និងសហការីគណឡើងទៅ។ នីតិវិធីនៃការជ្រើសរើស គឺមន្ត្រីសង្ឃ រួមជាមួយមន្ទីរធម្មការ និងសាសនាខេត្ត-រាជធានី

[36] មជ្ឈមណ្ឌលសម្រាប់ការសិក្សាស្រាវជ្រាវជាន់ខ្ពស់ ពិធីបំបួសនាគនៅប្រទេសកម្ពុជា អតីតកាល និងបច្ចុប្បន្ន ឆ្នាំ២០០៥, ទំព័រ២៧

ធ្វើសំណើរថ្វាយគណៈសង្ឃនាយក ដោយមានការឯកភាពពីអភិបាលរាជធានី-ខេត្ត។ បន្ទាប់មកគណៈសង្ឃនាយក ធ្វើសំណើរថ្វាយសម្តេចព្រះមហាសង្ឃរាជ ដើម្បីតែងតាំងជាផ្លូវការ ដោយមានការឯកភាពពីសម្តេចនាយករដ្ឋមន្ត្រី។

❖ **ការជ្រើសតាំង និងការតែងតាំងព្រះឧបជ្ឈាយ៍**

បេក្ខសមណសង្ឃជាព្រះឧបជ្ឈាយ៍ ត្រូវបានជ្រើសរើសក្នុងបណ្តា ព្រះមហាថេរដែលមានវស្សាចាស់ និងមានសមត្ថភាពខ្ពស់ គឺមានទាំងចរិយាសម្បត្តិ និងវិជ្ជាសម្បត្តិ។ នីតិវិធីនៃការជ្រើសរើស ក្នុងនោះមានសមាសភាព ព្រះមេគណ សហការីគណ ប្រធានមន្ទីរធម្មការ និងសាសនា ព្រះគ្រូអនុគណ សហការីអនុគណប្រធានការិយាល័យធម្មការ និងសាសនា ប្រជុំជ្រើសរើសដោយការបោះឆ្នោត ឬក៏ជ្រើសតាំងតែម្តង រួចហើយធ្វើសំណើរថ្វាយគណៈសង្ឃនាយក ដោយមានការឯកភាពពីព្រះមេគណរាជធានី-ខេត្ត និងប្រធានមន្ទីរធម្មការ និងសាសនា។ បន្ទាប់មកគណៈសង្ឃនាយក ចេញប្រកាសនីយបត្រដើម្បីតែងតាំងជាផ្លូវការ ដោយមានការយល់ព្រមពីរដ្ឋមន្ត្រីក្រសួងធម្មការ និងសាសនា រួចហើយគណៈសង្ឃនាយកធ្វើរបាយការណ៍ ថ្វាយសម្តេចព្រះមហាសង្ឃរាជដើម្បីទ្រង់ជ្រាប។

❖ **ការជ្រើសតាំង និងការតែងតាំងគណៈសង្ឃក្រុង-ស្រុក-ខណ្ឌ**

ព្រះមហាថេរអង្គណាមួយ ដែលត្រូវបានតែងតាំងជាព្រះគ្រូអនុគណផ្លូវការ ពីសម្តេចព្រះមហាសង្ឃរាជ ហើយត្រូវបំពេញតួនាទីរបស់ខ្លួន ក្នុងឋានៈជាព្រះគ្រូអនុគណ រួមជាមួយគណៈសង្ឃជាសហការី គឺព្រះវិន័យធរ ព្រះធម្មធរ ព្រះសមុហ៍ និងលេខាធិការ។ ព្រះគ្រូអនុគណសម្រាប់ក្រុង-ស្រុក-ខណ្ឌ នីមួយៗ មានអំណាចត្រួតត្រាព្រមទាំងចាត់ចែងការងារផ្សេងៗ ខាងព្រះពុទ្ធសាសនា មានកម្រិតព្រំដែនតែក្នុង ក្រុង-ស្រុក-ខណ្ឌ របស់ខ្លួនប៉ុណ្ណោះ។ ចំពោះកន្លែងធ្វើការរបស់គណៈសង្ឃ ក្រុង-ស្រុក-ខណ្ឌ ហៅថា សាលាអនុគណ ដែលមានទីតាំងនៅវត្តព្រះគ្រូអនុគណគង់នៅផ្ទាល់តែម្តង។

❖ **ការជ្រើសតាំង ព្រះគ្រូអនុគណ ក្រុង-ស្រុក-ខណ្ឌ**

បេក្ខសមណសង្ឃជាព្រះគ្រូអនុគណ ក្រុង-ស្រុក-ខណ្ឌ ត្រូវបានជ្រើសរើសក្នុងបណ្តាព្រះថេរដែលមានព្រះវស្សាចាស់មានសមត្ថភាព គឺមានទាំងចរិយាសម្បត្តិ និងវិជ្ជាសម្បត្តិ ដែលចេញពីមន្ត្រីសង្ឃ ក្រុង-ស្រុក-ខណ្ឌ។ នីតិវិធីនៃការជ្រើសរើស ក្នុងនោះមានសមាសភាព ព្រះមេគណ សហការីគណ មន្ត្រីសង្ឃក្រុង-ស្រុក-ខណ្ឌ ប្រធានមន្ទីរធម្មការ និងសាសនារាជធានី-ខេត្ត អភិបាលរាជធានី-ខេត្ត ឬតំណាងរបស់ខ្លួន និងចៅអធិការគ្រប់វត្តក្នុង ក្រុងស្រុក-ខណ្ឌ។ ប្រជុំដោយការបោះឆ្នោត ឬជ្រើសតាំងតែម្តង រួចហើយធ្វើសំណើរថ្វាយគណៈសង្ឃនាយក ដោយមានការឯកភាពពីអភិបាល រាជធានី-ខេត្ត។ បន្ទាប់មកគណៈសង្ឃនាយក ធ្វើសំណើរថ្វាយសម្តេចព្រះមហាសង្ឃរាជ ដើម្បីតែងតាំងជាផ្លូវការ ដោយមានការឯកភាពពីសម្តេចនាយករដ្ឋមន្ត្រី។

### ❖ ការជ្រើសតាំង និងការតែងតាំងសហការីអនុគណក្រុង-ស្រុក-ខណ្ឌ

សហការីអនុគណ ក្រុង-ស្រុក-ខណ្ឌមាន៖ ព្រះវិន័យធរ ព្រះធម្មធរ ព្រះសមុហ៍ និងលេខាធិការ។ បេក្ខសមណសង្ឃ ជាសហការីព្រះអនុគណ ក្រុង-ស្រុក-ខណ្ឌ ត្រូវបានជ្រើសរើសក្នុងបណ្ដា ព្រះថេរដែលមានវស្សាចាស់មានសមត្ថភាព គឺមានទាំងចរិយាសម្បត្តិ និងវិជ្ជាសម្បត្តិ ដែលចេញពីមន្ត្រីសង្ឃ ក្រុង-ស្រុក-ខណ្ឌ និងព្រះចៅអធិការអង្គណាមួយក្នុង ក្រុង-ស្រុក-ខណ្ឌនោះៗ។ នីតិវិធីនៃការជ្រើសរើស ក្នុងនោះមានសមាសភាពតំណាងព្រះមេគណមន្ត្រីសង្ឃ ក្រុង-ស្រុក-ខណ្ឌ ប្រធានការិយាល័យធម្មការ និងសាសនា អភិបាលក្រុង-ស្រុក-ខណ្ឌ និងចៅអធិការគ្រប់វត្តក្នុង ក្រុង-ស្រុក-ខណ្ឌ ប្រជុំជ្រើសរើសដោយការបោះឆ្នោត ឬក៏ជ្រើសតាំងតែម្ដង រួចហើយធ្វើសំណើរថ្វាយគណៈសង្ឃនាយក ដោយមានការឯកភាព ពីព្រះមេគណរាជធានី-ខេត្ត និងប្រធានមន្ទីរធម្មការ និងសាសនា។ បន្ទាប់មកគណៈសង្ឃនាយក ចេញប្រកាសនីយបត្រតែងតាំងជាផ្លូវការ ដោយមានការយល់ព្រមពីរដ្ឋមន្ត្រីក្រសួងធម្មការ និងសាសនា រួចហើយធ្វើរបាយការណ៍ ថ្វាយសម្ដេចព្រះមហាសង្ឃរាជដើម្បីទ្រង់ជ្រាប។

### ❖ ការជ្រើសតាំង និងការតែងតាំងគណៈសង្ឃវត្ត

**-ការជ្រើសតាំង និងការតែងតាំងចៅអធិការ**

គណៈសង្ឃវត្តបច្ចុប្បន្នមាន ៥ រូប គឺព្រះចៅអធិការ គ្រូសូត្រស្ដាំ គ្រូសូត្រឆ្វេង វិន័យធរ និងលេខាវត្ត។ ចៅអធិការ គ្រូសូត្រស្ដាំ គ្រូសូត្រឆ្វេង វិន័យធរ និងលេខាវត្តនីមួយៗ ត្រូវជ្រើសតាំងដោយភិក្ខុ-សាមណេរក្នុងវត្តនោះៗ តាមវិធីបោះឆ្នោត ហើយអនុវត្តតាមបែបបទដូចខាងក្រោម៖

ព្រះថេរជាតំណាងភិក្ខុ-សាមណេរទាំងអស់ ត្រូវធ្វើលិខិតស្នើសុំទៅអនុគណ ស្រុក-ខណ្ឌ តាមរយៈរដ្ឋអំណាចមូលដ្ឋានភូមិ-ឃុំ និងការិយាល័យធម្មការ និងសាសនា ស្រុក-ខណ្ឌ ដោយមានភ្ជាប់បញ្ជីរាយនាមភិក្ខុ សាមណេរក្នុងវត្ត និងប្រវត្តិរូបបេក្ខសមណចៅអធិការ គ្រូសូត្រស្ដាំ គ្រូសូត្រឆ្វេង វិន័យធរ និងលេខាវត្តទៅជាមួយផង។ អនុគណក្រោយពីបានពិភាក្សាឯកភាព ជាមួយសហការីជាមន្ត្រីសង្ឃក្រុង-ស្រុក-ខណ្ឌ និងប្រធានការិយាល័យធម្មការ និងសាសនា ក្រុង-ស្រុក-ខណ្ឌ ព្រមទាំងក្រុមប្រឹក្សាឃុំ-សង្កាត់ និងប្រធានភូមិរួចហើយ ក៏រៀបចំផ្ដល់ដំណឹងដើម្បីធ្វើការបោះឆ្នោត។ បន្ទាប់ពីបានសម្រេចបោះឆ្នោត ជ្រើសរើសព្រះមហាថេរអង្គណាជាព្រះចៅអធិការរួចហើយ ព្រះគ្រូអនុគណ ត្រូវធ្វើសំណើរតែងតាំងតាមរយៈការិយាល័យធម្មការ និងសាសនា ក្រុង-ស្រុក-ខណ្ឌ ព្រះមេគណ និងប្រធានមន្ទីរធម្មការ និងសាសនាខេត្ត-រាជធានី រួចហើយធ្វើសំណើរថ្វាយគណៈសង្ឃនាយក ដោយមានការឯកភាពពីព្រះមេគណរាជធានីខេត្ត និងប្រធានមន្ទីរធម្មការ និងសាសនា។ បន្ទាប់មកគណៈសង្ឃនាយកចេញ

ប្រកាសនីយបត្រតែងតាំងជាផ្លូវការ ដោយមានការយល់ព្រមពីរដ្ឋមន្ត្រីក្រសួងធម្មការ និងសាសនា រួចហើយធ្វើរបាយការណ៍ថ្វាយសម្តេច ព្រះមហាសង្ឃរាជដើម្បីទ្រង់ជ្រាប។

**-ការជ្រើសតាំង និងតែតាំងសហការីគណៈសង្ឃវត្ត**

ភិក្ខុដែលត្រូវឈរឈ្មោះ ឱ្យគេបោះឆ្នោតជ្រើសតាំងជាចៅអធិការ គ្រូសូត្រស្តាំ គ្រូសូត្រឆ្វេង វិន័យធរ និងលេខា ត្រូវមានជន្មាយុ ២៥ ឆ្នាំយ៉ាងតិច និងមានអាយុផ្នួសពី ៥ វស្សាឡើងទៅ ព្រមទាំងមានគុណសម្បត្តិ សមត្ថភាពគ្រប់គ្រាន់ មានជីវប្រវត្តិល្អ និងមានជំនឿទុកចិត្តលើភិក្ខុ សាមណេរ និងពុទ្ធបរិស័ទជើងវត្ត។ បេក្ខសមណដែលទទួលសន្លឹកឆ្នោតច្រើនជាងគេ ត្រូវជ្រើសតាំងជាចៅអធិការ បន្ទាប់មក ត្រូវបានតំណែងជាគ្រូសូត្រស្តាំ ឆ្វេង វិន័យធរ និងលេខា តាមលំដាប់សន្លឹកឆ្នោត។ ក្នុងករណីមានសន្លឹកឆ្នោតស្មើគ្នា នោះបេក្ខសមណដែលមានជន្មាយុច្រើន ឬមានផ្នួសវស្សាចាស់ជាងគេ និងត្រូវបានទទួលតំណែងជា បន្តបន្ទាប់តាមលំដាប់លំដោយ។ រួចបោះឆ្នោតរួចហើយ អនុគណ ក្រុង-ស្រុក-ខណ្ឌ ត្រូវធ្វើសំណើរតាមរយៈប្រធានការិយាល័យធម្មការ និងសាសនា ប្រធានមន្ទីរធម្មការ និងសាសនា ព្រមទាំងមេគណខេត្ត-រាជធានី ថ្វាយគណៈសង្ឃនាយកដោយមានការឯកភាព ពីព្រះមេគណរាជធានី-ខេត្ត និងប្រធានមន្ទីរធម្មការ និងសាសនា។ បន្ទាប់មកគណៈសង្ឃនាយក ចេញប្រកាសនីយបត្រតែងតាំងជាផ្លូវការ ដោយមានការយល់ព្រមពីរដ្ឋមន្ត្រីក្រសួងធម្មការ និងសាសនារួចហើយធ្វើរបាយការណ៍ថ្វាយសម្តេច ព្រះមហាសង្ឃរាជដើម្បីទ្រង់ជ្រាប។

### ២.១.៦.អំពីការជ្រើសតាំង និងតែងតាំងអាចារ្យ គណៈកម្មការវត្ត

គ្រប់វត្តអារាមទូទាំងព្រះរាជាណាចក្រកម្ពុជា ត្រូវរៀបចំជ្រើសរើសអាចារ្យ ១ ( មួយ ) ក្រុម និងគណៈកម្មការវត្ត ១ (មួយ) ក្រុមជាតំណាងពុទ្ធបរិស័ទចំណុះជើងវត្ត ដើម្បីជួយសម្រួលការងារគណៈសង្ឃវត្ត ក្នុងការគ្រប់គ្រងដឹកនាំវត្តអារាម តាមសំណើរបស់ព្រះគ្រូចៅអធិការវត្តសាមី។ ការរៀបចំជ្រើសរើស អាចារ្យ គណៈកម្មការវត្ត ត្រូវធ្វើឡើងដោយគណៈកម្មការរៀបចំមួយក្រុម ក្រោមការសម្របសម្រួលពី មន្ទីរធម្មការ និងសាសនា និងសាលាគណ រាជធានីខេត្ត។ ការរៀបចំជ្រើសរើសនេះ ត្រូវចាត់ចែងដោយផ្ទាល់ ពីសំណាក់ព្រះគ្រូចៅអធិការវត្តសាមី មានការចូលរួមពីសាលាអនុគណ ក្រុង-ស្រុក-ខណ្ឌ និងអាជ្ញាធរពាក់ព័ន្ធ ភូមិ-ឃុំ-សង្កាត់ តាមរយៈការបោះឆ្នោតដោយសម្ងាត់ ឬមិនសម្ងាត់អនុលោមតាមភាពជាក់ស្តែង។[37]

[37] ក្រសួងធម្មការ និងសាសនា ប្រកាសស្តីពី ការរៀបចំ និងការប្រព្រឹត្តទៅរបស់អាចារ្យ គណៈកម្មការវត្ត លេខ ១៤៣/១៩ ក.ធ.ស.ប្រក ថ្ងៃទី ០៥ ខែវិច្ឆិកា ឆ្នាំ២០១៩

## ២.២.តួនាទី និងភារកិច្ចមន្ត្រីសង្ឃគ្រប់បណ្តាថ្នាក់នៃគណៈសង្ឃកម្ពុជា

### ២.២.១.តួនាទី និងភារកិច្ចសម្តេចព្រះមហាសង្ឃរាជ និងព្រះសង្ឃនាយក

❖ **តួនាទី និងភារកិច្ចសម្តេចព្រះមហាសង្ឃរាជ**

-ទទួលគ្រប់គ្រងនិងដឹកនាំរួមលើការងារព្រះពុទ្ធសាសនាក្នុងប្រទេស និងទំនាក់ទំនងការងារព្រះពុទ្ធសាសនានៅក្រៅប្រទេស។

-ទទួលភារកិច្ចចុះព្រះហស្តលេខា លើប្រកាសនីយបត្រតែងតាំង ឬសញ្ញាបត្រតែងតាំង និងដកហូតមុខតំណែងមន្ត្រីសង្ឃមានគណៈសង្ឃខេត្ត-ក្រុង គណៈសង្ឃស្រុក-ខណ្ឌ គណៈសង្ឃវត្តទីប្រឹក្សា និងឋានានុក្រមសង្ឃរួមទាំងថ្នាក់ព្រះគ្រូ និងព្រះឧបជ្ឈាយ៍ផង តាមបែបបទពីមូលដ្ឋាន និងតាមករណីចាំបាច់ដោយមានការឯកភាព ពីរដ្ឋមន្ត្រីក្រសួងធម្មការ និងសាសនា។

-ធ្វើព្រះរាជសំណើថ្វាយព្រះមហាក្សត្រ ដោយមានការឯកភាពពីរដ្ឋមន្ត្រីក្រសួងធម្មការ និងសាសនាដើម្បីតែងតាំងព្រះរាជាគណៈគ្រប់ថ្នាក់ និងគោរម្យងារថ្នាក់សម្តេច។

-ការដឹកនាំបើកអនុសំវច្ឆរមហាសន្និបាតមន្ត្រីសង្ឃប្រចាំឆ្នាំ ត្រួតពិនិត្យដំណើរ និងការប្រព្រឹត្តទៅនៃវិស័យព្រះពុទ្ធសាសនា ក្នុងក្របខណ្ឌកិច្ចការរដ្ឋបាល និងទំនាក់ទំនងសាធារណៈ។[38]

❖ **តួនាទី និងភារកិច្ចសម្តេចព្រះសង្ឃនាយក**

-ទទួលភារកិច្ចស្តីទីក្នុងការគ្រប់គ្រង និងដឹកនាំការងារព្រះពុទ្ធសាសនា ក្នុងឱកាសអវត្តមានសម្តេចអគ្គមហាសង្ឃរាជាធិបតី សម្តេចមហាសង្ឃរាជ នៃព្រះរាជាណាចក្រកម្ពុជា។

-តែងតាំងលោកគ្រូចៅអធិការ គ្រូសូត្រឆ្វេង ស្តាំ ព្រះវិន័យធរ លេខាធិការ ព្រះឧប្បជ្ឈាយ៍ ព្រះវិន័យធរអនុគណព្រះសមុហ៍អនុគណ ព្រះលេខាធិការអនុគណ តាមសំណើរបស់សមូហភាពសង្ឃ តាមវត្តនីមួយៗ ដែលរួមមានទាំងព្រះអនុគណ ព្រះបាឡាត់គណ ព្រះមេគណ ដោយមានការយល់ព្រមពីអាជ្ញាធរមូលដ្ឋាន ស្រុក ខណ្ឌ និងខេត្តក្រុង តាមរយៈក្រសួងធម្មការ និងសាសនា ដោយត្រូវរាយការណ៍ថ្វាយ សម្តេចអគ្គមហាសង្ឃរាជាធិបតី សម្តេចមហាសង្ឃរាជដើម្បីទ្រង់ជ្រាប។

-ទទួលភារកិច្ច ក្តោបក្តាប់ការងារស្ថិតិវត្តអារាម ភិក្ខុ សាមណេរ អាចារ្យ គណៈកម្មការវត្ត កុមារ យុវជនស្នាក់នៅក្នុងវត្តនៅទូទាំងប្រទេស បូកសរុបរាយការណ៍ថ្វាយ សម្តេចអគ្គមហាសង្ឃរាជាធិបតី សម្តេចព្រះមហាសង្ឃរាជ។

---

[38] ព្រះសង្ឃប្រកាស ស្តីពី ការកំណត់បែងចែកភារកិច្ចសម្តេចព្រះអគ្គមហាសង្ឃរាជាធិបតី សម្តេចព្រះមហាសង្ឃរាជ និងសម្តេចព្រះមហាសុមេធាធិបតី ព្រះសង្ឃនាយក លេខ០០១/០៦ ម.ស.រធត ព.ស.២៥៥០ គ.ស. ២០០៦

-ការបើកអនុសំវច្ឆរមហាសន្និបាតមន្ត្រីសង្ឃប្រចាំឆ្នាំ ត្រួតពិនិត្យដំណើរការប្រព្រឹត្តទៅ នៃវិស័យព្រះពុទ្ធសាសនាក្នុងក្របខណ្ឌកិច្ចការរដ្ឋបាល និងទំនាក់ទំនងសាធារណៈ។

-ទទួលភារកិច្ច ក្តាប់ការងារពុទ្ធិកសិក្សាគ្រប់កម្រិត ចាប់ពីពុទ្ធិកបឋមសិក្សា រហូតដល់ពុទ្ធិកឧត្តមសិក្សា និងក្រោយពុទ្ធិកឧត្តមសិក្សាទូទាំងប្រទេស ក្នុងឋានៈជាអគ្គាធិការពុទ្ធិកសិក្សាជាតិ និងជាពុទ្ធិកបឋមសិក្សានៅថ្នាក់មូលដ្ឋាន មានបញ្ហាគ្រូ បញ្ហាសម្ភារបរិក្ខា កម្មវិធីសិក្សា។ល។ និងសាលាធម្មវិន័យទាំងបីថ្នាក់។

**២.២.២.តួនាទី និងភារកិច្ចព្រះសង្ឃនាយករង**

❖ **តួនាទី និងភារកិច្ចព្រះសង្ឃនាយករងទី១**

-ទទួលភារកិច្ចស្តីទីក្នុងការគ្រប់គ្រង និងដឹកនាំការងារព្រះពុទ្ធសាសនា ក្នុងឱកាសអវត្តមានសម្តេចព្រះមហាសុមេធាធិបតីព្រះសង្ឃនាយក នៃព្រះរាជាណាចក្រកម្ពុជា។

-ទទួលភារកិច្ចជាប្រធានថេរសភា នៃព្រះពុទ្ធសាសនានៅប្រទេសកម្ពុជា។

-ទទួលភារកិច្ចត្រួតពិនិត្យ ឯកសារ ធម៌ទេសនា តាមវិទ្យុ ទូរទស្សន៍ និងសៀវភៅដែលត្រូវបោះពុម្ពផ្សាយ។

❖ **តួនាទី និងភារកិច្ចព្រះសង្ឃនាយករងទី២**

-ទទួលភារកិច្ចការងាររដ្ឋបាល គ្រប់គ្រងត្រាការងារលិខិតស្នាម ទំនាក់ទំនងសាធារណៈជាមួយបណ្តាក្រសួងស្ថាប័ន អង្គភាពគ្រប់ខេត្ត-ក្រុង ក្នុងទូទាំងព្រះរាជាណាចក្រកម្ពុជា ទាំងផ្នែកពុទ្ធចក្រ និងទាំងផ្នែកអាណាចក្រ។

-ជួយក្តាប់ស្ថិតិវត្តអារាម ភិក្ខុ-សាមណេរ សីលវន្ត សីលវតី អាចារ្យ គណៈកម្មការ ចាស់ព្រឹទ្ធាចារ្យធិបតីព្រះសង្ឃនាយកប្រចាំខែ ប្រចាំត្រីមាស និងប្រចាំឆ្នាំ។

❖ **តួនាទី និងភារកិច្ចព្រះសង្ឃនាយករងទី៣**

-ជួយបំពេញព្រះភារកិច្ចរាល់ការងារចាត់តាំង តម្លើងឋានៈដកចេញតួនាទី ត្រួតពិនិត្យ ការសុំអនុញ្ញាតបំបួសកុលបុត្រ ( ភិក្ខុ-សាមណេរ ) ការសាងសង់សំណង់សំខាន់ៗ រៀបចំវត្តអារាមបរិស្ថាននៃវត្តនីមួយៗ ឱ្យស័ក្តិសមជាអារាមគួរគោរពបូជាដោយជ្រះថ្លា រក្សាបេតិកភ័ណ្ឌជាតិ បេតិកភ័ណ្ឌសាសនា ប្រពៃណី ទំនៀមទំលាប់ អារ្យធម៌ វប្បធម៌ជាតិ។[39]

-ជួយការងារតែងតាំង គ្រូសូត្រស្តាំ ឆ្វេង ចៅអធិការ ព្រះឧបជ្ឈាយ៍ ព្រះវិន័យធរអនុគណ ព្រះធម្មធរអនុគណ ព្រះសមុហ៍អនុគណ ព្រះលេខាធិការអនុគណ និងការកសង្ឃនៃវត្តនីមួយៗ ក្នុងកម្រិតថ្នាក់ស្រុក-ខណ្ឌ ឃុំ-សង្កាត់។

[39] ព្រះសង្ឃប្រកាស ស្តីពី ការកំណត់បែងចែកភារកិច្ចគណៈសង្ឃនាយក នៃព្រះរាជាណាចក្រកម្ពុជា លេខ០០៥/០៦ ស.ន.ក.ជ ថ្ងៃទី០២ ខែសីហា ព.ស.២៥៥០ គ.ស. ២០០៦

### ២.២.៣.តួនាទី និងភារកិច្ចព្រះរាជាគណៈគ្រប់ថ្នាក់

-ព្រះរាជាគណៈ ជាក្រុមមន្ត្រីសង្ឃជាន់ខ្ពស់ក្នុងពុទ្ធសាសនាកម្ពុជា ព្រះរាជាគណៈនេះមាន ៤ ថ្នាក់គឺ ឯក ទោ ត្រី និងចត្វា។ ចំពោះរាជាគណៈថ្នាក់ឯក ត្រូវបានជ្រើសរើសឱ្យធ្វើជាគណៈសង្ឃនាយកហើយ គឺសម្តេចព្រះធម្មលិខិតព្រះសង្ឃនាយករងទី១ សម្តេចព្រះពោធិវង្សព្រះសង្ឃនាយករងទី២ និងសម្តេចព្រះវនរ័តព្រះសង្ឃនាយករងទី៣ សុទ្ធសឹងមានភារកិច្ចរួចហើយ ដូចមានរៀបរាប់ខាងលើស្រេច។ ដោយឡែក រាជាគណៈក្នុងតំណែង ៣ ទៀតគឺ ទោ ត្រី និងចត្វា ព្រមទាំងរាជាគណៈថ្នាក់កិត្តិយសតោងមានតួនាទី និងភារកិច្ចដូចគ្នា។[40] ការងារដែលមន្ត្រីសង្ឃរាជាគណៈគ្រប់ថ្នាក់ត្រូវបំពេញនេះរួមាន៖

-ជាសេនាធិការរបស់សម្តេចព្រះសង្ឃរាជ ឬព្រះសង្ឃនាយក

-បំពេញតួនាទីជាមន្ត្រីសង្ឃថ្នាក់កណ្តាល និងមានភារកិច្ចចូលរួមព្រះរាជពិធី ជាប្រពៃណីរបស់ព្រះមហាក្សត្រក្នុងព្រះបរមរាជវាំង និងក្រៅព្រះរាជវាំងតាមលំអានពីបុរាណ។

-ការត្រួតមើលការងារគ្រប់គ្រងរបស់មន្ត្រីសង្ឃ និងព្រះឧបជ្ឈាយ៍ខេត្ត-រាជធានី អនុវត្តការងារដែលមហាសន្និបាតសង្ឃប្រចាំឆ្នាំ បានដាក់ចុះកាលពីឆ្នាំកន្លងមក។

-ជួយតម្រង់ទិសដៅការងារមន្ត្រីសង្ឃ ថ្នាក់មូលដ្ឋានឱ្យត្រូវចំតាមទិសដៅ និងស្របតាមគោលនយោបាយរបស់រាជរដ្ឋាភិបាល។

-ស្រង់យកលទ្ធផលការងាររបស់ខ្លួន និងរបាយការណ៍ស្តីពីការងារ របស់មន្ត្រីសង្ឃថ្នាក់មូលដ្ឋាននិងវាយតម្លៃទៅលើលទ្ធផលការងារ ក្នុងខេត្ត-ក្រុង របស់ខ្លួនដែលបានទទួលបន្ទុក ហើយរាយការណ៍ទូលថ្វាយ សម្តេចព្រះមហាសង្ឃរាជ ឬសម្តេចព្រះសង្ឃនាយក។

-ចុះតាមមូលដ្ឋានខេត្ត រាជធានី ក្រុង ស្រុក ខណ្ឌ ដើម្បីពិនិត្យទៅលើវិស័យពុទ្ធិកសិក្សា ដោយសិក្សាទៅលើចំណុចរីកចម្រើន និងចំណុចមិនរីកចម្រើន ព្រមទាំងចំណុចខ្សោយ និងចំណុចខ្លាំង។

-ដឹកនាំព្រះមេគណ ខេត្ត រាជាធានី ដែលខ្លួនទទួលបន្ទុកចូលគាល់ សម្តេចព្រះមហាសង្ឃរាជ ឬសម្តេចព្រះសង្ឃនាយករៀងរាល់ឆ្នាំ តាមប្រពៃណីដែលហៅថាឡើងគណ ដោយរាយការណ៍ទូលថ្វាយអំពីសុខទុក្ខភាពលំបាក ស្រណុក រីកចម្រើន និងមិនរីកចម្រើន ព្រមទាំងចំណុចខ្វះខាត និងគ្រប់គ្រាន់។

---

[40] ព្រះសង្ឃប្រកាស ស្តីពី ការកំណត់បែងចែកភារកិច្ចគណៈសង្ឃនាយក នៃព្រះរាជាណាចក្រកម្ពុជា លេខ០០៥/០៦ ស.ន.ក.ជ ថ្ងៃទី០២ ខែសីហា ព.ស.២៥៥០ គ.ស. ២០០៦

-ចូលរួមប្រជុំអនុសំវច្ឆរមហាសន្និបាត មន្ត្រីសង្ឃទូទាំងប្រទេសប្រចាំឆ្នាំ ដើម្បីផ្តល់យោបល់កែលម្អ លើកយកចំណុចខ្វះខាត ដែលបានជួបប្រទះក្នុងខេត្តក្រុងរបស់ខ្លួន ទទួលបន្ទុកដាក់ក្នុងមហាសន្និបាត សំដៅលើទិសដៅទៅឆ្នាំខាងមុខ។ តួនាទី និងភារកិច្ចដែលព្រះរាជាគណៈត្រូវបំពេញនេះ ក៏ត្រូវបានអនុវត្តជាប្រក្រតីរហូតមកដល់ទសវត្សរ៍ទី ៥០-៦០ និងពាក់កណ្តាលទី ៧០ និងដល់បច្ចុប្បន្ននេះក៏មានអនុវត្តដែរ តែពុំទាន់បានពេញលេញនៅឡើយ។

សូមបញ្ជាក់ថា ចំពោះព្រះរាជាគណៈគ្រប់ថ្នាក់ មានសិទ្ធិជ្រើសរើសសហការី ២ រូបសម្រាប់អម និងជួយកិច្ចការងាររបស់ខ្លួន។

### ២.២.៤.តួនាទី និងភារកិច្ចឋានានុក្រមព្រះគ្រូ

មន្ត្រីសង្ឃឋានានុក្រមថ្នាក់ព្រះគ្រូមានតួនាទី ជាជំនួយការរបស់ព្រះរាជាគណៈគ្រប់ថ្នាក់ ពោលគឺនៅពេលព្រះរាជាគណៈ ត្រូវការឱ្យជួយកិច្ចការគ្រប់ផ្នែកដែលលោកមាន។ ហើយក៏ជាព្រះមន្ត្រីសង្ឃបំរុងឡើងតួនាទីជាព្រះរាជាគណៈផង។

### ២.២.៥.តួនាទី និងភារកិច្ចគណៈសង្ឃថ្នាក់មូលដ្ឋាន

- **តួនាទី និងភារកិច្ចព្រះមេគណ**

ព្រះមេគណត្រូវបំពេញតួនាទីភារកិច្ច និងករណីកិច្ចរបស់ខ្លួនដូចខាងក្រោម៖

-ដឹកនាំ គ្រប់គ្រងព្រះអនុគណគ្រប់ក្រុង ស្រុក ខណ្ឌ

-ចាត់ចែង និងពិនិត្យមើលកិច្ចការខាងព្រះពុទ្ធសាសនា

-បំពេញតួនាទី ជាមេដឹកនាំប្រកបដោយនាយកធម៌

-ជាអធិបតី និងដឹកនាំកិច្ចប្រជុំ មន្ត្រីសង្ឃខេត្ត រាជធានី ក្រុង ស្រុក ខណ្ឌ

-ចុះហត្ថលេខាលើឯកសារ និងលិខិតស្នាមផ្សេងៗជាផ្លូវការ

-ស្នើតែងតាំងសហការីគណ និងព្រះអនុគណ

-ការប្រាស្រ័យទាក់ទងនឹងគណៈសង្ឃនាយក

-ធ្វើទំនាក់ទំនង និងសហការល្អជាមួយអាជ្ញាធរ និងស្ថាប័នពាក់ព័ន្ធ

-ទទួលជួប និងទំនាក់ទំនងជាមួយភ្ញៀវជាតិ អន្តរជាតិ

-ជួយកិច្ចការផ្សេងៗទៀត ដែលគណៈសង្ឃនាយកដាក់ចេញ

-ការគ្រប់គ្រងត្រាសាលាគណ ជាឆន្ទានុសិទ្ធិរបស់ព្រះមេគណ

-ធ្វើរបាយការណ៍អំពីកិច្ចការ ព្រះពុទ្ធសាសនាតាមរបបកំណត់ និងរបាយការណ៍ជំនាញថ្វាយគណៈសង្ឃនាយក។[41]

- **អំពីការត្រួតត្រាលើលោកអនុគណគ្រប់ស្រុក**

លោកមេគណនីមួយៗ ត្រួតត្រាលើលោកអនុគណគ្រប់ក្រុង ស្រុក ខណ្ឌ ក្នុងខេត្តដែលខ្លួនជាអ្នកត្រួតត្រាដូចតទៅនេះគឺៈ

-ត្រូវរំលឹកដាស់តឿនលោកអនុគណ ឱ្យប្រតិបត្តិតាមតួនាទីរបស់ខ្លួនកុំឱ្យធ្វេសប្រហែស ដើម្បីកុំឱ្យលោកអនុគណភ្លេចគិតដល់ករណីកិច្ចរបស់ខ្លួន។

-ត្រូវនិមន្តលោកអនុគណគ្រប់ស្រុក ឱ្យមកប្រជុំនៅទីវត្តលោកមេគណ ក្នុងមួយឆ្នាំឱ្យបាន២ដង គឺក្នុង ៦ ខែម្តង ។ ការប្រជុំនោះនាំឱ្យមានប្រយោជន៍ច្រើនយ៉ាងៈ

-បានជួបមុខគ្នាជារឿយៗ ជាហេតុនាំឱ្យមានសាមគ្គីធម៌រវាងគ្នានិងគ្នា

-បានរំលឹកដាស់តឿន ឬបានពិគ្រោះប្រឹក្សាគ្នាអំពីកិច្ចការផ្សេងៗ ខាងព្រះពុទ្ធសាសនា

-បានដឹកនាំកិច្ចការខាងព្រះពុទ្ធសាសនាដែលមានគ្រប់វត្ត

-ត្រូវធ្វើបញ្ជីវត្តអារាម និងភិក្ខុ សាមណេរគ្រប់ស្រុក ទុកក្នុងសាលាមេគណ ដើម្បីឱ្យបានដឹងថានៅក្នុងខេត្តដែលលោកមេគណជាអ្នកត្រួតត្រា ស្រុកណាមានវត្តប៉ុន្មាន មានភិក្ខុ សាមណេរប៉ុន្មានរូប រួមទាំងអស់ក្នុងមួយខេត្តមានប៉ុន្មានវត្ត ឯចំនួននៅភិក្ខុ សាមណេរ ត្រូវរៀបចំធ្វើជារៀងរាល់ឆ្នាំ ដើម្បីឱ្យបានដឹងថា ក្នុងឆ្នាំណាមានច្រើនឆ្នាំណាមានតិច។

- **អំពីការពិនិត្យមើលកិច្ចការខាងព្រះពុទ្ធសាសនា**

លោកមេគណត្រូវពិនិត្យមើលកិច្ចការ ខាងព្រះពុទ្ធសាសនាគ្រប់ស្រុក ក្នុងខេត្តទាំងមូលដូចតទៅនេះគឺៈ

-កិច្ចការសិក្សាខាងព្រះពុទ្ធសាសនា ដូចជាការសិក្សាក្នុងសាលាពុទ្ធិកបឋមសិក្សា និងសាលាធម្មវិន័យត្រូវពិនិត្យឱ្យដឹងថា ស្រុកណាមានសេចក្តីចម្រើន ស្រុកណាមិនមានសេចក្តីចម្រើន ដែលចម្រើន និងមិនចម្រើនដោយសារហេតុអ្វី លោកមេគណត្រូវប្រឹក្សាជាមួយនឹងអនុគណ រិះរកមធ្យោបាយដើម្បីធ្វើឱ្យការសិក្សា ដែលមិនចម្រើនឱ្យបានចម្រើនឡើងនៃការសិក្សា ដែលបានចម្រើនហើយ ឱ្យបានរឹងរឹតតែចម្រើនជាភិយ្យោភាពឡើងទៀត។

-កិច្ចការដទៃក្រៅអំពីការសិក្សាខាងលើនេះ មានផ្លូវប្រតិបត្តិតាមគន្លងព្រះពុទ្ធសាសនាក្តី ការរៀបចំទីវត្តអារាម

[41] ព្រះសង្ឃប្រកាស ស្តីពី ការកំណត់បែងចែកភារកិច្ចមន្ត្រីសង្ឃ ខេត្ត រាជធានី ស្រុង ខណ្ឌ ក្រុង និងវត្ត លេខ០៩/១១ ស.ន.ក.ជ ថ្ងៃទី ០៧ ខែកុម្ភៈ ព.ស.២៥៥៤ គ.ស.២០១១

ឱ្យបានស្អាតល្អ សមរម្យតាមកាលៈទេសៈក្តី ក៏ឈ្មោះថាជាកិច្ចការខាងព្រះពុទ្ធសាសនាដែរ។ លោកមេគណត្រូវពិនិត្យមើលហើយដឹងកិច្ចការទាំងនោះ ហើយរួមកំលាំងជាមួយនឹងលោកអនុគណ រកមធ្យោបាយធ្វើឱ្យបានចម្រើនឡើងជាបន្តបន្ទាប់។

-កិច្ចការអ្វីក៏ដោយខាងព្រះពុទ្ធសាសនា កាលបើមានការទាក់ទង ជាមួយនឹងរាជរដ្ឋាភិបាល ព្រះមេគណត្រូវយកចិត្តទុកដាក់ ជួយញ៉ាំងកិច្ចការទាំងនោះ ឱ្យបានសម្រេចតាមសមត្ថភាពរបស់ខ្លួន។

-លោកមេគណត្រូវមានកិច្ចមួយទៀត ជាពិសេស គឺត្រូវពិនិត្យមើលដល់កិច្ចការ នៃលោកអនុគណគ្រប់ស្រុក បើឃើញថាលោកអនុគណអង្គណា យកចិត្តទុកដាក់បំពេញមុខការរបស់ខ្លួន ខាងព្រះពុទ្ធសាសនាឱ្យបានចម្រើន ឱ្យបានសុខស្ងប់ក្នុងស្រុករបស់ខ្លួន ត្រូវសរសើរចំពោះព្រះអនុគណនោះដោយលិខិត ឬក៏ដោយផ្ទាល់ បើអនុគណណាខ្ជិលមិនយកចិត្តទុកដាក់ មិនរវល់នឹងកិច្ចការខាងព្រះពុទ្ធសាសនា ក្នុងស្រុករបស់ខ្លួនទេ ត្រូវបន្ទោសចំពោះអនុគណនោះដោយលិខិត ឬដោយផ្ទាល់។ រីឯលិខិតដែលសរសើរ ឬដែលបន្ទោសនោះ ត្រូវចម្លងផ្ញើទៅប្រគេនសម្តេចព្រះសង្ឃនាយក ព្រមទាំងឱ្យលោកអនុគណគ្រប់ស្រុកបានដឹងដោយសម្ងាត់ផង។

- **អំពីការត្រូវធ្វើសេចក្តីរាយការណ៍ខាងព្រះពុទ្ធសាសនា**

លោកមេគណ ត្រូវធ្វើសេចក្តីរាយការណ៍អំពីវត្តអារាម និងកិច្ចការផ្សេងៗ តាមការសិក្សាជាដើម ខាងព្រះពុទ្ធសាសនាក្នុងខេត្តទាំងមូល ដែលបានចម្រើនក្តី មិនចម្រើនក្តី ឬដែលមានហេតុភេទ ឬចម្លែកដូចម្តេចក្តី។ សេចក្តីរាយការណ៍នោះ ទោះតិចក្តី ឬច្រើនក្តីត្រូវធ្វើជាពីរច្បាប់ គឺមួយច្បាប់ទុកនៅសាលាមេគណ និងមួយច្បាប់ទៀតទុកទៅក្រសួងសម្តេចព្រះសង្ឃនាយកតាមរយៈផ្លូវការ។ ក្នុងសេចក្តីរាយការណ៍នោះ ជាពិសេស គឺត្រូវធ្វើឱ្យមានសេចក្តីសរសើរ ឬស្តីបន្ទោសចំពោះអនុគណ ដែលយកចិត្តទុកដាក់ ឬមិនយកចិត្តទុកដាក់ក្នុងកិច្ចការ នៃព្រះពុទ្ធសាសនាផង។ សេចក្តីរាយការណ៍នេះត្រូវធ្វើក្នុង ៦ ខែម្តង។

- **អំពីការទទួលភារកិច្ចជាអ្នករម្ងាប់អធិករណ៍**

លោកមេគណ ត្រូវទទួលភារកិច្ចជាអ្នករម្ងាប់អធិករណ៍ ខាងព្រះពុទ្ធសាសនាក្នុងរាជធានី ខេត្តទាំងមូលដូចតទៅនេះគឺ៖

-ព្រះមេគណត្រូវរំលឹកដាស់តឿន នូវអនុគណគ្រប់ក្រុង ស្រុក ខណ្ឌរបស់ខ្លួន ឱ្យយកចិត្តទុកដាក់ក្នុងការរួបរួមគ្នារវាងសង្ឃ និងសង្ឃឱ្យមានសាមគ្គីនិងគ្នា កុំឱ្យទាស់ទែងគ្នា ត្រូវចេះស្រលាញ់រាប់អានគ្នាដូចបងប្អូន ឱ្យខិតខំប្រឹងទូន្មានតាមផ្លូវធម៌ជាកិច្ចអប់រំព្រះសង្ឃ និងពុទ្ធបរិស័ទក្នុង រាជធានី ខេត្ត។ ឱ្យធុញទ្រាន់នូវការស្អប់ខ្ពើមឈ្លោះប្រកែកបែកបាក់គ្នា ដែលជាហេតុនាំឱ្យមានទុក្ខព្រួយ ហើយឱ្យស្រលាញ់ពេញចិត្តតែនឹងសេចក្តីសុខស្ងប់។

-ប្រសិនបើមានអធិករណ៍ ក្នុងវត្តលោកមេគណផ្ទាល់ លោកមេគណត្រូវប្រតិបត្តិ តាមករណីកិច្ចរបស់ចៅអធិការ បើមានអធិករណ៍ក្នុងស្រុកផ្សេងៗ ដែលលោកអនុគណរម្ងាប់មិនបាន ឬវិនិច្ឆ័យហើយ គូវិវាទនៅតែពុំសុខចិត្តពុំព្រមស្ងប់ ហើយលោកអនុគណបានបញ្ជូនមកលោកមេគណៗ ត្រូវប្រជុំគណៈសង្ឃសាលាមេគណឱ្យជំនុំជម្រះកាត់សេចក្តីដោយយុត្តិធម៌ បើអធិករណ៍នោះអាចរម្ងាប់បាន នៅទីសាលាមេគណក៏ជាការស្រេច។ ប៉ុន្តែ បើគូវិវាទមិនសុខចិត្ត ត្រូវបញ្ជូនសំណុំរឿងនោះ ទៅក្រសួងធម្មការតាមរយៈលោកចៅហ្វាយខេត្ត ដើម្បីប្រគេនមកក្រសួងសម្តេចព្រះសង្ឃនាយក ក្រសួងសម្តេចព្រះសង្ឃយក នឹងដាក់ឱ្យថេរសភាពិនិត្យជំនុំជម្រះដោយយុត្តិធម៌។

- **អំពីការប្រាស្រ័យទាក់ទងនឹងសម្តេចព្រះសង្ឃនាយក**

លោកមេគណដែលត្រូវទាក់ទងនឹងសម្តេចព្រះសង្ឃនាយកផ្ទាល់ ឬក្រសួងព្រះសង្ឃនាយកនោះ ក៏ឃើញថាធ្លាប់ប្រតិបត្តិឱ្យប្លែកជាងមុនៗ នោះឡើយ ដែលមានជាពិសេសខ្លះនោះគឺៈ

-កិច្ចការអ្វីមួយខាងព្រះពុទ្ធសាសនា ឬខាងរាជការ ដែលកើតមានឡើងក្នុងខេត្តជានិច្ច ការទាក់ទងដល់ព្រះមេគណត្រូវសម្រេច បើកិច្ចការនោះបន្តិចបន្តួចទេ ព្រះមេគណយល់ឃើញថាអាចទទួលខុសត្រូវលើខ្លួន ក៏គប្បីសម្រេចដោយខ្លួនឯងបាន ប៉ុន្តែ ត្រូវប្រគេនដំណឹងចំពោះ សម្តេចព្រះសង្ឃនាយកបានជ្រាបផង។ ប្រសិនបើព្រះមេគណគិតមិនយល់ មិនជាក់ច្បាស់ក្នុងចិត្តថា កិច្ចការនោះនឹងប្រព្រឹត្តទៅយ៉ាងណាទេ មិនហ៊ានទទួលការខុសត្រូវលើខ្លួន នោះលោកមេគណមិនត្រូវសម្រេច កិច្ចការនោះដោយផ្ទាល់ខ្លួនឯងទេ ត្រូវសូមយោបល់អំពីសម្តេចព្រះសង្ឃនាយកជាមុនសិន សឹមសម្រេចចិត្តជាខាងក្រោយ។

-ព្រះមេគណត្រូវដឹងថា កិច្ចការទាំងអស់ខាងព្រះពុទ្ធសាសនា ឬកិច្ចការដទៃក្រៅពីព្រះពុទ្ធសាសនា ប៉ុន្តែទាក់ទងដល់ព្រះពុទ្ធសាសនា ទើបកើតមានឡើងក្នុងខេត្ត កិច្ចការទាំងនោះ ទោះបីមេគណអាចសម្រេចបានដោយខ្លួនឯងក៏ដោយ គួរប្រគេនដំណឹងនេះចំពោះ សម្តេចព្រះសង្ឃនាយកបានជ្រាបផង ព្រោះសម្តេចព្រះសង្ឃនាយកកាន់តំណែង ខាងគ្រប់គ្រងព្រះពុទ្ធសាសនា ទទួលការខុសត្រូវក្នុងរឿង ព្រះពុទ្ធសាសនាទាំងមូលនៅក្នុងសមាសភាពរបស់សាលាគណនេះ មន្ត្រីសង្ឃក្នុងឋានានុក្រមនីមួយៗ មានមុខងារ និងតួនាទីដាច់ដោយឡែកពីគ្នា។

❖ **តួនាទី និងភារកិច្ចព្រះបាឡាត់គណ**

**ជាសហការីទី១** របស់មេគណមានតួនាទីជាមេគណស្តីទី នៅពេលព្រះមេគណអវត្តមាន គឺទទួលភារកិច្ច និងសម្រេចកិច្ចការជំនួសព្រះមេគណ បន្ទាប់មករាយការណ៍ប្រគេនមេគណដើម្បីជ្រាប និងស្នើសុំការឯកភាពតាមការដែលខ្លួនបានសម្រេច។

-ទទួលបន្ទុកធម្មវិន័យ និងពុទ្ធិកសិក្សា ចាត់ចែងត្រួតពិនិត្យសាលាធម្មវិន័យ និងសាលាពុទ្ធិកសិក្សាក្នុងរាជធានី ខេត្ត។

- ពិនិត្យ និងសម្របសម្រួលលើការបង្កើតសាលាធម្មវិន័យ និងសាលាពុទ្ធិកសិក្សា។

- ធ្វើអធិការកិច្ចលើការប្រព្រឹត្តិទៅ និងត្រួតពិនិត្យគុណភាពនៃសាលាធម្មវិន័យ និងសាលាពុទ្ធិកសិក្សា។

- គ្រប់គ្រងស្ថិតិសាលាធម្មវិន័យ និងសាលាពុទ្ធិកសិក្សា គ្រូ សមណសិស្ស សិស្ស។

- ជួយសម្រួលកិច្ចការផ្សេងៗទៀត ដែលព្រះមេគណប្រគល់ឱ្យ។

- ធ្វើរបាយការណ៍ស្ដីពីធម្មវិន័យ ពុទ្ធិកសិក្សាប្រគេនព្រះមេគណ។

❖ **តួនាទី និងភារកិច្ចព្រះវិន័យធរគណ**

**ជាសហការីទី២** របស់មេគណ ទទួលបន្ទុកទប់ស្កាត់ដោះស្រាយ និងរម្ងាប់អធិករណ៍មានតួនាទី និងភារកិច្ចដូចខាងក្រោម៖

-ដឹកនាំព្រះសង្ឃប្រតិបត្តិធម៌វិន័យឱ្យបានម៉ត់ចត់ ត្រឹមត្រូវ ខ្ជាប់ខ្ជួន។

-លើកទឹកចិត្តទំនុកបម្រុង និងសម្របសម្រួលផ្លូវច្បាប់ ដល់កុលបុត្រដែលមានសទ្ធាចង់បួស ព្រមទាំងដាស់តឿនលើការប្រតិបត្តិធម៌វិន័យ។

-ចាត់វិធានការណ៍ការពារ និងទប់ស្កាត់ការកើតឡើងនូវអធិករណ៍ផ្សេងៗ។

-ទទួលឯកសារសំណុំរឿង ដែលសាលាអនុគណបញ្ជូនមក ហើយសម្របសម្រួល និងរម្ងាប់អធិករណ៍នោះ។ ក្នុងករណីដែលមិនអាចសម្របសម្រួលបាន ត្រូវរៀបចំឯកសារសំណុំរឿងអធិករណ៍ ដាក់ប្រគេនសាលាគណ។

-គ្រប់គ្រងឯកសារពាក់ព័ន្ធសំណុំរឿងអធិករណ៍ផ្សេងៗ។

-ធ្វើរបាយការណ៍ស្ដីពីការកើតឡើង និងការរម្ងាប់អធិករណ៍ប្រគេនព្រះមេគណ។

❖ **តួនាទី និងភារកិច្ចព្រះធម្មធរគណ**

**ជាសហការីទី៣** របស់មេគណមានតួនាទី និងភារកិច្ចដូចខាងក្រោម៖

-ទទួលបន្ទុកការងារអប់រំ ផ្សព្វផ្សាយ ប្រមូលព័ត៌មានទាក់ទងនឹងការងារព្រះពុទ្ធសាសនា។

-រៀបចំកម្មវិធីអប់រំ ផ្សព្វផ្សាយ សីលធម៌ព្រះពុទ្ធសាសនា តាមមធ្យោបាយនានា។

-ផ្សព្វផ្សាយព័ត៌មាន ដែលទទួលបានពីគណៈសង្ឃនាយកទៅសាលាអនុគណ។

-គ្រប់គ្រងលើការផ្សព្វផ្សាយធម៌វិន័យ (ការសំដែងធម៌ទេសនា) តាមប្រព័ន្ធផ្សព្វផ្សាយ និងការបោះពុម្ពផ្សាយសៀវភៅនានា ដែលទាក់ទងនឹងព្រះពុទ្ធសាសនា។

- ជាឃោសកសនិកសាលាគណ។

- ធ្វើរបាយការណ៍ស្តីពីការអប់រំ ផ្សព្វផ្សាយប្រគេនព្រះមេគណ។

❖ **តួនាទី និងភារកិច្ចព្រះសមុហ៍គណ**

**ជាសហការីទី៤** របស់ព្រះមេគណមានតួនាទី និងភារកិច្ចដូចខាងក្រោម៖

-ទទួលបន្ទុកការងារស្ថិតិ ប្រមូលចងក្រងស្ថិតិវត្តអារាម ព្រះសង្ឃ អាចារ្យគណៈកម្មការវត្ត ដូនជីតាជី និងសិស្ស និស្សិតដែលស្នាក់នៅក្នុងវត្ត។

-ប្រមូលចងក្រងប្រវត្តិវត្តនានាទូទាំងរាជធានី។

-គ្រប់គ្រងឯកសារស្ថិតិ។

-ធ្វើផែនការអភិរក្សសំណង់ ស្ថាបត្យកម្មបុរាណ បេតិកភណ្ឌ ក្បាច់ចម្លាក់ព្រះពុទ្ធសាសនា។

-ធ្វើរបាយការណ៍ស្តីពីស្ថិតិប្រគេនព្រះមេគណ។

❖ **តួនាទី និងភារកិច្ចលេខាធិការគណ**

ជាជំនួយការសាលាគណ មានភារកិច្ចដូចខាងក្រោម៖

-តាក់តែងលិខិតបទដ្ឋាននានាសម្រាប់សាលាគណ។

-គ្រប់គ្រងលិខិតចេញ ចូល (ចុះលេខ និងកាលបរិច្ឆេទ) និងបញ្ជូនទៅតាមជំនាញ។

-ថែរក្សាទុកដាក់ឯកសារ លិខិតបទដ្ឋានផ្សេងៗ របស់សាលាគណ។

-ធ្វើកំណត់ហេតុអង្គប្រជុំក្នុងសាលាគណ។

-ធ្វើរបាយការណ៍សម្រាប់សាលាគណ។

❖ **តួនាទី និងភារកិច្ចរបស់ព្រះគ្រូអនុគណ ក្រុង-ស្រុក-ខណ្ឌ និងសហការី**

ព្រះមហាថេរអង្គណាមួយ ដែលបានទទួលការតែងតាំងជាព្រះអនុគណ ដោយត្រឹមត្រូវតាមច្បាប់រួចហើយ ត្រូវបំពេញតួនាទីរបស់ខ្លួនក្នុងឋានៈ ជាព្រះគ្រូអនុគណរួមជាមួយនឹង គណៈសង្ឃដែលជាសហការី។ ព្រះអនុគណនីមួយៗ មានអំណាចត្រួតត្រាព្រមទាំងចាត់ការផ្សេងៗ ខាងព្រះពុទ្ធសាសនាមានកម្រិតព្រំដែនតែក្នុង ក្រុង-ស្រុក ខណ្ឌ នីមួយៗ របស់ខ្លួនត្រូវបំពេញភារកិច្ចដូចខាងក្រោម។

-ដឹកនាំ គ្រប់គ្រងលើចៅអធិការគ្រប់វត្ត

-ចាត់ចែង និងពិនិត្យមើលកិច្ចការខាងព្រះពុទ្ធសាសនា

-បំពេញតួនាទីជាមេដឹកនាំប្រកបដោយនាយកធម៌

-ជាអធិបតី និងដឹកនាំកិច្ចប្រជុំមន្ត្រីសង្ឃ ក្រុង-ស្រុក-ខណ្ឌ និងវត្ត

-ចុះហត្ថលេខាលើឯកសារ និងលិខិតស្នាមផ្សេងៗជាផ្លូវការ

-ស្នើតែងតាំងសហការីអនុគណ និងមន្ត្រីសង្ឃវត្ត

-ប្រាស្រ័យទាក់ទងជាមួយនឹងព្រះមេគណ

-ធ្វើទំនាក់ទំនង និងសហការល្អជាមួយអាជ្ញាធរ និងស្ថាប័នពាក់ព័ន្ធ

-ទទួលជួប និងទំនាក់ទំនងជាមួយភ្ញៀវនានា

-ជួយកិច្ចការសង្គមដែលអាចជួយបាន

-បំពេញកិច្ចការផ្សេងៗទៀត ដែលព្រះមេគណដាក់ឱ្យ

-ការគ្រប់គ្រងត្រាសាលាគណ ជាឆន្ទានុសិទ្ធិរបស់ព្រះអនុគណ

-ធ្វើរបាយការណ៍តាមរបបកំណត់ និងរបាយការណ៍ជំនាញប្រគេនសាលាគណ។

- **អំពីការត្រួតត្រាលើលោកចៅអធិការគ្រប់វត្ត**

ព្រះគ្រូអនុគណក្នុងស្រុកនីមួយៗ ត្រូវត្រួតត្រាលើលោកចៅអធិការគ្រប់វត្តក្នុង ក្រុង-ស្រុក-ខណ្ឌ ទាំងមូលដូចតទៅនេះគឺ៖

-ត្រូវរំលឹកដាស់តឿនលោកចៅអធិការគ្រប់វត្ត ឱ្យប្រតិបត្តិតាមតួនាទីរបស់ខ្លួន កុំឱ្យធ្វេសប្រហែស

-ត្រូវនិមន្តព្រះគ្រូចៅអធិការគ្រប់វត្តទាំងអស់ មកប្រជុំនៅទីវត្តអនុគណឱ្យបាន ២ ដងក្នុងមួយឆ្នាំ គឺ ៦ ខែម្តង ការប្រជុំនោះនាំឱ្យមានប្រយោជន៍ច្រើនយ៉ាងគឺ៖

-បានជួបមុខគ្នារឿយៗ ជាមូលហេតុនាំឱ្យមានសាមគ្គីធម៌រវាងគ្នា និងគ្នា

-បានរំលឹកដាស់តឿន ឬបានពិគ្រោះប្រឹក្សាគ្នាពីកិច្ចការផ្សេងៗ ខាងព្រះពុទ្ធសាសនា

-បានដឹងកិច្ចការខាងព្រះពុទ្ធសាសនាដែលមានគ្រប់វត្ត

-ត្រូវធ្វើបញ្ជីវត្តទុកនៅសាលាអនុគណ ដើម្បីឱ្យដឹងថាក្នុង ក្រុង-ស្រុក-ខណ្ឌ ដែលលោកគ្រូអនុគណត្រួតត្រាមានវត្តប៉ុន្មាន ក្នុងវត្តនីមួយៗ មានភិក្ខុ-សាមណេររួមទាំងអស់ប៉ុន្មាន? ឯស្ថិតិចំនួនភិក្ខុ-សាមណេរត្រូវសើរើធ្វើរាល់ឆ្នាំ ដើម្បីឱ្យដឹងថាឆ្នាំណាមានតិច ឆ្នាំណាមានច្រើន។

- **អំពីការពិនិត្យមើលកិច្ចការខាងព្រះពុទ្ធសាសនា**

ព្រះគ្រូអនុគណត្រូវពិនិត្យមើល កិច្ចការខាងព្រះពុទ្ធសាសនា ក្នុងស្រុកដែលព្រះគ្រូអនុគណ ត្រូវត្រួតត្រាដូចតទៅគឺ៖

-កិច្ចការខាងព្រះពុទ្ធសាសនា ដូចជាការសិក្សាក្នុងពុទ្ធិកបឋមសិក្សា និងសាលាធម្មវិន័យ ត្រូវត្រួតពិនិត្យមើលឱ្យដឹងថា នៅវត្តណាមានសេចក្តីចម្រើន វត្តណាមិនចម្រើន ដែលចម្រើន និងមិនចម្រើន ដោយសារមូលហេតុអ្វី លោកគ្រូអនុគណត្រូវរួបរួមជាមួយ នឹងលោកចៅអធិការវត្តនោះៗ រិះរកមធ្យោបាយដើម្បីឱ្យការសិក្សាដែលមិនចម្រើន ឱ្យបានរីកចម្រើនឡើង ការសិក្សាដែលបានចម្រើនហើយ ឱ្យបានរឹងរឹតតែចម្រើនជាភិយ្យោភាពឡើងទៀត។

-បើវត្តណាពុំទាន់មានការសិក្សានៅឡើយ លោកគ្រូអនុគណត្រូវរកមធ្យោបាយពន្យល់ ឱ្យកើតមានការសិក្សាក្នុងវត្តនោះឡើង ប្រសិនបើភិក្ខុក្នុងវត្តនោះមានភិក្ខុសង្ឃច្រើន និងពុទ្ធបរិស័ទជើងវត្តនោះមានច្រើនដែរ វៀរលែងតែវត្តណាមួយជាវត្តតូច មានភិក្ខុសង្ឃបន្តិចបន្តួចទាំងពុទ្ធបរិស័ទជើងវត្ត ក៏មានបន្តិចបន្តួចដែរ។

-ចំពោះផ្លូវប្រតិបត្តិ ក្នុងកន្លងព្រះពុទ្ធសាសនា ឬការរៀបចំទីវត្តអារាមក៏ឈ្មោះថា ជាកិច្ចការខាងព្រះពុទ្ធសាសនាដែរ លោកគ្រូអនុគណត្រូវពន្យល់ ដល់លោកគ្រូចៅអធិការទាំងឡាយ ឱ្យយកចិត្តទុកដាក់ដឹកនាំភិក្ខុសាមណេរ ក្នុងទីវត្តឱ្យប្រតិបត្តិឱ្យបានត្រឹមត្រូវតាមពុទ្ធសាសនា ព្រមទាំងជួយដឹកនាំលោកចៅអធិការនោះ ឱ្យចេះរៀបចំទីវត្តអារាមឱ្យបានសមរម្យ ទាំងឱ្យបានស្អាតបាត សមជាកន្លែងដម្កល់ព្រះពុទ្ធសាសនា គួរឱ្យជនទាំងឡាយចូលទៅកើតសេចក្តីជ្រះថ្លា។

-កិច្ចការឯទៀតខាងព្រះពុទ្ធសាសនា កាលបើមានការទាក់ទងនឹងរាជរដ្ឋាភិបាល ក៏ត្រូវលោកអនុគណយកចិត្តទុកដាក់ ជួយញ៉ាំងកិច្ចការទាំងនោះ ឱ្យបានសម្រេចតាមសមត្ថភាពរបស់ខ្លួន។

- **អំពីការធ្វើសេចក្តីរាយការណ៍ខាងព្រះពុទ្ធសាសនា**

ព្រះគ្រូអនុគណ ត្រូវធ្វើសេចក្តីរាយការណ៍ អំពីការប្រព្រឹត្តទៅ នៃព្រះពុទ្ធសាសនាក្នុងស្រុកទាំងមូល ដូចជាវត្តអារាម និងការសិក្សាជាដើម ដែលចម្រើនក្តី មិនចម្រើនក្តី ឬដែលមានហេតុភេទដ៏ចំឡែកដូចម្តេចក្តី។ សេចក្តីរាយការណ៍នោះ តិចក្តីច្រើនក្តី ត្រូវធ្វើពីរច្បាប់ គឺ ១ ច្បាប់ទុកនៅសាលាអនុគណ និង ១ ច្បាប់ទៀតជូនទៅព្រះមេគណសម្រាប់ទុកនៅសាលាគណក្នុង ៦ ខែម្តង ក្នុង១ឆ្នាំត្រូវធ្វើពីរដង។

- **អំពីការទទួលភារកិច្ចជាអ្នករម្ងាប់អធិករណ៍ខាងព្រះពុទ្ធសាសនា**

ព្រះគ្រូអនុគណដែលត្រូវទទួលភារកិច្ច ជាអ្នករម្ងាប់អធិករណ៍ ខាងព្រះពុទ្ធសាសនាក្នុងស្រុកទាំងមូល ត្រូវធ្វើដូចតទៅនេះគឺ៖

ក-ត្រូវរំលឹកដាស់តឿនព្រះសង្ឃក្នុងស្រុកទាំងមូល មានលោកគ្រូចៅអធិការវត្តជាដើម ឱ្យចេះអត់ឱនឱ្យគ្នា ចេះរួបរួមគ្នាឱ្យមាន សាមគ្គីធម៌រវាងគ្នានិងគ្នា កុំឱ្យទាស់គ្នា ឱ្យចេះស្រឡាញ់រាប់អានគ្នាដូចបងប្អូន ឱ្យស្អប់ខ្ពើមធុញទ្រាន់នឹងការឈ្លោះប្រកែកបែកបាក់គ្នា ដែលជាហេតុនាំឱ្យមានទុក្ខ ឱ្យចេះស្រឡាញ់ពេញចិត្តនឹងសេចក្តីសុខស្ងប់។

ខ-ប្រសិនបើមានអធិករណ៍ ក្នុងវត្តព្រះអនុគណផ្ទាល់ អនុគណត្រូវប្រតិបត្តិតាម ករណីកិច្ចរបស់ចៅអធិការ បើមានរឿងអធិករណ៍ក្នុងវត្តដទៃ ដែលចៅអធិការរម្ងាប់មិនបាន ហើយគេបញ្ជូនមកត្រូវលោកអនុគណប្រជុំគណៈសង្ឃសាលាអនុគណ ជំនុំជំរះផ្សះផ្សាឱ្យសះនឹងគ្នា បើមិនបានសម្រេចត្រូវជំនុំជំរះ វិនិច្ឆ័យកាត់សេចក្ដី ដោយយុត្តិធម៌ បើគូវិវាទសុខចិត្តក៏ជាការស្រេច បើគូវិវាទមិនសុខចិត្ត ត្រូវបញ្ជូនសំណុំរឿងអធិករណ៍នោះ ទៅលោកមេគណដើម្បីឱ្យគណៈសង្ឃនៅសាលាមេគណជំនុំជំរះតទៅទៀត។

គ-របៀបជំនុំជំរះអធិករណ៍នីមួយៗ ត្រូវព្រះគ្រូអនុគណបំពេញលក្ខន្តិកៈ មានការធ្វើកំណត់ហេតុជាដើមឱ្យបានគ្រប់គ្រាន់។

- **ការប្រាស្រ័យទាក់ទងនិងព្រះមេគណ**

ព្រះគ្រូអនុគណ ត្រូវមានការប្រាស្រ័យទាក់ទងនឹងព្រះមេគណ ដូចជារាជការខាងអាណាចក្រដែរ គឺចៅហ្វាយស្រុកត្រូវប្រាស្រ័យទាក់ទង នឹងចៅហ្វាយខេត្តដូច្នោះដែរគឺៈ

ក-ត្រូវស្ដាប់បង្គាប់ព្រះមេគណជាដរាប កាលបើលោកមេគណមានបង្គាប់តាមផ្លូវសាសនា ឬក៏តាមផ្លូវការវៀរលែងតែ ព្រះមេគណមានបង្គាប់ក្នុងកិច្ចការផ្ទាល់ខ្លួន ដែលជាការខុសអំពីផ្លូវច្បាប់។

ខ-បើកិច្ចការអ្វីមួយខាងសាសនា ឬខាងរាជការជាកិច្ចការអនុគណត្រូវសម្រេច បើកិច្ចការនោះបន្តិចបន្តួច ព្រះគ្រូអនុគណអាចសម្រេចបានដោយខ្លួនឯង បើកិច្ចនោះធំដុំព្រះគ្រូអនុគណត្រូវស្នើយោបល់ឬពិគ្រោះផ្ទាល់ជាមួយនឹងព្រះមេគណជាមុនសិនទើបសម្រេចបាន។

គ-ព្រះគ្រូអនុគណ ត្រូវតែរួបរួមជាមួយ នឹងព្រះមេគណយ៉ាងជិតស្និទ្ធ ដើម្បីកុំឱ្យមានគំនិតបែកចេញពីព្រះមេគណ ត្រូវធ្វើការរួបរួមគ្នា ទើបកិច្ចការខាងព្រះពុទ្ធសាសនា និងមានសេចក្ដីចម្រុងចម្រើនរុងរឿងឡើងបាន។

- **ការជួយកិច្ចការរដ្ឋដែលអាចជួយបាន**

ព្រះគ្រូអនុគណត្រូវដឹងថា ព្រះពុទ្ធសាសនាជាសាសនារបស់រដ្ឋ គឺជាសាសនាដែលប្រជាពលរដ្ឋក្នុងប្រទេសស្ទើរតែទាំងអស់ ទទួលយកថាជាសាសនា ដែលខ្លួនត្រូវគោរពត្រូវកាន់តាម។ ដូច្នេះ ព្រះពុទ្ធសាសនា ជាសាសនាត្រូវជាប់ទាក់ទងជាមួយនឹងរដ្ឋ បើរដ្ឋ ឬប្រទេសធ្លាក់ចុះដុនដាប ទន់ខ្សោយឬក្រីក្រ ឬក៏ធ្លាក់ចុះទៅជាទាសភាពរបស់ប្រទេស ព្រះពុទ្ធសាសនាក៏ធ្លាក់ ចុះអាប់ឱនទៅជាមួយដែរ បើរដ្ឋ ឬប្រទេសរុងរឿងចម្រើនឡើង ព្រះពុទ្ធសាសនាក៏រុងរឿងចម្រើនឡើងដែរ។

ដូច្នេះ កិច្ចការទាំងឡាយដែលរាជរដ្ឋាភិបាល បានចាត់ចែងធ្វើឱ្យកើតមានឡើង ដើម្បីឱ្យប្រទេសបានចម្រើនរុងរឿង លោកអនុគណត្រូវតែយកចិត្តទុកដាក់ជាពិសេស ជួយចំពោះកិច្ចការណាដែលឥតទាស់ខុសនឹងច្បាប់

ព្រះពុទ្ធសាសនា ដែលពួកបព្វជិតអាចជួយបាន ត្រូវតែជួយកិច្ចកសាងសាលាសិក្សាជាដើម។ វៀរលែងកិច្ចការខ្លះ ដែលមានពុទ្ធបញ្ញត្តិ ហាមមិនឱ្យបព្វជិតធ្វើនោះទើបមិនគួរធ្វើ ប៉ុន្តែ មិនត្រូវហាមប្រាមគេមិនឱ្យធ្វើឡើយ ដោយហេតុថាកិច្ចការទាំងនោះផ្ទុយនឹងពុទ្ធប្បញ្ញត្តិមែន។ ប៉ុន្តែ កិច្ចការដែលរាជរដ្ឋាភិបាលបង្កើត ឱ្យមានដើម្បីឱ្យបានចម្រុងចម្រើនដល់ប្រទេស។

❖ **តួនាទី និងភារកិច្ចព្រះវិន័យធរអនុគណ**

ទទួលបន្ទុកការងារទប់ស្កាត់ ដោះស្រាយ និងរម្ងាប់អធិករណ៍មានភារកិច្ចដូចខាងក្រោម៖

-ដឹកនាំព្រះសង្ឃប្រតិបត្តិធម៌វិន័យ ឱ្យបានហ្មត់ចត់ ត្រឹមត្រូវ និងខ្ជាប់ខ្ជួន។

-លើកទឹកចិត្ត ទំនុកបម្រុង និងសម្របសម្រួលផ្លូវច្បាប់ ដល់កុលបុត្រដែលមានសទ្ធាចង់ចូលបួស ព្រមទាំងដាស់តឿនលើការប្រតិបត្តិធម៌វិន័យ។

-ចាត់វិធានការការពារ និងទប់ស្កាត់ការកើតឡើងនូវអធិករណ៍

-ទទួលឯកសារសំណុំរឿង ដែលវត្តនានាបញ្ជូនមក ហើយសម្របសម្រួល និងរម្ងាប់អធិករណ៍នោះ។ ក្នុងករណីដែលមិនអាចសម្របសម្រួលបាន ត្រូវរៀបចំឯកសារសំណុំរឿងអធិករណ៍ ដាក់ប្រគេនសាលាគណ។

-គ្រប់គ្រងឯកសារពាក់ព័ន្ធ សំណុំរឿងអធិករណ៍ផ្សេងៗ

-បំពេញកិច្ចការផ្សេងៗ ទៀតដែលព្រះអនុគណដាក់ឱ្យ

-ធ្វើរបាយការណ៍ស្តីពីការកើតឡើង និងការរម្ងាប់អធិករណ៍ប្រគេនព្រះអនុគណ។

❖ **តួនាទី និងភារកិច្ចព្រះធម្មធរអនុគណ**

ទទួលបន្ទុកធម្មវិន័យ និងពុទ្ធិកសិក្សាចាត់ចែង និងត្រួតពិនិត្យសាលាធម្មវិន័យ និងសាលាពុទ្ធិកសិក្សាក្នុងក្រុង-ស្រុក-ខណ្ឌ។

-សម្របសម្រួលក្នុងការបង្កើតសាលាធម្មវិន័យ និងសាលាពុទ្ធិកសិក្សា

-ធ្វើអធិការកិច្ចលើការប្រព្រឹត្តទៅ និងត្រួតពិនិត្យគុណភាពនៃសាលាធម្មវិន័យ និងសាលាពុទ្ធិកសិក្សា

-គ្រប់គ្រងស្ថិតិសាលាធម្មវិន័យ និងសាលាពុទ្ធិកសិក្សា គ្រូ សមណសិស្ស-សិស្ស

-ធ្វើរបាយការណ៍ស្តីពីធម្មវិន័យ ពុទ្ធិកសិក្សាប្រគេនព្រះគ្រូអនុគណ

-ទទួលបន្ទុកការងារអប់រំ ផ្សព្វផ្សាយ សីលធម៌ព្រះពុទ្ធសាសនាតាមមធ្យោបាយនានា

-ផ្សព្វផ្សាយព័ត៌មាន ដែលទទួលបានពីគណៈសង្ឃនាយកទៅសាលាអនុគណ

-គ្រប់គ្រងលើការផ្សព្វផ្សាយធម៌វិន័យ (ការសម្តែងធម៌ទេសនា) តាមប្រព័ន្ធផ្សព្វផ្សាយ និងការបោះពុម្ពផ្សាយ

-ជាឃោសនិកសាលាគណ

-ធ្វើរបាយការណ៍ស្តីពីការ អប់រំ ផ្សព្វផ្សាយប្រគេនព្រះមេគណ។

❖ **តួនាទី និងភារកិច្ចព្រះសមុហ៍អនុគណ**

-ទទួលបន្ទុកការងារស្ថិតិ ប្រមូលចងក្រងស្ថិតិ វត្តអារាម ព្រះសង្ឃ អាចារ្យ គណៈកម្មការវត្ត ដូនជីតាជី និង សិស្ស-និស្សិតដែលស្នាក់នៅក្នុងវត្ត។

-ប្រមូលចងក្រងប្រវត្តិរូបនានាទូទាំង ក្រុង-ស្រុក-ខណ្ឌ

-គ្រប់គ្រងឯកសារស្ថិតិ

-ធ្វើផែនការអភិរក្សសំណង់-ស្ថាបត្យកម្មបុរាណ បេតិកភណ្ឌ ក្បាច់ចម្លាក់ព្រះពុទ្ធសាសនា ដែលមាននៅតាម វត្តអារាមនានា

-ប្រមូលព័ត៌មានដែលទាក់ទង នឹងកិច្ចការព្រះពុទ្ធសាសនា

-រៀបចំកម្មវិធីអប់រំ ផ្សព្វផ្សាយ សីលធម៌ព្រះពុទ្ធសាសនាតាមមធ្យោបាយនានា

-ផ្សព្វផ្សាយព័ត៌មាន ដែលទទួលបានពីសាលាអនុគណទៅតាមវត្តនានា

-គ្រប់គ្រងលើការផ្សព្វផ្សាយធម៌វិន័យ (ការសម្តែងធម៌ទេសនា) តាមប្រព័ន្ធផ្សព្វផ្សាយ និងការបោះពុម្ពផ្សាយ

-ជាឃោសនិកសាលាអនុគណ

-ធ្វើរបាយការណ៍ស្តីពីស្ថិតិ ការអប់រំ ផ្សព្វផ្សាយ ប្រគេនព្រះអនុគណ

❖ **តួនាទី និងភារកិច្ចលេខាធិការព្រះអនុគណ**

ជាជំនួយការសាលាអនុគណមានភារកិច្ចដូចខាងក្រោមៈ

-តាក់តែងលិខិតបទដ្ឋាននានា សម្រាប់សាលាអនុគណ

-គ្រប់គ្រងលិខិតចេញ-ចូល (ចុះលេខ និងកាលបរិច្ឆេទ) និងបញ្ជូនទៅតាមជំនាញ

-ថែរក្សាទុកដាក់ឯកសារ លិខិតបទដ្ឋានផ្សេងៗ របស់សាលាអនុគណ

-ធ្វើកំណត់ហេតុអង្គប្រជុំ ក្នុងសាលាអនុគណ

-រៀបចំកម្មវិធីរបស់ព្រះអនុគណ

-ធ្វើរបាយការណ៍សម្រាប់សាលាអនុគណ។

❖ **តួនាទី និងភារកិច្ចគណៈសង្ឃវត្ត និងសហការី**

- **តួនាទី និងភារកិច្ចព្រះចៅអធិការ**

ព្រះចៅអធិការ ជាអធិបតីសង្ឃវត្តត្រូវបំពេញភារកិច្ចដូចខាងក្រោម៖

-ដឹកនាំ គ្រប់គ្រងវត្តទាំងមូល

-គ្រប់គ្រងភិក្ខុ សាមណេរ ព្រះសង្ឃ អាចារ្យគណៈកម្មការវត្ត ដូនជីតាជី និងសិស្ស-និស្សិតដែលស្នាក់នៅក្នុងវត្ត។

-រៀបចំចាត់ចែងវត្តអារាមឱ្យមានសណ្តាប់ធ្នាប់ របៀបរៀបរយ និងការរីកចម្រើន

-បំពេញតួនាទីជាអ្នកដឹកនាំ ប្រកបដោយនាយកធម៌ ព្រមទាំងចេះបាតិមោក្ខបាលីផង

-ជាអធិបតី និងដឹកនាំកិច្ចប្រជុំកិច្ចការវត្ត

-ចុះហត្ថលេខាលើឯកសារ និងលិខិតស្នាមផ្សេងៗជាផ្លូវការ

-គ្រប់គ្រងថវិកាវត្ត ដោយមានការសហការពីគណៈកម្មការវត្ត

-ដឹកនាំភិក្ខុ សាមណេរ ក្នុងវត្តធ្វើសង្ឃកម្ម និងកិច្ចវត្ត

-ដឹកនាំរៀបចំពិធីបុណ្យនានាក្នុងវត្ត

-លើកទឹកចិត្តទំនុកបម្រុង និងសម្របសម្រួលផ្លូវច្បាប់ដល់កុលបុត្រ ដែលមានសទ្ធាចង់បួសព្រមទាំងដាស់តឿនលើការប្រតិបត្តិធម៌វិន័យ។[42]

-ជម្រុញលើកទឹកចិត្តនិងទំនុកបម្រុងភិក្ខុសាមណេរចូលសិក្សាសាលាធម្មវិន័យនិងសាលាពុទ្ធិកសិក្សា

-ជួយសហការបង្កើត និងទំនុកបម្រុងសាលាធម្មវិន័យ និងសាលាពុទ្ធិកសិក្សា

-ជួយសម្រួលដល់ការរស់នៅរបស់ដូនជី តាជី សិស្ស-និស្សិត

-ប្រាស្រ័យទាក់ទងនឹងព្រះអនុគណ

-ធ្វើទំនាក់ទំនង និងសហការល្អជាមួយអាជ្ញាធរ និងស្ថាប័នពាក់ព័ន្ធ

-ទទួលជួប និងទំនាក់ទំនងជាមួយភ្ញៀវនានា

-ប្រាស្រ័យសុខទុក្ខជាមួយពុទ្ធបរិស័ទ និងជួយឧបត្ថម្ភដល់ប្រជាពលរដ្ឋ ដែលជួបការលំបាកនឹងគ្រោះមហន្តរាយផ្សេងៗ

-ជួយកិច្ចការសង្គមដែលអាចជួយបាន និងបំពេញកិច្ចការផ្សេងៗទៀត ដែលព្រះអនុគណដាក់ឱ្យ

-ធ្វើរបាយការណ៍តាមរបបកំណត់ និងរបាយការណ៍ជំនាញប្រគេនសាលាអនុគណ។

[42] ការផ្សាយពុទ្ធសាសនបណ្ឌិត្យ ករណីកិច្ចនៃ ចៅអធិការ អនុគណ និងមេគណ ព.ស.២៥៣៧ ទំព័រ ០៥

- **តួនាទី និងភារកិច្ចគ្រូសូត្រស្តាំ**

ជាជំនួយការព្រះចៅអធិការ មានតួនាទីជាចៅអធិការស្តីទី នៅពេលចៅអធិការអវត្តមាន ទទួលភារកិច្ច និងសម្រេចកិច្ចការជំនួសចៅអធិការ។ បន្ទាប់មករាយការណ៍ប្រគេនចៅអធិការដើម្បីជ្រាប និងស្នើសុំការឯកភាពតាមការដែលខ្លួនបានសម្រេចតាមគតិធម៌វិន័យ និងច្បាប់រដ្ឋ។

-ទទួលបន្ទុកការងារសាងសង់ និងគរុភ័ណ្ឌ ធ្វើផែនការលើកគម្រោង កសាង ថែទាំ ជួសជុលសមិទ្ធផលនានាក្នុងវត្តដាក់ប្រគេនគណៈសង្ឃវត្តសម្រេច។

-សិក្សាទីតាំង គម្រោងប្លង់សាងសង់ រចនាបទ ក្បូរក្បាច់ចម្លាក់តាមប្លង់មេ (នគរូបនីយកម្ម)

-ត្រួតពិនិត្យបច្ចេកទេសដំណើរការសាងសង់ និងគុណភាពសំណង់

-ចាត់វិធានការការពារ និងទប់ស្កាត់ការកើតឡើងនូវអធិករណ៍ក្នុងវត្ត

-សម្របសម្រួលវិវាទអធិករណ៍ ដែលកើតឡើងជាយថាហេតុ។ ក្នុងករណីដែលមិនអាចសម្របសម្រួលបានត្រូវរៀបចំឯកសារ សំណុំរឿងអធិករណ៍ដាក់ប្រគេនគណៈសង្ឃវត្ត

-គ្រប់គ្រងឯកសារពាក់ព័ន្ធសំណុំរឿងអធិករណ៍ផ្សេងៗ

-ថែរក្សាគរុភ័ណ្ឌវត្ត ដោយចុះបញ្ជីសារពើភ័ណ្ឌ

-ថែរក្សាសណ្តាប់ធ្នាប់ និងសុវត្ថិភាពក្នុងវត្ត

-បំពេញកិច្ចការផ្សេងៗទៀត ដែលព្រះចៅអធិការវត្តដាក់ឱ្យ។

- **តួនាទី និងភារកិច្ចគ្រូសូត្រឆ្វេង**

ជាជំនួយការព្រះចៅអធិការ ទទួលបន្ទុកការងារអប់រំ ផ្សព្វផ្សាយ និងសោភ័ណភាពមានភារកិច្ចដូចខាងក្រោមៈ

-ដឹកនាំព្រះសង្ឃក្នុងវត្តប្រតិបត្តិធម៌វិន័យ ឱ្យបានហ្មត់ចត់ ត្រឹមត្រូវ ខ្ជាប់ខ្ជួន

-បង្រៀនធម៌វិន័យដល់ភិក្ខុ សាមណេរ ដូនជីតាជី និងសិស្ស-និស្សិតក្នុងវត្ត

-ផ្តល់ការអប់រំដល់ ភិក្ខុ សាមណេរ សិស្ស-និស្សិត និងយុវជននូវសីលធម៌ សុជីវធម៌ ចរិយាមាយាទល្អក្នុងការរស់នៅ។

-ផ្សព្វផ្សាយព័ត៌មានដែលទាក់ទង នឹងព្រះពុទ្ធសាសនាតាមមធ្យោបាយនានា

-តាក់តែងលិខិតបទដ្ឋាននានាសម្រាប់វត្ត

-រៀបចំពិធីបុណ្យទានផ្សេងៗ

-ថែរក្សាសោភ័ណភាព អនាម័យ និងបរិស្ថានវត្ត

-ថែរក្សា និងដាំដើមឈើក្នុងបរិវេណវត្ត

-រៀបចំកម្មវិធីរបស់ព្រះចៅអធិការ

-បំពេញកិច្ចការផ្សេងៗទៀត ដែលព្រះចៅអធិការដាក់ឱ្យ។

- **តួនាទី និងភារកិច្ចព្រះវិន័យធរវត្ត**

ជាសហការីទី ៣ របស់ព្រះចៅអធិការ មានតួនាទី និងភារកិច្ចជាអ្នករម្ងាប់អធិករណ៍ និងជំនុំជំរះរឿង ដោះស្រាយវិវាទសង្ឃ ដែលកើតឡើងក្នុងវត្តរបស់ខ្លួន បន្ទាប់មករាយការណ៍មកចៅអធិការ ដែលជាប្រធានរបស់ខ្លួន ដើម្បីជ្រាប និងស្នើសុំការឯកភាពលើកិច្ចការរបស់ខ្លួនដែលបានធ្វើ ជាលទ្ធផលយ៉ាងណានោះ ស្រេចហើយលើចៅអធិការជាអ្នកសម្រេចតាមគតិធម៌វិន័យ (ច្បាប់)។

- **តួនាទី និងភារកិច្ចលេខាវត្ត**

ជាសហការីទី ៤ របស់ព្រះចៅអធិការ មានតួនាទី និងភារកិច្ចជំនួយការឱ្យគណៈសង្ឃវត្តទាំងមូល គឺនៅពេលដែលកិច្ចការវត្តមានមកដល់កាលណា លេខាវត្តត្រូវជួយធ្វើកិច្ចការនោះជាមួយចៅអធិការ និងសហការីរបស់ចៅអធិការទាំងអស់មិនថាអង្គជាអង្គណាទេ។ កិច្ចការនោះមានតាំងពីកិច្ចការងាររដ្ឋបាល ក្រដាសស្នាម កត់ត្រា និងលិខិតចេញ លិខិតចូលជាដើម។ល។

សូមបញ្ជាក់ថា វិន័យធរវត្ត និងលេខាវត្តទើបតែមានក្នុងសម័យនេះទេ សម័យមុនមិនមានទេ ព្រោះសម្តេចសង្ឃរាជព្រះអង្គទ្រង់យល់ឃើញថា ភារកិច្ច និងកិច្ចការវត្តបច្ចុប្បន្ននេះ កាន់តែមានច្រើនឡើងៗ។ ដូច្នេះ ត្រូវការមន្ត្រីសង្ឃបន្ថែម ដើម្បីជួយសម្រួល និងបន្ធូរការងារសំដៅជម្រុញធ្វើយ៉ាងណា ឱ្យមានការរីកចម្រើនដល់វត្តអារាម។

### ២.២.៦.តួនាទី និងភារកិច្ចអាចារ្យ គណៈកម្មការវត្ត

អាចារ្យ គណៈកម្មការវត្ត មានតួនាទី និងភារកិច្ចជាជំនួយការដល់គណៈសង្ឃវត្តលើការងារដូចខាងក្រោម៖

- **អាចារ្យ**

-ដឹកនាំរៀបចំពិធីកម្មសាសនា តាមប្រពៃណីទំនៀមទម្លាប់ខ្មែរ និងប្រពៃណីព្រះពុទ្ធសាសនា

-ទំនាក់ទំនងពុទ្ធបរិស័ទដើម្បីធ្វើការអប់រំ ផ្សព្វផ្សាយទ្រឹស្តីព្រះពុទ្ធសាសនា

-ទប់ស្កាត់ និងរម្ងាប់អធិករណ៍ទាំងឡាយណា ដែលកើតមានឡើងទាំងក្នុងវត្ត និងក្រៅវត្ត

-អនុវត្តកិច្ចការមួយចំនួនទៀត តាមសំណូមពរចាំបាច់របស់ពុទ្ធបរិស័ទ

-ជួយទុក្ខធុរៈព្រះសង្ឃ និងពុទ្ធបរិស័ទចំណុះជើងវត្ត

-សហការគ្រប់ការងារជាមួយគណៈកម្មការវត្ត។

- **គណៈកម្មការវត្ត**

-ការងាររដ្ឋបាលទូទៅរបស់វត្តទាំងមូល

-ការងារកិច្ចបញ្ជីការហិរញ្ញវត្ថុរបស់វត្ត (ដោយបង្កើតឱ្យមានគណនេយ្យករអ្នកកាន់លុយវត្ត ទាំងថវិកាកសាង ទាំងថវិកាវត្ត ត្រូវតម្កល់ទុកក្នុងធនាគារនៅជិតបំផុត។ អ្នកទទួលខុសត្រូវតម្កល់ និងដកថវិកាវត្តត្រូវមានសមាសភាព ព្រះគ្រូចៅអធិការវត្ត អាចារ្យធំ ប្រធានគណៈកម្មការវត្ត និងគណនេយ្យករ)

-ទំនាក់ទំនងជាមួយអាជ្ញាធរដែនដីគ្រប់លំដាប់ថ្នាក់ និងពុទ្ធបរិស័ទទូទៅ

-គ្រប់គ្រង ថែរក្សា និងចុះបញ្ជីទ្រព្យសម្បត្តិគរុភណ្ឌវត្ត

-ផ្គត់ផ្គង់ចង្ហាន់ព្រះសង្ឃ

-គ្រប់គ្រងស្ថិតិព្រះសង្ឃ និងអ្នកស្នាក់នៅក្នុងវត្ត

-រៀបចំសណ្តាប់ធ្នាប់ទូទៅ និងរក្សាសន្តិសុខសុវត្ថិភាពក្នុងវត្ត

-រៀបចំប្លង់មេ (ហេដ្ឋារចនាសម្ព័ន្ធវត្ត) របងក្លោងទ្វារវត្ត សម្រាប់អភិវឌ្ឍន៍វត្តអារាមឱ្យត្រូវតាម បែបបទព្រះពុទ្ធសាសនា និងវប្បធម៌ជាតិខ្មែរ។

-សាងសង់សំណង់ផ្សេងៗ និងកែលម្អសោភ័ណភាពវត្តឱ្យសក្តិសមជា រមណីយដ្ឋានទេសចរណ៍សាសនា និងបូជនីយដ្ឋានរបស់ជាតិ។

-សហការជាមួយអាចារ្យ ក្នុងការជួយរៀបចំពិធីបុណ្យផ្សេងៗ

-សហការជាមួយអាចារ្យ និងអ្នកពាក់ព័ន្ធ ក្នុងការរៀបចំចងក្រង និងរក្សាទុកនូវឯកសារផ្សេងៗ (ប្រវត្តិវត្ត ប្លង់កម្មសិទ្ធិ ដីវត្ត...)

-សហការទប់ស្កាត់ និងរម្ងាប់អធិករណ៍ទាំងឡាយណា ដែលកើតមានឡើងទាំងក្នុងវត្ត និងក្រៅវត្ត

-អនុវត្តភារកិច្ចមួយចំនួនទៀត តាមសំណូមពរចាំបាច់របស់សមូហភាព។

បញ្ជាក់ផងដែរថា៖ អាចារ្យ គណៈកម្មការវត្ត ដែលបានជ្រើសរើសតាមនីតិវិធី មានអាណត្តិការងាររបស់ខ្លួន រយៈពេល ០៣ (បី) ឆ្នាំ។ កាលបើផុតកំណត់រយៈពេល០៣ (បី) ឆ្នាំ អាចារ្យ គណៈកម្មការវត្តទាំងនោះ ត្រូវអស់សុពលភាពជាស្វ័យប្រវត្តិ។ មុនពេលបញ្ចប់តួនាទីភារកិច្ច អាចារ្យ គណៈកម្មការវត្តអាណត្តិចាស់ ត្រូវរៀបចំជម្រះបញ្ជី និងធ្វើរបាយការណ៍ទូទាត់ចំណូលចំណាយ ឱ្យបានត្រឹមត្រូវប្រគេនព្រះគ្រូចៅអធិការវត្ត ដើម្បីទុកជូនអាចារ្យ គណៈកម្មការវត្តអាណត្តិថ្មី។ ការជ្រើសរើសអាចារ្យ គណៈកម្មការវត្តអាណត្តិថ្មី ត្រូវរៀបចំតាមនីតិវិធី មិនឱ្យលើសរយៈពេល ៧ (ប្រាំពីរ) ថ្ងៃ បន្ទាប់ពីបញ្ចប់តួនាទីភារកិច្ចអាចារ្យ គណៈកម្មការវត្តអាណត្តិចាស់។

ដំណាក់កាលនេះអាចារ្យ គណៈកម្មការវត្តអាណត្តិចាស់ មានភារកិច្ចជួយសម្របសម្រួលការងារជាបណ្ដោះអាសន្ន រហូតដល់មានអាចារ្យ គណៈកម្មការវត្តអាណត្តិថ្មីមកជំនួស។[43]

## ២.៣.ថេរសភា (តុលាការសង្ឃ) នៃព្រះរាជាណាចក្រកម្ពុជា

### ២.៣.១.ការរៀបចំ និងការប្រព្រឹត្តទៅរបស់គណៈថេរសភានៃព្រះរាជាណាចក្រកម្ពុជា

ថេរសភានេះ គឺជាបុគ្គលយុត្តិធម៌ និងជាស្ថាប័នតុលាការមួយរបស់ពុទ្ធសាសនា ដែលមានចរិតជាអ្នកវិនិច្ឆ័យសេចក្ដីទៅលើរឿងក្ដីរបស់សង្ឃ ដែលអាជ្ញាធរសង្ឃគ្រប់លំដាប់ថ្នាក់ ដោះស្រាយពុំបានសម្រេច ហើយបានបញ្ជូនមកស្ថាប័នថេរសភា ដើម្បីជំរះសេចក្ដីជាទីបញ្ចប់ស្ថាប័ននេះ អាចនិយាយបានថាជាតុលាការ របស់សង្ឃអំណាចថេរសភាសង្ឃ។

**តុលាការសង្ឃ នៃព្រះរាជាណាចក្រកម្ពុជា ចែកចេញជា ៣ កម្រិត៖**

១-ថេរសភាសង្ឃ (តុលាការសង្ឃ) នៃព្រះរាជាណាចក្រកម្ពុជាថ្នាក់កំពូល

២-ថេរសភាសង្ឃ (តុលាការសង្ឃ) ថ្នាក់រាជធានី-ខេត្ត

៣-ថេរសភាសង្ឃ (តុលាការសង្ឃ) ថ្នាក់ក្រុង-ស្រុក-ខណ្ឌ

### ២.៣.២.ការជ្រើសតាំង និងការតែងតាំងគណៈថេរសភាសង្ឃថ្នាក់ជាតិ

ថេរសភា ត្រូវបានជ្រើសរើសបេក្ខសមណនោះ ចេញពីក្នុងចំណោមមន្ត្រីសង្ឃថ្នាក់ខ្ពស់ ដែលមានឋានៈជាព្រះរាជាគណៈទាំងបួនថ្នាក់ សមណបញ្ញវ័ន្តដែលមានទាំងចរិយាសម្បត្តិ និងវិជ្ជាសម្បត្តិពោល គឺចេះព្រះវិន័យយ៉ាងស្ទាត់ជំនាញ។

- **ថេរសភាមានសមាសភាពចំនួន ១២ រូប៖**

១.អធិបតីថេរសភា ១ រូប ដែលត្រូវជ្រើសចេញពី ក្នុងចំណោមព្រះរាជាគណៈថ្នាក់ឯក។

២.សមាជិកថេរសភា ១០ រូប ដែលត្រូវជ្រើសចេញពីក្នុងចំណោមមន្ត្រីសង្ឃ ដែលមានឋានៈជារាជាគណៈទាំងបួនថ្នាក់ ហើយសុទ្ធតែជាអ្នកចេះចាំនូវព្រះន័យយ៉ាងស្ទាត់ជំនាញ។

៣.លេខាត្រូវជ្រើសរើសព្រះរាជាគណៈថ្នាក់ចត្វា ១ រូប ពីក្នុងចំណោមសមាជិកថេរសភាទាំង ១០ យកមកធ្វើជាលេខា។

៤.អនុលេខា ១ រូប ត្រូវជ្រើសរើសយកចេញពី ក្នុងចំណោមសហការី ៨ រូប របស់សម្ដេចព្រះសង្ឃរាជ ឬព្រះសង្ឃនាយក។

[43] អនុក្រឹត្យ ស្ដីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួងធម្មការ និងសាសនា លេខៈ១៥៤. អនក្រ.បក ១១ កក្កដា ២០១១

នីតិវិធីនៃការជ្រើសតាំង គឺមានសមាសភាពរួមមាន៖ សម្តេចព្រះមហាសង្ឃរាជ ព្រះសង្ឃនាយក ព្រះសង្ឃនាយករងទី១ ទី២ ទី៣ មន្ត្រីសង្ឃជាន់ខ្ពស់ថ្នាក់សម្តេច និងរដ្ឋមន្ត្រីក្រសួងធម្មការ និងសាសនា ដែលជាតំណាងរាជរដ្ឋាភិបាល រួមគ្នាប្រជុំពិភាក្សាជ្រើសរើសយកបេក្ខសមណ ដែលសមគួរដល់ការផ្តល់តំណែង។ បន្ទាប់ពីបានឯកភាពជ្រើសយកបេក្ខជនគ្រប់សព្វហើយ សម្តេចព្រះមហាសង្ឃរាជ ឬព្រះសង្ឃនាយកធ្វើការស្នើទៅសម្តេចនាយករដ្ឋមន្ត្រីសុំការតែងតាំងដោយអនុក្រឹត្យ។[44]

### ២.៣.៣.តួនាទី និងភារកិច្ចគណៈថេរសភាសង្ឃថ្នាក់ជាតិ

-ជាសហធម្មិកសង្ឃជាន់ខ្ពស់ របស់សម្តេចព្រះមហាសង្ឃរាជ ឬព្រះសង្ឃនាយកក្នុងបេសកកម្មជួយអភិបាលកិច្ចសង្ឃ ដោះស្រាយរម្ងាប់អធិករណ៍ដែល កើតមានឡើងក្នុងព្រះពុទ្ធសាសនា នៅទូទាំងព្រះរាជាណាចក្រកម្ពុជា។

-ជំនុំជម្រះអធិករណ៍ដែលកើតឡើងរវាងសង្ឃ និងសង្ឃ រវាងសង្ឃ និងគ្រហស្ថ ដែលវិន័យធរ ធម្មធរ អនុគណ មេគណ សង្ឃនាយក ឬសង្ឃរាជ ពុំអាចរម្ងាប់បាន។ ចាត់តាំងតំណាងចុះទៅស្រាវជ្រាវ ស្វែងយល់រកហេតុផលពិតប្រាកដ អំពីប្រភពទំនាស់ អំពីយន្តការដោះស្រាយកន្លងមក ធ្វើរបាយការណ៍ច្បាស់លាស់ និងសន្និដ្ឋាន។

-រកគ្រប់វិធីធ្វើការណែនាំ សម្រុះសម្រួលនូវភាគីបង្កអធិករណ៍ឱ្យយល់គ្នា ដោយប្រើប្រាស់គ្រប់រូបភាព សិល្បវិធីក្នុងនាមជាសហធម្មិក និងជាភាតរភាពក្នុងពុទ្ធសាសនមណ្ឌល។

-ធ្វើការជំនុំពិភាក្សាគ្នាដោយហ្មត់ចត់ ច្រើនលើកច្រើនសារដោយផ្អែកលើគោលការណ៍ធម្មវិន័យ និងច្បាប់របស់រដ្ឋ ថ្លឹងថ្លែងគ្រប់ទិដ្ឋភាពទើបធ្វើសេចក្តីសម្រេច កាត់ក្តីជាចុងក្រោយដោយធ្វើឱ្យភាគីនីមួយៗ អាចទទួលយកបានដោយគ្មានការរង្កៀស។

-ត្រូវមានតម្លាភាព ក្នុងការរម្ងាប់អធិករណ៍នីមួយៗ ដោយឈរលើទស្សនគ្រប់ជ្រុងជ្រោយ លើមូលដ្ឋាននៃព្រះវិន័យពុទ្ធសាសនា និងច្បាប់រដ្ឋមិនលុះដោយអំណាចនៃអគតិធម៌ទាំង៤។

-ទទួលបំពេញភារកិច្ចផ្សេងៗទៀត ដែលសម្តេចព្រះមហាសង្ឃរាជ ឬព្រះសង្ឃនាយក តម្រូវឱ្យជួយដោះស្រាយ។

### ២.៣.៤.ការជ្រើសតាំង និងការតែងតាំងគណៈថេរសភាសង្ឃថ្នាក់មូលដ្ឋាន

ការតែងតាំងសមាសភាពថេរសភាថ្នាក់ រាជធានី-ខេត្ត-ក្រុង-ស្រុក-ខណ្ឌ នៃព្រះពុទ្ធសាសនាថេរវាទនៅព្រះរាជាណាចក្រកម្ពុជា ជាសហធម្មិកឱ្យថេរសភា នៃព្រះពុទ្ធសាសនានៅកម្ពុជាដើម្បីជំនុំជម្រះ និងដោះស្រាយរម្ងាប់អធិករណ៍ដែលមានសមាសភាពដូចខាងក្រោម៖

[44] អនុក្រឹត្យស្តីពី ការបង្កើតថេរសភានៃព្រះពុទ្ធសាសនានៅព្រះរាជាណាចក្រកម្ពុជា លេខ៥៧៦អនក្រ.តត ថ្ងៃទី២៥ ខែសីហា ឆ្នាំ២០០៦

❖ **ថេរសភាថ្នាក់រាជធានី-ខេត្ត**

| | |
|---|---|
| ១.ព្រះមេគណរាជធានី-ខេត្ត | ជាប្រធាន |
| ២-ព្រះបាឡាត់គណរាជធានី-ខេត្ត | ជាអនុប្រធានទី១ |
| ៣-ព្រះវិន័យធរគណរាជធានី-ខេត្ត | ជាអនុប្រធានទី២ |
| ៤-ព្រះធម្មធរគណរាជធានី-ខេត្ត | ជាសមាជិក |
| ៥-ព្រះសមុហ៍គណរាជធានី-ខេត្ត | ជាសមាជិក |
| ៦-ព្រះលេខាធិការគណរាជធានី-ខេត្ត | ជាសមាជិក |

❖ **ថេរសភាថ្នាក់ក្រុង-ស្រុក-ខណ្ឌ**

| | |
|---|---|
| ១- ព្រះអនុគណក្រុង-ស្រុក-ខណ្ឌ | ជាប្រធាន |
| ២-ព្រះវិន័យធរអនុគណក្រុង-ស្រុក-ខណ្ឌ | ជាអនុប្រធានទី១ |
| ៣-ព្រះធម្មធរអនុគណក្រុង-ស្រុក-ខណ្ឌ | ជាអនុប្រធានទី២ |
| ៤-ព្រះសមុហ៍អនុគណក្រុង-ស្រុក-ខណ្ឌ | ជាសមាជិក |
| ៥-ព្រះលេខាធិការអនុគណក្រុង-ស្រុក-ខណ្ឌ | ជាសមាជិក |

ថេរសភា ថ្នាក់រាជធានី-ខេត្ត-ក្រុង-ស្រុក-ខណ្ឌ ត្រូវរៀបចំលេខាធិការដ្ឋានមួយ ជាជំនួយការដែលដឹកនាំដោយព្រះសមុហ៍គណខេត្ត រាជធានី និងព្រះសមុហ៍អនុគណ ក្រុង-ស្រុក-ខណ្ឌ ជាលេខាធិការ ត្រូវធ្វើរបាយការណ៍ជាប្រចាំទូលថ្វាយតាម ឋានានុក្រមមកគណៈសង្ឃនាយក នៃព្រះរាជាណាចក្រកម្ពុជា និងជូនក្រសួងធម្មការ និងសាសនាជាប្រចាំខែ ត្រីមាស ឆមាស និងប្រចាំឆ្នាំ។ លេខាធិការដ្ឋានថេរសភា ថ្នាក់រាជធានី-ខេត្ត-ក្រុង-ស្រុក ខណ្ឌ នៃព្រះពុទ្ធសាសនាថេរវាទនៅកម្ពុជា ត្រូវអនុវត្តភារកិច្ចរបស់ខ្លួន តាមព្រះសង្ឃប្រកាសរបស់គណៈសង្ឃនាយក នៃព្រះរាជាណាចក្រកម្ពុជា និងមានការយល់ព្រមពីក្រសួងធម្មការ និងសាសនា។[45]

ថេរសភា ថ្នាក់រាជធានី-ខេត្ត-ក្រុង-ស្រុក-ខណ្ឌ នៃព្រះពុទ្ធសាសនាថេរវាទ នៅព្រះរាជាណាចក្រកម្ពុជា មានសិទ្ធិប្រើប្រាស់ត្រា ដោយឡែករបស់ថេរសភាថ្នាក់ រាជធានី-ខេត្ត-ក្រុង-ស្រុក-ខណ្ឌ នៃព្រះពុទ្ធសាសនាថេរវាទ នៅព្រះរាជាណាចក្រកម្ពុជា សម្រាប់ប្រតិបត្តិការងាររបស់ខ្លួន។

[45] អនុក្រឹត្យស្តីពី ការបង្កើតថេរសភារាជធានី ខេត្ត/ក្រុង ស្រុក ខណ្ឌ នៃព្រះពុទ្ធសាសនាថេរវាទ នៅព្រះរាជាណាចក្រកម្ពុជា លេខ៣៤ អនក្រ.បក ថ្ងៃទី០៦ ខែកុម្ភៈ ឆ្នាំ២០០៩

### ២.៣.៥.តួនាទី និងភារកិច្ចថេរសភាសង្ឃថ្នាក់រាជធានី-ខេត្ត

ជាសហធម្មិកសង្ឃ របស់ថេរសភានៃព្រះពុទ្ធសាសនា នៅព្រះរាជាណាចក្រកម្ពុជា ក្នុងបេសកកម្មជួយអភិបាលកិច្ចសង្ឃ ជំនុំជម្រះ និងដោះស្រាយរម្ងាប់អធិករណ៍ ដែលកើតមានឡើងនៅ រាជធានី-ខេត្ត និងតាមសំណើរបញ្ជូនរបស់ថេរសភា ក្រុង-ស្រុក-ខណ្ឌ។

-ជំនុំជម្រះអធិករណ៍ ដែលកើតមានឡើងរវាងសង្ឃ និងសង្ឃ រវាងសង្ឃ និងគ្រហស្ថដែលកើតមានឡើងនៅតាមបណ្តាវត្តអារាម និងអាស្រម។

-ចាត់តាំងតំណាងទៅស្រាវជ្រាវ ស្វែងយល់រកហេតុផលពិតប្រាកដ អំពីប្រភពទំនាស់ អំពីយន្តការដោះស្រាយកន្លងមក ធ្វើរបាយការណ៍ច្បាស់លាស់ និងសន្និដ្ឋាន។

-ត្រូវមានតម្លាភាពក្នុងការ រម្ងាប់អធិករណ៍នីមួយៗ ដោយឈរលើទស្សនគ្រប់ជ្រុងជ្រោយ លើមូលដ្ឋាននៃព្រះវិន័យព្រះពុទ្ធសាសនា និងច្បាប់រដ្ឋមិនលុះដោយ អំណាចនៃអគតិធម៌ទាំង៤។

-អធិករណ៍ដែលថេរសភា ក្រុង-ស្រុក-ខណ្ឌ មិនអាចដោះស្រាយបាន ត្រូវធ្វើរបាយការណ៍បញ្ជូនសំណុំរឿងមករាជធានី-ខេត្ត នៃព្រះពុទ្ធសាសនាថេរវាទ នៅព្រះរាជាណាចក្រកម្ពុជាដើម្បីដោះស្រាយ។

-ទទួលបំពេញភារកិច្ចផ្សេងៗទៀត ដែលថេរសភានៃព្រះពុទ្ធសាសនាថេរវាទ នៅព្រះរាជាណាចក្រកម្ពុជា និងថេរសភារាជធានី-ខេត្ត នៃព្រះពុទ្ធសាសនាថេរវាទ នៅព្រះរាជាណាចក្រកម្ពុជាស្នើសុំឱ្យជួយដោះស្រាយ។

-ការដោះស្រាយអធិករណ៍ ត្រូវមានការិយាល័យធម្មការ និងសាសនា ជាអ្នកពិគ្រោះយោបល់ និងសង្កេតការណ៍ក្នុងការដោះស្រាយអធិករណ៍។

-រកគ្រប់វិធីធ្វើការណែនាំ កោះហៅ សម្រុះសម្រួល នូវភាគីបង្កអធិករណ៍ ឱ្យយល់គ្នាដោយប្រើប្រាស់គ្រប់រូបភាព សិល្បវិធីក្នុងនាមសហធម្មិក និងជាភាតរភាពក្នុងពុទ្ធសាសនមណ្ឌល។

-ធ្វើការជំនុំពិភាក្សាគ្នា ដោយម៉ត់ចត់ ច្រើនលើកច្រើនសារ ដោយផ្អែកលើគោលការណ៍ធម្មវិន័យ និងច្បាប់របស់រដ្ឋ ថ្លឹងថ្លែងគ្រប់ទិដ្ឋភាព ធ្វើសេចក្តីសម្រេចកាត់ក្តីជាចុងក្រោយ ដោយធ្វើឱ្យភាគីនីមួយៗ ទទួលយកបានដោយគ្មានការរង្កៀស។

-ត្រូវមានតម្លាភាព ក្នុងការរម្ងាប់អធិករណ៍នីមួយៗ ដោយឈរលើទស្សនគ្រប់ជ្រុងជ្រោយ លើមូលដ្ឋាននៃព្រះវិន័យព្រះពុទ្ធសាសនា និងច្បាប់រដ្ឋមិនលុះដោយ អំណាចនៃអគតិធម៌ទាំង៤។[46]

---

[46] អនុក្រឹត្យស្តីពី ការបង្កើតថេរសភារាជធានី ខេត្ត/ក្រុង ស្រុក ខណ្ឌ នៃព្រះពុទ្ធសាសនាថេរវាទ នៅព្រះរាជាណាចក្រកម្ពុជា លេខ៣៨ អនក្រ.បក ថ្ងៃទី០៦ ខែកុម្ភៈ ឆ្នាំ២០០៩

## ២.៣.៦.តួនាទី និងភារកិច្ចថេរសភាសង្ឃថ្នាក់ក្រុង-ស្រុក-ខណ្ឌ

ជាសហធម្មិកសង្ឃរបស់ថេរសភា ពុទ្ធសាសនារាជធានី-ខេត្ត នៅព្រះរាជាណាចក្រកម្ពុជា ក្នុងបេសកកម្ម ជួយអភិបាលកិច្ចសង្ឃ ជំនុំជម្រះ និងដោះស្រាយរម្ងាប់អធិករណ៍ ដែលកើតមានឡើងនៅ ក្រុង-ស្រុក-ខណ្ឌ។

-ជំនុំជម្រះអធិករណ៍ ដែលកើតមានឡើងរវាងសង្ឃ និងសង្ឃ រវាងសង្ឃ និងគ្រហស្ថ ដែលកើតមានឡើងនៅ តាមបណ្តាវត្តអារាម និងអាស្រម។

-ចាត់តាំងតំណាង ទៅស្រាវជ្រាវឈ្វេងយល់ រកហេតុផលពិតប្រាកដ អំពីប្រភពទំនាស់ អំពីយន្តការ ដោះស្រាយកន្លងមក ធ្វើរបាយការណ៍ច្បាស់លាស់ និងសន្និដ្ឋាន។

-រកគ្រប់វិធីធ្វើការណែនាំ កោះហៅសម្រុះសម្រួល នូវភាគីបង្កអធិករណ៍ឱ្យយល់គ្នា ដោយប្រើប្រាស់គ្រប់រូប ភាព សិល្បវិធីក្នុងនាមសហធម្មិក និងជាភាតរភាពក្នុងពុទ្ធសាសនមណ្ឌល។

-ធ្វើការជំនុំពិភាក្សាគ្នាដោយម៉ត់ចត់ ច្រើនលើកច្រើនសារ ដោយផ្អែកលើគោលការណ៍ ធម្មវិន័យ និងច្បាប់ របស់រដ្ឋ ថ្លឹងថ្លែងគ្រប់ទិដ្ឋភាព ធ្វើសេចក្តីសម្រេចកាត់ក្តីជាចុងក្រោយ ដោយធ្វើឱ្យភាគីនីមួយៗទទួលយកបានដោយ គ្មានការរង្កៀស។

-ត្រូវមានតម្លាភាព ក្នុងការរម្ងាប់អធិករណ៍នីមួយៗ ដោយឈរលើទស្សនគ្រប់ជ្រុងជ្រោយ លើមូលដ្ឋាន នៃព្រះវិន័យព្រះពុទ្ធសាសនា និងច្បាប់រដ្ឋមិនលុះដោយ អំណាចនៃអគតិធម៌ទាំង៤។

-អធិករណ៍ដែលថេរសភា ក្រុង-ស្រុក-ខណ្ឌ មិនអាចដោះស្រាយបាន ត្រូវធ្វើរបាយការណ៍បញ្ជូនមក ថេរសភា រាជធានី-ខេត្ត ដើម្បីដោះស្រាយជាបន្ត។

# សេចក្តីសន្និដ្ឋាន

# សេចក្តីសន្និដ្ឋាន

ក្រោយពីបានសិក្សាស្រាវជ្រាវទៅលើប្រធានបទ ការគ្រប់គ្រងរដ្ឋបាលផ្នែកពុទ្ធចក្រនៃព្រះរាជាណាចក្រកម្ពុជា រួចមកយើងឃើញថា ព្រះពុទ្ធសាសនាដែលបានទូន្មានពុទ្ធសាសនិក និងមនុស្សលោកឱ្យមាននូវពន្លឺបញ្ញា ចេះដឹងខុសត្រូវ ចេះស្ងប់រម្ងាប់ ឱ្យចេះខន្តី ឱ្យចេះរំដោះខ្លួនរួចផុតអំពីសេក្តីទុក្ខលំបាក។ ហើយដោយព្រះរាជាណាចក្រកម្ពុជាជាប្រទេសដែលកាន់នូវព្រះពុទ្ធសាសនាដ៏មុតមាំផងនោះ ទើបមាននូវផ្នែកពុទ្ធចក្រផង និងផ្នែកអាណាចក្រផង ដែលអាណាចក្រជាផ្នែកខាងអំណាច និងពុទ្ធចក្រជាផ្នែកខាងសីលធម៌ ហើយចក្រទាំងពីរនេះត្រូវបានរៀបចំ ឱ្យដើរទន្ទឹមគ្នាដូចជាកង់យានយន្តនាំនាវាកម្ពុជាឆ្ពោះទៅរក វិបុលភាព សុខសន្តិភាព និងភាពរុងរឿង ទើបរាជរដ្ឋាភិបាលបានរៀបចំឱ្យមាននូវរដ្ឋបាលផ្នែកពុទ្ធចក្រមួយ ឱ្យសមស្របទៅនឹងផ្នែកអាណាចក្រផងដែរនោះ គឺដើម្បីឱ្យព្រះពុទ្ធសាសនាមានស្ថេរភាព រឹងមាំ និងរីកចម្រើនតទៅមុខទៀត។ ក្នុងនោះដែរ ការគ្រប់គ្រងរដ្ឋបាលផ្នែកព្រះពុទ្ធសាសនានៅប្រទេសកម្ពុជា គឺមានយន្តការនៃការគ្រប់គ្រងស្ថាប័នគណៈសង្ឃ គ្រប់លំដាប់ថ្នាក់ ឱ្យបានប្រព្រឹត្តទៅក្នុងរបៀបរៀបរយល្អ មានភាពរលូន ប្រកបដោយរចនាសម្ព័ន្ធ តួនាទី ភារកិច្ច ឱ្យគោរពឋានានុក្រម អព្យាក្រឹតភាព តម្លាភាព និងឱ្យមានស្ថេរភាពតទៅមុខទៀត។

មួយវិញទៀត តាមរយៈនៃការសិក្សាស្រាវជ្រាវខាងលើ បានបង្ហាញឱ្យយើងឃើញថា វិស័យពុទ្ធចក្រ និងវិស័យអាណាចក្រទាំងពីរនេះ តាំងពីសម័យអតីតកាល រហូតដល់បច្ចុប្បន្នកាលមាន ប្រព័ន្ធគ្រប់គ្រងរដ្ឋបាល និងមានការរៀបចំរចនាសម្ព័ន្ធគ្រប់គ្រងមួយយ៉ាងត្រឹមត្រូវ រឹងមាំប្រហាក់ប្រហែលនឹងគ្នា ដោយមានការវិវត្តតាមតំណាក់កាល និងការប្រែប្រួលទៅតាមទម្រង់ផ្សេងៗ នៃការរីកចម្រើនរបស់សង្គម។ ឈរលើមូលដ្ឋាននៃការរៀបចំឱ្យមាន ប្រព័ន្ធគ្រប់គ្រងរដ្ឋបាលសង្ឃកម្ពុជា ប្រកបដោយរចនាសម្ព័ន្ធត្រឹមត្រូវរឹងមាំនេះហើយ បានធ្វើឱ្យព្រះពុទ្ធសាសនា មានការរីកចម្រើនបន្តនិរន្តរភាព អាយុកាលរបស់ខ្លួនមកដល់ពេលបច្ចុប្បន្ននេះ។ តែទោះជាយ៉ាងណាក៏ដោយ យើងឃើញថាក្នុងវិស័យពុទ្ធចក្រនៅតែខ្វះយន្តការជាច្រើនដូចជា សាលាសង្ឃាភិបាល គណៈសង្ឃអធិការកិច្ច គណៈមន្ត្រីសង្ឃសណ្តាប់ធ្នាប់ជាដើម សម្រាប់រួមចំណែកគ្រប់គ្រង ដឹកនាំស្ថាប័នសង្ឃ និងពុទ្ធសាសនាឱ្យមានដំណើរការល្អប៉ុន្មាននៅឡើយទេ។

សរុបសេចក្តីមក ព្រះរាជាណាចក្រកម្ពុជាមានវិស័យពុទ្ធចក្រ ដែលអមជាមួយវិស័យអាណាចក្រប្រកបដោយរដ្ឋបាលត្រឹមត្រូវច្បាស់លាស់ ក្នុងនោះមានអង្គភាព ស្ថាប័ន រចនាសម្ព័ន្ធ មុខតំណែង តួនាទី ភារកិច្ច សម្រាប់ដឹកនាំគ្រប់គ្រងឱ្យមានវឌ្ឍនភាពទៅមុខដោយពិតប្រាកដ។

# អនុសាសន៍

# អនុសាសន៍

ដើម្បីចូលរួមចំណែកក្នុងការអភិវឌ្ឍ នូវផ្នែកពុទ្ធចក្រក៏ដូចជាវិស័យ ព្រះពុទ្ធសាសនាទាំងមូលឱ្យបានកាន់តែរីកចម្រើន យើងត្រូវលើកកម្ពស់ក៏ដូចជាផ្តល់ នូវតម្លៃនៃចំណេះដឹង សីលធម៌ គុណធម៌ ធានាបាននូវនិរន្តរភាពនៃសន្តិសុខសង្គម។

ក្នុងនាមខ្ញុំព្រះករុណាអាត្មាភាពជាកុលបុត្រខ្មែរ ហើយក៏ជាអ្នកបួសក្នុងសំណាក់ នៃពុទ្ធសាសនមណ្ឌលផងនោះ សូមប្រគេន-ជូនជាអនុសាសន៍ទៅដល់ សាធារណជនឱ្យបានជ្រាបដូចខាងក្រោមនេះ៖

-គួរបង្កើតសាលាសង្ឃាភិបាល សម្រាប់បណ្តុះបណ្តាលមន្ត្រីសង្ឃពុទ្ធសាសនា គ្រប់បណ្តាលថ្នាក់ ដើម្បីឱ្យមានចំណេះដឹងស៊ីជម្រៅ និងទូលំទូលាយលើការគ្រប់គ្រង និងដឹកនាំស្ថាប័នពុទ្ធសាសនាតាំងពីថ្នាក់មូលដ្ឋានរហូតដល់ថ្នាក់ជាតិ។

-ព្រះពុទ្ធសាសនា ជាសាសនារបស់រដ្ឋ ដូច្នេះ រដ្ឋគួរបង្កើតយុទ្ធសាស្ត្រ និងគោលការណ៍មានរយៈពេលច្បាស់លាស់ស្រដៀង និងអាណាចក្រសម្រាប់អភិវឌ្ឍន៍ វិស័យពុទ្ធសាសនាឱ្យមាននិរន្តរភាព។

-គួរបង្កើតគណៈអធិការកិច្ចសង្ឃមួយ សម្រាប់ពុទ្ធសាសនាដើម្បីធ្វើអធិការកិច្ច ទៅលើការគ្រប់គ្រងរដ្ឋបាលសង្ឃ និងការប្រព្រឹត្តិទៅនៃស្ថាប័នពុទ្ធសាសនា។

-គួរបង្កើតគណៈមន្ត្រីសង្ឃ សណ្តាប់ធ្នាប់គ្រប់ខេត្ត/រាជធានី ដើម្បីរៀបចំសណ្តាប់ធ្នាប់ព្រះសង្ឃក្នុងគ្រប់កម្មវិធីនិងគ្រប់ពេលវេលាឱ្យមានរបៀបរៀបរយល្អ គួរជាទីជ្រះថ្លារបស់ពុទ្ធបរិស័ទ។

-គួររៀបចំផែនការសម្រាប់មន្ត្រីសង្ឃ ដែលមានកម្រិតវប្បធម៌ខ្ពស់បង្កើតកម្មវិធីផ្សេងៗ ដូចជាបើកសិក្ខាសាលាចុះអប់រំផ្សព្វផ្សាយ ដល់ប្រជាពលរដ្ឋនៅឯជនបទឱ្យបានញឹកញាប់ ដើម្បីឱ្យគេបានយល់ដឹងអំពីតម្លៃព្រះពុទ្ធសាសនា និងតម្លៃនៃសេក្តីល្អ សីលធម៌ គុណធម៌ខិតខំអប់រំពុទ្ធបរិស័ទ ឱ្យចេះតម្កល់ខ្លួនប្រកបដោយសទ្ធា និងបញ្ញាប្រតិបត្តិត្រឹមត្រូវ តាមពុទ្ធោវាទ លះបង់ជំនឿផ្តេសផ្តាស ប្រាសចាកន្លងមាគ៌ាព្រះពុទ្ធសាសនាដោយគ្មានហេតុផល។

-គួរបញ្ចូលកម្មវិធីសីលធម៌ពុទ្ធសាសនា ទៅក្នុងសាលាសាធារណៈគ្រប់ភូមិសិក្សា ដោយបញ្ចូលព្រះសង្ឃដែលមានគុណធម៌ និងសមត្ថភាពទៅបង្ហាត់បង្រៀនមុខវិជ្ជានេះ ក្នុងគោលបំណងលើកស្ទួយនូវសីលធម៌សង្គមដែលបានធ្លាក់ចុះជាច្រើនទសវត្សរ៍មកហើយដ៏គួរឱ្យព្រួយបារម្ភ។

-សូមឱ្យមានការតែងតាំងនូវព្រះថេរអង្គណា ដែលលោកមានចំណេះដឹងជ្រៅជ្រះ មានការបដិបត្តិល្អក្នុងព្រះពុទ្ធសាសនា យ៉ាងហោចណាស់ក៏បញ្ចប់ថ្នាក់បរិញ្ញាបត្រ និងចំណេះដឹងផ្នែកភាសាបាលីផងដែរ ក្នុងការកាន់តួនាទីណាមួយ នៃរចនាសម្ព័ន្ធចាប់ពីគណៈសង្ឃនាយក រហូតដល់ថ្នាក់មូលដ្ឋាន។

# ឯកសារយោង

# ឯកសារយោង

## ១.ច្បាប់និងលិខិតបទដ្ឋានគតិយុត្ត

- រដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ១៩៩៣
- ព្រះរាជក្រឹត្យ ពស/រកត/ ០៤០៦/២០០ ស្ដីពី តែងតាំងសម្ដេចព្រះមហាសុមេធាធិបតី ទេព វង្ស ជាសម្ដេចព្រះអគ្គមហាសង្ឃរាជាធិបតី សម្ដេចមហាសង្ឃរាជនៃព្រះរាជាណាចក្រកម្ពុជា
- ព្រះរាជក្រឹត្យស្ដីពី ការបង្កើតគណៈសង្ឃនាយក នៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ២០០៦
- ព្រះរាជក្រឹត្យ នស/រកត/០២២០/១៧២ ចុះថ្ងៃទី១២ ខែកុម្ភៈ ឆ្នាំ២០២០ ស្ដីពី ការតម្លើងនិងតែងតាំងព្រះឋានៈសម្ដេចព្រះសង្ឃនៃគណៈសង្ឃនាយកនៃព្រះរាជាណាចក្រកម្ពុជា
- អនុក្រឹត្យស្ដីពី ការបង្កើតថេរសភានៃព្រះពុទ្ធសាសនាថេរវាទនៅព្រះរាជាណាចក្រកម្ពុជា ឆ្នាំ២០០៦
- អនុក្រឹត្យស្ដីពី ការបង្កើតថេរសភារាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ នៃព្រះពុទ្ធសាសនាថេរវាទ នៅព្រះរាជាណាចក្រកម្ពុជា ឆ្នាំ២០០៩
- អនុក្រឹត្យស្ដីពី ការបង្កើតអគ្គលេខាធិការដ្ឋានថេរសភា នៃពុទ្ធសាសនានៅព្រះរាជាណាចក្រកម្ពុជា លេខៈ២៤ អនក្រ.បក ចុះថ្ងៃទី៦ ខែមីនា ឆ្នាំ២០២០
- អនុក្រឹត្យស្ដីពី ការរៀបចំនិងប្រព្រឹត្តទៅរបស់ក្រសួងធម្មការនិងសាសនា លេខ១៥៤.អនក្រ.បក ចុះថ្ងៃទី ១១ ខែកក្កដា ឆ្នាំ២០១១
- ព្រះសង្ឃប្រកាសស្ដីពី ការកំណត់បែងចែកភារកិច្ច សម្ដេចព្រះអគ្គមហាសង្ឃរាជាធិបតី សម្ដេចព្រះមហាសង្ឃរាជ និងសម្ដេចព្រះមហាសុមេធាធិបតី ព្រះសង្ឃនាយក លេខៈ០០១/០៦ ម.ស.រធត ចុះថ្ងៃទី២៤ ខែសីហា ឆ្នាំ២០០៦
- ព្រះសង្ឃប្រកាសស្ដីពី ការកំណត់បែងចែកភារកិច្ចគណៈសង្ឃនាយក នៃព្រះរាជាណាចក្រកម្ពុជា លេខៈ០០៥/០៦ ស.ន.ក.ជ ចុះថ្ងៃទី២៩ ខែសីហា ឆ្នាំ២០០៦
- ព្រះសង្ឃប្រកាសស្ដីពី ការកំណត់បែងចែកភារកិច្ចមន្ត្រីសង្ឃខេត្ត រាជធានី ស្រុក ខណ្ឌ ក្រុង និងវត្ត លេខៈ០៥/១១ ស.ន.ក.ជ ចុះថ្ងៃទី៧ ខែកុម្ភៈ ឆ្នាំ២០១១

## ២.សៀវភៅតែងនិពន្ធ

- សម្ដេចសង្ឃរាជ ជួន ណាត វចនានុក្រមខ្មែរ ពុទ្ធសាសនាបណ្ឌិត្យភ្នំពេញ ព.ស.២៥១១ គ.ស.១៩៦៧
- ត្រឹង ងា ប្រវត្តិសាស្ត្រខ្មែរភាគ២ ឆ្នាំ១៩៧៣

- ឥន្ទបញ្ញោភិក្ខុ ហេង មណីចិន្តា ព្រះបាទធម្មិក ឆ្នាំ១៩៩៥
- ឥន្ទ ឱមសាម៉េង កម្រងប្រវត្តិសាស្រ្តនៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ២០០៣
- មជ្ឈមណ្ឌលសម្រាប់ការសិក្សាស្រាវជ្រាវជាន់ខ្ពស់ ពិធីបំបួសនាគនៅប្រទេសកម្ពុជា អតីតកាល និងបច្ចុប្បន្ន ឆ្នាំ ២០០៥
- សម្តេចព្រះមហាអរិយវង្ស សៅរ៍ ចន្ទថុល្ល ធម្មប្បដិបត្តិ ព.ស.២៥៥៥ គ.ស.២០១២
- ភិក្ខុគុណវរោ គង់ លី រដ្ឋបាលវត្តអារាម ព.ស.២៥៦០
- ការផ្សាយពុទ្ធសាសនបណ្ឌិត្យ ករណីកិច្ចនៃ ចៅអធិការ អនុគណ និងមេគណ ព.ស.២៥៣៧
- សម្តេចព្រះសង្ឃរាជ ជួន ណាត របៀបការគ្រប់គ្រងគណៈសង្ឃ(ទស្សនាវដ្តី ពន្លឺពុទ្ធចក្រលេខ១) ឆ្នាំ១៩៦១
- អំពីព្រះរាជប្រពៃណីព្រះមហាក្សត្រ និងសម្តេចព្រះសង្ឃរាជ ការផ្សាយរបស់ព្រះបរមរាជវាំង, ឆ្នាំ២០០៣
- ភិក្ខុ អ៊ុក អ៊ាន កម្ពុជាសុរិយាលេខ៩(ទស្សនៈពុទ្ធសាសនា) ការផ្សាយពុទ្ធសាសនាបណ្ឌិតឆ្នាំ១៩៧១
- ព្រះមហាវីរិយបណ្ឌិតោ ប៉ាង ខាត់ ប្រវត្តិពុទ្ធសាសនានៅកម្ពុជា
- លោកគ្រូអគ្គបណ្ឌិត ប៊ុត សាវង្ស ព្រះពុទ្ធសាសនា ព.ស.២៥៤៦

## ៣.គេហទំព័រ

- ការរក្សាសីលនៅក្នុងព្រះពុទ្ធសាសនា - Lotus Broadcasting Services (lotus-radio.com)
- ទស្សនៈពុទ្ធសាសនា | ឃ្លាំងគំនិត (wordpress.com)
- អរិយសច្ចៈ | អ្នកមាន (neakmien.club)
- ប្រវត្តិព្រះពុទ្ធសាសនានៅកម្ពុជា | (wordpress.com)
- http://pisrumsok.blogspot.com/2012/09/blog-post_21.html
- វត្តភិរម្យរាជ ភិរម្យសុខ (pisrumsok.blogspot.com)
- អនុសំវច្ឆរមហាសន្និបាតមន្ត្រីសង្ឃទូទាំងប្រទេសលើកទី២៨៖ ខ្លឹមសារនៃសង្ឃប្រកាស - Lokavidu News (lokavidunewsonline.blogspot.com)

# ឧបសម្ព័ន្ធ

# បញ្ជីឧបសម្ព័ន្ធ


ឧបសម្ព័ន្ធទី១៖ ព្រះរាជក្រឹត្យ ស្តីពីតែងតាំងសម្តេចព្រះមហាសុមេធាធិបតី ទេព វង្ស

ឧបសម្ព័ន្ធទី២៖ ព្រះរាជក្រឹត្យស្តីពី ការតែងតាំង និងរតម្លើងឋានៈ ប៊ូ គ្រី នៃគណៈធម្មយុត្តិកនិកាយ

ឧបសម្ព័ន្ធទី៣៖ ព្រះរាជក្រឹត្យស្តីពី ការបង្កើតគណៈសង្ឃនាយក នៃព្រះរាជាណាចក្រកម្ពុជា

ឧបសម្ព័ន្ធទី៤៖ ព្រះរាជក្រឹត្យ ស្តីពី ការតម្លើងនិងតែងតាំងព្រះឋានៈសម្តេចព្រះសង្ឃនៃគណៈសង្ឃនាយក

ឧបសម្ព័ន្ធទី៥៖ អនុក្រឹត្យស្តីពី ការបង្កើតអគ្គលេខាធិការដ្ឋានថេរសភា នៃពុទ្ធសាសនា

ឧបសម្ព័ន្ធទី៦៖ អនុក្រឹត្យស្តីពី ការបង្កើតថេរសភា នៃព្រះពុទ្ធសាសនាថេរវាទនៅព្រះរាជាណាចក្រកម្ពុជា

ឧបសម្ព័ន្ធទី៧៖ អនុក្រឹត្យស្តីពី ការរៀបចំនិងប្រព្រឹត្តទៅរបស់ក្រសួងធម្មការ និងសាសនា

ឧបសម្ព័ន្ធទី៨៖ ព្រះសង្ឃប្រកាសស្តីពី ការកំណត់បែងចែកភារកិច្ចមន្ត្រីសង្ឃ មូលដ្ឋាន

ឧបសម្ព័ន្ធទី៩៖ ព្រះសង្ឃប្រកាសស្តីពីការកំណត់បែងចែកភារកិច្ច សម្តេចមហាសង្ឃរាជ និងព្រះសង្ឃនាយក

ឧបសម្ព័ន្ធទី១០៖ ប្រកាសស្តីពី អាចារ្យ និងគណៈកម្មការវត្ត

ឧបសម្ព័ន្ធទី១១៖ សេចក្តីកំណត់ អំពីរបៀបរបប នៃការជ្រើសរើសមន្ត្រីសង្ឃ

ឧបសម្ព័ន្ធទី១២៖ រូបភាព

# ឧបសម្ព័ន្ធទី១

នស/រកត/០៤០៦/២០០

# ព្រះរាជក្រឹត្យ

យើង

ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី
សមានគុមិជាតិសាសនា រក្ខតខត្តិយា ខេមរាជរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ
ខេមរាជនា សមូហោភាស កម្ពុជឯករាជរជ្ជបូរណសន្តិ សុភមង្គលា សិរីវិបុលា
ខេមរាស្ត្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី

«យោងតាមសេចក្តីក្រាបបង្គំទូលថ្វាយ របស់សម្តេចនាយករដ្ឋមន្ត្រី នៃរាជរដ្ឋាភិបាលកម្ពុជា»

## តែងតាំង

ព្រះមហាសុមេធាធិបតី នន ងែត
សម្តេចព្រះសង្ឃរាជគណៈមហានិកាយ នៃព្រះរាជាណាចក្រកម្ពុជា

ជា

សម្តេចព្រះអគ្គមហាសង្ឃរាជាធិបតី សម្តេចព្រះមហាសង្ឃរាជ
នៃព្រះរាជាណាចក្រកម្ពុជា

ព្រះហស្តលេខា និងព្រះរាជលញ្ឆករ
នរោត្តម សីហមុនី

៣៧៧.០៦០៤.២០៩

ធ្វើនៅព្រះបរមរាជវាំង រាជធានីភ្នំពេញ, ថ្ងៃទី ២៥ ខែមេសា ឆ្នាំ២០០៦

លេខ: ១៩៥. ច.ល
ដើម្បីចម្លងចែកជូន
រាជធានីភ្នំពេញ ថ្ងៃទី ០៣ ខែឧសភា ឆ្នាំ២០០៦
អគ្គលេខាធិការរាជរដ្ឋាភិបាល
[illegible]

# ឧបសម្ព័ន្ធទី២

សម្តេចព្រះ នរោត្តម សីហនុ

ព្រះប្រមុខរដ្ឋ

ប្រធានក្រុមប្រឹក្សាជាតិជាន់ខ្ពស់ កម្ពុជា

យោងតាមសេចក្តីស្នើរបស់ ឯកឧត្តមប្រធាន ជា ស៊ីម

ទ្រង់ព្រះករុណា មានមហាកិត្តិយស តម្លើងនូវ ព្រះឋានៈ នៃ សម្តេចព្រះគ្រូ
ជួរ ស្រី ចន្ទរីកា ជា

សម្តេច ព្រះសង្ឃរាជ គណៈធម្មយុត្តិកនិកាយ
នៃ កម្ពុជា

ធ្វើនៅ រាជធានីភ្នំពេញ ថ្ងៃទី ៧ ខែធ្នូ ឆ្នាំ ១៩៩១

ន.សីហនុ

នរោត្តម សីហនុ

# ព្រះរាជក្រឹត្យ

នស/រកត/១០០៧/៥៣៨

យើង

ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី
សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមរារដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ
ខេមររាជនា សមូហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា
ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី

- បានទ្រង់យលរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជសាររបស់សម្តេច ព្រះនរោត្តម សីហនុ ព្រះប្រមុខរដ្ឋ ប្រធានក្រុមប្រឹក្សាជាតិជាន់ខ្ពស់កម្ពុជា ចុះថ្ងៃទី ០៧ ខែ ធ្នូ ឆ្នាំ ១៩៩១ ស្តីពីការតម្លើងព្រះឋានៈ ជា សម្តេចព្រះសង្ឃរាជគណៈធម្មយុត្តិកនិកាយនៃកម្ពុជា ។

ព្រះរាជក្រឹត្យ

ប្រោសព្រះរាជទាន

មាត្រា ១ : ថ្វាយព្រះគោរមងារ សម្តេចព្រះសុគន្ធាធិបតី បួរ គ្រី សម្តេចព្រះសង្ឃរាជគណៈធម្មយុត្តិកនិកាយនៃកម្ពុជា ជា សម្តេចព្រះអភិសិរីសុគន្ធាមហាសង្ឃរាជាធិបតី សម្តេចព្រះមហាសង្ឃរាជនៃគណៈធម្មយុត្តិកនិកាយ នៃព្រះរាជាណាចក្រកម្ពុជា ។

មាត្រា ២ : ស័ព្ទប្រើចំពោះ សម្តេចព្រះអភិសិរីសុគន្ធាមហាសង្ឃរាជាធិបតី សម្តេចព្រះមហាសង្ឃរាជនៃគណៈធម្មយុត្តិកនិកាយ នៃព្រះរាជាណាចក្រកម្ពុជា ជារាជស័ព្ទ ហើយព្រះអង្គមានសិទ្ធិប្រើឆ័ត្រយសពិសេស ។

មាត្រា ៣ : ព្រះរាជក្រឹត្យនេះចូលជាធរមាន ចាប់ពីថ្ងៃឡាយព្រះហស្ថលេខានេះតទៅ ។

៣រល.០៧១០.៥៦៧

នរោត្តម សីហមុនី

នរោត្តម សីហមុនី

ធ្វើនៅព្រះបរមរាជវាំង រាជធានីភ្នំពេញ ថ្ងៃទី ២៦ ខែ តុលា ឆ្នាំ ២០០៧

# ឧបសម្ព័ន្ធទី៣

# ព្រះរាជក្រឹត្យ

នស/រកត/០៥០៦/២០៧

យើង

ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី
សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមរដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ
ខេមរាជនា សមូហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា
ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី

- បានទ្រង់យល់រដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/០៧០៤/១២៤ ចុះថ្ងៃទី ១៥ ខែ កក្កដា ឆ្នាំ ២០០៤ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/០១៩៦/១៨ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីការបង្កើតក្រសួងធម្មការ និងសាសនា
- បានទ្រង់យល់សេចក្តីក្រាបបង្គំទូលថ្វាយ របស់សម្តេចនាយករដ្ឋមន្ត្រី នៃរាជរដ្ឋាភិបាលកម្ពុជា

## ត្រាស់បង្គាប់

មាត្រា ១ : ត្រូវបានបង្កើត **គណៈសង្ឃនាយក នៃព្រះរាជាណាចក្រកម្ពុជា** ។

មាត្រា ២ : ត្រូវបានតែងតាំងសមាសភាពគណៈសង្ឃនាយក នៃព្រះរាជាណាចក្រកម្ពុជា ដូចមានរាយព្រះនាមខាងក្រោម :

១- សម្តេចព្រះពោធិវ័ង្ស **ឥន្ទ វ៉ែត** ព្រះរាជាគណៈថ្នាក់ឯក ជាសម្តេចព្រះមហាសុមេធាធិបតី ព្រះសង្ឃនាយក នៃព្រះរាជាណាចក្រកម្ពុជា ។

២- សម្តេចព្រះធម្មលិខិត **លាសំ ឡាយ** ព្រះរាជាគណៈថ្នាក់ឯក ជាសម្តេចព្រះធម្មលិខិត ព្រះសង្ឃនាយករង ទី ១ នៃព្រះរាជាណាចក្រកម្ពុជា ។

៣- សម្តេចព្រះវ័នរត **អំ លីមហេង** ព្រះរាជាគណៈថ្នាក់ឯក ជាសម្តេចព្រះពោធិវ័ង្ស ព្រះសង្ឃនាយករង ទី ២ នៃព្រះរាជាណាចក្រកម្ពុជា ។

៤- ព្រះឃោសធម្ម **ណយ ច្រឹក** ព្រះរាជាគណៈថ្នាក់ទោ ជាសម្តេចព្រះវ័នរត ព្រះរាជាគណៈថ្នាក់ឯក ព្រះសង្ឃនាយករង ទី ៣ នៃព្រះរាជាណាចក្រកម្ពុជា ។

មាត្រា ៣ : រាល់បទប្បញ្ញត្តិទាំងឡាយណា ដែលមានខ្លឹមសារផ្ទុយនឹងព្រះរាជក្រឹត្យនេះ ត្រូវចាត់ទុកជានិរាករណ៍ ។

មាត្រា ៤ : សម្តេចនាយករដ្ឋមន្ត្រី នៃរាជរដ្ឋាភិបាលកម្ពុជា ត្រូវទទួលបន្ទុកអនុវត្តឱ្យបានសំរេចនូវព្រះរាជក្រឹត្យនេះ ។

មាត្រា ៥ : ព្រះរាជក្រឹត្យនេះ ចូលជាធរមាន ចាប់ពីថ្ងៃឡាយព្រះហស្តលេខានេះ តទៅ ។

**ព្រះហស្តលេខា និងព្រះរាជលញ្ឆករ**

**នរោត្តម សីហមុនី**

៣៧៧.០៦០៤.២១៦

*ធ្វើនៅព្រះបរមរាជវាំង រាជធានីភ្នំពេញ, ថ្ងៃទី ៦ ខែ ឧសភា ឆ្នាំ ២០០៦*

លេខ: ១៩៨ ច.ល

**ដើម្បីចម្លងចេញផ្សាយ**

រាជធានីភ្នំពេញ ថ្ងៃទី ០៩ ខែឧសភា ឆ្នាំ២០០៦

អគ្គលេខាធិការរាជរដ្ឋាភិបាល

ស៊ីផាន

# ឧបសម្ព័ន្ធទី៤

## ព្រះរាជក្រឹត្យ

នស/រកត/០២២០/១០៧

**យើង**

**ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី**
**សមានគុណជាតិសាសនា ទេ្ចតខត្តិយា ខេមរជាតិរដ្ឋ ពុទ្ធិន្ទ្រាធរាមហាក្សត្រ**
**ខេមរាជនា សមូហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា**
**ខេមរាស្រីពិរាស្ដ្រ ព្រះចៅក្រុងកម្ពុជាធិបតី**

- បានទ្រង់យល់រដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/០៩១៨/៩២៥ ចុះថ្ងៃទី០៦ ខែកញ្ញា ឆ្នាំ២០១៨ ស្ដីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/០៦១៨/០១២ ចុះថ្ងៃទី ២៨ ខែ មិថុនា ឆ្នាំ ២០១៨ ដែលប្រកាសឱ្យប្រើច្បាប់ស្ដីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/០១៩៦/១៩ ចុះថ្ងៃទី ២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើប្រាស់ច្បាប់ ស្ដីពីការបង្កើតក្រសួងធម្មការ និងសាសនា
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/០៩០៦/២០៧ ចុះថ្ងៃទី ០៤ ខែឧសភា ឆ្នាំ២០០៦ ស្ដីពីការបង្កើតគណៈសង្ឃនាយក នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់សេចក្ដីក្រាបបង្គំទូលថ្វាយរបស់ សម្ដេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា

### ត្រាស់បង្គាប់

**មាត្រា ១ :** តម្លើង និងតែងតាំងព្រះឋានៈ សម្ដេចព្រះសង្ឃ នៃគណៈសង្ឃនាយក នៃព្រះរាជាណាចក្រកម្ពុជា ចំនួន ០៣ ព្រះអង្គ ៖

១- សម្ដេចព្រះពោធិវង្ស **អ៊ំ លឹមហេង** ឡើងជា សម្ដេចព្រះសង្ឃនាយករងទី១

២- សម្ដេចព្រះវន្ន័ត **ណយ ជ្រឹក** ឡើងជា សម្ដេចព្រះសង្ឃនាយករងទី២

៣- សម្ដេចព្រះឧត្តមវង្សា **មុខ វ៉ា** តែងតាំងជា សម្ដេចព្រះសង្ឃនាយករងទី៣

**មាត្រា ២ :** សម្ដេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា ត្រូវទទួលបន្ទុកអនុវត្តព្រះរាជក្រឹត្យនេះ ចាប់ពីថ្ងៃឡាយព្រះហស្ថលេខាតទៅ ។

ចរណ. ២០០៤.១៤០

នរោត្តម សីហមុនី (signature)

**នរោត្តម សីហមុនី**

*ធ្វើនៅព្រះបរមរាជវាំង, ថ្ងៃទី ១៤ ខែ កុម្ភៈ ឆ្នាំ ២០២០*

# ឧបសម្ព័ន្ធទី៥

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា

លេខ : ២៤ អនក្រ.បក

# អនុក្រឹត្យ

## ស្តីពី

## ការបង្កើតអគ្គលេខាធិការដ្ឋានថេរសភា នៃពុទ្ធសាសនា នៅព្រះរាជាណាចក្រកម្ពុជា

### រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៨/៩២៥ ចុះថ្ងៃទី០៦ ខែកញ្ញា ឆ្នាំ២០១៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦១៨/០១២ ចុះថ្ងៃទី២៨ ខែមិថុនា ឆ្នាំ២០១៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅ នៃគណៈរដ្ឋមន្ត្រី
- បានឃើញអនុក្រឹត្យលេខ ១៥៤ អនក្រ.បក ចុះថ្ងៃទី១១ ខែកក្កដា ឆ្នាំ២០១១ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួងធម្មការ និងសាសនា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៥០៦/២០៧ ចុះថ្ងៃទី០៤ ខែឧសភា ឆ្នាំ២០០៦ ស្តីពីការបង្កើតគណៈសង្ឃនាយក នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញអនុក្រឹត្យលេខ៥៧៦ អនក្រ.បក ចុះថ្ងៃទី២៥ ខែសីហា ឆ្នាំ២០០៦ ស្តីពីការបង្កើតថេរសភា នៃព្រះពុទ្ធសាសនា នៅព្រះរាជាណាចក្រកម្ពុជា
- យោងសំណើលេខ ០៥៣/២០ ស.ន.ក.ជ ចុះថ្ងៃទី០២ ខែមីនា ឆ្នាំ២០២០ របស់គណៈសង្ឃនាយក ស្តីពីការរៀបចំដំឡើងឋានៈ និងតែងតាំងមន្ត្រីសង្ឃជាន់ខ្ពស់ ក្នុងស្ថាប័នថេរសភា នៃពុទ្ធសាសនា នៅព្រះរាជាណាចក្រកម្ពុជា និងបង្កើតអគ្គលេខាធិការដ្ឋាន

### សម្រេច

**មាត្រា១ ៖** ត្រូវបានបង្កើតអគ្គលេខាធិការដ្ឋានថេរសភា នៃពុទ្ធសាសនា នៅព្រះរាជាណាចក្រកម្ពុជា។

**មាត្រា២ ៖** អគ្គលេខាធិការដ្ឋានថេរសភា នៃពុទ្ធសាសនា ជាសេនាធិការឱ្យថេរសភា នៃពុទ្ធសាសនា នៅព្រះរាជាណាចក្រកម្ពុជា ដឹកនាំដោយអគ្គលេខាធិការ ១អង្គ និងអគ្គលេខាធិការរង ២អង្គ។

**មាត្រា៣ ៖** អគ្គលេខាធិការដ្ឋាន មានតួនាទី និងភារកិច្ច ដូចខាងក្រោម ៖

-ដំណើរការកិច្ចការរដ្ឋបាលទូទៅរបស់ថេរសភា នៃពុទ្ធសាសនា នៅព្រះរាជាណាចក្រកម្ពុជា

-សម្របសម្រួលការប្រព្រឹត្តទៅរបស់ថេរសភា នៃពុទ្ធសាសនា

-ទទួលសំណុំអធិករណ៍ពីគណៈសង្ឃនាយក និងរៀបចំឯកសារ ប្រគេនថ្នាក់ដឹកនាំថេរសភា នៃពុទ្ធសាសនា ដើម្បីដោះស្រាយ និងជំនុំជម្រះ

-រៀបចំដំណើរបេសកកម្មរបស់ថ្នាក់ដឹកនាំថេរសភា នៃពុទ្ធសាសនា

-ចាត់ចែងរៀបចំការប្រជុំរបស់ថេរសភា នៃពុទ្ធសាសនា

-រៀបចំវគ្គបណ្តុះបណ្តាលដល់មន្ត្រីសង្ឃថេរសភារាជធានី-ខេត្ត ក្រុង-ស្រុក-ខណ្ឌ

-រៀបចំក្រុមចុះស្រាវជ្រាវស៊ើបអង្កេតអធិករណ៍តាមករណីជាក់ស្តែង

-ប្រមូលព័ត៌មានដែលទាក់ទងនឹងអធិករណ៍ពុទ្ធសាសនា

-ស្រាវជ្រាវ និងប្រមូលចងក្រងលិខិតបទដ្ឋានគតិយុត្តដែលពាក់ព័ន្ធ

-ធ្វើកំណត់ហេតុប្រជុំរបស់ថេរសភា នៃពុទ្ធសាសនា

-ធ្វើទំនាក់ទំនងជាមួយអាជ្ញាធរពាក់ព័ន្ធ និងតុលាការខាងអាណាចក្រ

-ការងារបញ្ជូនសំណុំអធិករណ៍ទៅថ្នាក់ដឹកនាំថេរសភា នៃពុទ្ធសាសនា

-ធ្វើទំនាក់ទំនងជាមួយលេខាធិការដ្ឋានគណៈសង្ឃនាយក

-ការងារទំនាក់ទំនងសាធារណៈ

-ការងារគ្រប់គ្រងបច្ចេកទេស សម្រាប់កម្មវិធីការងារជម្រះអធិករណ៍

-អនុវត្តការងារផ្សេងៗទៀត តាមការកំណត់នៃលិខិតបទដ្ឋានគតិយុត្ត

-ទទួលការងារផ្សេងៗទៀត តាមការចង្អុលបង្ហាញរបស់ប្រធានថេរសភា នៃពុទ្ធសាសនា

-ធ្វើរបាយការណ៍តាមរបបកំណត់ និងរបាយការណ៍ជំនាញ ថ្វាយទៅគណៈសង្ឃនាយក

**មាត្រា៤ ៖** បទប្បញ្ញត្តិទាំងឡាយណាដែលមានខ្លឹមសារផ្ទុយនឹងអនុក្រឹត្យនេះ ត្រូវទុកជានិរាករណ៍។

**មាត្រា៥ ៖** រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងធម្មការ និងសាសនា រដ្ឋមន្ត្រីគ្រប់ក្រសួងស្ថាប័នដែលពាក់ព័ន្ធ រាជធានី-ខេត្ត ត្រូវទទួលបន្ទុកអនុវត្តអនុក្រឹត្យនេះ ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

ថ្ងៃសុក្រ ១៣កើត ខែផល្គុន ឆ្នាំកុរ ឯកស័ក ព.ស.២៥៦៣

រាជធានីភ្នំពេញ ថ្ងៃទី...... ខែ...... ឆ្នាំ២០២០

**នាយករដ្ឋមន្ត្រី**

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

**កន្លែងទទួល**

-សម្តេចព្រះមហាសង្ឃរាជទាំងពីរគណៈ
-ក្រសួងព្រះបរមរាជវាំង
-អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ
-អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
-អគ្គលេខាធិការដ្ឋានរដ្ឋសភា
-ខុទ្ទកាល័យសម្តេចតេជោនាយករដ្ឋមន្ត្រី
-ខុទ្ទកាល័យទីស្តីការគណៈរដ្ឋមន្ត្រី
-ខុទ្ទកាល័យសម្តេច ឯកឧត្តម លោកជំទាវ ឧបនាយករដ្ឋមន្ត្រី
-សាលារាជធានី-ខេត្ត/ក្រុង-ស្រុក-ខណ្ឌ
-ថេរសភារាជធានី-ខេត្ត/ក្រុង-ស្រុក-ខណ្ឌ
-ដូចមាត្រា៥
-រាជកិច្ច
-ឯកសារ-កាលប្បវត្តិ

# ឧបសម្ព័ន្ធទី៦

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា
លេខ: ៥៧៦ អនក្រ.បក

# អនុក្រឹត្យ
## ស្តីពី
## ការបង្កើតថេរសភានៃព្រះពុទ្ធសាសនា
## នៅព្រះរាជាណាចក្រកម្ពុជា

---

## រាជរដ្ឋាភិបាល

-បានឃើញ រដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា.

-បានឃើញ ព្រះរាជក្រឹត្យលេខ នស/រកត/០៧០៤ ចុះថ្ងៃទី១៥/០៧/២០០៤ ស្តីពីការតែងតាំង រាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា ។

-បានឃើញ ព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០/០៧/១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី ។

-បានឃើញ សង្ឃប្រកាសលេខ ៣៣.គសរ.វ ចុះថ្ងៃទី០៧ ខែកញ្ញា ឆ្នាំ១៩៩៣ ស្តីពីការទទួលស្គាល់ ករណីកិច្ចនៃចៅអធិការ អនុគណ មេគណ ដែលអនុសំវច្ឆរមហាសន្និបាតទី ១៨ នៃមន្ត្រីសង្ឃសម្រាប់ឆ្នាំ ១៩៦២ បានសំរេចហើយនោះទុកជាករណីកិច្ចចរមាន ដើម្បីបន្តអនុវត្តសម្រាប់គ្រប់គ្រងកិច្ចការពុទ្ធសាសនាតទៅ ។

-បានឃើញ ដំណើរការប្រព្រឹត្តទៅនៃវិស័យព្រះពុទ្ធសាសនា នៅព្រះរាជាណាចក្រកម្ពុជា និងការកើតឡើងនូវអធិករណ៍ជាបន្តបន្ទាប់ នៅក្នុងជួរនៃអ្នកបួសក្នុងព្រះពុទ្ធសាសនា រវាងព្រះសង្ឃនិងព្រះសង្ឃ រវាងព្រះសង្ឃនិងគ្រហស្ថជាបុគ្គល ឬជាសមូហភាព ដែលជាហេតុនាំឱ្យមានផលប៉ះពាល់ដល់ព្រះពុទ្ធសាសនា ជាសាសនារបស់ជាតិ ។

-យោងតាមស្មារតីអង្គប្រជុំថ្ងៃទី ២១ ខែសីហា ឆ្នាំ២០០៦ ស្តីពីការបង្កើតថេរសភា នៃព្រះពុទ្ធសាសនា នៅព្រះរាជាណាចក្រកម្ពុជា

-តាមសំណូមពរ របស់សម្តេចព្រះអគ្គមហាសង្ឃរាជាធិបតី នន្ទ ងៀង សម្តេចព្រះមហាសង្ឃរាជនៃព្រះរាជាណាចក្រកម្ពុជា,

## សម្រេច

<u>មាត្រា</u> ១-បង្កើតថេរសភានៃព្រះពុទ្ធសាសនាមួយនៅព្រះរាជាណាចក្រកម្ពុជា ដែលជាអង្គការកំពូល សម្រាប់ដោះស្រាយអធិករណ៍នៃពុទ្ធសាសនា ដែលមានសមាសភាពដូចខាងក្រោមនេះ :

| | | | |
|---|---|---|---|
| ១- | សម្តេចព្រះធម្មលិខិត | លាស់ ឡាយ | ប្រធាន |
| ២- | សម្តេចព្រះឧត្តមមុនី | ឃោច ឈាងហោ | អនុប្រធានទី ១ |

៣- សម្តេចព្រះវន្ន័ត ណយ ច្រឹក អនុប្រធានទី ២
៤- សម្តេចព្រះពោធិវង្ស អំ លីមហេង អនុប្រធានទី ៣
៥- សម្តេចព្រះឧត្តមវង្សា ម្ចូង រ៉ា លេខាធិការ
៦- សម្តេចព្រះឧត្តមបញ្ញា ជួន ផន់ សមាជិក
៧- សម្តេចព្រះឧត្តមចរិយា ឈើង ប៊ុនឈា សមាជិក
៨- ព្រះមុនីកោសល ហ៊ិល សុវណ្ណ សមាជិក
៩- ព្រះសិរីសម្មតិវង្ស យឿង យ៉ារ សមាជិក

<u>មាត្រា</u> ២-ថេរសភានៃព្រះពុទ្ធសាសនាមានភារកិច្ចដូចតទៅនេះ :

-ជាសហធម្មិកសង្ឃជាន់ខ្ពស់របស់សម្តេចព្រះអគ្គមហាសង្ឃរាជាធិបតី និងសម្តេចព្រះមហាសុមេធាធិបតី ក្នុងបេសកកម្មជួយអភិបាលកិច្ចសង្ឃ ដោះស្រាយរម្ងាប់អធិករណ៍ ដែលកើតមានឡើងនៅទូទាំងព្រះរាជាណាចក្រកម្ពុជា។

-ជំនុំជម្រះអធិករណ៍ ដែលកើតឡើងរវាងសង្ឃ និងសង្ឃ, រវាងសង្ឃ និងគ្រហស្ថ ដែលវិនយធរ ធម្មធរ អនុគណ មេគណ សង្ឃនាយក ឬ សង្ឃរាជ ពុំអាចរំងាប់បាន។

-ចាត់តាំងតំណាងចុះទៅស្រាវជ្រាវស្វែងយល់រកហេតុផលពិតប្រាកដ អំពីប្រភពទំនាស់ អំពីយន្តការដោះស្រាយកន្លងមក ធ្វើរបាយការណ៍ឲ្យច្បាស់លាស់ និងសុក្រិដ្ឋាន។

-រកគ្រប់វិធីធ្វើការណែនាំ សម្រុះសម្រួល នូវភាគីបង្កអធិករណ៍ឱ្យយល់គ្នា ដោយប្រើប្រាស់គ្រប់វូបភាពសិល្បវិធី ក្នុងនាមជាសហធម្មិក និងជាភាតរភាពក្នុងពុទ្ធសាសនមណ្ឌល។

-ធ្វើការជំនុំពិភាក្សាគ្នាដោយម៉ត់ចត់ ច្រើនលើកច្រើនសារ ដោយផ្អែកលើគោលការណ៍ធម្មវិន័យ និងច្បាប់របស់រដ្ឋ ថ្លឹងថ្លែងគ្រប់ទិដ្ឋភាព ទើបធ្វើសេចក្តីសំរេចកាត់ក្តីជាចុងក្រោយ ដោយធ្វើឱ្យភាគីនិមួយៗ អាចទទួលយកបានដោយគ្មានការរង្កៀស។

-ត្រូវមានឯកភាពក្នុងការរម្ងាប់អធិករណ៍និមួយៗ ដោយឈរលើទស្សនៈគ្រប់ជ្រុងជ្រោយលើមូលដ្ឋាននៃព្រះវិន័យពុទ្ធសាសនា និងច្បាប់របស់រដ្ឋ មិនលុះដោយអំណាចអគតិធម៌ទាំង ៤។

-ទទួលបំពេញភារកិច្ចផ្សេងៗទៀត ដែលសម្តេចព្រះអគ្គមហាសង្ឃរាជាធិបតី និងសម្តេចព្រះមហាសុមេធាធិបតី តម្រូវឱ្យជួយដោះស្រាយ។

<u>មាត្រា</u> ៣-ថេរសភានៃព្រះពុទ្ធសាសនា ត្រូវរៀបចំលេខាធិការដ្ឋានមួយ ដឹកនាំដោយសម្តេចព្រះឧត្តមវង្សា ម្ចូង រ៉ា និងមានសមាជិកមួយចំនួន ជាជំនួយការ។

<u>មាត្រា</u> ៤-ថេរសភានៃព្រះពុទ្ធសាសនា មានសិទ្ធិប្រើប្រាស់ត្រាដោយឡែក សំរាប់ដំណើរការ។

<u>មាត្រា</u> ៥-រដ្ឋមន្ត្រីទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងធម្មការនិងសាសនា រដ្ឋមន្ត្រី រដ្ឋលេខាធិការពាក់ព័ន្ធ គ្រប់ខេត្ត-ក្រុង និងសមាសភាពដូចក្នុងមាត្រា ១ ត្រូវទទួលអនុវត្តតាមអនុក្រឹត្យនេះ។

<u>មាត្រា</u> ៦-បទប្បញ្ញត្តិទាំងឡាយណាផ្ទុយពីអនុក្រឹត្យនេះ ត្រូវទុកជានិរាករណ៍។

<u>មាត្រា</u> ៧-អនុក្រឹត្យនេះ មានប្រសិទ្ធភាពចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី ... ខែ ... ឆ្នាំ ២០០៦

ហ៊ុន សែន

<u>កន្លែងទទួល</u>
- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- អគ្គលេខាធិការរាជរដ្ឋាភិបាល
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- ដូចមាត្រា ៥
- ឯកសារ-កាលប្បវត្តិ

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា

លេខ: ៧៨០ អនក្រ.បក

# អនុក្រឹត្យ
## ស្តីពី
## ការបង្កើតថេរសភានៃព្រះពុទ្ធសាសនានៃគណៈធម្មយុត្តិកនិកាយ នៃព្រះរាជាណាចក្រកម្ពុជា

---

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៣/៩០៣ ចុះថ្ងៃទី២៤ ខែកញ្ញា ឆ្នាំ២០១៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដាឆ្នាំ១៩៩៤ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃទីស្តីការគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/១៩ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងធម្មការ និងសាសនា
- បានឃើញអនុក្រឹត្យលេខ ១៥៤ ចុះថ្ងៃទី១១ ខែកក្កដា ឆ្នាំ២០១១ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួងធម្មការ និងសាសនា
- យោងតាមសំណូមពររបស់សម្តេចព្រះអភិសិរីសុគន្ធាមហាសង្ឃរាជាធិបតី បួរ គ្រី សម្តេចព្រះមហាសង្ឃរាជ នៃគណៈធម្មយុត្តិកនិកាយនៃព្រះរាជាណាចក្រកម្ពុជា
- យោងតាមសំណើរបស់រដ្ឋមន្ត្រីក្រសួងធម្មការ និងសាសនា

## សម្រេច

**មាត្រា ១ :** បង្កើតថេរសភានៃព្រះពុទ្ធសាសនានៃគណៈធម្មយុត្តិកនិកាយ ដែលជាអង្គការកំពូលសម្រាប់ជំនុំជម្រះដោះស្រាយអធិករណ៍ ដែលមានសមាសភាពដូចខាងក្រោម៖

| | | |
|---|---|---|
| ១-សម្តេចព្រះពុទ្ធាចារ្យ | **ទូច សុខខោហោរ** | ប្រធាន |
| ២-ព្រះមហារាជធម្ម | **ផន្យ ឆេឆេតា** | អនុប្រធានទី១ |
| ៣-ព្រះមហាព្រហ្មមុនី | **គីម សុផា** | អនុប្រធានទី២ |
| ៤-ព្រះអរិយវង្ស | **គង់ ច័ន្ទថុល** | សមាជិក |
| ៥-ព្រះធម្មវរោត្តម | **ទូច សាឆន** | សមាជិក |
| ៦-ព្រះវជិរមេធា | **ល្បឿន ហារុនី** | សមាជិក |
| ៧-ព្រះគ្រូមង្គលមុនី | **ឈិន ហាន** | សមាជិក |
| ៨-ព្រះគ្រូធម្មរាជចរិយា | **ទូន ស្តេចតន្ត្រី** | លេខាធិការ |
| ៩-ព្រះគ្រូទីបញ្ញាណមុនី | **ខេន ស៊ាខណ៍** | លេខាធិការរង ។ |

**មាត្រា ២ :** ថេរសភានៃព្រះពុទ្ធសាសនានៃគណៈធម្មយុត្តិកនិកាយ មានភារកិច្ចដូចខាងក្រោម៖

- ជាសហធម្មិកសង្ឃជាន់ខ្ពស់របស់សម្តេចព្រះអភិសិរីសុគន្ធាមហាសង្ឃរាជាធិបតី សម្តេចព្រះមហាសង្ឃរាជនៃគណៈធម្មយុត្តិកនិកាយ ក្នុងបេសកកម្មជួយអភិបាលកិច្ចសង្ឃជំនុំជម្រះ និងដោះស្រាយរាល់អធិករណ៍ដែលកើតមានឡើងនៅទូទាំងព្រះរាជាណាចក្រកម្ពុជា ។
- ជំនុំជម្រះអធិករណ៍ដែលកើតមានឡើងរវាងសង្ឃនិងសង្ឃ រវាងសង្ឃនិងគ្រហស្ថ ដែលវិន័យធរ ធម្មធរ អនុគណ មេគណ គណៈសង្ឃនៃគណៈធម្មយុត្តិកនិកាយ មិនរកចរម្ងាប់បាន ។

- ចាត់តាំងតំណាងចុះទៅស្រាវជ្រាវ ស្វែងយល់រកហេតុផលពិតប្រាកដអំពីប្រភពទំនាស់អំពីយន្តការដោះស្រាយកន្លងមកធ្វើរបាយការណ៍ច្បាស់លាស់ និងសន្និដ្ឋាន ។
- រកគ្រប់វិធី ធ្វើការណែនាំ សម្របសម្រួលនូវភាគីបង្កអធិករណ៍ឲ្យយល់គ្នាដោយប្រើប្រាស់គ្រប់រូបភាពសិល្បវិធី ក្នុងនាមជាសហធម្មិក និងជាភាតរភាពក្នុងពុទ្ធសាសនមណ្ឌល ។
- ធ្វើការជំនុំពិភាក្សាគ្នាដោយមិត្តចិត្ត ច្រើនលើកច្រើនសារ ដោយផ្អែកលើគោលការណ៍ធម្មវិន័យ និងច្បាប់របស់រដ្ឋ ថ្លឹងថ្លែងគ្រប់ទិដ្ឋភាព ទើបធ្វើសេចក្តីសម្រេចកាត់ក្តីជាចុងក្រោយ ដោយធ្វើឲ្យភាគីនីមួយៗអាចទទួលយកបានដោយគ្មានការរង្កៀស ។
- ត្រូវមានតម្លាភាពក្នុងការរម្ងាប់អធិករណ៍នីមួយៗ ដោយឈរលើទស្សនៈគ្រប់ជ្រុងជ្រោយលើមូលដ្ឋាននៃព្រះវិន័យពុទ្ធសាសនា និងច្បាប់របស់រដ្ឋ មិនលុះដោយអំណាចអគតិធម៌ទាំង៤ ។
- ទទួលបំពេញភារកិច្ចផ្សេងៗទៀត ដែលសម្តេចព្រះអភិសិរីសុគន្ធាមហាសង្ឃរាជាធិបតី សម្តេចព្រះមហាសង្ឃរាជនៃគណៈធម្មយុត្តិកនិកាយ ឬក្រសួងធម្មការ និងសាសនា ប្រគល់ឲ្យពិនិត្យដោះស្រាយ ។
- ក្នុងការដោះស្រាយអធិករណ៍ត្រូវមានតំណាងមន្ទីរធម្មការ និងសាសនារាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ នៅនឹងកន្លែងអធិករណ៍ ចូលរួមជាអ្នកពិគ្រោះយោបល់ និងអង្កេតការណ៍ក្នុងការដោះស្រាយរម្ងាប់អធិករណ៍នោះ ។
- ថេរសភានៃព្រះពុទ្ធសាសនានៃគណៈធម្មយុត្តិកនិកាយ ត្រូវធ្វើរបាយការណ៍អំពីករណីអធិករណ៍ និងករណីបានជំនុំជម្រះដោះស្រាយអធិករណ៍នីមួយៗ បញ្ជូនមកសម្តេចព្រះអភិសិរីសុគន្ធាមហាសង្ឃរាជាធិបតី សម្តេចព្រះមហាសង្ឃរាជនៃគណៈធម្មយុត្តិកនិកាយ និងក្រសួងធម្មការ និងសាសនា ដើម្បីមានមុខការបន្ត ។

**មាត្រា ៣ :** ថេរសភានៃព្រះពុទ្ធសាសនានៃគណៈធម្មយុត្តិកនិកាយ ត្រូវរៀបចំលេខាធិការដ្ឋានមួយដឹកនាំដោយព្រះប្រធាន ០១ រូប និងមានសមាជិកមួយចំនួនជាជំនួយការ តាមការចាំបាច់ ដែលត្រូវកំណត់ដោយប្រកាសរបស់ក្រសួងធម្មការ និងសាសនា ។

**មាត្រា ៤ :** ថេរសភានៃព្រះពុទ្ធសាសនានៃគណៈធម្មយុត្តិកនិកាយ មានសិទ្ធិប្រើប្រាស់ត្រាដោយឡែកសម្រាប់ដំណើរការ ។

**មាត្រា ៥ :** បទបញ្ញត្តិទាំងឡាយណាដែលផ្ទុយពីអនុក្រឹត្យនេះ ត្រូវទុកជានិរាករណ៍។

**មាត្រា ៦ :** រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងធម្មការ និងសាសនា រដ្ឋមន្ត្រីគ្រប់ក្រសួង និងប្រធានស្ថាប័នដែលពាក់ព័ន្ធ គ្រប់រាជធានី ខេត្ត និងសមាសភាពដូចមានចែងក្នុងមាត្រា ១ ត្រូវទទួលអនុវត្តតាមអនុក្រឹត្យនេះ ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី ៣១ ខែ តុលា ឆ្នាំ២០១៤

**នាយករដ្ឋមន្ត្រី**

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

បានយកសេចក្តីគោរពជូន

សម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រី

នៃព្រះរាជាណាចក្រកម្ពុជា សូមចុះហត្ថលេខា

**រដ្ឋមន្ត្រីក្រសួងធម្មការ និងសាសនា**

**មិន ខិន**

**កន្លែងទទួល**
- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- អគ្គលេខាធិការដ្ឋានរាជរដ្ឋាភិបាល
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យឧបនាយករដ្ឋមន្ត្រី
- ដូចមាត្រា៦
- រាជកិច្ច
- ឯកសារ-កាលប្បវត្តិ

# ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា

លេខ: ៣៤ អនក្រ.បក

# អនុក្រឹត្យ

## ស្តីពី

## ការបង្កើតថេរសភារាជធានី-ខេត្ត/ក្រុង-ស្រុក-ខណ្ឌ នៃព្រះពុទ្ធសាសនាថេរវាទ នៅព្រះរាជាណាចក្រកម្ពុជា

---

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩០៨/១០៥៥ ចុះថ្ងៃទី២៥/០៩/២០០៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា ។
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០/០៧/១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី ។
- បានឃើញព្រះរាជក្រម លេខ នស/រកម/០១៩៦/១៥ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីការបង្កើតក្រសួងធម្មការ និងសាសនា
- ព្រះរាជក្រឹត្យ លេខ នស/រកត/០៥០៦/២០៧ ចុះថ្ងៃទី០៤ ខែឧសភា ឆ្នាំ ២០០៦ ស្តីពីការបង្កើតគណៈសង្ឃនាយក នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញអនុក្រឹត្យ លេខ ១៣ អនក្រ.បក ចុះថ្ងៃទី ០៩ ខែ កុម្ភៈ ឆ្នាំ ១៩៩៨ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួងធម្មការ និងសាសនា
- បានឃើញអនុក្រឹត្យលេខ ៥៧៦ អនក្រ.តត ចុះថ្ងៃទី ២៤/០៨/២០០៦ ស្តីពីការបង្កើតថេរសភា នៃព្រះពុទ្ធសាសនា នៅព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជសង្ឃប្រកាស លេខ ០០១/០៦ ម.ស.រ.ធ.ត ចុះថ្ងៃទី ២៤ ខែសីហា ឆ្នាំ ព.ស ២៥៥០ / គ.ស ២០០៦ ស្តីពីការកំណត់បែងចែកភារកិច្ចសម្តេចព្រះអគ្គមហាសង្ឃរាជាធិបតី សម្តេចព្រះមហាសង្ឃរាជ និងសម្តេចព្រះមហាសុមេធាធិបតី ព្រះសង្ឃនាយក នៃព្រះរាជាណាចក្រកម្ពុជា ។
- បានឃើញសង្ឃប្រកាសលេខ ៣៣.សករ.រ ចុះថ្ងៃទី ០៧ ខែកញ្ញា ឆ្នាំ១៩៩៣ ស្តីពីការទទួលស្គាល់ករណីយកិច្ចនៃចៅអធិការ អនុគណ មេគណ ដែលអនុសំវច្ឆរមហាសន្និបាតទី ១៨ នៃមន្ត្រីសង្ឃសម្រាប់ឆ្នាំ១៩៦២ បានសំរេចហើយនោះទុកជាករណីយកិច្ចចរមាន ដើម្បីបន្តអនុវត្តសម្រាប់គ្រប់គ្រងកិច្ចការពុទ្ធសាសនាតទៅ
- យោងតាមសំណើរបស់រដ្ឋមន្ត្រី ក្រសួងធម្មការ និងសាសនា

# ស ម្រេ ច

**មាត្រា១** : ត្រូវបានបង្កើតថេរសភារាជធានី-ខេត្ត/ក្រុង-ស្រុក-ខណ្ឌ នៃព្រះពុទ្ធសាសនាថេរវាទ នៅព្រះរាជាណាចក្រកម្ពុជា ជាសហធម្មិក ឱ្យថេរសភា នៃព្រះពុទ្ធសាសនា នៅព្រះរាជាណាចក្រកម្ពុជា ដើម្បីជំនុំជម្រះ ដោះស្រាយអធិករណ៍ ដែលមានសមាសភាព ដូចខាងក្រោមនេះ :

**ក. ថេរសភារាជធានី-ខេត្ត**

| | |
|---|---|
| ១- ព្រះមេគណរាជធានី-ខេត្ត | ប្រធាន |
| ២- ព្រះបាឡាត់គណរាជធានី-ខេត្ត | អនុប្រធានទី ១ |
| ៣- ព្រះវិន័យធរគណរាជធានី-ខេត្ត | អនុប្រធានទី ២ |
| ៤- ព្រះធម្មធរគណរាជធានី-ខេត្ត | សមាជិក |
| ៥- ព្រះសមុហ៍គណរាជធានី-ខេត្ត | សមាជិក |
| ៦- ព្រះលេខាគណរាជធានី-ខេត្ត | សមាជិក |

**ខ. ថេរសភាក្រុង-ស្រុក-ខណ្ឌ**

| | |
|---|---|
| ១- ព្រះអនុគណក្រុង-ស្រុក-ខណ្ឌ | ប្រធាន |
| ២- ព្រះវិន័យធរអនុគណក្រុង-ស្រុក-ខណ្ឌ | អនុប្រធានទី ១ |
| ៣- ព្រះធម្មធរអនុគណក្រុង-ស្រុក-ខណ្ឌ | អនុប្រធានទី ២ |
| ៤- ព្រះសមុហ៍អនុគណក្រុង-ស្រុក-ខណ្ឌ | សមាជិក |
| ៥- ព្រះលេខាអនុគណក្រុង-ស្រុក-ខណ្ឌ | សមាជិក |

**មាត្រា២** : ថេរសភារាជធានី-ខេត្ត/ក្រុង-ស្រុក-ខណ្ឌ នៃព្រះពុទ្ធសាសនាថេរវាទ នៅព្រះរាជាណាចក្រកម្ពុជា មានភារកិច្ចដូច ខាងក្រោម:

**ក. ថេរសភារាជធានី-ខេត្ត**

- ជាសហធម្មិកសង្ឃរបស់ថេរសភានៃព្រះពុទ្ធសាសនា នៅព្រះរាជាណាចក្រកម្ពុជា ក្នុងបេសកកម្ម ជួយអភិបាលកិច្ចសង្ឃ ជំនុំជម្រះ និងដោះស្រាយរម្ងាប់អធិករណ៍ ដែលកើតមានឡើងនៅរាជធានី-ខេត្ត និងតាមសំណើបញ្ជូនរបស់ថេរសភាក្រុង-ស្រុក-ខណ្ឌ
- ជំនុំជម្រះអធិករណ៍ ដែលកើតឡើងរវាងសង្ឃនិងសង្ឃ រវាងសង្ឃនិងគ្រហស្ថ ដែលកើតមានឡើងនៅតាមវត្តអារាម ឬ អាស្រម
- ចាត់តាំងតំណាងចុះទៅស្រាវជ្រាវស្វែងយល់រកហេតុផលពិតប្រាកដ អំពីប្រភពទំនាស់អំពីយន្តការដោះស្រាយកន្លងមក ធ្វើរបាយការណ៍ច្បាស់លាស់ និងសន្និដ្ឋាន

- រកគ្រប់វិធី ធ្វើការណែនាំ កោះហៅ សម្រុះសម្រួលនូវភាគីបង្កអធិករណ៍ឱ្យយល់គ្នា ដោយប្រើប្រាស់គ្រប់រូបភាព សិល្បវិធី ក្នុងនាមជាសហធម្មិក និងជាភាតរភាព ក្នុងពុទ្ធសាសនមណ្ឌល
- ធ្វើការជំនុំពិភាក្សាគ្នាដោយម៉ត់ចត់ ច្រើនលើកច្រើនសារ ដោយផ្អែកលើគោលការណ៍ធម្មវិន័យ និងច្បាប់របស់រដ្ឋ ថ្លឹងថ្លែងគ្រប់ទិដ្ឋភាព ធ្វើសេចក្តីសម្រេចកាត់ក្តីជាចុងក្រោយ ដោយធ្វើឱ្យភាគីនីមួយៗ អាចទទួលយកបានដោយគ្មានការរង្កៀស
- ត្រូវមានតម្លាភាពក្នុងការរម្ងាប់អធិករណ៍និមួយៗ ដោយឈរលើទស្សនៈ គ្រប់ជ្រុងជ្រោយលើមូលដ្ឋាននៃព្រះវិន័យពុទ្ធសាសនា និងច្បាប់របស់រដ្ឋ មិនលុះដោយអំណាច អគតិធម៌ទាំង ៤
- អធិករណ៍ដែលថេរសភារាជធានី-ខេត្ត មិនអាចដោះស្រាយបាន ត្រូវធ្វើរបាយការណ៍បញ្ជូនមកគណៈសង្ឃនាយក នៃព្រះរាជាណាចក្រកម្ពុជា ដើម្បីដោះស្រាយ ។
- អធិករណ៍ដែលគណៈសង្ឃនាយក នៃព្រះរាជាណាចក្រកម្ពុជា មិនអាចដោះស្រាយបាន ត្រូវធ្វើរបាយការណ៍បញ្ជូនមកថេរសភា នៃព្រះពុទ្ធសាសនា នៅព្រះរាជាណាចក្រកម្ពុជា ដើម្បីជំនុំជម្រះដោះស្រាយបិទផ្លូវតវ៉ា
- ទទួលបំពេញភារកិច្ចផ្សេងៗទៀត ដែលថេរសភា នៃព្រះពុទ្ធសាសនា នៅព្រះរាជាណាចក្រកម្ពុជា ស្នើឱ្យជួយដោះស្រាយ
- ការដោះស្រាយអធិករណ៍ត្រូវមានតំណាងមន្ទីរធម្មការ និងសាសនារាជធានី-ខេត្ត ជាអ្នកពិគ្រោះយោបល់ និងសង្កេតការ ក្នុងការដោះស្រាយអធិករណ៍ ។

## ខ. ថេរសភាក្រុង-ស្រុក-ខណ្ឌ

- ជាសហធម្មិកសង្ឃរបស់ថេរសភានៃព្រះពុទ្ធសាសនារាជធានី/ខេត្ត ក្នុងបេសកកម្មជួយអភិបាលកិច្ចសង្ឃជំនុំជម្រះនិងដោះស្រាយរម្ងាប់អធិករណ៍ដែលកើតមានឡើងនៅក្រុង-ស្រុក-ខ័ណ្ឌ
- ជំនុំជម្រះអធិករណ៍ ដែលកើតឡើងរវាងសង្ឃនិងសង្ឃ រវាងសង្ឃនិងគ្រហស្ថ ដែលកើតមានឡើងនៅតាមវត្តអារាម ឬ អាស្រម
- ចាត់តាំងតំណាងចុះទៅស្រាវជ្រាវស្វែងយល់រកហេតុផលពិតប្រាកដ អំពីប្រភពទំនាស់អំពីយន្តការដោះស្រាយកន្លងមក ធ្វើរបាយការណ៍ឲ្យាស់លាស់ និងសន្និដ្ឋាន
- រកគ្រប់វិធី ធ្វើការណែនាំ កោះហៅ សម្រុះសម្រួលនូវភាគីបង្កអធិករណ៍ឱ្យយល់គ្នា ដោយប្រើប្រាស់គ្រប់រូបភាព សិល្បវិធី ក្នុងនាមជាសហធម្មិក និងជាភាតរភាព ក្នុងពុទ្ធសាសនមណ្ឌល
- ធ្វើការជំនុំពិភាក្សាគ្នាដោយម៉ត់ចត់ ច្រើនលើកច្រើនសារ ដោយផ្អែកលើគោលការណ៍ធម្មវិន័យ និងច្បាប់របស់រដ្ឋ ថ្លឹងថ្លែងគ្រប់ទិដ្ឋភាព ទើបធ្វើសេចក្តីសម្រេចកាត់ក្តីជាចុងក្រោយ ដោយធ្វើឱ្យភាគីនីមួយៗ អាចទទួលយកបានដោយគ្មានការរង្កៀស

- ត្រូវមានឥន្ទ្រិយភាពក្នុងការវិនិច្ឆ័យអធិករណ៍និមួយៗ ដោយឈរលើទស្សនៈ គ្រប់ជ្រុងជ្រោយលើមូលដ្ឋាននៃព្រះវិន័យពុទ្ធសាសនា និងច្បាប់របស់រដ្ឋ មិនលុះដោយអំណាចអគតិធម៌ទាំង ៤
- អធិករណ៍ដែលថេរសភាក្រុង-ស្រុក-ខ័ណ្ឌ មិនអាចដោះស្រាយបាន ត្រូវធ្វើរបាយការណ៍បញ្ជូនសុំណុំរឿងមកថេរសភារាជធានី-ខេត្ត នៃព្រះពុទ្ធសាសនាថេរវាទ នៅព្រះរាជាណាចក្រកម្ពុជា ដើម្បីដោះស្រាយ
- ទទួលបំពេញភារកិច្ចផ្សេងៗទៀត ដែលថេរសភា នៃព្រះពុទ្ធសាសនាថេរវាទ នៅព្រះរាជាណាចក្រកម្ពុជា និងថេរសភារាជធានី-ខេត្ត នៃព្រះពុទ្ធសាសនាថេរវាទ នៅព្រះរាជាណាចក្រកម្ពុជា ស្នើសុំឱ្យជួយដោះស្រាយ
- ការដោះស្រាយអធិករណ៍ត្រូវមានការិយាល័យធម្មការ និងសាសនា ជាអ្នកពិគ្រោះយោបល់ និងសង្កេតការ ក្នុងការដោះស្រាយអធិករណ៍ ។

**មាត្រា៣ :** ការតែងតាំងសមាសភាពថេរសភារាជធានី-ខេត្ត/ក្រុង-ស្រុក-ខណ្ឌ នៃព្រះពុទ្ធសាសនាថេរវាទ នៅព្រះរាជាណាចក្រកម្ពុជា ត្រូវអនុវត្តតាមគោរណីកាណ៏តែងតាំងក្នុងព្រះរាជសង្ឃប្រកាស លេខ ០០១/០៦ ម.ស.រ.ធ.គ ស្ដីពីការកំណត់បែងចែកភារកិច្ចសម្ដេចព្រះអគ្គមហាសង្ឃរាជាធិបតី សម្ដេចព្រះមហាសង្ឃរាជ និងសម្ដេចព្រះមហាសុមេធាធិបតី ព្រះសង្ឃនាយក ចុះថ្ងៃទី ២៤ ខែសីហា ឆ្នាំ ព.ស ២៥៥០ / គ.ស ២០០៦ ។

**មាត្រា៤ :** ថេរសភារាជធានី-ខេត្ត/ក្រុង-ស្រុក-ខណ្ឌ នៃព្រះពុទ្ធសាសនាថេរវាទ នៅព្រះរាជាណាចក្រកម្ពុជា ត្រូវរៀបចំលេខាធិការដ្ឋានមួយជាជំនួយការ ដែលដឹកនាំដោយព្រះសមុហ៍គណរាជធានី-ខេត្ត និងព្រះសមុហ៍អនុគណក្រុង-ស្រុក-ខណ្ឌ ជាលេខាធិការ ត្រូវធ្វើរបាយការណ៍ជាប្រចាំទូលថ្វាយតាមឋានានុក្រម មកគណៈសង្ឃនាយកនៃព្រះរាជាណាចក្រកម្ពុជា និងជូនក្រសួងធម្មការ និងសាសនា ជាប្រចាំខែ ត្រីមាស ឆមាស និងប្រចាំឆ្នាំ។

**មាត្រា៥ :** លេខាធិការដ្ឋានថេរសភារាជធានី-ខេត្ត/ក្រុង-ស្រុក-ខណ្ឌ នៃព្រះពុទ្ធសាសនាថេរវាទ នៅព្រះរាជាណាចក្រកម្ពុជា ត្រូវអនុវត្តភារកិច្ចរបស់ខ្លួន តាមព្រះសង្ឃប្រកាសរបស់គណៈសង្ឃនាយក នៃព្រះរាជាណាចក្រកម្ពុជា និងមានការយល់ព្រមពីក្រសួងធម្មការ និងសាសនា ។

**មាត្រា៦ :** ថេរសភារាជធានី-ខេត្ត/ក្រុង-ស្រុក-ខណ្ឌ នៃព្រះពុទ្ធសាសនាថេរវាទ នៅព្រះរាជាណាចក្រកម្ពុជា មានសិទ្ធិប្រើប្រាស់ត្រាដោយឡែករបស់ថេរសភារាជធានី-ខេត្ត/ក្រុង-ស្រុក-ខណ្ឌ នៃព្រះពុទ្ធសាសនាថេរវាទ នៅព្រះរាជាណាចក្រកម្ពុជា សំរាប់ប្រតិបត្តិការរបស់ខ្លួន។

**មាត្រា៧ :** បទប្បញ្ញត្តិទាំងឡាយណាផ្ទុយពីអនុក្រឹត្យនេះ ត្រូវទុកជានិរាករណ៍។

**មាត្រា៨ :** រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងធម្មការ និងសាសនា រដ្ឋមន្ត្រី រដ្ឋលេខាធិការ គ្រប់ក្រសួង-ស្ថាប័ន រាជធានី/ខេត្ត និងសាមីអង្គ ដូចមានចែងក្នុងមាត្រា១ ត្រូវអនុវត្តតាមអនុក្រឹត្យនេះ ចាប់ពីថ្ងៃចុះហត្ថលេខា តទៅ ។

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី ០៦ ខែ កុម្ភៈ ឆ្នាំ ២០០៩

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

បានយកសេចក្តីគោរពជូន
សម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រី
នៃព្រះរាជាណាចក្រកម្ពុជា សូមចុះហត្ថលេខា
រដ្ឋមន្ត្រី ក្រសួងធម្មការ និងសាសនា

**មិន ឃិន**

<u>**កន្លែងទទួល**</u>

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- អគ្គលេខាធិការគណៈរដ្ឋាភិបាល
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យឧបនាយករដ្ឋមន្ត្រី
- ដូចមាត្រា ៨
- រាជកិច្ច
- ឯកសារ-កាលប្បវត្តិ

# ឧបសម្ព័ន្ធទី៧

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា

លេខ: ១៥៤ អនក្រ.បក

# អនុក្រឹត្យ

## ស្តីពី

## ការរៀបចំនិងការប្រព្រឹត្តទៅរបស់ក្រសួងធម្មការនិងសាសនា

### រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩០៨/១០៥៥ ចុះថ្ងៃទី២៥ ខែកញ្ញា ឆ្នាំ២០០៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/១៥ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងធម្មការនិងសាសនា
- បានឃើញអនុក្រឹត្យលេខ២០ អនក្រ.បក ចុះថ្ងៃទី៣០ ខែមេសា ឆ្នាំ១៩៩៦ ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅរបស់ក្រសួងនិងរដ្ឋលេខាធិការដ្ឋាន
- បានឃើញអនុក្រឹត្យលេខ៤០ អនក្រ.បក ចុះថ្ងៃទី១៥ ខែកុម្ភៈ ឆ្នាំ២០០៥ ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃសវនកម្មផ្ទៃក្នុងនៅតាមបណ្តាស្ថាប័ន ក្រសួង និងសហគ្រាសសាធារណៈ
- បានទទួលការឯកភាពពីគណៈរដ្ឋមន្ត្រីក្នុងសម័យប្រជុំពេញអង្គ នាថ្ងៃទី២៤ ខែមិថុនា ឆ្នាំ២០១១

### សម្រេច

### ជំពូកទី១

### បទប្បញ្ញត្តិទូទៅ

**មាត្រា ១.-**

អនុក្រឹត្យនេះមានគោលបំណងកំណត់អំពីការរៀបចំនិងការប្រព្រឹត្តទៅរបស់ក្រសួងធម្មការ និងសាសនា។

**មាត្រា ២.-**

*អនុក្រឹត្យនេះមានគោលដៅដូចខាងក្រោម៖*

- រៀបចំបេសកកម្មនិងរចនាសម្ព័ន្ធគ្រប់គ្រងរបស់ក្រសួងធម្មការនិងសាសនា
- រៀបចំមុខងារនិងភារកិច្ចរបស់អង្គភាពនានានៃក្រសួងធម្មការនិងសាសនា
- ធានាគុណភាពនិងប្រសិទ្ធភាពនៃការងារក្នុងវិស័យធម្មការនិងសាសនា។

**មាត្រា ៣.-**

អនុក្រឹត្យនេះ មានវិសាលភាពអនុវត្តលើវិស័យធម្មការនិងសាសនា នៅគ្រប់អង្គភាពថ្នាក់កណ្តាល ថ្នាក់រាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ និងគ្រឹះស្ថានពុទ្ធិកសិក្សា។

## ជំពូកទី២
## បេសកកម្មនិងរចនាសម្ព័ន្ធ

**មាត្រា ៤.-**

ក្រសួងធម្មការនិងសាសនា មានបេសកកម្មដឹកនាំនិងគ្រប់គ្រងវិស័យធម្មការនិងសាសនា ពុទ្ធិកសិក្សា ការអប់រំ ការសិក្សា ស្រាវជ្រាវ វប្បធម៌ អក្សរសាស្ត្រ ប្រពៃណីទំនៀមទម្លាប់ និងការបោះពុម្ពផ្សាយនានាដែលទាក់ទងនឹងសាសនា។

**មាត្រា ៥.-**

ក្រសួងធម្មការនិងសាសនា មានមុខងារនិងភារកិច្ចដូចតទៅ៖

- កំណត់វិធានការដឹកនាំនិងគ្រប់គ្រងសាសនាទាំងអស់ ដែលមានទីតាំងនិងធ្វើសកម្មភាពនៅលើទឹកដីនៃព្រះរាជាណាចក្រកម្ពុជា ជាពិសេសយកចិត្តទុកដាក់លើព្រះពុទ្ធសាសនាដែលជាសាសនារបស់រដ្ឋ
- ណែនាំនិងត្រួតពិនិត្យអង្គការសាសនាក្រោមនិកាយ វត្តអារាម និកាយសាសនា មណ្ឌលសិក្សាស្រាវជ្រាវសាសនានានា និងរាល់អង្គការ សមាគមដែលមានចរិតសាសនា ឲ្យប្រតិបត្តិនិងធ្វើសកម្មភាពសាសនាស្របតាមច្បាប់របស់រដ្ឋ
- សម្របសម្រួលបរិស័ទគ្រប់សាសនាឲ្យមានសុខដុមនីយកម្ម និងលើកទឹកចិត្តដល់បរិស័ទឲ្យប្រតិបត្តិគោរពតាមក្រឹត្យវិន័យនិងពិធីសាសនារៀងៗខ្លួន មានសាមគ្គីភាពក្នុងរង្វង់សាសនារបស់ខ្លួន និងជាមួយអ្នកកាន់សាសនាផ្សេងៗ
- សម្របសម្រួលការងារពុទ្ធិកសិក្សា សំដៅបណ្តុះបណ្តាលធនធានមនុស្សក្នុងជួរព្រះសង្ឃ
- ធ្វើទំនាក់ទំនងនិងសហការយ៉ាងជិតស្និទ្ធជាមួយនឹងសម្តេចព្រះសង្ឃរាជទាំងពីរគណៈ គណៈសង្ឃនាយកនិងមេដឹកនាំពាហិរសាសនាក្នុងវិស័យកិច្ចការសាសនា
- រៀបចំគោលនយោបាយសម្រាប់ការគ្រប់គ្រងនិងរៀបចំរចនាសម្ព័ន្ធសាសនាគ្រប់និកាយទាំងអស់នៅក្នុងព្រះរាជាណាចក្រកម្ពុជា
- ពិនិត្យ សិក្សាស្រាវជ្រាវ បកប្រែ ចងក្រង ថែរក្សា បោះពុម្ព និងផ្សព្វផ្សាយឲ្យបានទូលំទូលាយ នូវសៀវភៅ ក្បួនច្បាប់ គម្ពីរដីកាស្តីពីធម៌អាថ៌ អក្សរសាស្ត្រ វប្បធម៌ សិល្បៈ ទំនៀមទម្លាប់ ពុទ្ធសាសនា និងសាសនាផ្សេងៗទៀត
- ផ្តល់អនុសាសន៍និងមានវិធានការសមស្របចំពោះការសំដែងសិល្បៈដែលអាចធ្វើឲ្យប៉ះពាល់ដល់វិស័យសាសនា។

- ពិនិត្យតាមដានការផ្សព្វផ្សាយធម៌អាថ៌និងឯកសារគ្រប់ប្រភេទមានជាអាទិ៍ រូបភាព សំឡេង និងសំណេរដែលទាក់ទងវិស័យសាសនាដោយសហការជាមួយក្រសួងស្ថាប័នពាក់ព័ន្ធ
- ពិនិត្យអនុញ្ញាតឲ្យបង្កើតឬបិទសកម្មភាពព្រះពុទ្ធសាសនា តាមការស្នើសុំរបស់គណៈសង្ឃនាយក
- ពិនិត្យអនុញ្ញាតឲ្យបង្កើតឬបិទសកម្មភាពឬស្នាក់ការពាហិរសាសនា
- ពិនិត្យនិងផ្តល់យោបល់ក្នុងការអនុញ្ញាតឲ្យបង្កើតឬបិទគ្រឹះស្ថានសាសនសិក្សា
- ជំរុញនិងលើកទឹកចិត្តឲ្យមានការសន្ទនាព្រះធម៌និងនាទីព្រះពុទ្ធសាសនាផ្សារភ្ជាប់សង្គម
- ទទួលស្គាល់ការតែងតាំងមន្ត្រីសង្ឃគ្រប់ឋានានុក្រម ដែលគណៈសង្ឃនាយកបានរៀបចំ
- ធ្វើសហប្រតិបត្តិការអន្តរជាតិលើវិស័យធម្មការនិងសាសនា សម្របសម្រួល និងជំរុញឲ្យមានការបណ្តុះបណ្តាលនិងធ្វើវិក្រឹតការគ្រូបង្រៀន សាស្ត្រាចារ្យពុទ្ធិកសិក្សា អាចារ្យ និងគណៈកម្មការវត្ត
- ចូលរួមក្នុងការធ្វើអធិការកិច្ចលើវិស័យសាសនា វិស័យសាសនសិក្សាធិការនិងដោះស្រាយអធិករណ៍
- ពិនិត្យនិងណែនាំការសាងសង់ ការរុះរើ ឬការផ្លាស់ប្តូរទីកន្លែង សំណង់សាសនានានាដោយសហការជាមួយស្ថាប័នពាក់ព័ន្ធ
- ជំរុញការបង្កើតបណ្ណាល័យនៅតាមវត្តអារាមនានា សម្រាប់ជាប្រយោជន៍ដល់សាធារណជនរួមទាំងបព្វជិត ទាំងគ្រហស្ថក្នុងព្រះរាជាណាចក្រកម្ពុជា
- លើកទឹកចិត្តឲ្យសាសនាទាំងអស់ ចូលរួមអភិវឌ្ឍសេដ្ឋកិច្ចនិងសង្គម ជំរុញវត្តអារាម និងវិហារសាសនានានា ឲ្យក្លាយជាមជ្ឈមណ្ឌលអប់រំខាងផ្នែកស្មារតី សីលធម៌ វប្បធម៌ និងសង្គមកិច្ច
- រក្សាឲ្យបាននូវសុខដុមនីយកម្មនិងសេរីភាពខាងជំនឿសាសនាទាំងអស់
- សិក្សាស្រាវជ្រាវនិងធ្វើស្ថិតិលើជំនឿនិងចំនួនជនជាតិដើមភាគតិច ដើម្បីអភិវឌ្ឍនិងអភិរក្ស
- ទទួលអនុវត្តភារកិច្ចផ្សេងទៀតដែលរាជរដ្ឋាភិបាលប្រគល់ជូន។

**មាត្រា ៦.-**

ក្រសួងធម្មការនិងសាសនា មានរចនាសម្ព័ន្ធដូចខាងក្រោម៖

១- អង្គភាពកណ្តាល
- អគ្គនាយកដ្ឋានកិច្ចការសាសនា
- អគ្គនាយកដ្ឋានរដ្ឋបាលនិងហិរញ្ញវត្ថុ
- អធិការដ្ឋាន
- នាយកដ្ឋានសវនកម្មផ្ទៃក្នុង
- ខុទ្ទកាល័យ

២- អង្គភាពមូលដ្ឋាន

៣- អគ្គាធិការដ្ឋានពុទ្ធិកសិក្សាជាតិ

អង្គការលេខក្រសួងធម្មការនិងសាសនា ជាឧបសម្ព័ន្ធ១ និងអង្គការលេខរបស់អគ្គាធិការដ្ឋានពុទ្ធិកសិក្សាជាតិ ជាឧបសម្ព័ន្ធ២ ហើយតារាងបច្ច័យសម្រាប់ចាត់ចែងតាម[illegible]ឧបសម្ព័ន្ធ៣ របស់អនុក្រឹត្យនេះ។

ព្រះអគ្គាធិការ ព្រះអគ្គាធិការរង អគ្គាធិការរង និងមន្ត្រីនៃអគ្គាធិការដ្ឋានពុទ្ធិកសិក្សាជាតិនៃព្រះរាជាណាចក្រកម្ពុជា ត្រូវបំពេញភារកិច្ចរបស់ខ្លួនដដែលរហូតដល់មានការតែងតាំងឬផ្ទេរទៅបំពេញភារកិច្ចថ្មីស្របតាមអនុក្រឹត្យនេះ។

## ជំពូកទី១២
## អវសានប្បញ្ញត្តិ

**មាត្រា ៣៤.-**

អនុក្រឹត្យលេខ១៣ អនក្រ.បក ចុះថ្ងៃទី១៩ ខែកុម្ភៈ ឆ្នាំ១៩៩៨ ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅរបស់ក្រសួងធម្មការនិងសាសនា អនុក្រឹត្យលេខ២៩ អនក្រ.បក ចុះថ្ងៃទី២៨ ខែមីនា ឆ្នាំ២០០២ ស្តីពីការធ្វើវិសោធនកម្ម មាត្រា៧ ជំពូក៣នៃអនុក្រឹត្យលេខ១៣ អនក្រ.បក ចុះថ្ងៃទី១៩ ខែកុម្ភៈ ឆ្នាំ១៩៩៨ ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅរបស់ក្រសួងធម្មការនិងសាសនា អនុក្រឹត្យលេខ៨៨ អនក្រ.បក ចុះថ្ងៃទី២៨ ខែសីហា ឆ្នាំ២០០៦ ស្តីពីការបង្កើតអគ្គាធិការដ្ឋានពុទ្ធិកសិក្សាជាតិនៃព្រះរាជាណាចក្រកម្ពុជា និងអនុក្រឹត្យលេខ១១២ អនក្រ.បក ចុះថ្ងៃទី២៨ ខែកក្កដា ឆ្នាំ២០០៩ ស្តីពីការបង្កើតនាយកដ្ឋានសវនកម្មផ្ទៃក្នុងនិងនាយកដ្ឋានសហប្រតិបត្តិការអន្តរជាតិនៃក្រសួងធម្មការនិងសាសនា និងបទប្បញ្ញត្តិទាំងឡាយណាដែលផ្ទុយនឹងអនុក្រឹត្យនេះ ត្រូវទុកជានិរាករណ៍។

**មាត្រា ៣៥.-**

រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ រដ្ឋមន្ត្រីក្រសួងធម្មការនិងសាសនា ព្រះអគ្គាធិការនៃអគ្គាធិការដ្ឋានពុទ្ធិកសិក្សាជាតិ រដ្ឋមន្ត្រី រដ្ឋលេខាធិការក្រសួង ស្ថាប័នពាក់ព័ន្ធ ត្រូវអនុវត្តអនុក្រឹត្យនេះ ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

រាជធានីភ្នំពេញ ថ្ងៃទី ១១ ខែ [illegible] ឆ្នាំ២០១១

នាយករដ្ឋមន្ត្រី

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

**កន្លែងទទួល៖**

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- អគ្គលេខាធិការរាជរដ្ឋាភិបាល
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យឯកឧត្តម លោកជំទាវឧបនាយករដ្ឋមន្ត្រី
- ដូចមាត្រា ៣៥
- រាជកិច្ច
- ឯកសារ កាលប្បវត្តិ

ក្រសួងធម្មការ និងសាសនា
អគ្គនាយកកិច្ចការសាសនា
នាយកដ្ឋានកិច្ចការព្រះពុទ្ធសាសនា

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

# ស្ថិតិវត្ត និងព្រះសង្ឃទូទាំងព្រះរាជាណាចក្រកម្ពុជា ឆ្នាំ២០១៨-២០១៩

| ល.រ | ឈ្មោះ រាជធានី-ខេត្ត | ចំនួនវត្ត | | | ចំនួនព្រះសង្ឃ | | | | | | |
|---|---|---|---|---|---|---|---|---|---|---|---|
| | | | | | | មហានិកាយ | | | ធម្មយុត្តិកនិកាយ | | |
| | | វត្តសរុប | មហានិកាយ | ធម្មយុត្តិក | ព្រះសង្ឃសរុប | ភិក្ខុ | សាមណេរ | សរុប | ភិក្ខុ | សាមណេរ | សរុប |
| ១ | ខេត្តបន្ទាយមានជ័យ | 246 | 237 | 9 | 4,541 | 1,343 | 2,980 | 4,323 | 70 | 148 | 218 |
| ២ | ខេត្តបាត់ដំបង | 381 | 365 | 16 | 5,471 | 1,759 | 3,486 | 5,245 | 102 | 124 | 226 |
| ៣ | ខេត្តកំពង់ចាម | 376 | 364 | 12 | 6,004 | 1,320 | 4,427 | 5,747 | 77 | 180 | 257 |
| ៤ | ខេត្តកំពង់ឆ្នាំង | 218 | 215 | 3 | 2,582 | 845 | 1,648 | 2,493 | 7 | 82 | 89 |
| ៥ | ខេត្តកំពង់ស្ពឺ | 289 | 271 | 18 | 3,825 | 1,046 | 2,528 | 3,574 | 90 | 161 | 251 |
| ៦ | ខេត្តកំពង់ធំ | 275 | 272 | 3 | 3,683 | 797 | 2,856 | 3,653 | 8 | 22 | 30 |
| ៧ | ខេត្តកំពត | 272 | 247 | 25 | 2,584 | 762 | 1,523 | 2,285 | 99 | 200 | 299 |
| ៨ | ខេត្តកណ្ដាល | 352 | 322 | 30 | 6,503 | 1,535 | 4,115 | 5,650 | 255 | 598 | 853 |
| ៩ | ខេត្តកោះកុង | 54 | 47 | 7 | 578 | 172 | 215 | 387 | 79 | 112 | 191 |
| ១០ | ខេត្តក្រចេះ | 167 | 158 | 9 | 1,514 | 315 | 1,043 | 1,358 | 55 | 101 | 156 |
| ១១ | ខេត្តមណ្ឌលគិរី | 29 | 22 | 7 | 243 | 41 | 110 | 151 | 25 | 67 | 92 |
| ១២ | រាជធានីភ្នំពេញ | 150 | 142 | 8 | 9,027 | 3,799 | 4,711 | 8,510 | 115 | 402 | 517 |
| ១៣ | ខេត្តព្រះវិហារ | 105 | 104 | 1 | 890 | 242 | 610 | 852 | 5 | 33 | 38 |
| ១៤ | ខេត្តព្រៃវែង | 513 | 495 | 18 | 4,399 | 1,134 | 2,959 | 4,093 | 98 | 208 | 306 |
| ១៥ | ខេត្តពោធិ៍សាត់ | 193 | 184 | 9 | 2,031 | 514 | 1,326 | 1,840 | 87 | 104 | 191 |
| ១៦ | ខេត្តរតនគិរី | 36 | 33 | 3 | 338 | 85 | 219 | 304 | 7 | 27 | 34 |
| ១៧ | ខេត្តសៀមរាប | 246 | 236 | 10 | 4,805 | 1,740 | 2,881 | 4,621 | 79 | 105 | 184 |
| ១៨ | ខេត្តព្រះសីហនុ | 39 | 37 | 2 | 678 | 177 | 469 | 646 | 7 | 25 | 32 |
| ១៩ | ខេត្តស្ទឹងត្រែង | 76 | 75 | 1 | 412 | 113 | 292 | 405 | 2 | 5 | 7 |
| ២០ | ខេត្តស្វាយរៀង | 244 | 243 | 1 | 2,150 | 842 | 1,292 | 2,134 | 5 | 11 | 16 |
| ២១ | ខេត្តតាកែវ | 341 | 317 | 24 | 4,057 | 1,065 | 2,610 | 3,675 | 103 | 279 | 382 |
| ២២ | ខេត្តឧត្ដរមានជ័យ | 88 | 81 | 7 | 870 | 272 | 422 | 694 | 75 | 101 | 176 |
| ២៣ | ខេត្តកែប | 16 | 14 | 2 | 179 | 41 | 96 | 137 | 7 | 35 | 42 |
| ២៤ | ខេត្តប៉ៃលិន | 30 | 24 | 6 | 422 | 92 | 206 | 298 | 35 | 89 | 124 |
| ២៥ | ខេត្តត្បូងឃ្មុំ | 249 | 239 | 10 | 3,067 | 688 | 2,273 | 2,961 | 35 | 71 | 106 |
| | សរុប | 4,985 | 4,744 | 241 | 70,853 | 20,739 | 45,297 | 66,036 | 1,527 | 3,290 | 4,817 |

បានឃើញ និងឯកភាព
ថ្ងៃ [illegible] ឆ្នាំច សំរឹទ្ធិស័ក ព.ស.២៥៦២
រាជធានីភ្នំពេញ ថ្ងៃទី[illegible] ខែ [illegible] ឆ្នាំ២០១៨
អគ្គនាយក

ហ៊ឹម_ចិន្តាឫទ្ធិ

ថ្ងៃ [illegible] ឆ្នាំច សំរឹទ្ធិស័ក ព.ស.២៥៦២
រាជធានីភ្នំពេញ ថ្ងៃទី[illegible] ខែ [illegible] ឆ្នាំ២០១៨
ប្រធាននាយកដ្ឋាន

ភឹម_ជុំប

# ឧបសម្ព័ន្ធទី៨

គណៈសង្ឃនាយក
នៃព្រះរាជាណាចក្រកម្ពុជា
លេខ:...០៥/១១....ស.ន.ក.ជ

# ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

## ព្រះសង្ឃប្រកាស

ស្ដីពី

ការកំណត់បែងចែកភារកិច្ចមន្ត្រីសង្ឃខេត្ត-រាជធានី ស្រុក-ខណ្ឌ-ក្រុង និងវត្ត

សម្ដេចព្រះមហាសុមេធាធិបតី ព្រះសង្ឃនាយក នៃព្រះរាជាណាចក្រកម្ពុជា

-បានទ្រង់យល់រដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា

-បានទ្រង់យល់ព្រះរាជក្រឹត្យ លេខ នស/រកម/០៥០៦/២០៧ ចុះថ្ងៃទី ០៤ ខែឧសភា ឆ្នាំ ២០០៦ ស្ដីពីការបង្កើតគណៈសង្ឃនាយក នៃព្រះរាជាណាចក្រកម្ពុជា

-បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/០១៩៦/១៩ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្ដីពីការបង្កើតក្រសួងធម្មការ និងសាសនា

-បានទ្រង់យល់អនុក្រឹត្យ លេខ ១៣ អនក្រ.បក ចុះថ្ងៃទី ១៩ ខែ កុម្ភៈ ឆ្នាំ ១៩៩៨ ស្ដីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួងធម្មការ និងសាសនា

-បានទ្រង់យល់ព្រះសង្ឃប្រកាស លេខ០០១.មសរធត ចុះថ្ងៃទី ២៤ ខែ សីហា ឆ្នាំ ២០០៦ ស្ដីពីការកំណត់បែងចែកភារកិច្ច សម្ដេចព្រះអគ្គមហាសង្ឃរាជាធិបតី សម្ដេចព្រះមហាសង្ឃរាជ និងសម្ដេចព្រះមហាសុមេធាធិបតី ព្រះសង្ឃនាយក

-បានទ្រង់យល់ព្រះសង្ឃប្រកាស លេខ០០៥.០៦ សនកជ ចុះថ្ងៃទី ២៩ ខែ សីហា ឆ្នាំ ២០០៦ ស្ដីពីការកំណត់បែងចែងភារកិច្ចគណៈសង្ឃនាយក នៃព្រះរាជាណាចក្រកម្ពុជា

-យោងស្មារតីអង្គប្រជុំថ្ងៃទី ០៤ ខែ កុម្ភៈ ឆ្នាំ ២០១១ របស់គណៈសង្ឃនាយក នៃព្រះរាជាណាចក្រកម្ពុជា និងក្រសួងធម្មការ និងសាសនា ស្ដីពីការពង្រឹងការគ្រប់គ្រងគណៈសង្ឃព្រះពុទ្ធសាសនា

-យោងតម្រូវការចាំបាច់របស់គណៈសង្ឃនាយក នៃព្រះរាជាណាចក្រកម្ពុជា

### សម្រេច

ប្រការ១ : ព្រះសង្ឃប្រកាសនេះមានទិសដៅកំណត់បែងចែកភារកិច្ចមន្ត្រីសង្ឃខេត្ត-រាជធានី ស្រុក-ខណ្ឌ-ក្រុង និងវត្ត

ប្រការ២ : ព្រះសង្ឃប្រកាសនេះមានគោលបំណងដូចខាងក្រោម :

- សម្រួលការងារសាលាគណ សាលាអនុគណ និងវត្ត
- ពង្រឹងការអនុវត្តការងាររបស់មន្ត្រីសង្ឃ
- ធានាគុណភាព និងប្រសិទ្ធភាពការងាររបស់គណៈសង្ឃ

ប្រការ៣ : ព្រះសង្ឃប្រកាសនេះ ជាបទប្បញ្ញត្តិបំពេញបន្ថែមលើព្រះសង្ឃដីកាស្តីពីករណីយកិច្ច តួនាទី និងមុខការ របស់ចៅអធិការ អនុគណ មេគណ ដែលអនុម័តដោយអនុសំវច្ឆរមហាសន្និបាត ទី១៨ នៃមន្ត្រីសង្ឃ នៅឆ្នាំ ១៩៦២ និង ទទួលស្គាល់ឱ្យប្រើប្រាស់ជាផ្លូវការឡើងវិញ ដោយព្រះសង្ឃប្រកាស លេខ ៣៣ កសវ ចុះថ្ងៃទី ០៧ ខែកញ្ញា ឆ្នាំ ១៩៩៣។

## គណៈសង្ឃ ខេត្ត-រាជធានី

ប្រការ៤ : គណៈសង្ឃខេត្ត-រាជធានី មានការបែងចែកភារកិច្ចដូចតទៅ :

ក-ព្រះមេគណ ទទួលបន្ទុកដឹកនាំគ្រប់គ្រងរួម មានភារកិច្ចដូចខាងក្រោម :

- ដឹកនាំគ្រប់គ្រងព្រះអនុគណគ្រប់ស្រុក-ខណ្ឌ-ក្រុង
- ចាត់ចែង និងត្រួតពិនិត្យកិច្ចការព្រះពុទ្ធសាសនា
- បំពេញតួនាទីជាមេដឹកនាំប្រកបដោយនាយកធម៌
- ជាអធិបតី និងដឹកនាំអង្គប្រជុំមន្ត្រីសង្ឃខេត្ត-រាជធានី ស្រុក-ខណ្ឌ-ក្រុង
- ចុះហត្ថលេខាលើឯកសារ និងលិខិតស្នាមផ្សេងៗជាផ្លូវការ
- ស្នើតែងតាំងសហការីគណ និងព្រះអនុគណ
- ប្រាស្រ័យទាក់ទងនឹងគណៈសង្ឃនាយក
- ធ្វើទំនាក់ទំនង និងសហការល្អជាមួយអាជ្ញាធរ និងស្ថាប័នពាក់ព័ន្ធ
- ទទួលជួប និងធ្វើទំនាក់ទំនងជាមួយភ្ញៀវជាតិ-អន្តរជាតិ
- ជួយកិច្ចការសង្គម ដែលអាចជួយបាន
- បំពេញកិច្ចការផ្សេងៗទៀត ដែលគណៈសង្ឃនាយកដាក់ចេញ
- ការគ្រប់គ្រងត្រាសាលាគណ ជាឆន្ទានុសិទ្ធិរបស់ព្រះមេគណ
- ធ្វើរបាយការណ៍តាមរបបកំណត់ និងរបាយការណ៍ជំនាញ ថ្វាយគណៈសង្ឃនាយក

ខ-ព្រះបាឡាត់គណ ទទួលបន្ទុកធម្មវិន័យ និងពុទ្ធិកសិក្សា មានភារកិច្ចដូចខាងក្រោម :

- ចាត់ចែង និងត្រួតពិនិត្យសាលាធម្មវិន័យ និងសាលាពុទ្ធិកសិក្សាក្នុងខេត្ត-រាជធានី
- ពិនិត្យ និងសម្របសម្រួលលើការបង្កើតសាលាធម្មវិន័យ និងសាលាពុទ្ធិកសិក្សា
- ធ្វើអធិការកិច្ចលើការប្រព្រឹត្តទៅ និងត្រួតពិនិត្យគុណភាពនៃសាលាធម្មវិន័យ និងសាលាពុទ្ធិកសិក្សា
- គ្រប់គ្រងស្ថិតិសាលាធម្មវិន័យ សាលាពុទ្ធិកសិក្សា គ្រូ និងសមណៈសិស្ស-សិស្ស
- ជួយកិច្ចការផ្សេងៗទៀត ដែលព្រះមេគណប្រគល់ឱ្យ

- ធ្វើរបាយការណ៍ស្តីពីធម្មវិន័យ និងពុទ្ធិកសិក្សា ប្រគេនព្រះមេគណ

គ-ព្រះវិន័យធរគណ ទទួលបន្ទុកការងារទប់ស្កាត់ ដោះស្រាយ និងរម្ងាប់អធិករណ៍ មានភារកិច្ចដូចខាងក្រោម៖

- ដឹកនាំព្រះសង្ឃប្រតិបត្តិធម៌វិន័យឱ្យបានម៉ឺងម៉ាត់ និងខ្ជាប់ខ្ជួន
- លើកទឹកចិត្ត ទំនុកបម្រុង និងសម្របសម្រួលផ្លូវច្បាប់ដល់កុលបុត្រ ដែលមានសទ្ធាចង់បួស ព្រមទាំងដាស់តឿនលើការប្រតិបត្តិធម៌វិន័យ
- ចាត់វិធានការការពារ និងទប់ស្កាត់ការកើតឡើងនូវអធិករណ៍
- ទទួលឯកសារសំណុំរឿងអធិករណ៍ ដែលសាលាអនុគណបញ្ជូនមក ហើយសម្របសម្រួល និងរម្ងាប់អធិករណ៍នោះ។ ក្នុងករណីមិនអាចសម្របសម្រួលបាន ត្រូវរៀបចំឯកសារសំណុំរឿងអធិករណ៍ដាក់ប្រគេនសាលាគណ។
- គ្រប់គ្រងឯកសារពាក់ព័ន្ធសំណុំរឿងអធិករណ៍ផ្សេងៗ។
- ធ្វើរបាយការណ៍ស្តីពីការកើតឡើង និងការរម្ងាប់អធិករណ៍ ប្រគេនព្រះមេគណ

ឃ-ព្រះធម្មធរគណ ទទួលបន្ទុកការងារអប់រំផ្សព្វផ្សាយ មានភារកិច្ចដូចខាងក្រោម :

- ប្រមូលព័ត៌មានទាក់ទងនឹងកិច្ចការព្រះពុទ្ធសាសនា
- រៀបចំកម្មវិធីអប់រំផ្សព្វផ្សាយសីលធម៌ព្រះពុទ្ធសាសនាតាមមធ្យោបាយនានា
- ផ្សព្វផ្សាយព័ត៌មានដែលទទួលពីគណៈសង្ឃនាយក ទៅសាលាអនុគណ
- គ្រប់គ្រង និងត្រួតពិនិត្យលើការផ្សព្វផ្សាយធម៌វិន័យ (ការសម្តែងធម៌ទេសនា) តាមប្រព័ន្ធផ្សព្វផ្សាយ និងការបោះពុម្ពផ្សាយនានា
- ជាឃោសកសាលាគណ
- ធ្វើរបាយការណ៍ស្តីពីការអប់រំផ្សព្វផ្សាយ ប្រគេនព្រះមេគណ

ង-ព្រះសមុហ៍គណ ទទួលបន្ទុកការងារស្ថិតិ មានភារកិច្ចដូចខាងក្រោម :

- ប្រមូលចងក្រងស្ថិតិវត្តអារាម ព្រះសង្ឃ អាចារ្យ-គណៈកម្មការវត្ត ដូនជី-តាជី និងសិស្ស-និស្សិតដែលស្នាក់នៅក្នុងវត្ត
- ប្រមូលចងក្រងប្រវត្តិវត្តនានាទូទាំងខេត្ត-រាជធានី
- គ្រប់គ្រងឯកសារស្ថិតិ
- ធ្វើផែនការអភិរក្សសំណង់-ស្ថាបត្យកម្មបុរាណ បេតិកភណ្ឌ ក្បាច់ ចម្លាក់ព្រះពុទ្ធសាសនា
- ធ្វើរបាយការណ៍ស្តីពីស្ថិតិ ប្រគេនព្រះមេគណ

ច-ព្រះលេខាធិការគណ ជាជំនួយការសាលាគណ មានភារកិច្ចដូចខាងក្រោម :

- តាក់តែងលិខិតបទដ្ឋាននានាសម្រាប់សាលាគណ
- គ្រប់គ្រងលិខិតចេញ-ចូល (ចុះលេខ-កាលបរិច្ឆេទ) និងបញ្ជូនទៅតាមជំនាញ
- ថែរក្សាទុកដាក់ឯកសារ លិខិតបទដ្ឋានផ្សេងៗរបស់សាលាគណ
- ធ្វើកំណត់ហេតុអង្គប្រជុំក្នុងសាលាគណ
- រៀបចំកម្មវិធីរបស់ព្រះមេគណ
- ធ្វើរបាយការណ៍សម្រាប់សាលាគណ

## គណៈសង្ឃ ស្រុក-ខណ្ឌ-ក្រុង

ប្រការ៥ : គណៈសង្ឃស្រុក-ខណ្ឌ-ក្រុង មានការបែងចែកភារកិច្ចដូចតទៅ :

ក-**ព្រះអនុគណ** ទទួលបន្ទុកដឹកនាំគ្រប់គ្រងរួម មានភារកិច្ចដូចខាងក្រោម :

- ដឹកនាំគ្រប់គ្រងលើចៅអធិការគ្រប់វត្ត
- ចាត់ចែង និងត្រួតពិនិត្យកិច្ចការខាងព្រះពុទ្ធសាសនា
- បំពេញតួនាទីជាអ្នកដឹកនាំប្រកបដោយនាយកធម៌
- ជាអធិបតី និងដឹកនាំអង្គប្រជុំមន្ត្រីសង្ឃស្រុក-ខណ្ឌ-ក្រុង និងវត្ត
- ចុះហត្ថលេខាលើឯកសារ និងលិខិតស្នាមផ្សេងៗជាផ្លូវការ
- ស្នើតែងតាំងសហការីអនុគណ និងមន្ត្រីសង្ឃវត្ត
- ប្រាស្រ័យទាក់ទងនឹងព្រះមេគណ
- ធ្វើទំនាក់ទំនង និងសហការល្អជាមួយអាជ្ញាធរមូលដ្ឋាន និងស្ថាប័នពាក់ព័ន្ធ
- ទទួលជួប និងធ្វើទំនាក់ទំនងជាមួយភ្ញៀវនានា
- ជួយកិច្ចការសង្គម ដែលអាចជួយបាន
- បំពេញកិច្ចការផ្សេងៗទៀត ដែលព្រះមេគណដាក់ឱ្យ
- ការគ្រប់គ្រងត្រាសាលាអនុគណ ជាឆន្ទានុសិទ្ធិរបស់ព្រះអនុគណ
- ធ្វើរបាយការណ៍តាមរបបកំណត់ និងរបាយការណ៍ជំនាញ ប្រគេនសាលាគណ

ខ-**ព្រះវិន័យធរអនុគណ** ទទួលបន្ទុកការងារទប់ស្កាត់ ដោះស្រាយ និងរម្ងាប់អធិករណ៍ មានភារកិច្ចដូចខាងក្រោម :

- ដឹកនាំព្រះសង្ឃប្រតិបត្តិធម៌វិន័យឱ្យបានម៉ឺងម៉ាត់ និងខ្ជាប់ខ្ជួន
- លើកទឹកចិត្ត ទំនុកបម្រុង និងសម្របសម្រួលផ្លូវច្បាប់ដល់កុលបុត្រ ដែលមានសទ្ធាចង់បួស ព្រមទាំងដាស់

ជឿនលើការប្រតិបត្តិធម៌វិន័យ

- ចាត់វិធានការការពារ និងទប់ស្កាត់ការកើតឡើងនូវអធិករណ៍
- ទទួលឯកសារសំណុំរឿងអធិករណ៍ ដែលវត្តនានាបញ្ជូនមក ហើយសម្របសម្រួល និងរម្ងាប់អធិករណ៍នោះ ។ ក្នុងករណីមិនអាចសម្របសម្រួលបាន ត្រូវរៀបចំឯកសារសំណុំរឿងអធិករណ៍ដាក់ប្រគេនសាលាគណ ។
- គ្រប់គ្រងឯកសារពាក់ព័ន្ធសំណុំរឿងអធិករណ៍ផ្សេងៗ
- បំពេញកិច្ចការផ្សេងៗទៀត ដែលព្រះអនុគណប្រគល់ឱ្យ
- ធ្វើរបាយការណ៍ស្តីពីការកើតឡើង និងការរម្ងាប់អធិករណ៍ ប្រគេនព្រះអនុគណ

**គ-ព្រះធម្មធរអនុគណ ទទួលបន្ទុកធម្មវិន័យ និងពុទ្ធិកសិក្សា មានភារកិច្ចដូចខាងក្រោម :**

- ចាត់ចែង និងត្រួតពិនិត្យសាលាធម្មវិន័យ និងសាលាពុទ្ធិកសិក្សា
- សម្របសម្រួលលើការបង្កើតសាលាធម្មវិន័យ និងសាលាពុទ្ធិកសិក្សា
- ធ្វើអធិការកិច្ចលើការប្រព្រឹត្តទៅ និងត្រួតពិនិត្យគុណភាពនៃសាលាធម្មវិន័យ និងសាលាពុទ្ធិកសិក្សា
- គ្រប់គ្រងស្ថិតិសាលាធម្មវិន័យ សាលាពុទ្ធិកសិក្សា គ្រូ និងសមណៈសិស្ស-សិស្ស
- ធ្វើរបាយការណ៍ស្តីពីធម្មវិន័យ និងពុទ្ធិកសិក្សា ប្រគេនព្រះអនុគណ

**ឃ-ព្រះសមុហ៍អនុគណ ទទួលបន្ទុកការងារស្ថិតិ និងការងារអប់រំផ្សព្វផ្សាយ មានភារកិច្ចដូចខាងក្រោម :**

- ចងក្រងស្ថិតិវត្តអារាម ព្រះសង្ឃ អាចារ្យ-គណៈកម្មការវត្ត ដូនជី-តាជី និងសិស្ស-និស្សិតដែលស្នាក់នៅក្នុងវត្ត
- គ្រប់គ្រងឯកសារស្ថិតិ
- ចងក្រងប្រវត្តិវត្តនានាទូទាំងស្រុក-ខណ្ឌ-ក្រុង
- ធ្វើផែនការអភិរក្សសំណង់-ស្ថាបត្យកម្មបុរាណ បេតិកភណ្ឌ ក្បូរក្បាច់ ចម្លាក់ព្រះពុទ្ធសាសនា ដែលមាននៅតាមវត្តនានា
- ប្រមូលព័ត៌មានទាក់ទងនឹងកិច្ចការព្រះពុទ្ធសាសនា
- រៀបចំកម្មវិធីអប់រំផ្សព្វផ្សាយសីលធម៌ព្រះពុទ្ធសាសនាតាមមធ្យោបាយនានា
- ផ្សព្វផ្សាយព័ត៌មានដែលទទួលពីសាលាអនុគណ ទៅវត្តនានា
- គ្រប់គ្រង និងត្រួតពិនិត្យលើការផ្សព្វផ្សាយធម៌វិន័យ (ការសម្តែងធម៌ទេសនា) តាមប្រព័ន្ធផ្សព្វផ្សាយ និងការបោះពុម្ពផ្សាយនានា
- ជាលេខាធិការសាលាអនុគណ
- ធ្វើរបាយការណ៍ស្តីពីស្ថិតិ និងការអប់រំផ្សព្វផ្សាយ ប្រគេនព្រះអនុគណ

ង-ព្រះលេខាធិការអនុគណ ជាជំនួយការសាលាអនុគណ មានភារកិច្ចដូចខាងក្រោម :

- តាក់តែងលិខិតបទដ្ឋាននានា
- គ្រប់គ្រងលិខិតចេញ-ចូល (ចុះលេខ-កាលបរិច្ឆេទ) និងបញ្ជូនទៅតាមជំនាញ
- ថែរក្សាទុកដាក់ឯកសារ និងលិខិតបទដ្ឋានផ្សេងៗ
- រៀបចំ និងធ្វើកំណត់ហេតុអង្គប្រជុំ
- រៀបចំកម្មវិធីរបស់ព្រះអនុគណ
- ធ្វើរបាយការណ៍សម្រាប់សាលាអនុគណ

## គណៈសង្ឃវត្ត

ប្រការ៦ : គណៈសង្ឃវត្តមានការបែងចែកភារកិច្ចដូចតទៅ :

ក-ព្រះចៅអធិការ ជាអធិបតីសង្ឃវត្ត មានភារកិច្ចដូចខាងក្រោម :

- ដឹកនាំគ្រប់គ្រងវត្តទាំងមូល
- គ្រប់គ្រងភិក្ខុ-សាមណេរ អាចារ្យ-គណៈកម្មការវត្ត ដូនជី-តាជី និងសិស្ស-និស្សិតដែលស្នាក់នៅក្នុងវត្ត
- រៀបចំចាត់ចែងវត្តអារាមឱ្យមានសណ្តាប់ធ្នាប់ របៀបរៀបរយ និងការរីកចម្រើន
- បំពេញតួនាទីជាអ្នកដឹកនាំប្រកបដោយនាយកធម៌ ព្រមទាំងចេះបាតិមោក្ខបាលីផង
- ជាអធិបតី និងដឹកនាំអង្គប្រជុំកិច្ចការវត្ត
- ចុះហត្ថលេខាលើឯកសារ និងលិខិតស្នាមផ្សេងៗជាផ្លូវការ
- គ្រប់គ្រងថវិកាវត្ត ដោយមានការសហការពីគណៈកម្មការវត្ត
- ដឹកនាំភិក្ខុ-សាមណេរក្នុងវត្តធ្វើសង្ឃកម្ម និងកិច្ចវត្ត
- ដឹកនាំការរៀបចំពិធីបុណ្យនានាក្នុងវត្ត
- លើកទឹកចិត្ត ទំនុកបម្រុង និងសម្របសម្រួលផ្លូវច្បាប់ដល់កុលបុត្រ ដែលមានសទ្ធាចង់បួស ព្រមទាំងដាស់តឿនលើការប្រតិបត្តិធម៌វិន័យ
- ជម្រុញ លើកទឹកចិត្ត និងទំនុកបម្រុងភិក្ខុ-សាមណេរចូលសិក្សាសាលាធម្មវិន័យ និងសាលាពុទ្ធិកសិក្សា
- ជួយសហការបង្កើត និងទំនុកបម្រុងសាលាធម្មវិន័យ និងសាលាពុទ្ធិកសិក្សា
- ជួយសម្រួលដល់ការរស់នៅរបស់ដូនជី-តាជី និងសិស្ស-និស្សិត
- ប្រាស្រ័យទាក់ទងនឹងព្រះអនុគណ
- ធ្វើទំនាក់ទំនង និងសហការល្អជាមួយអាជ្ញាធរមូលដ្ឋាន និងស្ថាប័នពាក់ព័ន្ធ

- ទទួលជួប និងធ្វើទំនាក់ទំនងជាមួយភ្ញៀវនានា
- ប្រាស្រ័យសុខទុក្ខជាមួយពុទ្ធបរិស័ទ និងជួយឧបត្ថម្ភដល់ប្រជាពលរដ្ឋដែលជួបការលំបាក និងគ្រោះមហន្តរាយផ្សេងៗ
- ជួយកិច្ចការសង្គម ដែលអាចជួយបាន
- បំពេញកិច្ចការផ្សេងៗទៀត ដែលព្រះអនុគណដាក់ឱ្យ
- ការគ្រប់គ្រងត្រាវត្ត ជាឆន្ទានុសិទ្ធិរបស់ព្រះចៅអធិការ
- ធ្វើរបាយការណ៍តាមរបបកំណត់ និងរបាយការណ៍ជំនាញ ប្រគេនសាលាអនុគណ

ខ-គ្រូសូត្រស្តាំ ជាជំនួយការព្រះចៅអធិការ ទទួលបន្ទុកការសាងសង់ និងគរុភ័ណ្ឌ មានភារកិច្ចដូចខាងក្រោម :
- ធ្វើផែនការ លើកគម្រោងកសាង ថែទាំ ជួសជុលសមិទ្ធិនានាក្នុងវត្ត ដាក់ប្រគេនគណៈសង្ឃវត្តសម្រេច
- សិក្សាទីតាំង គម្រោង-ប្លង់សាងសង់ រចនាបទ ក្បូរក្បាច់ ចម្លាក់ តាមប្លង់មេ (នគរូបនីយកម្ម)
- ត្រួតពិនិត្យបច្ចេកទេស ដំណើរការសាងសង់ និងគុណភាពសំណង់
- ចាត់វិធានការការពារ និងទប់ស្កាត់ការកើតឡើងនូវអធិករណ៍ក្នុងវត្ត
- សម្របសម្រួលវិវាទ អធិករណ៍ ដែលកើតឡើងដោយថាហេតុ។ ក្នុងករណីមិនអាចសម្រុះសម្រួលបានត្រូវរៀបចំឯកសារសំណុំរឿងដាក់ប្រគេនគណៈសង្ឃវត្ត។
- គ្រប់គ្រងឯកសារពាក់ព័ន្ធសំណុំរឿងអធិករណ៍ផ្សេងៗ
- ថែរក្សាគរុភ័ណ្ឌវត្ត ដោយចុះបញ្ជីសារពើភ័ណ្ឌ
- ថែរក្សាសណ្តាប់ធ្នាប់ និងសុវត្ថិភាពក្នុងវត្ត
- បំពេញកិច្ចការផ្សេងៗទៀត ដែលព្រះចៅអធិការប្រគល់ឱ្យ

គ-គ្រូសូត្រឆ្វេង ជាជំនួយការព្រះចៅអធិការ ទទួលបន្ទុកការងារអប់រំផ្សព្វផ្សាយ និងសោភ័ណភាព មានភារកិច្ចដូចខាងក្រោម :
- ដឹកនាំព្រះសង្ឃក្នុងវត្តប្រតិបត្តិធម៌វិន័យឱ្យបានម៉ឺងម៉ាត់ និងខ្ជាប់ខ្ជួន
- បង្រៀនធម៌វិន័យដល់ភិក្ខុ-សាមណេរ ដូនជី-តាជី និងសិស្ស-និស្សិតវត្ត
- អប់រំភិក្ខុ-សាមណេរ សិស្ស-និស្សិត និងយុវជន នូវសីលធម៌ សុជីវធម៌ ចរិយាមារយាទល្អក្នុងការរស់នៅ
- ផ្សព្វផ្សាយព័ត៌មានទាក់ទងនឹងព្រះពុទ្ធសាសនាតាមមធ្យោបាយនានា
- តាក់តែងលិខិតបទដ្ឋាននានាសម្រាប់វត្ត
- គ្រប់គ្រងលិខិតចេញ-ចូល (ចុះលេខ-កាលបរិច្ឆេទ)

- ថែរក្សាទុកដាក់ឯកសារ និងលិខិតបទដ្ឋានផ្សេងៗរបស់វត្ត
- រៀបចំ និងធ្វើកំណត់ហេតុអង្គប្រជុំក្នុងវត្ត
- ធ្វើរបាយការណ៍សម្រាប់វត្ត
- រៀបចំពិធីបុណ្យទានផ្សេងៗ
- ថែរក្សាសោភ័ណភាព អនាម័យ និងបរិស្ថានវត្ត
- ថែរក្សា និងដាំដើមឈើក្នុងបរិវេណវត្ត
- រៀបចំកម្មវិធីរបស់ព្រះចៅអធិការ
- បំពេញកិច្ចការផ្សេងៗទៀត ដែលព្រះចៅអធិការប្រគល់ឱ្យ

ប្រការ៧ :-ក្នុងករណីព្រះមេគណទុព្វលភាព ឬបាត់បង់សមត្ថភាពការងារ ត្រូវផ្ទេរភារកិច្ចទៅព្រះបាឡាត់គណ ក្នុងឋានៈជាមេគណស្ដីទី ជាលាយល័ក្ខណ៍អក្សរ។

- ក្នុងករណី សហការីគណអង្គណាមួយទុព្វលភាព ឬបាត់បង់សមត្ថភាពការងារ ព្រះមេគណត្រូវផ្ទេរភារកិច្ចឱ្យទៅសហការីគណអង្គដទៃទៀតតាមលំដាប់ឋានានុក្រម ឬតាមស្ថានភាពជាក់ស្ដែង។
- ក្នុងករណី ព្រះមេគណ ឬសហការីគណអង្គណាមួយអវត្តមាន ត្រូវផ្ទេរភារកិច្ចបណ្ដោះអាសន្នឱ្យទៅសហការីគណអង្គដទៃទៀតតាមលំដាប់ឋានានុក្រម ឬតាមស្ថានភាពជាក់ស្ដែង។ បើអវត្តមានគ្មានដំណឹងចាប់ពី៦ខែឡើងទៅ ត្រូវចាត់ទុកថាបោះបង់ចោលការងារ ឬអវត្តមានដោយមានច្បាប់ ចាប់ពីមួយឆ្នាំឡើងទៅ ចាត់ទុកថាអស់សុពលភាពការងារ។

ប្រការ៨ :-ក្នុងករណី ព្រះអនុគណទុព្វលភាព ឬបាត់បង់សមត្ថភាពការងារ ត្រូវផ្ទេរភារកិច្ចទៅវិន័យធរអនុគណ ក្នុងឋានៈជាអនុគណស្ដីទី ជាលាយល័ក្ខណ៍អក្សរ។

- ក្នុងករណី សហការីអនុគណអង្គណាមួយទុព្វលភាព ឬបាត់បង់សមត្ថភាពការងារ ព្រះអនុគណត្រូវផ្ទេរភារកិច្ចឱ្យទៅសហការីអនុគណអង្គដទៃទៀតតាមលំដាប់ឋានានុក្រម ឬតាមស្ថានភាពជាក់ស្ដែង។
- ក្នុងករណី ព្រះអនុគណ ឬសហការីអនុគណអង្គណាមួយអវត្តមាន ត្រូវផ្ទេរភារកិច្ចបណ្ដោះអាសន្នឱ្យទៅសហការីអនុគណអង្គដទៃទៀតតាមលំដាប់ឋានានុក្រម ឬតាមស្ថានភាពជាក់ស្ដែង។ បើអវត្តមានដោយគ្មានដំណឹងចាប់ពី៦ខែឡើងទៅ ត្រូវចាត់ទុកថាបោះបង់ចោលការងារ ឬអវត្តមានដោយមានច្បាប់ចាប់ពីមួយឆ្នាំឡើងទៅ ត្រូវចាត់ទុកថាអស់សុពលភាពការងារ។

ប្រការ៩ :-ក្នុងករណីព្រះចៅអធិការទុព្វលភាព ឬបាត់បង់សមត្ថភាពការងារ គ្រូសូត្រស្ដាំត្រូវបំពេញតួនាទីជាចៅអធិការស្ដីទី។ បើគ្រូសូត្រស្ដាំស្ថិតក្នុងស្ថានភាពដូចគ្នា គ្រូសូត្រឆ្វេងត្រូវបំពេញតួនាទីជាចៅអធិការស្ដីទី។

- ក្នុងករណី ព្រះចៅអធិការ គ្រូសូត្រស្តាំ ឬគ្រូសូត្រឆ្វេង អវត្តមានដោយគ្មានដំណឹងចាប់ពី៦ខែឡើងទៅ ត្រូវចាត់ទុកថាបោះបង់ចោលការងារ ឬអវត្តមានដោយមានច្បាប់ ចាប់ពី១ឆ្នាំឡើងទៅ ត្រូវចាត់ទុកថាអស់សុពលភាពការងារ ។

ប្រការ១០ : មន្ត្រីសង្ឃដូចក្នុងប្រការ៤, ៥, ៦ ត្រូវអនុវត្តសង្ឃប្រកាសនេះឱ្យបានម៉ឺងម៉ាត់ ។

ប្រការ១១ : សង្ឃប្រកាសនេះ មានប្រសិទ្ធភាពចាប់ពីថ្ងៃឡាយព្រះហស្តលេខា និងចុះហត្ថលេខានេះតទៅ ។

រាជធានីភ្នំពេញ ថ្ងៃទី ០៧ ខែ កុម្ភៈ ព.ស.២៥៥៤ / គ.ស.២០១១

សម្តេចព្រះសង្ឃនាយក

នន្ទ_ង៉ែត

បានឃើញ និង ឯកភាព

ថ្ងៃទី [illegible] ឆ្នាំ ២០១១

រដ្ឋមន្ត្រីក្រសួងធម្មការ និងសាសនា

មិន.ឃិន

ចម្លងផ្ញើជូន

- សម្តេចព្រះមហាសង្ឃរាជទាំងពីរគណៈ
- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យឧបនាយករដ្ឋមន្ត្រីប្រចាំការ
- ទីស្តីការគណៈរដ្ឋមន្ត្រី
- ក្រសួងមហាផ្ទៃ
- សាលាខេត្ត-រាជធានី សាលាស្រុក-ខណ្ឌ-ក្រុង
  "ដើម្បីថ្វាយ-ជូនជ្រាប"
- សាលាគណ និងមន្ទីរធម្មការ និងសាសនាខេត្ត-រាជធានី
- សាលាអនុគណ និងការិយាល័យធម្មការ និងសាសនាស្រុក-ខណ្ឌ-ក្រុង
- វត្តទូទាំងប្រទេស
  "ដើម្បីអនុវត្ត"
- ឯកសារ-កាលប្បវត្តិ

# ឧបសម្ព័ន្ធទី៩

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

លេខ ០០១/០៦ ម.ស.រាជ

# ព្រះសង្ឃប្រកាស

## ស្តីពី

## ការកំណត់បែងចែកភារកិច្ច សម្តេចព្រះអគ្គមហាសង្ឃរាជាធិបតី សម្តេចព្រះមហាសង្ឃរាជ និងសម្តេចព្រះមហាសុមេធាធិបតី ព្រះសង្ឃនាយក

**សម្តេចព្រះអគ្គមហាសង្ឃរាជាធិបតី សម្តេចព្រះមហាសង្ឃរាជនៃព្រះរាជាណាចក្រកម្ពុជា និងសម្តេចព្រះមហាសុមេធាធិបតី ព្រះសង្ឃនាយកនៃព្រះរាជាណាចក្រកម្ពុជា**

- បានឃើញ រដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា,
- បានឃើញ ព្រះរាជក្រឹត្យលេខ នស/រកត/០៤០៦/២០០ ចុះថ្ងៃទី២៥ ខែមេសា ឆ្នាំ២០០៦ ស្តីពីការតែងតាំង ព្រះមហាសុមេធាធិបតី ទេព វង្ស សម្តេចព្រះសង្ឃរាជ គណៈមហានិកាយនៃព្រះរាជាណាចក្រកម្ពុជា ឱ្យឡើងព្រះឋានៈ ជាសម្តេចព្រះអគ្គមហាសង្ឃរាជាធិបតី សម្តេចព្រះមហាសង្ឃរាជនៃព្រះរាជាណាចក្រកម្ពុជា,
- បានឃើញ ព្រះរាជក្រឹត្យលេខ នស/រកត/០៥០៦/២០៧ ចុះថ្ងៃទី ០៤ ខែឧសភា ឆ្នាំ២០០៦ ស្តីពីការបង្កើត គណៈសង្ឃនាយក ដោយតម្លើងសម្តេចព្រះពោធិវង្ស នន់ ង៉ែត ឱ្យឡើងព្រះឋានៈជាសម្តេចព្រះមហាសុមេធាធិបតី ព្រះសង្ឃនាយកនៃព្រះរាជាណាចក្រកម្ពុជា,
- យោងតាមស្មារតីអង្គប្រជុំ ថ្ងៃទី ២១ ខែ សីហា ឆ្នាំ២០០៦ ស្តីពីដំណើរការប្រព្រឹត្តទៅ នៃវិស័យព្រះពុទ្ធសាសនានៅព្រះរាជាណាចក្រកម្ពុជា,
- យោងតាមសំណូមពរ និងតម្រូវការចាំបាច់

## ស ម្រេ ច

<u>ប្រការ</u> ១- កំណត់បែងចែកព្រះភារកិច្ចថ្វាយ-ប្រគេន សម្តេចព្រះអគ្គមហាសង្ឃរាជាធិបតី ទេព វង្ស សម្តេចព្រះមហាសង្ឃរាជនៃព្រះរាជាណាចក្រកម្ពុជា និងសម្តេចព្រះមហាសុមេធាធិបតី នន់ ង៉ែត ព្រះសង្ឃនាយក នៃព្រះរាជាណាចក្រកម្ពុជា ដូចតទៅនេះ :

ក/ <u>ព្រះរាជភារកិច្ច សម្តេចព្រះអគ្គមហាសង្ឃរាជាធិបតី</u> :

ក-១- ទទួលគ្រប់គ្រង និងដឹកនាំការងារព្រះពុទ្ធសាសនាក្នុងប្រទេស និងទំនាក់ទំនងការងារពុទ្ធសាសនានៅក្រៅប្រទេស ឱ្យប្រព្រឹត្ត ទៅប្រកបដោយកិត្តិយស សេចក្តីថ្លៃថ្នូរ ។

ក-២- ទទួលភារកិច្ចចុះព្រះហស្តលេខា លើប្រកាសនីយប័ត្រតែងតាំងព្រះសមុហ៍គណ ព្រះធម្មធរគណ ព្រះវិន័យធរគណ ព្រះបាឡាត់គណ ព្រះអនុគណ និងព្រះមេគណឡើងទៅ តាមបែបបទពីមូលដ្ឋាន និងតាមសំណើរបស់គណៈសង្ឃនាយក ដោយមានការយល់ព្រមពីសម្តេចនាយករដ្ឋមន្ត្រីនៃរាជរដ្ឋាភិបាល ។

ក-៣- រាល់ការតែងតាំងតម្លើង ឬដកឋានៈគោរម្យងារ ជាទីប្រឹក្សា, ជារាជាគណៈកិត្តិយស, ជារាជាគណៈក្នុងងារ ឋានានុក្រម និងមុខងារផ្សេងៗ ពាក់ព័ន្ធដល់ព្រះរាជក្រឹត្យ ត្រូវធ្វើតាមសំណើរពីគណៈសង្ឃនាយក និងការយល់ព្រមពីសម្តេចនាយករដ្ឋមន្ត្រី នៃរាជរដ្ឋាភិបាល ។

៦/ **ព្រះភារកិច្ចរបស់សម្តេចព្រះមហាសុមេធាធិបតី ព្រះសង្ឃនាយក**

៦-១- ទទួលភារកិច្ចស្តីទី ក្នុងការគ្រប់គ្រង និងដឹកនាំការងារពុទ្ធសាសនា ក្នុងឱកាសអវត្តមានសម្តេចព្រះអគ្គមហាសង្ឃ រាជាធិបតី សម្តេចព្រះមហាសង្ឃរាជនៃព្រះរាជាណាចក្រកម្ពុជា ។

៦-២- ចុះព្រះហស្ថលេខា លើប្រកាសនីយបត្រ តែងតាំងលោកគ្រូចៅអធិការ គ្រូសូត្រស្តាំ-ឆ្វេង ព្រះវិន័យធរ លេខាធិការ ព្រះឧបជ្ឈាយ៍ ព្រះវិន័យធរអនុគណ ព្រះធម្មធរអនុគណ ព្រះសមុហ៍អនុគណ ព្រះលេខាធិការអនុគណ តាមសំណើរបស់សមុហកាពសង្ឃនៃវត្តនីមួយៗ ដែលរួមមានទាំងព្រះអនុគណ ព្រះមេគណ ព្រះចៅឡាត់គណ ដោយមានការយល់ព្រមពីអាជ្ញាធរមូលដ្ឋាន ស្រុក-ខ័ណ្ឌ និងខេត្ត-ក្រុង តាមរយៈក្រសួងធម្មការនិងសាសនា ដោយត្រូវរាយការណ៍ថ្វាយសម្តេចព្រះអគ្គមហាសង្ឃរាជាធិបតី សម្តេចព្រះមហាសង្ឃរាជទ្រង់ជ្រាប ។

៦-៣- ទទួលព្រះភារកិច្ច ក្តាប់ការងារស្ថិតិវត្តអារាម ភិក្ខុ សាមណេរ អាចារ្យ គណៈកម្មការវត្ត កុមារ យុវជន ស្នាក់នៅក្នុងវត្តនៅក្នុងទូទាំងប្រទេស បូកសរុបរាយការណ៍ថ្វាយសម្តេចព្រះអគ្គមហាសង្ឃរាជាធិបតី សម្តេចព្រះមហាសង្ឃរាជ ការបើកអនុសំវច្ឆរៈមហាសន្និបាតមន្ត្រីសង្ឃប្រចាំឆ្នាំ ត្រួតពិនិត្យដំណើរការប្រព្រឹត្តទៅនៃវិស័យព្រះពុទ្ធសាសនា ក្នុងក្របខ័ណ្ឌកិច្ចការវប្បធម៌ និងទំនាក់ទំនងសាធារណៈ ។

៦-៤- ទទួលព្រះភារកិច្ច ក្តាប់ការងារពុទ្ធិកសិក្សាគ្រប់កម្រិត ចាប់ពីពុទ្ធិកបឋមសិក្សារហូតដល់ពុទ្ធិកឧត្តមសិក្សា ក្នុងឋានៈជាអគ្គនាយកពុទ្ធិកសិក្សា និងជាពុទ្ធិកសាកលវិទ្យាធិការនៃពុទ្ធិកសាកលវិទ្យាល័យ ដោយត្រូវផ្តោតព្រះទ័យទៅលើការពង្រឹងគុណភាព នៅសាលាពុទ្ធិកបឋមសិក្សានៅថ្នាក់មូលដ្ឋាន មានបញ្ហាគ្រូ បញ្ហាសម្ភារៈបរិក្ខារ កម្មវិធីសិក្សា ។ល។ និងសាលាធម្មវិន័យទាំងពាថ្នាក់ ។

<u>ប្រការ</u> ២- សម្តេចព្រះអគ្គមហាសង្ឃរាជាធិបតី សម្តេចព្រះមហាសង្ឃរាជ និងសម្តេចព្រះមហាសុមេធាធិបតី ព្រះសង្ឃនាយក មានមន្ត្រីសង្ឃ និងគ្រហស្ថមួយចំនួន ជាជំនួយការតាមតម្រូវការចាំបាច់ និងប្រើប្រាស់គ្រាជាផ្លូវការ តាមកម្រិតស្មើរមួយងារគំណត់រៀងៗព្រះអង្គ ។

<u>ប្រការ</u> ៣- សម្តេចព្រះអគ្គមហាសង្ឃរាជាធិបតី សម្តេចព្រះមហាសង្ឃរាជ និងសម្តេចព្រះមហាសុមេធាធិបតី ព្រះសង្ឃនាយកធ្វើការងារដោយសហការជិតស្និទ្ធ ក្នុងជំហរសាមគ្គីភាព ជាសហធម្មិកតាមភារកិច្ច ដែលបានកំណត់ឱ្យប្រព្រឹត្តទៅប្រកបដោយសទ្ធផលល្អប្រសើរ ។

<u>ប្រការ</u> ៤- រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងធម្មការនិងសាសនា រដ្ឋមន្ត្រី រដ្ឋលេខាធិការពាក់ព័ន្ធ គ្រប់ខេត្ត-ក្រុង និងមន្ត្រីសង្ឃគ្រប់ជាន់ថ្នាក់ ត្រូវអនុវត្តតាមព្រះសង្ឃប្រកាសនេះ ។

<u>ប្រការ</u> ៥- បទប្បញ្ញត្តិទាំងឡាយណា ផ្ទុយពីព្រះសង្ឃប្រកាសនេះ ត្រូវទុកជានិរាករណ៍ ។

<u>ប្រការ</u> ៦- ព្រះសង្ឃប្រកាសនេះ មានប្រសិទ្ធភាព និងស្មេរភាពចាប់ពីថ្ងៃចុះព្រះហស្ថលេខា និងហត្ថលេខាតទៅ ។

ធ្វើនៅរាជធានីភ្នំពេញ, ថ្ងៃទី២៤ ខែ[illegible] ព.ស ២៥៥០
គ.ស ២០០៦

លេខ : ០១ ព្រ.ក...

បានឃើញ និងឯកភាព
រាជធានីភ្នំពេញ ថ្ងៃទី២៤ ខែ [illegible] ឆ្នាំ២០០៦
នាយករដ្ឋមន្ត្រី

ហ៊ុន សែន

សម្តេចព្រះមហាសុមេធាធិបតី
ព្រះសង្ឃនាយក

នន្ទ ង៉ែត

សម្តេចព្រះអគ្គមហាសង្ឃរាជាធិបតី
សម្តេចព្រះមហាសង្ឃរាជ

ទេព វង្ស

<u>ចម្លងជូន</u>
- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- អគ្គលេខាធិការរាជរដ្ឋាភិបាល
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- ដូចមាត្រា ៤
- ឯកសារ-កាលប្បវត្តិ

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

សម្តេចព្រះមហាសុមេធាធិបតី
ព្រះសង្ឃនាយក នៃព្រះរាជាណាចក្រកម្ពុជា
លេខៈ..០០៥/០៦.....ស.ន.ក.ជ

# ព្រះសង្ឃប្រកាស
## ស្តីពី
## ការកំណត់បែងចែកភារកិច្ចគណៈសង្ឃនាយក នៃព្រះរាជាណាចក្រកម្ពុជា

## សម្តេចព្រះមហាសុមេធាធិបតី ព្រះសង្ឃនាយក នៃព្រះរាជាណាចក្រកម្ពុជា

- បានឃើញ រដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា,
- បានឃើញ ព្រះរាជក្រឹត្យលេខ នស/រកត/០៥០៦/២០៧ ចុះថ្ងៃទី០៤ ខែឧសភា ឆ្នាំ២០០៦ ស្តីពីការបង្កើតគណៈសង្ឃនាយក នៃព្រះរាជាណាចក្រកម្ពុជា,
- បានឃើញ អនុក្រឹត្យលេខ ៥៧៦ អនក្រ/តត ចុះថ្ងៃទី ២៤ ខែសីហា ឆ្នាំ២០០៦ ស្តីពីការបង្កើតថេរសភា នៃព្រះពុទ្ធសាសនា នៅព្រះរាជាណាចក្រកម្ពុជា,
- បានឃើញ សង្ឃប្រកាសលេខ ០០១/០៦ មស.រធត ចុះថ្ងៃទី ២៤ ខែសីហា ឆ្នាំ២០០៦ ស្តីពីការកំណត់បែងចែកភារកិច្ចសម្តេចព្រះអគ្គមហាសង្ឃរាជាធិបតី សម្តេចព្រះមហាសង្ឃរាជ និងសម្តេចព្រះមហាសុមេធាធិបតី ព្រះសង្ឃនាយក
- យោងតាមស្មារតីអង្គប្រជុំថ្ងៃទី២១ ខែសីហា ឆ្នាំ២០០៦ ស្តីពីដំណើរការប្រព្រឹត្តទៅ នៃវិស័យព្រះពុទ្ធសាសនា នៅព្រះរាជាណាចក្រកម្ពុជា,
- យោងតាមសំណូមពរ និងតម្រូវការចាំបាច់

## ស ម្រេ ច

ប្រការ ១- កំណត់បែងចែកព្រះភារកិច្ចប្រគេន មន្ត្រីសង្ឃជាន់ខ្ពស់ក្នុងជួរគណៈសង្ឃនាយកនៃព្រះរាជាណាចក្រកម្ពុជា ដូចតទៅនេះ :

* <u>ព្រះភារកិច្ចរបស់សម្តេចព្រះមហាសុមេធាធិបតី នន្ទ ង៉ែត ព្រះសង្ឃនាយក</u>

- ទទួលភារកិច្ចស្តីទី ក្នុងការគ្រប់គ្រង និងដឹកនាំការងារពុទ្ធសាសនា ក្នុងឱកាសអវត្តមានសម្តេចព្រះអគ្គមហាសង្ឃ រាជាធិបតី សម្តេចព្រះមហាសង្ឃរាជនៃព្រះរាជាណាចក្រកម្ពុជា។
- តែងតាំងលោកគ្រូចៅអធិការ គ្រូសូត្រស្តាំ-ឆ្វេង ព្រះវិន័យធរ លេខាធិការ ព្រះឧបជ្ឈាយ៍ ព្រះវិន័យធរអនុគណ ព្រះធម្មធរអនុគណ ព្រះសមុហ៍អនុគណ ព្រះលេខាធិការអនុគណ តាមសំណើ របស់សមូហភាពសង្ឃនៃវត្តនីមួយៗ ដែលរួមមានទាំងព្រះអនុគណ ព្រះបាឡាត់គណ ព្រះមេគណ ដោយមានការយល់ ព្រមពីអាជ្ញាធរមូលដ្ឋាន ស្រុក-ខ័ណ្ឌ និងខេត្ត-ក្រុង តាមរយៈក្រសួងធម្មការនិងសាសនា ដោយត្រូវរាយការណ៍ថ្វាយ សម្តេចព្រះអគ្គមហាសង្ឃរាជាធិបតី សម្តេចព្រះមហាសង្ឃរាជទ្រង់ជ្រាប ។
- ទទួលព្រះភារកិច្ច ក្តាប់ការងារស្ថិតិវត្តអារាម ភិក្ខុ សាមណេរ អាចារ្យ គណៈកម្មការវត្ត កុមារ យុវជន ស្នាក់នៅក្នុងវត្ត នៅក្នុងទូទាំងប្រទេស ប្រមូលរបាយការណ៍ថ្វាយសម្តេចព្រះអគ្គមហាសង្ឃរាជាធិបតី សម្តេចព្រះមហាសង្ឃរាជ ការបើកអនុសំវច្ឆរៈមហាសន្និបាតមន្ត្រីសង្ឃប្រចាំឆ្នាំ ត្រួតពិនិត្យដំណើរការប្រព្រឹត្តទៅនៃវិស័យព្រះពុទ្ធសាសនា ក្នុងក្របខ័ណ្ឌកិច្ចការរដ្ឋបាល និងទំនាក់ទំនងសាធារណៈ ។
- ទទួលព្រះភារកិច្ច ក្តាប់ការងារពុទ្ធិកសិក្សាគ្រប់កម្រិត ចាប់ពីពុទ្ធិកបឋមសិក្សារហូតដល់ពុទ្ធិកឧត្តមសិក្សានិងក្រោយពុទ្ធិកឧត្តមសិក្សាទូទាំងប្រទេស ក្នុងឋានៈជា អគ្គាធិការពុទ្ធិកសិក្សាជាតិ និងជាពុទ្ធិកសាកលវិទ្យាធិការនៃពុទ្ធិកសាកលវិទ្យាល័យ ដោយត្រូវផ្តោតព្រះទ័យទៅលើការពង្រឹង គុណភាព នៅសាលាពុទ្ធិកបឋមសិក្សានៅថ្នាក់មូលដ្ឋាន មានបញ្ហាគ្រូ បញ្ហាសម្ភារៈបរិក្ខារ កម្មវិធីសិក្សា ។ល។ និងសាលា ធម្មវិន័យទាំងពាថ្នាក់ ។/

* <u>ព្រះភារកិច្ចសម្តេចព្រះធម្មលិខិត លាស់ ឡាយ ព្រះសង្ឃនាយករងទី១</u> :

- ទទួលព្រះភារកិច្ចស្តីទី ក្នុងការគ្រប់គ្រង និងដឹកនាំការងារព្រះពុទ្ធសាសនា ក្នុងឱកាសអវត្តមានសម្តេចព្រះមហាសុមេធាធិបតី នន្ទ ង៉ែត ព្រះសង្ឃនាយក នៃព្រះរាជាណាចក្រកម្ពុជា ។
- ទទួលភារកិច្ច ជាប្រធានថេរសភា នៃព្រះពុទ្ធសាសនា នៅព្រះរាជាណាចក្រកម្ពុជា ។
- ទទួលភារកិច្ច ត្រួតពិនិត្យនូវរាល់អត្ថបទ ឯកសារ ធម៌ទេសនា សំដែងតាមវិទ្យុ ទូរទស្សន៍ និងសៀវភៅធម៌ទាំងឡាយ ដែលត្រូវបោះពុម្ពផ្សាយ ។

* <u>ព្រះភារកិច្ចសម្តេចព្រះពោធិវង្ស អំ លឹមហេង ព្រះសង្ឃនាយករងទី២</u>

- ទទួលព្រះភារកិច្ចការងាររដ្ឋបាល គ្រប់គ្រងត្រា ការងារលិខិតស្នាម ទំនាក់ទំនងសាធារណៈជាមួយបណ្តាក្រសួង ស្ថាប័ន អង្គភាព និងខេត្ត-ក្រុង ក្នុងទូទាំងព្រះរាជាណាចក្រកម្ពុជា ទាំងផ្នែកពុទ្ធចក្រ និងទាំងផ្នែកអាណាចក្រ ។
- ជួយក្តាប់ស្ថិតិវត្តអារាម ភិក្ខុសាមណេរ សីលវន្ត សីលវតី អាចារ្យ គណៈកម្មការ ចាស់ព្រឹទ្ធាចារ្យ កុមារ យុវជន ស្នាក់នៅវត្ត នៅក្នុងទូទាំងព្រះរាជាណាចក្រកម្ពុជា បូកសរុបរាយការណ៍ប្រគេនសម្តេចព្រះមហាសុមេធាធិបតី ព្រះសង្ឃនាយកប្រចាំខែ ប្រចាំត្រីមាស និងប្រចាំឆ្នាំ

* <u>ព្រះភារកិច្ចសម្តេចព្រះវនរ័ត ណយ ជ្រឹង ព្រះសង្ឃនាយករងទី៣</u>

- ជួយបំពេញព្រះភារកិច្ចរាល់ការងារចាត់តាំង តម្លើងឋានៈ ដកចេញតួនាទី ត្រួតពិនិត្យ ការសុំអនុញ្ញាតបំបួសគុលបុត្រ ( ភិក្ខុ សាមណេរ) ការសាងសង់សំណង់សំខាន់ៗ រៀបចំវត្តអារាម បរិស្ថាននៃវត្តនីមួយៗ ស័ក្តិសមជាអារាម គួរគោរពបូជា ដោយជ្រះថ្លា រក្សាបេតិកភ័ណ្ឌជាតិ បេតិកភ័ណ្ឌសាសនា ប្រពៃណីទំនៀមទំលាប់ អារ្យធម៌ វប្បធម៌ជាតិ
- ជួយការងារតែងតាំង គ្រូសូត្រស្តាំ-ឆ្វេង ចៅអធិការ ព្រះឧបជ្ឈាយ៍ ព្រះវិន័យធរអនុគណ ព្រះធម្មធរអនុគណ-ព្រះសមុហ៍អនុគណ ព្រះលេខាធិការអនុគណ និង គារកសង្ឃនៃវត្តនីមួយៗ ក្នុងកម្រិតថ្នាក់ស្រុក ខ័ណ្ឌ ឃុំ សង្កាត់

<u>ប្រការ</u> ២- សម្តេចព្រះសង្ឃនាយក សម្តេចព្រះនាយករងគ្រប់អង្គ មានសហការីមួយចំនួនជាជំនួយការ តាមតំរូវការជាក់ស្តែង នៃភារកិច្ចមួយអង្គៗ និងទទួលបំពេញភារកិច្ចបន្ថែមតាមតម្រូវការរបស់សម្តេចព្រះសង្ឃនាយក ។

<u>ប្រការ</u> ៣- គណៈសង្ឃនាយកគ្រប់អង្គ ធ្វើការងារដោយកិច្ចសហការជិតស្និទ្ធ ក្នុងជំហរសាមគ្គីភាព ជាសហធម្មិក តាមភារកិច្ចដែលបានកំណត់ ឱ្យប្រព្រឹត្តទៅទទួលបានជោគជ័យ និងលទ្ធផលល្អប្រសើរ ។

<u>ប្រការ</u> ៤- រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងធម្មការនិងសាសនា រដ្ឋមន្ត្រី រដ្ឋលេខាធិការពាក់ព័ន្ធ គ្រប់ខេត្ត-ក្រុង និងមន្ត្រីសង្ឃគ្រប់ជាន់ថ្នាក់ ត្រូវអនុវត្តតាមព្រះសង្ឃប្រកាសនេះ ។

<u>ប្រការ</u> ៥- បទប្បញ្ញត្តិទាំងឡាយណា ដែលមានខ្លឹមសារផ្ទុយពីព្រះសង្ឃប្រកាសនេះ ត្រូវទុកជានិរាករណ៍ ។

<u>ប្រការ</u> ៦- ព្រះសង្ឃប្រកាសនេះ មានប្រសិទ្ធភាព និងស្ថេរភាព ចាប់ពីថ្ងៃចុះព្រះហស្តលេខា តទៅ

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី២៥ ខែធ្នូ ព.ស ២៥៥០ គ.ស ២០០៦

សម្តេចព្រះមហាសុមេធាធិបតី
ព្រះសង្ឃនាយក

នន្ទ ង៉ែត

លេខ : ០២ ព្រស-បក

បានឃើញ និងឯកភាព
រាជធានីភ្នំពេញ ថ្ងៃទី ២៩ ខែ ធ្នូ ឆ្នាំ២០០៦
នាយករដ្ឋមន្ត្រី

ហ៊ុន សែន

<u>ចម្លងជូន</u>
- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- អគ្គលេខាធិការរាជរដ្ឋាភិបាល
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- ដូចប្រការ ៤
- ឯកសារ-កាលប្បវត្តិ

# ឧបសម្ព័ន្ធទី១០

**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

ក្រសួងធម្មការ និង សាសនា

លេខ ១៤៣/១៩ ក.ធ.សប្រក

# ប្រកាស

## ស្តីពី

## ការរៀបចំជ្រើសរើស និងការប្រព្រឹត្តទៅរបស់អាចារ្យ គណៈកម្មការវត្ត

## ទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងធម្មការ និងសាសនា

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៨/៩២៥ ចុះថ្ងៃទី០៦ ខែកញ្ញា ឆ្នាំ២០១៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦១៨/០១២ ចុះថ្ងៃទី២៨ ខែមិថុនា ឆ្នាំ២០១៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅ នៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/១៩ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងធម្មការ និងសាសនា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៨០១/១៤ ចុះថ្ងៃទី៣០ ខែសីហា ឆ្នាំ២០០១ ដែលប្រកាសឱ្យប្រើច្បាប់ភូមិបាល
- បានឃើញអនុក្រឹត្យលេខ ១៥៤ អនក្រ.បក ចុះថ្ងៃទី១១ ខែ កក្កដា ឆ្នាំ ២០១១ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួងធម្មការ និងសាសនា
- យោងលិខិតលេខ ១២៣១ សជណ ចុះថ្ងៃទី២៣ ខែសីហា ឆ្នាំ២០១៩ ស្តីពីការឯកភាពលើសំណើសុំគោលការណ៍រៀបចំតាក់តែងសេចក្តីព្រាងច្បាប់ស្តីពីការគ្រប់គ្រងសាសនា
- យោងតាមតម្រូវការចាំបាច់របស់ក្រសួងធម្មការ និងសាសនា។

## សម្រេច

## ជំពូកទី ១

## បទប្បញ្ញត្តិទូទៅ

**ប្រការ១._**

ប្រកាសនេះ មានគោលដៅ ពង្រឹងការគោរពប្រតិបត្តិវិស័យព្រះពុទ្ធសាសនានៅព្រះរាជាណាចក្រកម្ពុជា ដើម្បីធានានូវសុក្រឹតភាព ស្របតាមពុទ្ធប្បញ្ញត្តិ ពុទ្ធានុញ្ញាត និងអភិសមាចារ ដោយផ្អែកលើព្រះធម៌វិន័យ និងច្បាប់រដ្ឋ។

**ប្រការ២._**

ប្រកាសនេះ មានគោលបំណង ៖

-ដើម្បីគ្រប់គ្រង និងថែរក្សា ទ្រព្យសម្បត្តិ កុសលនិងថវិកាវត្ត ឱ្យមានតម្លាភាព តម្លាភាព និងប្រសិទ្ធភាពខ្ពស់



# 393, វិថី ព្រះស៊ីសុវត្ថិ សង្កាត់ ជ័យជំនះ ខណ្ឌ ដូនពេញ រាជធានីភ្នំពេញ ទូរស័ព្ទ : (៨៥៥-២៣) ៧២២ ៦៥៥ ទូរសារ : (៨៥៥-២៣) ៧២៥ ៦៥៥ អ៊ីម៉ែល : ministry religion@yahoo.com Web site : www.mocar.gov.kh

-ដើម្បីទប់ស្កាត់រាល់ការរំលោភយកអចលនទ្រព្យ សម្បត្តិគរុភណ្ឌ និងថវិកាវត្ត

-ដើម្បីថែរក្សាប្រពៃណី ទំនៀមទម្លាប់ ក្នុងការរៀបចំពុទ្ធសាសនពិធីឱ្យបានត្រឹមត្រូវស្របតាមពុទ្ធបញ្ញត្តិ ពុទ្ធានុញ្ញាត និងអភិសមាចារ ស័ក្តិសមជាសាសនារបស់រដ្ឋ

-ដើម្បីជាជំនួយការ គណៈសង្ឃវត្ត ក្នុងការគ្រប់គ្រងដឹកនាំឱ្យមានសណ្តាប់ធ្នាប់ និងរបៀបរៀបរយល្អ គួរជាទីគោរពសក្ការបូជា។

**ប្រការ៣._**

ប្រកាសនេះ មានវិសាលភាពអនុវត្ត ចំពោះអាចារ្យ គណៈកម្មការវត្ត និងបុគ្គល(អ្នក) ពាក់ព័ន្ធទូទាំងព្រះរាជាណាចក្រកម្ពុជា។

## ជំពូកទី ២
## ការរៀបចំ និងការជ្រើសរើស

**ប្រការ៤._**

គ្រប់វត្តអារាមទូទាំងព្រះរាជាណាចក្រកម្ពុជា ត្រូវរៀបចំជ្រើសរើសអាចារ្យ០១ (មួយ)ក្រុម និងគណៈកម្មការវត្ត០១ (មួយ)ក្រុម ជាតំណាងពុទ្ធបរិស័ទចំណុះជើងវត្ត ដើម្បីជួយសម្រួលការងារគណៈសង្ឃវត្ត ក្នុងការគ្រប់គ្រង ដឹកនាំវត្តអារាមតាមសំណើរបស់ព្រះគ្រូចៅអធិការវត្តសាមី។

**ប្រការ៥._**

សមាសភាពអាចារ្យ និងគណៈកម្មការវត្ត ត្រូវរៀបចំឱ្យមានដូចខាងក្រោម ÷

១.អំពីអាចារ្យវត្ត ត្រូវរៀបចំជាចំនួនសេស ដែលមានសមាសភាព :

- អាចារ្យធំ០១ (មួយ) រូប
- អាចារ្យរងមួយចំនួនតាមការចាំបាច់។

២.អំពីគណៈកម្មការវត្ត ត្រូវរៀបចំជាចំនួនសេស ដែលមានសមាសភាព :

- ប្រធាន០១ (មួយ) រូប
- អនុប្រធាន០១ (មួយ) រូប
- សមាជិកមួយចំនួនតាមការចាំបាច់។

**ប្រការ៦._**

បេក្ខជនអាចារ្យ គណៈកម្មការវត្ត និងអ្នកបោះឆ្នោត ត្រូវមានលក្ខណៈសម្បត្តិដូចខាងក្រោម÷

១.បេក្ខជនអាចារ្យ

-ជាទីតិជន មានសញ្ជាតិខ្មែរពីកំណើត

-ធ្លាប់បានបួសជាភិក្ខុ ឬសាមណេរក្នុងព្រះពុទ្ធសាសនា

-ជាអ្នកសមាទានសីល និងមានអាស័យដ្ឋានជាអចិន្ត្រៃយ៍ចំណុះជើងវត្តសាមី

-មានចំណេះដឹងអំពីព្រះពុទ្ធសាសនា សាសនពិធី វប្បធម៌ ប្រពៃណី និងទំនៀមទម្លាប់ផ្សេងៗ

-ត្រូវចូលរួមវគ្គបណ្តុះបណ្តាលតួនាទី ភារកិច្ច និងក្រមសីលធម៌អាចារ្យខ្មែរដែលរៀបចំឡើងដោយក្រសួងធម្មការ និងសាសនា

-មានសុខភាពល្អ ឈ្លាសវៃក្នុងការដឹកនាំចាត់ចែង និងមានឆន្ទៈទទួលខុសត្រូវការងារ

-មានទំនាក់ទំនងល្អក្នុង និងក្រៅវត្ត

-មានសីលធម៌ គុណធម៌ សុជីវធម៌ និងសាមគ្គីធម៌

-មានការបញ្ជាក់ពីអាជ្ញាធរដែនដី (មេឃុំ ចៅសង្កាត់)

២. បេក្ខជនគណៈកម្មការវត្ត

-ជានីតិជន មានសញ្ជាតិខ្មែរពីកំណើត

-ធ្លាប់បានបួសជាភិក្ខុ ឬសាមណេរក្នុងព្រះពុទ្ធសាសនា

-ត្រូវចូលរួមវគ្គបណ្តុះបណ្តាលតួនាទី ភារកិច្ច និងក្រមសីលធម៌អាចារ្យខ្មែរដែលរៀបចំឡើងដោយក្រសួងធម្មការ និងសាសនា

-ជាអ្នកសមាទានសីល និងមានអាសយដ្ឋានជាអចិន្ត្រៃយ៍ចំណុះជើងវត្តសាមី មិនមែនជាមន្ត្រីរាជការ ឬ អាជ្ញាធរមានសមត្ថកិច្ច

-មានការយល់ដឹងផ្នែករដ្ឋបាល និងហិរញ្ញវត្ថុ

-មានសុខភាពល្អ ឈ្លាសវៃក្នុងការដឹកនាំចាត់ចែង និងមានឆន្ទៈទទួលខុសត្រូវការងារ

-មានទំនាក់ទំនងល្អក្នុង និងក្រៅវត្ត

-មានសីលធម៌ គុណធម៌ សុជីវធម៌ និងសាមគ្គីភាពល្អ

-មានការបញ្ជាក់ពីអាជ្ញាធរដែនដី (មេឃុំ ចៅសង្កាត់)។

៣. អ្នកបោះឆ្នោត

-ជាអ្នកសមាទានសីល និងមានអាសយដ្ឋានជាអចិន្ត្រៃយ៍ ចំណុះជើងវត្តសាមី ដែលទទួលស្គាល់ដោយព្រះគ្រូចៅអធិការវត្ត។

**ប្រការ៧._**

ការរៀបចំជ្រើសរើស អាចារ្យ គណៈកម្មការវត្ត ត្រូវធ្វើឡើងដោយគណៈកម្មការរៀបចំមួយក្រុមក្រោមការសម្របសម្រួលពី មន្ទីរធម្មការ និងសាសនា និងសាលាគណ រាជធានី ខេត្ត។

ការរៀបចំជ្រើសរើសនេះ ត្រូវចាត់ចែងផ្ទាល់ពីសំណាក់ព្រះគ្រូចៅអធិការវត្តសាមី មានការចូលរួមពីសាលាអនុគណក្រុង ស្រុក ខណ្ឌ និងអាជ្ញាធរពាក់ព័ន្ធភូមិ ឃុំ សង្កាត់ តាមរយៈការបោះឆ្នោតដោយសម្ងាត់ ឬមិនសម្ងាត់ អនុលោមតាមភាពជាក់ស្តែង។

**ប្រការ៨._**

ការជ្រើសរើសអាចារ្យ គណៈកម្មការវត្ត ប្រព្រឹត្តទៅតាមនីតិវិធីដូចខាងក្រោម÷

១. មុនថ្ងៃបោះឆ្នោត :

-គណៈកម្មការរៀបចំ ប្រជុំគ្រប់ភាគីពាក់ព័ន្ធដោយកំណត់ថ្ងៃបោះឆ្នោត និងធ្វើការប្រកាសផ្សាយអំពីការជ្រើសរើស

-ការទទួលពាក្យរបស់បេក្ខជន ត្រូវធ្វើឡើងតាមនីតិវិធី

-ការទទួលពាក្យត្រូវបញ្ចប់រយៈពេល១៥ (ដប់ប្រាំ) ថ្ងៃ ចាប់ពីថ្ងៃជូនដំណឹង

-ការប្រកាសបិទផ្សាយបញ្ជីឈ្មោះបេក្ខជន រយៈពេល០៧ (ប្រាំពីរ) ថ្ងៃដោយគិតចាប់ពីថ្ងៃឈប់ទទួលពាក្យរហូតដល់ថ្ងៃបោះឆ្នោត

-អញ្ជើញអ្នកបោះឆ្នោតឱ្យមកបោះឆ្នោត។

២. ថ្ងៃបោះឆ្នោត :

-ការបោះឆ្នោត ត្រូវធ្វើឡើងតែ០១ (មួយ) ថ្ងៃ គឺថ្ងៃឧបោសថសីល

-មន្ត្រីធម្មការ និងសាសនា ត្រូវប្រកាសពីនីតិវិធីបោះឆ្នោត ក្រុមការងាររៀបចំ ក្រុមរាប់សន្លឹកឆ្នោត និងបេក្ខជនឈរឈ្មោះឱ្យគេបោះឆ្នោត៖

-បេក្ខជនម្នាក់ៗត្រូវធ្វើការណែនាំខ្លួន និងចំណាប់អារម្មណ៍នៅចំពោះមុខអ្នកបោះឆ្នោត តាមការណែនាំរបស់គណៈកម្មការរៀបចំ

-ចាប់ផ្តើមដំណើរការបោះឆ្នោត បន្ទាប់មកធ្វើការរាប់សន្លឹកឆ្នោត និងប្រកាសលទ្ធផលភ្លាមៗ នៅចំពោះមុខអ្នកចូលរួម និងអ្នកបោះឆ្នោតទាំងអស់

-និងធ្វើកំណត់ហេតុទទួលស្គាល់លទ្ធផលឆ្នោត ដោយចុះហត្ថលេខារួមគ្នាជាការបញ្ចប់កិច្ចការបោះឆ្នោត។

៣. ក្រោយថ្ងៃបោះឆ្នោត :

-ដោយមានការយល់ព្រមពីសាលាគណរាជធានី ខេត្ត មន្ទីរធម្មការ និងសាសនារាជធានី ខេត្ត ត្រូវរៀបចំលិខិតបង្គាប់ការទទួលស្គាល់ និងប័ណ្ណសម្គាល់ខ្លួនជូនបេក្ខភាពដែលជាប់ឆ្នោតជាផ្លូវការមិនឱ្យលើសពី០៧ (ប្រាំពីរ) ថ្ងៃក្រោយពីប្រកាសលទ្ធផលបោះឆ្នោត

-ទម្រង់ នៃប័ណ្ណសម្គាល់ខ្លួនរបស់អាចារ្យ គណៈកម្មការវត្ត ត្រូវរៀបចំកំណត់ដោយ នាយកដ្ឋានកិច្ចការព្រះពុទ្ធសាសនា នៃក្រសួងធម្មការ និងសាសនា។

**ប្រការ៩._**

ប្រការដែលត្រូវជៀសវាង មានដូចខាងក្រោម÷

-ប្រាស់ចាកនូវលក្ខណៈសម្បត្តិ ដូចមានចែងក្នុង ប្រការ ៦ ខាងលើ

-បេក្ខជន មកពីសមាសភាពអាចារ្យ ឬ គណៈកម្មការវត្តអាណត្តិចាស់ ដែលធ្លាប់បានប្រព្រឹត្តអំពើខុសឆ្គង ហើយត្រូវបានព្រះគ្រូចៅអធិការវត្ត និងអ្នកពាក់ព័ន្ធដកសេចក្តីទុកចិត្តដោយមានកំណត់ហេតុបញ្ជាក់ត្រឹមត្រូវ

-មន្ត្រីរាជការ អាជ្ញាធរ សកម្មជនអង្គការ សមាគម និងផ្នែកពាហិរសាសនា

-ពិរុទ្ធជនដែលកំពុងស្ថិតនៅក្រោមការតាមដានពីច្បាប់របស់រដ្ឋ ឬខណ្ឌិត

-អ្នកជ្រួញជួរ (ជំនួញខុសច្បាប់ប្រការ) សេពគ្រឿងញៀន គ្រឿងស្រវឹង និងប្រើអំពើហិង្សាគ្រប់ទម្រង់។

## ជំពូកទី ៣
## តួនាទី និងភារកិច្ច

**ប្រការ១០._**

អាចារ្យ គណៈកម្មការវត្ត មានតួនាទី និងភារកិច្ច ជាជំនួយការដល់គណៈសង្ឃវត្តលើការងារដូចខាងក្រោម÷

១. អាចារ្យ :

-ដឹកនាំរៀបចំពិធីកម្មសាសនា តាមប្រពៃណីទំនៀមទម្លាប់ខ្មែរ និងប្រពៃណីព្រះពុទ្ធសាសនា

-ទំនាក់ទំនងពុទ្ធបរិស័ទដើម្បីធ្វើការអប់រំ ផ្សព្វផ្សាយ ទ្រទ្រង់ព្រះពុទ្ធសាសនា

-ទប់ស្កាត់ និងរម្ងាប់អធិករណ៍ទាំងឡាយណាដែលកើតមានឡើងទាំងក្នុងវត្ត និងក្រៅវត្ត

-អនុវត្តកិច្ចការមួយចំនួនទៀត តាមសំណូមពរចាំបាច់របស់ពុទ្ធបរិស័ទ

-ជួយទំនុកបម្រុងព្រះសង្ឃ និងពុទ្ធបរិស័ទចំណុះជើងវត្ត

-សហការគ្រប់ការងារជាមួយគណៈកម្មការវត្ត ។

២. គណៈកម្មការវត្ត :

-ការងាររដ្ឋបាលទូទៅរបស់វត្តទាំងមូល

-ការងារកិច្ចបញ្ជីការហិរញ្ញវត្ថុរបស់វត្ត (ដោយបង្កើតឱ្យមានគណនេយ្យករ អ្នកកាន់លុយវត្ត" ទាំងថវិកាកសាង ទាំងថវិកាវត្ត ត្រូវតម្កល់ទុកក្នុងធនាគារនៅជិតបំផុត។ អ្នកទទួលខុសត្រូវតម្កល់ និងដក ថវិកាវត្ត ត្រូវមានសមាសភាពព្រះគ្រូចៅអធិការវត្ត អាចារ្យធំ ប្រធានគណៈកម្មការវត្ត និងគណនេយ្យករ)

-ទំនាក់ទំនងជាមួយអាជ្ញាធរដែនដីគ្រប់លំដាប់ថ្នាក់ និងពុទ្ធបរិស័ទទូទៅ

-គ្រប់គ្រង ថែរក្សា និងចុះបញ្ជីទ្រព្យសម្បត្តិគុរុភណ្ឌវត្ត

-ផ្គត់ផ្គង់ចង្ហាន់ព្រះសង្ឃ

-គ្រប់គ្រងស្ថិតិព្រះសង្ឃ និងអ្នកស្នាក់នៅក្នុងវត្ត

-រៀបចំសណ្តាប់ធ្នាប់ទូទៅ និងរក្សាសន្តិសុខសុវត្ថិភាពក្នុងវត្ត

-រៀបចំប្លង់មេ(ហេដ្ឋារចនាសម្ព័ន្ធវត្ត) របងក្លោងទ្វារវត្ត សម្រាប់អភិវឌ្ឍន៍វត្តអារាមឱ្យត្រូវតាម បែបបទព្រះពុទ្ធសាសនា និងវប្បធម៌ជាតិខ្មែរ

-សាងសង់សំណង់ផ្សេងៗ និងកែលម្អសោភណ្ឌភាពវត្តឱ្យសក្តិសមជារមណីយដ្ឋានទេសចរណ៍ សាសនា និងបូជានីយដ្ឋានរបស់ជាតិ

-សហការជាមួយអាចារ្យ ក្នុងការជួយរៀបចំពិធីបុណ្យផ្សេងៗ

-សហការជាមួយអាចារ្យ និងអ្នកពាក់ព័ន្ធ ក្នុងការរៀបចំ ចងក្រង និងរក្សាទុកនូវឯកសារផ្សេងៗ (ប្រវត្តិវត្ត ប្លង់កម្មសិទ្ធិដីវត្ត...)

-សហការទប់ស្កាត់ និងរម្ងាប់អធិករណ៍ទាំងឡាយណាដែលកើតមានឡើងទាំងក្នុងវត្ត និងក្រៅវត្ត

-អនុវត្តភារកិច្ចមួយចំនួនទៀត តាមសំណូមពរចាំបាច់របស់សមូហភាព។

**ប្រការ១១._**

អាចារ្យ គណៈកម្មការវត្ត ដែលបានទទួលស្គាល់រួចហើយ ត្រូវអនុវត្តតួនាទី និងភារកិច្ចរបស់ខ្លួនតាម អាណត្តិដែលបានកំណត់។

## ជំពូកទី ៤
## ការបញ្ចប់តួនាទី និងភារកិច្ច

**ប្រការ១២._**

អាចារ្យ គណៈកម្មការវត្ត ដែលបានជ្រើសរើសតាមនីតិវិធី មានអាណត្តិការងាររបស់ខ្លួន រយៈពេល ០៣ (បី)ឆ្នាំ។ កាលបើផុតកំណត់រយៈពេល០៣ (បី)ឆ្នាំ អាចារ្យ គណៈកម្មការវត្តទាំងនោះ ត្រូវអស់សុពលភាព ជាស្វ័យប្រវត្តិ។

មុនពេលបញ្ចប់តួនាទីភារកិច្ច អាចារ្យ គណៈកម្មការវត្តអាណត្តិចាស់ ត្រូវរៀបចំជម្រះបញ្ជី និង ធ្វើរបាយការណ៍ទូទាត់ចំណូលចំណាយឱ្យបានត្រឹមត្រូវ ប្រគេនព្រះគ្រូចៅអធិការវត្ត ដើម្បីទុកជូនអាចារ្យ គណៈកម្មការវត្តអាណត្តិថ្មី។

ការជ្រើសរើសអាចារ្យ គណៈកម្មការវត្តអាណត្តិថ្មី ត្រូវរៀបចំតាមនីតិវិធី មិនឱ្យលើស រយៈពេល០៧ (ប្រាំពីរ)ថ្ងៃ បន្ទាប់ពីបញ្ចប់តួនាទីភារកិច្ចអាចារ្យ គណៈកម្មការវត្តអាណត្តិចាស់។ ដំណាក់កាលនេះ អាចារ្យ គណៈកម្មការវត្តអាណត្តិចាស់ មានភារកិច្ចជួយសម្របសម្រួលការងារជាបណ្តោះអាសន្ន រហូតដល់មាន អាចារ្យ គណៈកម្មការវត្តអាណត្តិថ្មីមកជំនួស។

**ប្រការ១៣._**

ការស្នើសុំលុបឈ្មោះ ឬបញ្ឈប់សមាជិកណាម្នាក់ និងកែសម្រួលសមាសភាពអាចារ្យ គណៈកម្មការវត្ត ក្នុងអាណត្តិ ត្រូវធ្វើឡើងតាមស្មារតីរួមនៃការប្រជុំអ្នកពាក់ព័ន្ធ ដូចមានចែងក្នុងប្រការ៧ នៃប្រកាសនេះ។

ក្នុងករណីបាត់បង់សមាសភាពអាចារ្យ គណៈកម្មការវត្តណាមួយក្នុងអាណត្តិការងារដោយមរណភាព បាត់បង់សមត្ថភាព កំហុសធ្ងន់ធ្ងរ ឬបំពេញបន្ថែមសមាសភាពថ្មី ព្រះគ្រូចៅអធិការវត្ត និងអ្នកពាក់ព័ន្ធត្រូវធ្វើរបាយការណ៍ទៅមន្ទីរធម្មការ និងសាសនា និងសាលាគណរាជធានី ខេត្តបានជ្រាប និងរៀបចំជ្រើសរើសបេក្ខភាពជំនួស ឬបន្ថែមតាមឋានានុក្រម។

## ជំពូកទី ៥
## អំពីទណ្ឌកម្ម

**ប្រការ១៤._**

អាចារ្យ គណៈកម្មការវត្ត ត្រូវទទួលទណ្ឌកម្មរដ្ឋបាលតាមច្បាប់ និងបទប្បញ្ញត្តិជាធរមាន ចំពោះសកម្មភាពដែលមិនបានប្រតិបត្តិតាមតួនាទី ភារកិច្ចរបស់ខ្លួន ឬប្រព្រឹត្តនូវកំហុសឆ្គងណាមួយដូចមានចែងក្នុងប្រកាសនេះ ដោយមិនគិតដល់ទណ្ឌកម្មព្រហ្មទណ្ឌ និងសំណងរដ្ឋប្បវេណី។

**ប្រការ១៥._**

ការដាក់ទណ្ឌកម្មរដ្ឋបាល ចំពោះអាចារ្យ គណៈកម្មការវត្ត រួមមាន÷

-ការស្តីបន្ទោស(ដោយមានកំណត់ហេតុ)

-ការបញ្ឈប់ដោយបង្ខំ តាមវិធានការខាងវិន័យព្រះពុទ្ធសាសនា

-ការលុបឈ្មោះមុនអាណត្តិ

-ការហាមឃាត់មិនឱ្យដឹកនាំពិធីកម្មសាសនា

-ឈប់ឱ្យឈរឈ្មោះជាបេក្ខភាពតទៅទៀត ។

## ជំពូកទី ៦
## អន្តរប្បញ្ញត្តិ

**ប្រការ១៦._**

មន្ទីរធម្មការ និងសាសនា និងសាលាគណ រាជធានី ខេត្ត មានភារកិច្ចក្នុងការសម្របសម្រួលជាមួយគណៈសង្ឃគ្រប់លំដាប់ថ្នាក់ដើម្បីរៀបចំជ្រើសរើស អាចារ្យ គណៈកម្មការវត្ត ឱ្យបានគ្រប់វត្តតាមខ្លឹមសារនៃប្រកាសនេះ។

ក្នុងករណីមិនមានការយល់ព្រមពីព្រះគ្រូចៅអធិការវត្ត ឬអាជ្ញាធរពាក់ព័ន្ធ ត្រូវធ្វើរបាយការណ៍មកក្រសួងធម្មការ និងសាសនា និងគណៈសង្ឃនាយកបានជ្រាបដើម្បីមានវិធានការ ។

**ប្រការ១៧._**

អាចារ្យ គណៈកម្មការដែលមិនមានវត្តជាប្រចាំ(តាមអាស្រម សាលាឆទាន ប្រចាំភូមិ និងគេហដ្ឋាន) ត្រូវមកចុះបញ្ជីទទួលស្គាល់នៅមន្ទីរធម្មការ និងសាសនា០៣ (បី) ឆ្នាំម្តងជាកំហិត។ អាចារ្យ គណៈកម្មការទាំងនេះ ត្រូវមានលក្ខណៈសម្បត្តិដូចប្រការ៦ នៃប្រកាសនេះ។

អាចារ្យ គណៈកម្មការដែលមិនមានវត្តជាប្រចាំ នៅក្នុងសមាគមអាចារ្យដោយបានទទួលស្គាល់ជាផ្លូវការរួចហើយ ត្រូវអនុវត្តតាមលក្ខន្តិកៈរបស់សមាគមឱ្យបានត្រឹមត្រូវ និងត្រូវមកចុះបញ្ជីទទួលស្គាល់នៅមន្ទីរធម្មការ និងសាសនារាជធានី ខេត្ត០៣ (បី) ឆ្នាំម្តងដូចគ្នា។

ក្នុងករណីពុំបានមកចុះបញ្ជី មិនអនុញ្ញាតឱ្យធ្វើសកម្មភាពបម្រើក្នុងពិធីកម្មសាសនាឡើយ។

**ប្រការ១៨._**

អាចារ្យ គណៈកម្មការវត្ត ត្រូវស្លៀកពាក់នូវសម្លៀកបំពាក់ឱ្យបានសមរម្យស្របតាមទំនៀមទម្លាប់ប្រពៃណីជាតិ និងសាសនពិធីនានា

**ប្រការ១៩._**

អាចារ្យ គណៈកម្មការទាំងអស់នេះ ត្រូវមានឆន្ទៈបំពេញការងារដោយស្ម័គ្រចិត្ត ដើម្បីលើកកម្ពស់ព្រះពុទ្ធសាសនានៅក្នុងព្រះរាជាណាចក្រកម្ពុជា។

## ជំពូកទី ៧
## អវសានប្បញ្ញត្តិ

**ប្រការ២០._**

បទប្បញ្ញត្តិទាំងឡាយណា ដែលមានខ្លឹមសារផ្ទុយនឹងប្រកាសនេះ ត្រូវទុកជានិរាករណ៍ ។

**ប្រការ២១._**

នាយកខុទ្ទកាល័យ អគ្គនាយក នៃអគ្គនាយកដ្ឋានកិច្ចការសាសនា អគ្គនាយក នៃអគ្គនាយករដ្ឋបាល និងហិរញ្ញវត្ថុ លេខាធិការដ្ឋានគណៈសង្ឃនាយកទាំងពីរគណៈ ប្រធានមន្ទីរធម្មការ និងសាសនា រាជធានី ខេត្ត សាលាអនុគណក្រុង ស្រុក ខណ្ឌ និងព្រះគ្រូចៅអធិការគ្រប់វត្ត ត្រូវអនុវត្តប្រកាសនេះ ឱ្យមានប្រសិទ្ធភាពខ្ពស់ ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ [illegible]

ថ្ងៃ[illegible] ខែ[illegible] ឆ្នាំ[illegible]ស័ក ព.ស.២៥៦៣

រាជធានីភ្នំពេញ ថ្ងៃទី.០៥..ខែ.វិច្ឆិកា...ឆ្នាំ២០១៩

**ទេសរដ្ឋមន្ត្រី**

**រដ្ឋមន្ត្រីក្រសួងធម្មការ និងសាសនា**

ក្រសួងធម្មការនិងសាសនា

ហ៊ឹម_ឆែម

**កន្លែងទទួល:**

- សម្តេចព្រះមហាសង្ឃរាជទាំងពីរគណៈ
- គណៈសង្ឃនាយកទាំងពីរគណៈ
- ក្រសួងព្រះបរមរាជវាំង
- ទីស្តីការគណៈរដ្ឋមន្ត្រី
- ក្រសួងមហាផ្ទៃ
- ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- ក្រសួងវប្បធម៌ និងវិចិត្រសិល្បៈ
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- ខុទ្ទកាល័យសម្តេចតេជោនាយករដ្ឋមន្ត្រី "ដើម្បី ជ្រាប-ជូនជ្រាប"
- ស្ថាប័ន និងអង្គភាពពាក់ព័ន្ធ
- ដូចប្រការ ២១ "ដើម្បីអនុវត្ត"
- ឯកសារ-កាលប្បវត្តិ

# ឧបសម្ព័ន្ធទី១១

# សេចក្តីកំណត់

## ស្តីពីរបៀបរបប នៃការជ្រើសតាំងព្រះសង្ឃនាយក

## មេគណ-អនុគណ ចៅអធិការ-គ្រូសូត្រស្តាំ-ឆ្វេង

### I– ចៅអធិការ គ្រូសូត្រស្តាំ-ឆ្វេង

ប្រការ ១ : ចៅអធិការ គ្រូសូត្រស្តាំ-ឆ្វេង ក្នុងវត្តនីមួយៗ ត្រូវជ្រើសតាំងដោយភិក្ខុសាមណេរក្នុងវត្តនោះ តាមវិធីបោះឆ្នោត ហើយត្រូវអនុវត្តតាមបែបបទដូចតទៅៈ

ក- ព្រះថេរៈជាតំណាងភិក្ខុ សាមណេរទាំងអស់ត្រូវធ្វើលិខិតស្នើសុំទៅ អនុគណស្រុកតាមរយៈរណសិរ្ស និងរដ្ឋអំណាចមូលដ្ឋានដោយមានភ្ជាប់បញ្ជីរាយនាមភិក្ខុ សាមណេរក្នុងវត្ត និងប្រវត្តិរូបបេក្ខសមណៈចៅអធិការ គ្រូសូត្រ ស្តាំ-ឆ្វេងទៅជាមួយផង ។

ខ- អនុគណ ក្រោយបានពិភាក្សាឯកភាពជាមួយរណសិរ្ស គណបក្ស និងរដ្ឋអំណាចស្រុករួចហើយត្រូវធ្វើ លិខិតទៅរណសិរ្ស រដ្ឋអំណាចឃុំ-សង្កាត់ ឱ្យធ្វើសេចក្តីប្រកាសមួយ ដោយបញ្ជាក់នាមភិក្ខុបីរូប ដែលត្រូវឈរឈ្មោះឱ្យ គេបោះឆ្នោតនោះ ។ សេចក្តីប្រកាសនោះ កំណត់រយៈវេលា ៣០ថ្ងៃ បើគ្មាន ភិក្ខុ-សាមណេររូបណាមួយតវ៉ាអ្វីទេ រណសិរ្សនិងរដ្ឋអំណាចឃុំ-សង្កាត់ត្រូវ ធ្វើកំណត់ហេតុបញ្ជាក់ថា ក្នុងរយៈពេល ៣០ថ្ងៃនេះ គ្មានការតវ៉ាអ្វីទេ ហើយត្រូវធ្វើសេចក្តីប្រកាសមួយទៀតបិទផ្សាយ កំណត់កាលបរិច្ឆេទបោះឆ្នោតឲ្យបានយ៉ាងយូរបំផុតមួយសប្តាហ៍ ។

ប្រការ ២ : គណៈកម្មការបោះឆ្នោត គឺអនុគណធ្វើជាប្រធាន ដោយមានតំណាងរណសិរ្សស្រុក ០១រូប តំណាងរដ្ឋអំណាចស្រុក ០១ រូប អាចារ្យវត្ត ០១ រូប ជាសមាជិក និងលេខាកត់ត្រា ០១ រូប ។

ប្រការ ៣ : ភិក្ខុដែលត្រូវឈរឈ្មោះឱ្យគេបោះឆ្នោតជ្រើសតាំងជា ចៅអធិការគ្រូសូត្រស្តាំ-ឆ្វេងត្រូវមាន អាយុ ២៥ឆ្នាំយ៉ាងតិច និងមានអាយុផ្នួសពី ៥ វស្សាឡើងទៅព្រមទាំងមានគុណសម្បត្តិ សមត្ថភាពគ្រប់គ្រាន់ មានជីវប្រវត្តិល្អ និងមានជំនឿទុកចិត្តពីភិក្ខុ សាមណេរ និងពុទ្ធបរិស័ទជើងវត្ត ។

ប្រការ ៤ : បព្វជិតដែលមានជន្មាយុពី ១៩ឆ្នាំឡើងទៅ ហើយបានបួសនៅវត្តនោះរយៈ ១ឆ្នាំ ឬមួយមកគង់នៅវត្តនោះ ពីពីរ ឆ្នាំឡើងទៅ ទើបមានសិទ្ធិបោះឆ្នោត ។

ប្រការ ៥ : បេក្ខសមណៈ ដែលបានទទួលសន្លឹកឆ្នោតច្រើនជាងគេ ត្រូវបានជ្រើសតាំងជាចៅអធិការ បន្ទាប់ទៀត ត្រូវបានជាគ្រូសូត្រស្តាំ-ឆ្វេង ។

ប្រការ ៦ : ក្នុងករណីមានសន្លឹកឆ្នោតស្មើគ្នានោះបេក្ខសមណៈ ដែលមានជន្មាយុ ឬមានផ្នួសវស្សាចាស់ជាងគេនឹងត្រូវទទួលតំណែងជាបន្តបន្ទាប់ តាមលំដាប់លំដោយ ។

ប្រការ ៧ : លុះបោះឆ្នោតរួចហើយ គណៈកម្មការចាត់ចែងការបោះឆ្នោត ត្រូវធ្វើកំណត់ហេតុនៃការបោះឆ្នោត និងលទ្ធផលនៃការបោះឆ្នោត ដោយភ្ជាប់ជាមួយពាក្យស្នើសុំសេចក្តីសម្រេចចាត់តាំងទៅ គណៈកម្មាធិការ រណសិរ្សសាមគ្គីកសាងការពារមាតុភូមិកម្ពុជាខេត្ត-ក្រុង ដើម្បីសុំសេចក្តីសម្រេចពីថ្នាក់លើ ។

III - អនុគណ និង សហការីអនុគណ

ប្រការ ៨ : ស្រុក-ខ័ណ្ឌដែលពុំទាន់មានអនុគណនោះ ត្រូវសហការីអនុគណ ឬ ចៅអធិការវត្តណាមួយ ដែលមានវ័យ និងវស្សាចាស់ជាងគេធ្វើពាក្យស្នើសុំទៅមេគណខេត្ត-ក្រុង ដើម្បីឱ្យជ្រើសតាំងអនុគណ ដោយមានភ្ជាប់ទៅ ជាមួយនូវបញ្ជីរាយនាម ចៅអធិការគ្រប់វត្តក្នុងស្រុក-ខ័ណ្ឌផង ។

ប្រការ៩ : មេគណ ខេត្ត-ក្រុង កាលបើបានទទួលសំណុំលិខិតស្នើហើយ ត្រូវពិភាក្សាជាមួយរណសិរ្សខេត្ត ដើម្បីរណសិរ្សពិភាក្សាជាមួយគណបក្សខេត្ត និងរដ្ឋអំណាចខេត្តប្រមើល មើលបេក្ខជនសមណៈអនុគណ ២រូប ក្នុងចំណោមចៅអធិការ ឬក្នុងបណ្តាសហការីអនុគណស្រុក-ខ័ណ្ឌនោះ សម្រាប់ឈរឈ្មោះ ឱ្យគេបោះឆ្នោតជ្រើសតាំងជាអនុគណ ។ នេះជាភារកិច្ចផ្ទាល់របស់មេគណខេត្ត រណសិរ្សខេត្ត គណបក្សខេត្ត និងរដ្ឋអំណាចខេត្ត ពិភាក្សាគ្នាដោះស្រាយ ។ ក្នុងករណីជួបបញ្ហាលំបាក គួរចាត់តាំងការបោះឆ្នោតជ្រើសរើសបេក្ខភាពមួយលើកសិន ។ លុះជ្រើសរើសបានហើយ រណសិរ្ស និងរដ្ឋអំណាចស្រុក ធ្វើសេចក្តីប្រកាសមួយច្បាប់ស្តីពីការបោះឆ្នោតជ្រើសរើសអនុគណ ដោយមានដាក់នាមវត្ត និងនាមបេក្ខសមណៈអនុគណផង ។ សេចក្តីប្រកាសនេះត្រូវផ្ញើទៅចៅអធិការគ្រប់វត្តក្នុងស្រុក-ខ័ណ្ឌ មានរយៈវេលា ៣០ថ្ងៃ គ្រប់កំណត់ ៣០ថ្ងៃហើយ បើសិនមិនមានប្រតិកម្មអ្វីទេ រណសិរ្ស និងរដ្ឋអំណាចស្រុក-ខ័ណ្ឌ ត្រូវធ្វើលិខិតទៅមេគណខេត្ត-ក្រុង សុំសេចក្តីសម្រេចកាលបរិច្ឆេទនៃការបោះឆ្នោត មិនឱ្យលើស ពីមួយសប្តាហ៍ ។

ប្រការ ១០ : បេក្ខសមណៈអនុគណ ត្រូវធ្វើប្រវត្តិរូបឲ្យច្បាស់លាស់ ។

ប្រការ ១១ : ភិក្ខុដែលមានសិទ្ធិបោះឆ្នោតនោះ គឺភិក្ខុជាសហការីនៃមេគណ និងជាចៅអធិការវត្តនៅក្នុង ស្រុក-ខ័ណ្ឌ របស់ខ្លួន ដែលមានសេចក្តីសម្រេចចាត់តាំង ជាផ្លូវការត្រឹមត្រូវរួចហើយ ។

ប្រការ ១២ : គណៈកម្មការបោះឆ្នោតជ្រើសរើសអនុគណនោះមាន: មេគណខេត្តជាប្រធានដោយមានតំណាងរណសិរ្សខេត្ត ១រូប តំណាងគណបក្សខេត្ត ១រូប តំណាងរដ្ឋអំណាចខេត្ត ១រូប តំណាងរណសិរ្សស្រុក-ខ័ណ្ឌ ១រូប តំណាងរដ្ឋអំណាចស្រុក-ខ័ណ្ឌ និងលោករាចារ្យ ១រូប ជាសមាជិកក្នុងនោះ ១រូបជាលេខាកត់ត្រា ។

ប្រការ ១៣ : បើបោះឆ្នោតទៅហើយ សន្លឹកឆ្នោតបានស្មើគ្នានោះ បេក្ខសមណៈ ដែលមានជន្មាយុច្រើន ឬមានវស្សា ផ្នួសចាស់ជាង នឹងត្រូវបានចាត់តាំងជាអនុគណ ។

ប្រការ ១៤ : លុះបោះឆ្នោតរួចហើយ ត្រូវធ្វើកំណត់ហេតុបញ្ចូលសំណុំលិខិត ស្តីពីលទ្ធផលបោះឆ្នោតនេះ ទៅគណៈអចិន្ត្រៃយ៍ក្រុមប្រឹក្សាជាតិរណសិរ្ស ដើម្បីពិនិត្យចេញសេចក្តីចាត់តាំងជាផ្លូវការ ។

ប្រការ ១៥ : អនុគណថ្មី ក្រោយពីបានទទួលសេចក្តីសម្រេចជាផ្លូវការហើយ ត្រូវជ្រើសរើសព្រះថេរៈ ១រូប បំពេញបន្ថែមកន្លែងដែលខ្វះវិញ ។

ប្រការ ១៦ : សហការីអនុគណទាំង ៤រូប មិនមានការបោះឆ្នោតជ្រើសតាំងទេ គឺអនុគណឯកភាពជាមួយរណសិរ្សគណបក្ស និងរដ្ឋអំណាចស្រុក-ខេត្ត ជ្រើសរើសបណ្តាព្រះថេរានុត្ថេរៈ ដែលមាន សមត្ថភាពក្នុងស្រុក-ខ័ណ្ឌ ខេត្តសាមី ហើយធ្វើលិខិតស្នើដោយមានភ្ជាប់ប្រវត្តិរូបសង្ខេបផង ទៅគណៈអចិន្ត្រៃយ៍ក្រុមប្រឹក្សាជាតិរណសិរ្ស តាមរយៈមេគណខេត្ត-ក្រុង ដើម្បីពិនិត្យចេញសេចក្តីសម្រេចទទួលស្គាល់ជាផ្លូវការ ។

## III - មេគណ និង សហការីមេគណ

ប្រការ ១៧ : ខេត្ត-ក្រុងណាដែលមិនមានមេគណសហការីមេគណ ឬអនុគណដែលមានវ័យចាស់ជាងគេ ត្រូវពិភាក្សាជាមួយរណសិរ្ស គណបក្ស និងរដ្ឋអំណាចខេត្ត-ក្រុងសាមី ដើម្បីស្នើសំណុំបែបបទជ្រើសតាំងទៅលេខាធិការដ្ឋាន ព្រះសង្ឃនាយក ដោយមានបញ្ជាក់នាមសហការី ឬអនុគណស្រុកណាមួយចំនួនពីរ ឬ បីរូបឱ្យឈរជាបេក្ខសមណៈ ដោយមានភ្ជាប់បញ្ជីរាយនាម និងជីវប្រវត្តិរបស់បេក្ខសមណៈនោះ ទៅជាមួយផង ។

ប្រការ ១៨ : លេខាធិការដ្ឋានព្រះសង្ឃនាយក ជាមួយគណៈអចិន្ត្រៃយ៍ក្រុមប្រឹក្សាជាតិរណសិរ្ស ក្រោយពីបានពិភាក្សាឯកភាពលើសំណុំលិខិតនេះហើយ ត្រូវជូនដំណឹងទៅរណសិរ្ស គណបក្ស និងរដ្ឋអំណាចខេត្ត-ក្រុង ឱ្យចេញសេចក្តីប្រកាសមួយ ស្តីពីការបោះឆ្នោតជ្រើសរើសមេគណខេត្ត-ក្រុង ដោយមានបញ្ជាក់នាម បេក្ខសមណៈមេគណពីរ ឬ បីរូបនោះ សរសេរនាមច្បាស់លាស់ទៅគ្រប់អនុគណស្រុក-ខ័ណ្ឌ ក្នុងរយៈវេលា ៣០ថ្ងៃ ។ គ្រប់កំណត់ ៣០ថ្ងៃហើយ បើមានប្រតិកម្មអវិជ្ជមានពីបណ្តាអនុគណ ឬ ពីសហការីមេគណនោះ ត្រូវស៊ើបសាជាថ្មី ហើយប្រកាសថ្មីក្នុងរយៈវេលា ៣០ថ្ងៃទៀត បើគ្មានប្រតិកម្មអ្វីទេ ត្រូវស្នើទៅលេខាធិការដ្ឋានព្រះសង្ឃនាយក ដោយកំណត់ច្បាស់លាស់កាលបរិច្ឆេទ បោះឆ្នោតកុំឱ្យហួស ពីមួយសប្តាហ៍ ។

ប្រការ ១៩ : គណៈកម្មាធិការបោះឆ្នោតជ្រើសតាំងមេគណមាន : តំណាងព្រះសង្ឃនាយក ១រូប ជាប្រធាន តំណាង រណសិរ្សខេត្ត-ក្រុង ១រូប តំណាងគណបក្សខេត្ត-ក្រុង ១រូប តំណាងរដ្ឋអំណាចខេត្ត-ក្រុង ១រូប អាចារ្យវត្ត ១រូប ជាសមាជិក និងលេខាធិការកត់ត្រា ១ រូបផង ។

ប្រការ ២០ : បើការបោះឆ្នោតមានសន្លឹកឆ្នោតស្មើគ្នានោះ បេក្ខសមណៈដែលមានជន្មាយុច្រើន ឬវស្សាចាស់ជាង ត្រូវបានជ្រើសតាំងជាមេគណ ។

ប្រការ ២១ : លុះបោះឆ្នោតរួចហើយ ត្រូវធ្វើកំណត់ហេតុបញ្ជូនសំណុំលិខិតទាំងមូល ទៅលេខាធិការដ្ឋានព្រះសង្ឃនាយក ដើម្បីពិនិត្យដាក់ជូនគណៈអចិន្ត្រៃយ៍ក្រុមប្រឹក្សាជាតិរណសិរ្សពិនិត្យសម្រេច ។

ប្រការ ២២ : មេគណថ្មី កាលបើបានទទួលសេចក្តីសម្រេចតែងតាំងជាផ្លូវការហើយ ត្រូវស្នើសុំជ្រើសរើស ចាត់តាំង សហការី ឬអនុគណណាដែលខ្វះចន្លោះនោះ បង្គ្រប់ឡើងវិញ ។

ប្រការ ២៣ : សហការីមេគណទាំង ៤រូប មិនមានការបោះឆ្នោតទេ ស្រេចលើមេគណឯកភាពជាមួយរណសិរ្ស គណបក្សនិងរដ្ឋអំណាចខេត្ត-ក្រុង ដើម្បីជ្រើសរើស ព្រះថេរានុត្ថេរៈរូបណាខ្លះ ដែលមានសមត្ថភាពតាមសេចក្តីស្នើឡើងទៅ គណៈព្រះសង្ឃនាយក និងគណៈអចិន្ត្រៃយ៍ក្រុមប្រឹក្សាជាតិរណសិរ្ស ដើម្បីចេញសេចក្តីសម្រេច តែងតាំងជាផ្លូវការដោយមានភ្ជាប់ប្រវត្តិរូបសង្ខេប ទៅជាមួយផង ។

## IV - សង្ឃនាយក និង សហការី :

ប្រការ ២៤ : នៅពេលដែលមិនមានព្រះសង្ឃនាយកតំណាងសមាជិក ឬ សហការីនៃលេខាធិការដ្ឋានព្រះសង្ឃនាយក ធ្វើលិខិតស្នើសុំជ្រើសតាំងពីរ ឬបីអង្គជាបេក្ខសមណៈសង្ឃនាយកជូនគណៈអចិន្ត្រៃយ៍ក្រុមប្រឹក្សាជាតិរណសិរ្ស ដើម្បីពិចារណា ។

ប្រការ ២៥ : គណៈអចិន្ត្រៃយ៍ក្រុមប្រឹក្សាជាតិរណសិរ្ស ក្រោយពិនិត្យពិចារណា បើឃើញថាសមហេតុផល ហើយត្រូវចេញសេចក្តីប្រកាសមួយ ស្តីពីការបោះឆ្នោតជ្រើសតាំងព្រះសង្ឃនាយកដោយសរសេរនាមបេក្ខសមណៈ ពីរ ឬ បីអង្គនោះ ទៅជាមួយផង ប្រគេនទៅមេគណគ្រប់ខេត្ត-ក្រុង ដើម្បីពិនិត្យពិចារណាក្នុងរយៈវេលា ៤៥ ថ្ងៃ ។

គ្រប់កំណត់ ៤៥ ថ្ងៃហើយ បើមានសំណូមពរអវិជ្ជមាន នោះត្រូវជ្រើសរើសជាថ្មី ហើយកំណត់ រយៈវេលា ១៥ថ្ងៃ ជាកំហិត ។ ក្នុងរយៈវេលាប៉ុណ្ណេះ បើគ្មានសំណូមពរអ្វីទេ ត្រូវប្រកាសពេលបោះឆ្នោតក្នុងរយៈពីរសប្តាហ៍ ។

ប្រការ ២៦ : បេក្ខសមណៈសង្ឃនាយក ត្រូវជ្រើសរើសក្នុងបណ្តាព្រះថេរៈ ដែលមានសមត្ថភាព គឺមានទាំងចរិយាសម្បត្តិ និង វិជ្ជាសម្បត្តិ ហើយជាសមាជិកព្រះសង្ឃនាយក ឬ ជាមេគណនៅពេលមានហើយ ។

ប្រការ ២៧ : គណៈកម្មការចាត់តាំងបោះឆ្នោតជ្រើសរើសព្រះសង្ឃនាយក មាន : តំណាងគណៈអចិន្ត្រៃយ៍ក្រុមប្រឹក្សាជាតិរណសិរ្ស ១រូប ជាប្រធាន តំណាងលេខាធិការដ្ឋានព្រះសង្ឃនាយក ២អង្គ តំណាងអាចារ្យវត្ត ១រូប ជាសមាជិក និងលេខាកត់ត្រា ២ រូប ។

ប្រការ ២៨ : អ្នកមានសិទ្ធិបោះឆ្នោតជ្រើសរើសព្រះសង្ឃនាយក គឺបណ្តាមេគណគ្រប់ខេត្ត-ក្រុងដែលតែងតាំងជាផ្លូវការហើយ ។

ប្រការ ២៩ : បើបោះឆ្នោតទៅហើយ មានសន្លឹកឆ្នោតស្មើគ្នា ត្រូវចាត់តាំងបោះឆ្នោតសាជាថ្មី ។

ប្រការ ៣០ : លុះបោះឆ្នោតចប់សព្វគ្រប់ហើយគណៈកម្មាធិការបោះឆ្នោត ត្រូវធ្វើកំណត់ហេតុបញ្ជូនសំណុំលិខិតនេះ ទៅគណៈអចិន្ត្រៃយ៍ក្រុមប្រឹក្សាជាតិរណសិរ្សពិនិត្យ និងស្នើទៅក្រុមប្រឹក្សារដ្ឋ ដើម្បីចេញក្រឹតចាត់តាំងជាផ្លូវការ ។

ប្រការ ៣១ : ព្រះសង្ឃនាយកជ្រើសរើសព្រះថេរានុត្ថេរៈ ដែលមានសមត្ថភាព ជាសមាជិកចំនួន ៥រូប និងសហការីចំនួន ០៨រូប ស្នើសុំទៅគណៈអចិន្ត្រៃយ៍ក្រុមប្រឹក្សាជាតិរណសិរ្ស ដើម្បីសម្រេចចាត់តាំងជាផ្លូវការតទៅ ។

ភ្នំពេញ, ថ្ងៃទី ០១ ខែ មករា ឆ្នាំ ១៩៩០

ដកស្រង់ចេញពីសៀវភៅ

ស្ថាប័នពុទ្ធសាសនា នៃរដ្ឋកម្ពុជា បោះពុម្ពនៅឆ្នាំ ១៩៩០

ក្រោមសេចក្តីណែនាំស្តីពីការរៀបចំរចនាសម្ព័ន្ធពុទ្ធសាសនា

លេខ ០៧/៩០ កជរស ចុះថ្ងៃទី ២៦ ខែ មិថុនា ឆ្នាំ ១៩៩០

ដោយក្រុមប្រឹក្សាជាតិរណសិរ្សសាមគ្គីកសាងការពារមាតុភូមិកម្ពុជា

# ឧបសម្ព័ន្ធទី១២

## សមណសក្តិ

សមណស័ក្តិព្រះសង្ឃ មានគោរម្យងារ ជាព្រះសង្ឃនាយក សម្តេចព្រះសង្ឃនាយក រឺសម្តេចព្រះសង្ឃរាជ, ជារាជាគណៈថ្នាក់ឯក, ជារាជាគណៈថ្នាក់ទោ, ជារាជាគណៈថ្នាក់ត្រី, ជារាជាគណៈថ្នាក់ចត្វា, ជាព្រះគ្រូ ព្រះគ្រូបាឡាត់, ព្រះគ្រូវិន័យធម្ម រឺព្រះគ្រូសមុហ៍ តើមានអ្វីជាគ្រឿងសំគាល់ដែរ រឺទេ?

បើនៅក្នុងពិធីធំៗ ក្រៅពីការស្គាល់ច្បាស់ មានផ្ចិតជាគ្រឿងសំគាល់បានខ្លះៗ ដូចជាដឹងបានថា ជារាជាគណៈថ្នាក់ណាមួយ រឺជាឋានានុក្រម ។ តែមិនអាចដឹងបានថា ព្រះអង្គណាមួយមានគោរម្យងារជាអ្វីឡើយ ។

សូមបញ្ជាក់ថា ព្រះសង្ឃនាយក, សម្តេចព្រះសង្ឃនាយក, សម្តេចព្រះសង្ឃរាជ, រាជាគណៈថ្នាក់ឯក, ថ្នាក់ទោ, ថ្នាក់ត្រី, និងថ្នាក់ចត្វា ផ្ចិតមានកំពូលស្រួច មានក្បាច់ជុំវិញឈរឡើងដូចគ្នា តែផ្ចិតសម្តេចព្រះសង្ឃរាជ នៅត្រង់កណ្តាល មានរូបព្រះរាជសង្ហា ។ ឯផ្ចិតព្រះសង្ឃនាយក, សម្តេចព្រះសង្ឃនាយក និងព្រះរាជាគណៈទាំង ៤ ថ្នាក់វិញ មានក្បាច់រចនា ដូចផ្កាទៅវិញ ។

**កំនត់សំគាល់**

- ផ្ចិតសម្តេចព្រះសង្ឃរាជ មានពណ៌លឿង
- ផ្ចិតព្រះសង្ឃនាយក, សម្តេចព្រះសង្ឃនាយក មានពណ៌លឿង
- ផ្ចិតរាជាគណៈថ្នាក់ឯក មានពណ៌ក្រហម
- ផ្ចិតរាជាគណៈថ្នាក់ទោ មានពណ៌បៃតង
- ផ្ចិតរាជាគណៈថ្នាក់ត្រី មានពណ៌ស្វាយ
- ផ្ចិតរាជាគណៈថ្នាក់ចត្វា មានពណ៌ខៀវ ។


ផ្លិតយសសមណសក្តិព្រះសង្ឃក្រុងកម្ពុជា
សម្តេចព្រះមហាសង្ឃរាជ
មហានិកាយ
សម្តេចព្រះមហាសង្ឃរាជ
ធម្មយុត្តិកនិកាយ
សម្តេចព្រះសង្ឃនាយក
មហានិកាយ
ព្រះរាជាគណៈថ្នាក់សម្តេច
ថ្នាក់ឯក/ថ្នាក់កិត្តិយស
ព្រះរាជាគណៈថ្នាក់ឯក
ព្រះរាជាគណៈថ្នាក់ទោ
ព្រះរាជាគណៈថ្នាក់ត្រី
ព្រះរាជាគណៈថ្នាក់ចត្វា
ព្រះរាជាគណៈថ្នាក់កិត្តិយស
ថ្នាក់ព្រះគ្រូ
ថ្នាក់ព្រះបាឡាត់

# សម្ភុហ៍

បព្ចជិតដែលមានងារទុតជា សម្ភុហ៍ , ត្រូវប្រើផ្លិតមុខព្រហ្ម មានរាងមូលទ្រវែង និងមានក្បាច់រចនាផ្សេងៗ គួរជាទីចាប់អារម្មណ៍ ។



**ឋានានុក្រម**
**សម្ភុហ៍**
ត្រូវប្រើផ្លិតមុខព្រហ្ម

ការប្រើផ្លិត មានពណ៌ដូចផ្លិត ព្រះរាជាគណៈដែលបានតែងតាំងខ្លួននោះ



គ្រែសំរាប់ការសម្តែងធម៌របស់សម្តេចសង្ឃ



# ព្រះរាជពិធីស្រង់សុគន្ធវារី
## ថ្វាយគណៈសង្ឃនាយក នៃព្រះរាជាណាចក្រកម្ពុជា



នៅថ្ងៃ សុក្រ ទី ២៦ ខែ ឧសភា ឆ្នាំ ២០០៦ ក្រោមអធិបតីភាព សម្ដេចព្រះអគ្គមហាសង្ឃរាជាធិបតី **ទេព វង្ស** សម្ដេចព្រះមហាសង្ឃរាជ នៃព្រះរាជាណាចក្រកម្ពុជា សម្ដេច **ហ៊ុន សែន** នាយករដ្ឋមន្ត្រី នៃរាជរដ្ឋាភិបាលកម្ពុជា និង លោក**ជំទាវ** ។ បានយាង និង អញ្ជើញជាអធិបតីភាពដ៏ខ្ពង់ខ្ពស់ក្នុងព្រះរាជពិធី ស្រង់សុគន្ធវារី ថ្វាយគណៈសង្ឃនាយក នៃព្រះរាជាណាចក្រ-កម្ពុជា ដែលបានប្រទានឋានៈពី

**ព្រះករុណាព្រះបាទសម្ដេចព្រះបរមនាថ នរោត្តម សីហមុនី** ព្រះមហាក្សត្រ នៃព្រះរាជាណាចក្រកម្ពុជា ។

សមាសភាព គណៈសង្ឃនាយក នៃព្រះរាជាណាចក្រកម្ពុជា ដែលត្រូវបានតែងតាំងមាន ៖

១- សម្ដេចព្រះពោធិវង្ស **នន្ទ ង៉ែត** ព្រះរាជាគណៈថ្នាក់ឯក ជាសម្ដេចព្រះមហាសុមេធាធិបតី ព្រះសង្ឃនាយក នៃព្រះរាជាណាចក្រកម្ពុជា ។

២- សម្ដេចព្រះធម្មលិខិត **ឈាស់ ឡាយ** ព្រះរាជាគណៈថ្នាក់ឯក ជាសម្ដេចព្រះធម្មលិខិត ព្រះសង្ឃនាយករងទី ១ នៃព្រះរាជាណាចក្រកម្ពុជា ។

៣- សម្ដេចព្រះវនរ័ត **អ៊ំ លឹមហេង** ព្រះរាជាគណៈថ្នាក់ឯក ជាសម្ដេចព្រះពោធិវង្ស ព្រះសង្ឃនាយករងទី ២ នៃព្រះរាជាណាចក្រកម្ពុជា ។

៤- សម្ដេចព្រះឃោសធម្ម **ណយ ច្រឹក** ព្រះរាជាគណៈថ្នាក់ទោ ជាសម្ដេចព្រះវនរ័ត ព្រះរាជាគណៈថ្នាក់ឯក ព្រះសង្ឃនាយករងទី ៣ នៃព្រះរាជាណាចក្រកម្ពុជា ។

ព្រះរាជពិធីនេះ បានប្រារព្ធធ្វើឡើងនៅក្នុងបរិវេណ ***វត្តមុនីសុវណ្ណ*** ហៅ ***វត្តចំពុះក្អែក*** ស្រុកកៀនស្វាយ ខេត្តកណ្ដាល ។

ចូលរួមក្នុងពិធីជាប្រវត្តិសាស្ត្រនេះមាន ៖

ព្រះមេគណ អនុគណ គ្រប់ខេត្ត-ក្រុង សម្តេច ទ្រង់ ឯកឧត្តម លោកជំទាវ អ្នកឧកញ៉ា មន្ត្រីរាជការគ្រប់ស្ថាប័ន ប្រធានមន្ទីរធម្មការ និងសាសនា គ្រប់ខេត្ត-ក្រុង ព្រមទាំងប្រជា-ពលរដ្ឋយ៉ាងច្រើនកុះករ !



សម្តេចនាយករដ្ឋមន្ត្រី **ហ៊ុន សែន** និងលោកជំទាវ ក្នុងឱកាស
ស្រង់សុគន្ធវារីថ្វាយគណៈសង្ឃនាយក
នៃព្រះរាជាណាចក្រកម្ពុជា



សម្តេចនាយករដ្ឋមន្ត្រី ហ៊ុន សែន ថ្វាយព្រះរាជក្រឹត្យ (ព្រះសុវណ្ណបត្រ)
សម្តេចព្រះមហាសុមេធាធិបតី ព្រះសង្ឃនាយក នៃព្រះរាជាណាចក្រកម្ពុជា



សម្តេចនាយករដ្ឋមន្ត្រី ហ៊ុន សែន ថ្វាយវៃជយន្តីសម្តេចព្រះធម្មលិខិត
លាស់ ឡាយ ព្រះសង្ឃនាយករងទី១ នៃព្រះរាជាណាចក្រកម្ពុជា



សម្តេចព្រះពោធិវង្ស អំ លឹមហេង ព្រះសង្ឃនាយករងទី ២
នៃព្រះរាជាណាចក្រកម្ពុជា



សម្តេចនាយករដ្ឋមន្ត្រី ហ៊ុន សែន ថ្វាយវិជយ៉ានីសម្តេចព្រះវនរ័ត
ណាយ ច្រឹក ព្រះរាជគណៈថ្នាក់ឯក ព្រះសង្ឃនាយករងទី ៣
នៃព្រះរាជាណាចក្រកម្ពុជា








SPM
PAGE










eace Tour
ntation of Peaceful Re
m Penh Cambodia
30th World Peace Tour
Peace Message for the Implementation
of Peaceful Religions





